# ករណីសិក្សា
# CASE STUDY





## តើខ្ញុំអាចទ្រាំរហូតដល់ពេលណា?

## ជីវិតពិតកម្មករ-កម្មការិនី
## កាត់ដេរកម្ពុជា

*Real life of the Cambodiam garment workers*

ករណីសិក្សាទី ១

តំបន់មានជ័យ

ថ្ងៃទី ៣០ មិថុនា ២០០៥

នាងខ្ញុំឈ្មោះ អ វ មានអាយុ២៧ឆ្នាំ បានធ្វើការនៅរោងចក្រមួយក្នុងសង្កាត់ចាក់អង្រែខណ្ឌមានជ័យ រោងចក្រនោះមានឈ្មោះថា **គីនតាយ។** នាងខ្ញុំមានបងប្អូន៨នាក់ ហើយពុកម៉ែរបស់ខ្ញុំរស់នៅឃុំស្ពានត្នោត ស្រុកជីក្រែង ខេត្តសៀមរាប មានមុខរបរជាអ្នកធ្វើស្រែចំការ គ្រួសារខ្ញុំមានដីស្រែ២ហិចតា ហើយក្នុងមួយឆ្នាំយើងទទួលផលបាន ៥០ថាំង= ១000 គីឡូ តែផលស្រូវទាំងនោះវាតិចតួចណាស់ មិនបានហូបចុកអោយគ្រប់គ្រាន់ពេញមួយឆ្នាំវិញនោះទេ ហើយម្យ៉ាងវិញទៀត កាលពីមុនក្រៅពីធ្វើស្រែគ្រួសាររបស់ខ្ញុំអាចទៅរកត្រីបានបន្តិចបន្តួចដែរ គឺគ្រាន់សំរាប់ហូបដោយមិនចាំបាច់ទិញគេនោះ ទេ តែឥឡូវនេះវិញយើងលែងរកបានដូចកាលពីមុនទៀតហើយ អ្វីៗសព្វយ៉ាងគឺត្រូវទិញទាំងអស់ ។

នៅក្នុងភូមិខ្ញុំមានកម្មវិធីគំរោងឥណទានរបស់ អេស៊ីលីដា តាំងពីមានគំរោងឥណទាននេះមកមានអ្នកភូមិជាច្រើននាក់បានត្រូវបាត់បង់អស់ផ្ទះសម្បែង ព្រោះតែត្រូវលក់វាដើម្បីសងត្រឡប់នូវបំណុលដែលបានជាប់ជំពាក់ទាំងនោះ ។ គ្រួសារខ្ញុំក៏បានខ្ចីពីអ្នកភូមិខ្លះដែរ ដោយសារត្រូវយកមកមើលពេលម៉ែឈឺ អ្នកដែលត្រូវទៅខ្ចីនោះគឺបងស្រីរបស់ខ្ញុំ ក្នុងមួយជីមាសការមួយហ៊ុនក្នុងមួយខែ ពេលនោះពុករបស់ខ្ញុំគាត់ក៏រកលុយបានខ្លះដែរតែត្រូវចំណាយវាដើម្បីចិញ្ចឹម កូនៗនៅពេលដែលគេមកទារលុយយើងរកមិនបាន ហើយមិនដឹងបានអីសងគេនោះទេ បងប្អូនខ្ញុំក៏សំរេចចិត្តឈប់រៀន ជាបន្តបន្ទាប់កាលនោះខ្ញុំរៀនទើបបានថ្នាក់ទី៣ ហើយក៏ត្រូវឈប់រៀនដើម្បីដើរស៊ីឈ្នួលគេរំលួសបំណុល និងជួយម៉ែពុកក្នុងការធ្វើស្រែតែនៅតែជំពាក់គេដដែល។ ក្រោយមកទៀតខ្ញុំក៏សំរេចចិត្តមករកការងារធ្វើ ហើយបងស្រីខ្ញុំមិនអាចមកបានព្រោះម៉ែខ្ញុំគាត់មិនហ៊ានបណ្តោយគាត់នោះទេ តែចំពោះខ្ញុំគាត់អត់ខ្លាចទេគាត់ទុកចិត្តជាង។

ពេលដែលខ្ញុំចាកចេញពីស្រុកដំបូង គឺមកជាមួយអ្នកដែលចាំយកអ្នកភូមិមកធ្វើការនៅទីក្រុង តែពួកគេមិនចិត្តអាក្រក់នោះទេ។ ពេលមកដល់ដំបូងខ្ញុំមិនទាន់បានចូលរោងចក្រភ្លាមទេ ខ្ញុំត្រូវជួលផ្ទះគេដើម្បីស្នាក់នៅសិន ហើយផ្ទះជួលនោះត្រូវបង់អោយគេមួយខែ៥ដុល្លា ។ ខ្ញុំមានពូនៅភ្នំពេញម្នាក់ដែរមិនបានប៉ុន្មានថ្ងៃបន្ទាប់ពីខ្ញុំមករកការងាធ្វើនៅទីក្រុងគាត់បានទៅលេងស្រុកហើយបានដឹងពីពុកខ្ញុំថាខ្ញុំមកធ្វើការនៅភ្នំពេញ ពេលដែលគាត់ត្រឡប់មកភ្នំពេញវិញគាត់ក៏បានដើររកខ្ញុំ ហើយដល់ពេលរកខ្ញុំឃើញ ហើយគាត់ក៏ចេញលុយថ្លៃឈ្នួលផ្ទះឱ្យខ្ញុំ។ ពូរបស់ខ្ញុំបានសុំម៉ែរបស់ខ្ញុំរួចជាស្រេចនិងយកខ្ញុំទៅនៅជាមួយគាត់ ហើយពេលទៅដល់ផ្ទះគាត់មិនបានប៉ុន្មានថ្ងៃផងខ្ញុំក៏ទៅរកការងារធ្វើព្រោះខ្ញុំគិតថាខ្ញុំមិនចង់ដេកស៊ីកំលាំងរបស់គាត់នោះទេ។ ដំបូងឡើយខ្ញុំបានស្គាល់គេនៅជិតផ្ទះពូ ហើយក៏ទៅសុំគេធ្វើការក្នុងភោជនីយដ្ឋានមួយថៅកែភោជនីយដ្ឋានក៏យល់ព្រមអោយខ្ញុំធ្វើការពេលដែលខ្ញុំទៅសុំជាលើកដំបូង នៅទីនោះគេឱ្យខ្ញុំធ្វើខាងផ្នែកលាងចានប៉ុន្តែការងារនោះហត់ខ្លាំងណាស់ ខ្ញុំត្រូវអង្គុយយ៉ាងយូរហើយត្រូវអោនងើបៗរហូតពេញមួយថ្ងៃ។ ចំណែកពូរបស់ខ្ញុំវិញគាត់មិនចង់ឱ្យខ្ញុំធ្វើទេនៅពេលដែលលឺថាជាកន្លែងដែល មានស្រីឡង់សេផងនោះ ខ្ញុំធ្វើបានតែកន្លះខែប៉ុណ្ណោះក៏ឈប់ធ្វើ

ការនៅទីនោះទៅព្រោះមានគេតាមខ្ញុំជាញឹកញាប់ព្រោះ គេគិតថាខ្ញុំជាស្រីឡង់សេ ហើយពួកវាប្រាប់ថៅកែថាវាមានបំនងមកលើខ្ញុំ តែថៅកែប្រាប់ថាខ្ញុំគ្រាន់តែជាអ្នកលាងចាន មិនធ្វើជាស្រីឡង់សេទេ។ នៅទីនោះមានមនុស្សម្នាក់បានប្រាប់ខ្ញុំដោយបំនងល្អថា ខ្ញុំគួរតែឈប់ធ្វើការនៅទីនោះទៅព្រោះវាមិនល្អសំរាប់ខ្ញុំទេ ខ្ញុំគួរតែរកការងារផ្សេងក្រៅពីនេះវាល្អជាង។

ពូរបស់ខ្ញុំហើយនិងម្តាយរបស់គាត់យល់ព្រមមិនអោយខ្ញុំធ្វើការនោះតទៅទៀតទេ ព្រោះខ្លាចមានអ្នកផ្សេងគេនិងមើលងាយមើលថោកនៅពេលដែលគេដឹងថាមានការធ្វើនៅកន្លែងដែលមានល្អ ហើយម្យ៉ាងទៀតវាជាកន្លែងដែលងាយអូសទាញអោយជ្រុលខ្លួនប្រព្រឹត្តរឿងមិនល្អដែលសង្គមមិនអោយតំលៃ យើងសូម្បីតែខ្ញុំក៏មិនចង់ឱ្យខ្លួនខ្ញុំខុសដែរ។ ខ្ញុំឈប់ធ្វើការនៅក្នុងហាងនោះបាន៣ថ្ងៃ ខ្ញុំក៏ដើររកការងារធ្វើទៀតហើយបានជួបនឹងប្អូនថ្លៃរបស់ពូគាត់បានបបួលខ្ញុំទៅធ្វើការនៅហាងខារ៉ាអូខេមួយ ពេលនោះប្រពន្ធរបស់ពូបានប្រាប់ថាធ្វើការនេះមិនល្អទេគួរតែកុំធ្វើអីល្អជាង ចំពោះខ្ញុំពេលនោះចង់ដឹងដែរថា តើការងារនេះវាមិនល្អមែននឹងដូចដែលសំដីគេថារឺអត់? ខ្ញុំក៏សំរេចចិត្តទៅធ្វើការជាមួយគាត់ទៅ។ ពេលទៅដល់ដំបូងថៅកែហាងឱ្យខ្ញុំដាំបាយនិងធ្វើម្ហូប តាមសំណើរដែលខ្ញុំសុំគេធ្វើការនៅទីនោះ ពេលក្រោយមកបន្ទាប់ពីខ្ញុំធ្វើម្ហូបរួចនៅផ្ទះបាយ ខ្ញុំក៏លើកចានដាក់ទឹកត្រីឱ្យភ្ញៀវ ពេលនោះខ្ញុំបានឃើញគេអោបស្រីនៅក្នុងបន្ទប់ ហើយពេលខ្ញុំទៅដល់គេឃើញខ្ញុំ គេក៏សួរថាម្នាក់ហ្នឹងមកថ្មីឬអី ពេលនោះស្រីម្នាក់ហ្នឹងក៏ប្រាប់ថាខ្ញុំទើបតែមកថ្មី ហើយភ្ញៀវនោះក៏លែងអោបស្រីនោះហើយបែរជាមកតាមខ្ញុំវិញរហូតដល់ផ្ទះបាយ។ ពេលនោះគាត់បានសួរពីប្រវត្តិរបស់ខ្ញុំ មកពីស្រុកភូមិណា ហើយពេលគាត់ដឹងហើយគេក៏សួរខ្ញុំត្រង់ៗថាដេកជាមួយគាត់មួយយប់ខ្ញុំយកថ្លៃប៉ុន្មាន? ខ្ញុំមានអារម្មណ៍ភ្ញាក់ផ្អើលយ៉ាងខ្លាំង ខ្ញុំនិយាយតបទាំងភ័យថា ខ្ញុំមិនមែនជាស្រីអញ្ចឹងទេ គាត់ក៏សួរខ្ញុំបន្តថា បើខ្ញុំមិនមែនជាស្រីអញ្ចឹងហេតុអ្វីក៏ចូលមកធ្វើការកន្លែងនេះ ពេលនោះខ្ញុំក៏សួរគាត់វិញភ្លាមថា តើអ្នកដែលនៅកន្លែងហ្នឹងសុទ្ធតែស្រីមិនល្អទាំងអស់មែនឬ? គាត់ឆ្លើយថាមែនហើយ។ គាត់ថែមទាំងនិយាយថាមួយយប់ គាត់ឱ្យខ្ញុំ១០០ដុល្លា អោយតែខ្ញុំទៅដេកជាមួយគាត់ តែខ្ញុំអត់មាត់តបតវានោះទេ ដូច្នេះគាត់ក៏និយាយទៀតថា២០០ដុល្លាព្រមឬអត់? ខ្ញុំនៅតែប្រកាន់ពាក្យដដែលថាខ្ញុំមិនមែនជាស្រីអញ្ចឹងទេ។ បន្ទាប់មកគាត់ក៏សុំទោសខ្ញុំ ហើយនិយាយថាគាត់គ្រាន់តែលលេងចិត្តខ្ញុំទេ គាត់ដឹងថាខ្ញុំមិនមែនជាស្រីអញ្ចឹងដែរតាំងពីផ្តើមសួរដំបូងម្ល៉េះ គាត់បានប្រាប់ខ្ញុំថាគាត់មានប្រពន្ធមានកូន២នាក់រួចទៅហើយ គឺស្រីមួយនិងប្រុសមួយ។ តែគាត់នៅតែសួរថាតើខ្ញុំព្រមធ្វើ ប្រពន្ធចុងវាឬអត់? ហើយខ្ញុំឆ្លើយថាខ្ញុំមិនព្រមទេ។ គាត់បានសរសើរខ្ញុំថាពិតជាស្រីរឹងប៉ឹងមែនដែលមិនចុះញ្ញោមសំដីអ្នកដ៏ទៃ អាចការពារខ្លួនបាន គាត់ក៏ប្រាប់ខ្ញុំថាឈប់ធ្វើការហ្នឹងទៅវាមិនល្អសំរាប់ខ្ញុំនោះទេ។ បន្ទាប់មកខ្ញុំក៏សំរេចចិត្តឈប់ធ្វើការ ថៅកែហាងបានបើកលុយឱ្យ២០ដុល្លា សំរាប់រយៈពេលមួយអាទិត្យដែលខ្ញុំបានធ្វើការនៅទីនោះ។ បន្ទាប់ពីបានលុយខ្លះហើយខ្ញុំក៏បានជិះម៉ូតូឌុបត្រឡប់មកផ្ទះវិញ បុរសម្នាក់ដែលសួរនាំខ្ញុំនៅក្នុងហាងនោះបានជិះមក តាមខ្ញុំដើម្បីស្គាល់កន្លែងដែលខ្ញុំស្នាក់នៅ ខ្ញុំនៅតែមានអារម្មណ៍ភ័យខ្លាចព្រោះដឹងថាមានគេនាំមក ពេលមកដល់ខ្ញុំក៏យករឿងរ៉ាវទាំងអស់ប្រាប់ពូ និងបងប្អូនទាំងអស់នៅក្នុងផ្ទះ ពួកគេអត់មាត់មួយម៉ាត់ទេ អ្នកខ្លះស្រក់ទឹកភ្នែកអាណិតដល់ខ្ញុំពួកគាត់ក៏សំរេចចិត្តមិនអោយខ្ញុំទៅណានោះទេ គឺអោយនៅតែដាំបាយនៅផ្ទះប៉ុណ្ណោះ។

ពេលមួយនោះភ្ញៀវម្នាក់ដែលជួបនៅហាងខារ៉ាអូខេនោះ គាត់បាននាំប្រពន្ធកូនគាត់មកលេងផ្ទះពូរបស់ខ្ញុំ ខ្ញុំមានការងឿនឆ្ងល់យ៉ាងខ្លាំង គាត់ប្រាប់ថាគាត់មកក្នុងន័យល្អនោះទេ គាត់សួរពូរបស់ខ្ញុំថាគាត់ ចង់យកខ្ញុំទៅធ្វើការរោងចក្រកាណាឌីយ៉ា ព្រោះប្រពន្ធគាត់ធ្វើអ្នកបកប្រែចិននៅរោងចក្រនោះ ហើយម្យ៉ាងវិញទៀតប្អូនពៅរបស់ពូខ្ញុំក៏បានស្គាល់ប្រពន្ធគាត់ដែរ ។ ដូចនេះគាត់ក៏សំរេចចិត្តឱ្យខ្ញុំ ទៅធ្វើការនៅរោង ចក្រកាណាឌីយ៉ានោះទៅ ។

ខ្ញុំធ្វើការនៅទីនោះបានមួយខែ ខ្ញុំក៏ឈប់ព្រោះកម្មករនៅរោងចក្រនោះបានធ្វើបាតុកម្ម ខ្ញុំមិនបានដឹងពីមូលហេតុច្បាស់លាស់នោះទេ តែបន្ទាប់មកខ្ញុំក៏សំរេចចិត្តត្រឡប់ទៅស្រុកវិញ ព្រោះមានគេមកប្រាប់ខ្ញុំថាពុកស្លាប់នៅឯស្រុកតែពេលខ្ញុំទៅដល់ស្រុកទើបដឹងថាគេកុហកខ្ញុំសោះ ។ ពេលបាននៅផ្ទះខ្ញុំលែងចង់មករកការងារវិញហើយ ប៉ុន្តែម៉ែខ្ញុំឱ្យខ្ញុំត្រឡប់មកវិញព្រោះតែគ្រួសារខ្វះខាត ហើយណាមួយមានបងប្អូននៅក្នុងភូមិដែលបានការងារធ្វើការនៅរោងចក្រ **តាក់ហ្វាក់** នៅចាក់អង្រែ ខ្ញុំក៏មករកការធ្វើម្តងទៀត ហើយបានឱ្យលុយទៅអ្នកនាំចូលនោះ៥០ដុល្លាដែលលុយនោះខ្ញុំបានមកពីចងការហើយសន្យានិងសងរំលោះពេលបើកប្រាក់ខែ ទើបសងគេតិចៗវិញ ។

ពេលចូលធ្វើការនៅរោងចក្រនេះដំបូងខ្ញុំបើកលុយឈ្នួលបានមួយខែ៣៥ដុល្លា ខ្ញុំបំរើការនៅផ្នែកប៉ាក់ ។ តែ៣ខែក្រោយមកខ្ញុំក្លាយជាកម្មករពេញសិទ្ធិ ខ្ញុំក៏ទទួលបានប្រាក់ឈ្នួល ៤៥ដុល្លាក្នុងមួយខែ ។ ខ្ញុំចាំថាពេលចូលដំបូងខ្ញុំប្រឹងប្រែងធ្វើការជាខ្លាំងខ្ញុំមិនហ៊ានសុំច្បាប់ឈប់នោះទេ ហើយម្យ៉ាងវិញទៀតខ្ញុំលឺពីមិត្តថាពេលសុំច្បាប់ម្តងៗគឺពិបាកណាស់ ទោះជាទៅដល់ការិយាល័យក៏ចិនមិនបានឱ្យទេ សុំយ៉ាងណាក៏អត់ឱ្យដែរទោះបីជាមួយថ្ងៃក៏មិនឱ្យដែរ ។ នៅក្នុងរោងចក្រនេះមានសហជីព២ ប៉ុន្តែខ្ញុំមិនដឹងឈ្មោះទេគឺគ្រាន់តែដឹងថាសហជីពមួយខាងចិន និងមួយទៀតខាងកម្មករ ខ្ញុំជាកម្មករចូលថ្មីដូចនេះខ្ញុំមិនសូវដឹងពីសហជីពនោះទេ ។

ក្រៅពីការសុំច្បាប់ពិបាក សូម្បីតែពេលទៅបង្គន់ខាងរោងចក្រតំរូវអោយសន្តិសុខកត់លេខកាត បើកម្មករណាចូលទៅយូរត្រូវបានគេយកកាតចូលទៅការិយាល័យ ឬ ប្តឹងទៅចិន ។ ពេលធ្វើការនៅរោងចក្រនេះយូរៗទៅខ្ញុំក៏មានជំងឺក្រពះនិងគ្រុនពោះវៀន ព្រោះតែការហូបបាយមិនសូវទៀងពេល ពេលនោះខ្ញុំបានទៅសុំច្បាប់ចិនតែវាមិនឱ្យខ្ញុំទេ ហើយវានិយាយថាកាលពីមុនវាសុំឱ្យធ្វើអ្នកបើកសំភារៈ តែខ្ញុំអត់ព្រម ឥលូវវាក៏អត់ធ្វើតាមខ្ញុំដែរ ពេលនោះខ្ញុំខឹងខ្លាំងណាស់តែមិនដឹងជាធ្វើយ៉ាងណានោះទេ ហើយក៏ចេះតែទ្រាំទៅ ព្រោះអ្នកផ្ទះខ្វះខាតលុយធ្វើស្រែ ហើយប្រាក់ខែក៏បានតិចទៀត ។ ប្រាក់ឈ្នួលដែលខ្ញុំបានមកវាតិចណាស់ ខ្ញុំមិនអាចចាយគ្រប់ទេ ណាថ្លៃផ្ទះជួល ណាលុយផ្ញើរទៅផ្ទះ ដូចនេះខ្ញុំសុំចិនដេរស៊ីបុងតែវាអត់ព្រមអោយខ្ញុំទេ ។ ក្រោយមកម៉ែខ្ញុំក៏ឱ្យប្អូនស្រីរបស់ខ្ញុំម្នាក់ទៀតមករកការងារធ្វើដែល នាងបានការងារធ្វើនៅរោងចក្រ គីនតាយ មិនយូរប៉ុន្មាននាងក៏ហៅខ្ញុំមកធ្វើការនៅរោងចក្រជាមួយនាង ។

ពេលមកធ្វើតេស្តដំបូងនៅរោងចក្រ **គីនតាយ** ប្រធានក្រុមហ៊ុនចេញមកមើលគាត់ក៏ព្រមទទួលអោយធ្វើការ ហើយបានប្រាក់ឈ្នួលក្នុងមួយខែ ៤៥ដុល្លា ។ បន្ទាប់មកខ្ញុំពីរនាក់បងប្អូនខំធ្វើការថែមម៉ោងយ៉ាងខ្លាំង ដើម្បីយកលុយទៅជួយ

អ្នកផ្ទះ។ នៅតាមក្រុមនីមួយៗប្រធានចិនបង្ខំឱ្យដេរ អោយលឿន បើមិនលឿន គេនិងដកចេញ ហើយខ្ញុំបានធ្វើខាងផ្នែកចល័ត។ នៅផ្នែកនេះគេមិនអនុញ្ញាតអោយជជែកគ្នាទេ បើគេដឹងថាយើងជជែកគ្នាគេនិងដេញចេញ។ ខ្ញុំចូលធ្វើការក្នុងរោងចក្រនេះនៅឆ្នាំ ២០០០ ពេលនោះខាងរោងចក្រមិនទាន់មានសហជីពទេមានតែតំណាងកម្មករ ពេលនោះចិននៅតាមក្រុមមានអំណាចធំណាស់អាចដកកម្មករចេញតាមចិត្ត។ សហជីពបានបង្កើតក្នុងឆ្នាំ ២០០២នៅក្នុងរោងចក្រចាប់ពីពេលនោះមកការងារបានសំរួលច្រើន ព្រោះពេលនោះសហជីពជួយដោះស្រាយឱ្យកម្មករបានគ្រប់ពេលដែលម្មករសំនូមពរ។ ចំពោះការងារថែមម៉ោងមានរហូត កម្មករចង់ថែមម៉ោងក៏បាន អត់ក៏បានតាមចិត្តរបស់កម្មករ។

ក្នុងឆ្នាំ២០០៥ ការងារក៏អត់សូវមានធ្វើ ហើយរោងចក្រមានការកែប្រែប្រព័ន្ធដូចជា រំសាយកម្មករចាស់ដែលពូកែតវ៉ាចេញ ហើយបើផ្នែកតុកាត់ បង្ហើយការ និងបោកគក់វិញ គឺរើសកម្មករថ្មីយកតែមនុស្សស្រី។ ហើយប្តូរប្រព័ន្ធផ្នែកដេរដោយកាលពីមុនមាន ២៤ក្រុមតែឥលូវនេះសល់តែ ១៦ក្រុមប៉ុណ្ណោះ ហើយកម្មករដែលនៅសល់ត្រូវប្តូរទៅធ្វើនៅផ្នែកបង្ហើយការនិងខ្លះទៀតទៅផ្នែកកាត់។ ហើយផ្នែកបង្ហើយការគេរើសកម្មករថ្មីបន្ថែម ហើយផ្នែកនេះមានអ្នកថ្មីច្រើនជាងគេ។ ផ្នែកបង្ហើយការនិងបោកគក់ មានពីរវេន គឺវេនថ្ងៃ ចូលម៉ោង ៧:៣០ ចេញម៉ោង ៤:៣០ ហើយវេនយប់ ចូលម៉ោង ៤ល្ងាច ចេញម៉ោង ៦ព្រឹក។

នៅក្នុងរោងចក្រនេះមានសហជីព២ គឺសហជីពស៊ីខៅខ្វ និងសហជីពយុវជនខ្មែរដែលមានប្រធានឈ្មោះលោកយន្ត រិទ្ធី។ តែឥលូវនេះសហជីពមិនសូវដោះស្រាយឱ្យកម្មករទេ ពេលមានគ្រោះថ្នាក់ការងារ កម្មករនៅផ្នែកដេរម្នាក់ត្រូវរងរបួសដោយសារទេះអូសក្រណាត់របស់អ្នកធ្វើការនៅផ្នែកតុកាត់ ពេលដែលទៅព្យាបាលរបួសនៅខាងក្រៅរោងចក្រ ហើយក៏យកវិក័យប័ត្រមកទូទាត់លុយតែប្រធានរោងចក្រមិនបានគិតលុយអោយនោះទេ ហើយបែរជានិយាយថា អ្នកណានាំទៅពេទ្យអ្នកនោះជាអ្នកចេញលុយទៅ ហើយប្តីអ្នករងគ្រោះបានទៅពឹងសហជីព ប៉ុន្តែគេមិនបានអើពើនោះទេ។ ហើយឥលូវនេះទោះមានរឿងអ្វីក៏ដោយក៏គេមិនអើពើដែរគឺ សហជីពស៊ីខៅខ្វ។ ប្រសិនបើពេលដែលមកធ្វើ ការលើសមួយនាទី ៣ដងគេកាត់លុយព្រឹម៥ដុល្លា។ ធ្វើការឥលូវបង្ខំខ្លាំងណាស់មិនថាផ្នែកណាទេ បើអ្នកថ្មីគេកំណត់ឱ្យធ្វើ បើធ្វើមិនគ្រប់ទេគេដេញចេញហើយពេលឈឺគេមិនឱ្យច្បាប់ទេ។

ឥលូវខ្ញុំមិនសូវបានផ្ញើរលុយទៅផ្ទះទេ ប៉ុន្តែបានប្អូនប្រុសខ្ញុំដែលទៅធ្វើការនៅថៃ រកលុយបានខ្លះផ្ញើរមកឱ្យម៉ែនៅ ស្រុក។ ខ្ញុំបានជួលបន្ទប់គេនៅ ក្នុងតំលៃ៩ដុល្លាក្នុងមួយខែ ហើយបន្ទប់ធំល្មមទំហំ ៤គុណ៥ និងទីធ្លាស្រលះដែរ ព្រោះជួលគ្នាតិចហើយកូនម្ចាស់ផ្ទះស្រី មិនសូវរើសអើងទេ តែកូនប្រុសគាត់ មិនសូវនិយាយស្តីរកពួកខ្ញុំប៉ុន្មានទេ។
បើថ្ងៃក្រោយរោងចក្របិទទ្វារ ខ្ញុំឈប់ធ្វើការនៅទីក្រុងហើយ ខ្ញុំនិងត្រឡប់ទៅស្រុកវិញនៅផ្ទះធ្វើស្រែ ហើយបើធ្វើស្រែអត់បាន ខ្ញុំក៏មិនមកវិញដែរ ខ្ញុំនិងព្យាយាមរករបរផ្សេងនៅស្រុកធ្វើខ្ញុំឈប់មកភ្នំពេញហើយ។ បើមានលុយថ្ងៃក្រោយខ្ញុំចង់បើកហាងកាត់ដេរសំអាងការនៅស្រុក។

## ករណីសិក្សាទី ២

## តំបន់ទឹកថ្លា

## មិថុនា ២០០៥

នាងខ្ញុំឈ្មោះ ផ សល មានអាយុ២៣ឆ្នាំ រស់នៅភូមិកំពង់ស្វាយ ឃុំកំពង់ស្វាយ ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូន៨នាក់ (ប្រុស ៤ និងស្រី ៤) និងជាកូនទី៥ក្នុងគ្រួសារ។ បងប្អូនខ្ញុំបានរៀបការរួច ២នាក់ហើយ ចំណែកឯគ្រួសាររបស់ខ្ញុំគឺជាអ្នកធ្វើស្រែ។ គ្រួសារខ្ញុំមានដីស្រែតែខ្ញុំមិនថាមានប៉ុន្មាននោះទេ មានគោខ្លះដែរ នៅពេលរដូវធ្វើស្រែពុកនិងម៉ែទៅខ្ចីលុយពីអេស៊ីលីដា ដើម្បីទិញជីដាក់ស្រែប្រាំង។ ហើយខ្ញុំខំធ្វើការរកលុយដើម្បីសងដើមនិងការប្រាក់ទៅគេវិញ។ ខ្ញុំបានឈប់រៀននៅថ្នាក់ទី ៦ បន្ទាប់ពីនោះមកបាន៣ឆ្នាំ ក៏មករកការងារធ្វើ នៅភ្នំពេញតាមរយៈបងស្រី។

ខ្ញុំមករកការងារធ្វើតាំងពីខ្ញុំមានអាយុ១៨ឆ្នាំម្ល៉េះ មុននិងបានការងារធ្វើខ្ញុំត្រូវរង់ចាំអស់រយៈពេល២ខែ ខ្ញុំបានជាប់ការធ្វើតេស្តដោយខ្លួនឯងហើយបានធ្វើការនៅក្នុងរោងចក្រមួយបាន៧ខែ ខ្ញុំមិនចាំឈ្មោះរោងចក្រនោះទេ។ ធ្វើដំបូងខ្ញុំទទួលយកប្រាក់ឈ្នួលគិតតាមថ្ងៃក្នុងតំលៃ៥០០០រៀល ហើយធ្វើការលំបាកខ្លាំងណាស់ទោះជា៨ម៉ោងក្នុងមួយថ្ងៃក៏ដោយ។ ក្រោយមកគេបានដូរដោយឱ្យប្រាក់ឈ្នួលខ្ញុំក្នុងមួយខែ៣០ដុល្លា ពេលនោះខ្ញុំចាយមិនគ្រាន់ទេ ហើយក៏មិនបានផ្ញើរលុយកាក់ទៅផ្ទះនោះដែរ ខ្ញុំចំណាយលើថ្លៃបន្ទប់ ២៥ដុល្លា តែស្នាក់នៅ៥នាក់ ម្នាក់ត្រូវបង់៥ដុល្លា។ ថ្លៃទឹកថ្លៃភ្លើងអស់ប្រហែល ៤០០០០រៀលក្នុងមួយខែ តែពួកខ្ញុំជួយគ្នាចេញ។ កាលនោះរោងចក្រនេះមិនមានសហជីពទេ។

បន្ទាប់មកខ្ញុំក៏ឈប់ធ្វើការនៅទីនោះ ហើយក៏ទៅធ្វើការនៅរោងចក្រ ឡាក់គីហ្សូនបានជាងមួយឆ្នាំ។ ចំពោះលក្ខណ្ឌការងារនៅរោងចក្រនោះល្អគួរសម ។ ក្រោយពីរោងចក្រឡាក់គីហ្សូនបានបិទខ្ញុំក៏ចូលធ្វើការនៅរោងចក្រ**អិលអេ** នៅក្នុង ២០០៥ ចំពោះលក្ខខណ្ឌការងារនៅរោងចក្រនេះវិញគឺលំបាកខ្លាំងណាស់ ថៅកែរោងចក្រមិនគោរពច្បាប់ការងារទេ ហើយប្រាក់ឈ្នួលវិញក៏បានតិចទៀត។ កាលធ្វើការនៅរោងចក្រឡាក់គីហ្សូន រោងចក្រនោះមានសហជីព ២ គឺសេរីកម្មករនិងសហព័ន្ធសហជីពខ្មែរ។ កាលនោះខ្ញុំធ្វើការនៅផ្នែកកាត់ព្រុយស៊ីប្រាក់ខែគោល ហើយដើម្បីបានសល់លុយខ្លះផ្ញើទៅផ្ទះដើម្បីឱ្យប្អូនប្រុសរៀនហើយម៉ែគាត់ចាយវាយផ្សេងៗទៀត ដូច្នេះខ្ញុំត្រូវធ្វើការបន្ថែមម៉ោងជាញឹកញាប់។

មុនពេលរោងចក្រឡាក់គីហ្សូនបិទ ខាងរដ្ឋបាល និងថៅកែ តែងតែប្រាប់ពួកកម្មករថារោងចក្រនេះមិនបិទទេគ្រាន់តែផ្អាកដំនើរការមួយរយៈ តែកម្មករទាំងអស់មានការមិនទុកចិតរក៏ធ្វើការតវ៉ាខ្លាំង កម្មករបាននាំគ្នាមកជួបជុំនៅពីមុខរោងចក្រ ហើយពេលយប់ដេកយាម ទើបថៅកែប្រាប់កម្មកររោងចក្រនេះបិទទ្វារ នៅថ្ងៃទី ១៥ មករា ២០០៥។ ពេលនោះដែរកម្មករបានពឹងសហជីពក្នុងការដោះស្រាយរឿងនេះ តែកម្មករនៅតែបន្តនិងទាមទារ បន្ទាប់មកទើបខាងរោងចក្រគិតឱ្យកម្មករនូវប្រាក់មួយចំនួនទៅតាមឆ្នាំដែលកម្មករធ្វើការ គឺក្នុងមួយឆ្នាំគេគិតឱ្យមួយខែគឺ៤៥ដុល្លា ចំនែកប្រាក់ផ្សេងៗ

ទៀតគឺមិនបាននោះទេ។ ចំណែកខ្ញុំវិញក៏បានទទួល ៤៥ដុល្លាដែរ ព្រោះខ្ញុំធ្វើការក្នុងរោងចក្រនេះមួយឆ្នាំ ក្រៅពីនេះមិនបានអីសោះ។ បន្ទាប់ពីឈប់បានមួយខែ ទើបចូលធ្វើការនៅរោងចក្រ **អិលអេ២** ៣ខែដំបូងបានប្រាក់ខែតែ ៤០ដុល្លា ហើយខាងរោងចក្រកំនត់ថាបើកម្មករណាមកធ្វើការយឺតជាង៥នាទី និងត្រូវកាត់លុយព្រឹម។ នៅរោងចក្រនេះមិនបានតំណាងសហជីពទេ ហើយលក្ខខណ្ឌការងារលំបាកណាស់ បើសិនជាអត់ថែមម៉ោងគេនឹងដកប៉ុងទុកចំណាំ។ ហើយកិច្ចសន្យាការងារធ្វើ៣ខែម្តង បន្ទាប់មក៦ខែម្តង នេះជាកិច្ចសន្យាមានថេរៈវេលាកំនត់។ សព្វថ្ងៃនេះខ្ញុំមានអារម្មណ៍ភ័យ ប្រសិនជារោងចក្រត្រូវបិទមែននោះ ខ្ញុំនិងមិនមានលុយឱ្យថ្លៃផ្ទះជួល អត់មានលុយផ្ញើរទៅស្រុក ខ្ញុំប្រាកដណាស់ជាត្រូវត្រឡប់ទៅផ្ទះធ្វើស្រែវិញជាមិនខាន តែខ្ញុំចង់ធ្វើការនៅរោងចក្រកាត់ដេរតែមួយមុខគត់។

ខ្ញុំជួលបន្ទប់ថ្លៃ ២៥ដុល្លា នៅគ្នា២នាក់ ហើយថ្លៃទឹកភ្លើងប្រហែលជាអស់៣៥០០០រៀលក្នុងមួយខែ ការហូបចុកវិញម្នាក់ត្រូវចំណាយអស់ជិត ៥០០០រៀលក្នុងមួយថ្ងៃ និងត្រូវចំណាយសំរាប់របស់របរផ្សេងៗទៀត ហើយឥលូវនេះវិញអ្វីៗក៏ឡើងថ្លៃ តែប្រាក់ឈ្នួលនៅដដែលអត់ឡើងសោះ។ បងស្រីរបស់ខ្ញុំបានទៅធ្វើការនៅប្រទេសម៉ាឡេស៊ី ។ ពេលធ្វើការនៅរោងចក្រ **អិលអេ២**នេះ មានបញ្ហារឿងប្រាក់ប៉ុង ព្រោះតែថៅរោងចក្រអោយប្រាក់ប៉ុងនោះទាប ជាហេតុធ្វើអាយកម្មករធ្វើការតវ៉ាដំឡើងតំលៃប៉ុង តែពួកយើងមិនបានជោគជ័យនោះទេ។ ពេលជ្រើសរើសអ្នកដែលជាតំណាងកម្មករ នោះបានទាល់តែថៅកែពេញចិត្ត ក៏ប៉ុន្តែនៅតែមិនមានតំណាងដដែល។ នៅអិលអេ២ តែងមានបញ្ហាឈឺសន្លប់ ខាងថៅកែក៏មិនដែលរវល់អ្វីទេ ទោះបីជាសន្លប់ក៏ត្រូវកាត់លុយព្រឹម និងលុយប្រាក់ថ្ងៃដោយគ្មានគោរពច្បាប់ការងាររបស់រដ្ឋទេ។ នៅក្នុងមួយថ្ងៃធ្វើការបន្ថែមម៉ោងទៅតាមការប្រញាប់ការងារ ពេលខ្លះត្រូវធ្វើការទល់ភ្លឺក៏មានដែរ។ ប្រសិនបើធ្វើការថែមម៉ោង២ម៉ោង ខាងរោងចក្រគិតលុយឱ្យ ៣៥០០រៀល ។

ករណីសិក្សាទី ៣

តំបន់មានជ័យ

១៣ មិថុនា ២០០៥

នាងខ្ញុំឈ្មោះ ក វណ្ណ មានអាយុ ២៤។ គ្រួសារខ្ញុំរស់នៅ ភូមិព្រៃកសំរោង ឃុំតាខ្មៅ ស្រុកតាខ្មៅ ខេត្តកណ្តាល។ សមាជិកគ្រួសារខ្ញុំមាន ៥នាក់។ ម្តាយរបស់ខ្ញុំបានស្លាប់យូរមកហើយ នៅសល់តែពុក និងបងស្រីខ្ញុំក៏ជាស្រីមេម៉ាយដែរ គាត់មានកូនប្រុស ២នាក់។ ពុករបស់ខ្ញុំគាត់ជាអ្នកដាំបន្លែ ហើយខ្ញុំនិងបងស្រីជាអ្នកធ្វើការនៅរោងចក្រ។ ខ្ញុំរៀនចប់ថ្នាក់ទី ១២ នៅវិទ្យាល័យ ហ៊ុនសែន តាខ្មៅ។ ខ្ញុំឈប់រៀនឆ្នាំ ២០០១ ដោយសារតែគ្រួសារខ្ញុំខ្វះខាតហើយគ្មានប្រាក់ចំនូលគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ទើបខ្ញុំសំរេចចិត្តចូលធ្វើការនៅរោងចក្រ ដោយដំបូងឡើយបានលឺសូរគេថារោងចក្រមានរើសកម្មករ ហើយក៏មកធ្វើតេស្តសាកល្បង លើកទី១ និងលើកទី២ ខ្ញុំអត់បានជាប់នោះទេ តែលើកទី៣ក៏បានជាប់នៅរោងចក្រ MV សង្កាក់ចាក់អង្រែ ខណ្ឌមានជ័យ។ មុនពេលចូលធ្វើការគេឱ្យទៅពិនិត្យសុខភាពសិន ពេលនោះខ្ញុំបានចំណាយអស់១៣000រៀល បន្ទាប់មកខាងរោងចក្រគេយល់ព្រមអោយខ្ញុំធ្វើការសាកល្បង៣ខែ ដោយចុះកិច្ចសន្យាជាលាយលក្ខអក្សរជាមួយនិងការយល់ព្រមធ្វើការនូវថ្ងៃអាទិត្យ និងថ្ងៃបុណ្យ និងមិនត្រូវបានគិតលុយព្រឹមឱ្យក្នុងរយៈពេល៣ខែនៃការសាកល្បង។ មុនដំបូងគេអត់គិតលុយអោយជាប្រាក់ឈ្នួលប្រចាំខែនោះទេ តែគេទូទាត់អោយតាមចំនួនឡដែលបានធ្វើ ហើយខ្ញុំអត់បានដឹងថាតំលៃឡប៉ុន្មាននោះដែរ ពេលបើកលុយកន្លះខែដំបូងបាន២៥ដុល្លា។ នៅរោងចក្រនេះគេបើកលុយអោយកន្លះខែម្តង ដូចនេះប្រាក់ឈ្នួលសរុបប្រចាំខែ គិតទាំងធ្វើការថ្ងៃអាទិត្យ និងថ្ងៃបុណ្យបានប្រហែលជា៥0ដុល្លា។ ក្នុងពេលសាកល្បងខាងរោងចក្របានចាត់ប្រធានម្នាក់អោយមកបង្រៀនខ្ញុំ ពីរបៀបធ្វើការនិងអោយចំណាំលេខម៉ូតនីមួយៗ។

ថ្ងៃមួយខ្ញុំច្រលំលេខម៉ូតអាវខុស ក៏ត្រូវបានអ្នកកត់ឡ មកហែកផ្លាកចោលនៅនឹងមុខខ្ញុំ ដោយមិនបាននែនាំ ឬហៅទៅប្រាប់នោះទេ ហើយពេលនោះខ្ញុំបានទៅប្រាប់ប្រធានខ្ញុំ គាត់ក៏មកស្តីឱ្យខ្ញុំទៀត ដោយគាត់គ្មានសួររកមូលហេតុ សោះពេលនោះខ្ញុំអត់មានតវ៉ានឹងគេទេ ព្រោះខ្ញុំជាកម្មករថ្មី គឺបានត្រឹមតែយំប៉ុណ្ណោះ។ គេឱ្យខ្ញុំថែមម៉ោងដល់ម៉ោង ៩យប់ហើយពេលចេញមកផ្ទះអត់មានរម៉ក់ជិះនោះទេ តែបានមិត្តភក្តិពីរនាក់ដែលធ្វើការជាមួយដើរមកជាមួយដែរ។ នៅតាមផ្លូវត្រឡប់មកផ្ទះវិញនោះ មានពួកជើងកាងស្រែកឡូឡា ហើយមានប្រុស១ជិះម៉ូតូមកវ៉ៃគូទទៀត។ ខ្ញុំដើរទាំងភ័យខ្លាចមែនទែនទំរាំតែដល់ផ្ទះ គឺរហូតដល់ម៉ោង ១១យប់។

ពីរបីខែក្រោយមក ទើបខ្ញុំក្លាយជាកម្មករពេញសិទ្ធ ហើយខ្ញុំមិនសូវខ្លាចគេដូចមុនទៀតដែរ តែនៅពេលដែលខ្ញុំធ្វើខុសគេដកតំលៃឡរបស់ខ្ញុំ ហើយបើខ្ញុំធ្វើការលើសចំនួនឡ ដែលគេដាក់ឱ្យក៏ត្រូវគេដកចំនួនឡខ្ញុំដែរ ពេលនោះខ្ញុំខឹងជាខ្លាំងក៏ទៅសួរគេហេតុអ្វីបានជាដកឡរបស់ខ្ញុំ គេប្រាប់ថាចំនួនលើសត្រូវដកឡដូច្នោះហើយគ្មានសិទ្ធតវ៉ាទេ ហើយពេលនោះរោងចក្រអត់មានតំណាងកម្មករ រឺសហជីពទេ ហើយតំលៃឡពេលនេះមួយឡថ្លៃបំផុតបាន 0,៦៥សេន។

ក្រោយធ្វើការបានមួយឆ្នាំ ទើបបានបោះឆ្នោតរើសតំណាងកម្មករ តែពេលនោះខ្ញុំអត់ដឹងទេ ពេលខ្ញុំកំពុងធ្វើការ ស្រាប់តែមានសន្តិសុខម្នាក់យកក្រដាសឆ្នោតមកឱ្យ ហើយគេប្រាប់ថាពេញចិត្តអ្នកណា យើងគូសឈ្មោះអ្នកហ្នឹងទៅ តែពេលនោះខ្ញុំអត់ដឹងថា សហជីពជាអ្វីទេ គេប្រាប់ថាយ៉ាងម៉េចខ្ញុំធ្វើតាមគេទាំងអស់។ ប៉ុន្តែក្រោយពីបោះឆ្នោតមក កន្លែងធ្វើការរបស់ខ្ញុំប្រែប្រួលច្រើនដែរដូចជា ខ្ញុំមិនចង់ថែមម៉ោងគឺអាចចេញបាន តំលៃឡូថោកមានសហជីពដែល អាចតវ៉ាអោយបាន។ ពេលសុំច្បាប់ត្រឹម៣ថ្ងៃ គេឱ្យដោយស្រួលមិនមាន បញ្ហានោះទេ ថ្ងៃមួយខ្ញុំឈឺគ្រុនក្តៅជាខ្លាំង តែខ្ញុំមិនអាចឈប់ទេដោយសារតែខ្ញុំខ្លាចបើកលុយបានតិច ព្រោះអីក្នុងគ្រួសារខ្ញុំបានជំពាក់លុយធានាគារអេស៊ីលីដា ៣០០ដុល្លា ជាមួយនិងការប្រាក់ ៤០ដុល្លាក្នុងមួយខែ តែសងគេមិនទាន់រួចនោះទេ នៅ៤ខែទៀតទើបសងគេរួច។

កាលឆ្នាំ ២០០៤ រោងចក្រនេះសំបូរការងារធ្វើ តំលៃឡូក៏បានថ្លៃ បើកប្រាក់ខែបានច្រើន ហើយយើងអាចតវ៉ាតំលៃឡូ ក៏បានដែរព្រោះមានសហជីពជួយដោះស្រាយឱ្យ តែនៅពេលដែលរោងចក្រត្រូវការសំលៀកបំពាក់ប្រញាប់នាំចេញនោះ ក៏នៅតែត្រូវគេបង្ខំអោយថែមម៉ោង ហើយប្រសិនបើមិនថែមម៉ោងនោះទេ ខាងរដ្ឋបាលនិងហៅទៅផ្តិតមេដៃ គេនិយាយថាបើយើងអត់ថែមម៉ោងគេនឹងដឹកខោអាវឱ្យរោងចក្រផ្សេងធ្វើជំនួស។ ហើយកម្មករខ្លាចពួកចិនទើបនាំគ្នា ថែមម៉ោង ពេលឈឺអត់ថែមម៉ោងត្រូវគេស្តីឱ្យហើយគេសួរពួកយើងថា មកធ្វើការដើម្បីលុយហេតុអ្វីមិនថែមម៉ោង?

មកដល់ឆ្នាំ ២០០៥ អត់សូវមានខោអាវធ្វើនោះទេ ឯតំលៃឡូក៏ចុះថោក តវ៉ាអត់បានទេ ហើយសហជីពធ្វើមិន ដឹងមិនលឺទៀត។ ពេលនោះសុំច្បាប់គឺងាយស្រួលណាស់ព្រោះអត់មានការងារធ្វើ ប៉ុន្តែខាងរោងចក្រមិនអោយប្រើ បំណាច់ឆ្នាំនោះទេ កម្មករខឹងយ៉ាងខ្លាំងក៏ទៅសុំអោយសហជីពតវ៉ាអោយ តែសហជីពនិយាយតបថាប្រយ័ត្នអត់ការ ងារធ្វើ។ ឥលូវមានការងារធ្វើខ្លះអត់ខ្លះ ពេលឈប់គេឱ្យស៊ី៥០ភាគរយ មិនដាច់លុយព្រឹមទេ។ សហជីពមានពីរ គឺម៉ញ៉ឹក និងរស់សុខ ខ្ញុំស្គាល់តែឈ្មោះប្រធានសហជីពប៉ុណ្ណោះ។ រាល់ថ្ងៃខ្ញុំរស់នៅផ្ទះផ្ទាល់ខ្លួន ជិះឡានទៅផ្ទះមួយខែអស់៣ដុល្លា ខ្ញុំខំប្រឹងធ្វើការណាស់ ទាំងថ្ងៃបុណ្យ និងថ្ងៃអាទិត្យ ខ្ញុំបើកប្រាក់ឈ្នួលបានជិត ១០០ដុល្លា តែត្រូវបង់ការប្រាក់អស់ ៣០ដុល្លា អោយអ្នកផ្ទះខ្លះទៀត ទុកប្រាក់តិចតួចណាស់នៅជាប់ខ្លួន១០ដុល្លាសំរាប់ចាយលើថ្លៃម្ហូបអាហារ ។ ហើយបើខែខ្លះ អត់បានដល់១០០ដុល្លាទេនោះ គឺចាយអត់គ្រប់ទេត្រូវខ្ចីលុយគេខ្លះទៀតសំរាប់ក្រុមគ្រួសារ។ បើសិនខ្ញុំ នៅម្នាក់ឯង ខ្ញុំប្រហែលជាសល់ខ្លះ តែដោយសារនៅក្នុងគ្រួសារ ខ្ញុំជាអ្នកចំនាយនិងផ្គត់ផ្គង់ទាំងអស់។

បើសិនរោងចក្របិទ ខ្ញុំមិនដឹងរកការងារធ្វើឯណាទេ មានតែទៅលក់បន្លែនៅផ្សារជាមួយពុកហើយមើលទៅ ព្រោះ គាត់ជាអ្នកដាំបន្លែស្រាប់ ។ បើសិនជាខ្ញុំមានលុយច្រើនគួរសមនោះ ខ្ញុំចង់ធ្វើជាអ្នកចំការដដែល ចង់ទិញដីដាំដើមឈើ ហូបផ្លែ និងចង់រៀនបន្តទៀតនូវបច្ចេកទេសផ្សេងៗ។

ករណីសិក្សាទី ៤

តំបន់ដង្កោ

មិថុនា ២០០៥

នាងខ្ញុំឈ្មោះ វ៉ាំង ស្រីណុច ធ្វើការនៅរោងចក្រ **ប្រាំមួយជាន់**។ គ្រួសារខ្ញុំរស់នៅ ភូមិទ័ពស្តេច ឃុំឆាយ ស្រុកបាភ្នំ ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូន ៦នាក់ (ស្រី ៥នាក់ និងប្រុស១នាក់) ហើយខ្ញុំជាកូនទី ៤ រៀនបានត្រឹមថ្នាក់ទី ៥។ គ្រួសារខ្ញុំមានដីស្រែមួយហិចតា ពុកម៉ែជាអ្នកធ្វើស្រែ និងនេសាទត្រី។ កាលនៅផ្ទះ ខ្ញុំដើរស៊ីឈ្នួលស្ទូងឱ្យគេ ហើយធ្វើស្រែខ្លួនឯងផង។ ធ្វើស្រែហូបមិនដែលគ្រាន់នោះទេ ម្យ៉ាងទៀតបងស្រីដែលបានការងារធ្វើនៅរោងចក្រក៏មានជំងឺទៀតដូចនេះគាត់មិនសូវបានលុយផ្ញើមកផ្ទះនោះទេ គ្រួសារខ្ញុំនៅឯស្រុករកព្រឹកខ្វះល្ងាច រកល្ងាចខ្វះព្រឹក និងមានប្អូនៗនៅតូចពីរបីនាក់ទៀត។ ដោយសារមូលហេតុនេះហើយ ទើបខ្ញុំសំរេចចិត្តមកធ្វើការនៅភ្នំពេញតាមបងស្រីហើយមកដោយខ្លួនឯងគ្មានអ្នកណាបង្ខំទេ។ ពេលមកដល់ភ្នំពេញដំបូង ខ្ញុំមានការភ័យខ្លាចជាខ្លាំង ព្រោះមិនដែលមក។

ពេលមកដល់បាន៣ថ្ងៃរៀនដេរអស់៥ដុល្លា ហើយក៏ដើរធ្វើតេស្តតាមរោងចក្រ ខ្ញុំក៏បានជាប់ជាកម្មករបណ្តែតនៅរោងចក្រហុងវ៉ា។ ខែដំបូងដែលខ្ញុំធ្វើការខ្ញុំបើកប្រាក់ខែបាន៤០ដុល្លា ពេលបើករួចខ្ញុំក៏ដាក់លុយចូលក្នុងហោប៉ៅហើយចេញមកបន្ទប់ជួល តែពេលមកដល់ផ្ទះខ្ញុំមិនដឹងថាលុយខ្ញុំបាត់ដោយរបៀបណាទេអស់ ២០ដុល្លា ខ្ញុំយំជាខ្លាំងពេលដឹងថាបាត់លុយ។ ខ្ញុំធ្វើការនៅរោងចក្រនោះបានតែមួយខែក៏ត្រូវគេរំសាយពីការងារ ព្រោះខាងរោងចក្រគេនិយាយថាគ្មានការងារអោយធ្វើតទៅទៀត។ បន្ទាប់មកខ្ញុំរង់ចាំមួយអាទិត្យ ទើបដើរធ្វើតេស្តជាប់នៅរោងចក្រប្រាំមួយជាន់ ខ្ញុំធ្វើការនៅទីនោះបានមួយឆ្នាំកន្លះ លក្ខខណ្ឌការងារពីមុន និងឥលូវមានការប្រែប្រួលខុសគ្នា ដូចជាសុំច្បាប់ពិបាកទាល់តែយំទើបសុំច្បាប់បាន។ ហើយឥលូវមិនសូវសំបូរការងារទេ គឺគេឱ្យចេញម៉ោង ៤ និងតំលៃបុងធ្លាក់ចុះ ដូចជាពីមុន ១០០ឡូ បាន៤ដុល្លា តែឥលូវ ១០០ឡូ បានតែ ៣,៥ដុល្លា។ បើថែមមួយម៉ោងបាន៣០០០រៀល និងលុយបាយ ១០០០។ ពេលទៅបន្ទប់ទឹកយូរក៏មិនបានដែរ ត្រូវប្រធានចិនស្តីឱ្យមិនខានទេ។ ធ្វើការចូលលើស ៥នាទី និងដាច់លុយរង្វាន់(លុយលើកទឹកចិត្ត)។ រោងចក្រនេះឥលូវកម្មករឈប់ច្រើន ព្រោះធ្វើការច្រើនតែពេលបើកលុយបានតិចពេកមិនគ្រប់គ្រាន់សំរាប់ការចាយវាយ។ ខ្ញុំបានដឹងពីច្បាប់សំរាលកូនខ្លះដែរគឺគេឱ្យ ៩០ថ្ងៃ ហើយគិតលុយឱ្យ ៥០ភាគរយ។ ក្នុងរោងចក្រមានបន្ទប់ទឹកចំនួន២០ គឺ ប្រុស១០បន្ទប់ និងស្រី១០បន្ទប់ ហើយចំពោះការងារវិញមិនសូវបង្ខំនោះទេ។ ក្នុងមួយថ្ងៃខ្ញុំដេរបាន២០ទៅ៣០ឡូ ចំពោះតំលៃបុងខ្ញុំមិនដឹងទេទាល់តែបើកលុយទើបដឹង បើកលុយម្តងបានពី៥០ ទៅ៦០ដុល្លា។ រោងចក្រនេះមានសហជីពមួយឈ្មោះសេរីកម្មករ។

ក្នុងមួយខែខ្ញុំផ្ញើរលុយពី២៥ទៅ៣០ដុល្លាទៅផ្ទះ ហើយសល់ប៉ុន្មានបែងចែកទៅលើថ្លៃផ្ទះ ទឹក និងទុកចាយវាយលើម្ហូបអាហារខ្លះ ។ ប្រាក់ខែដែលខ្ញុំបើកបានក្នុងមួយខែៗតិចតួចណាស់ ចាយស្ទើរតែមិនគ្រាន់ ណាត្រូវផ្ញើរទៅផ្ទះទៀត។ ខ្ញុំគិតថាចង់ឈប់ធ្វើការនៅរោងចក្រនេះទៅធ្វើតេស្តនៅរោងចក្រផ្សេង ព្រោះមិនចង់នៅទៀតទេ មិនបានថែមម៉ោង

តំលៃឡូវាក៏ថោកទៀត។ នៅថ្ងៃខាងមុខទោះជាមានរឿងអ្វីកើតឡើងចំពោះរោងចក្រ រឺក៏ត្រូវបិទទ្វារក៏ដោយក៏ខ្ញុំមិនត្រឡប់ទៅផ្ទះវិញនោះទេ ខ្ញុំនិងដើររកការធ្វើបន្តពីរោងចក្រមួយទៅរោងចក្រមួយទៀត និងអាចបានលុយកាក់ខ្លះផ្ញើអោយពុកម៉ែនៅ ឯស្រុកដើម្បីធ្វើស្រែព្រោះពួកគាត់កាន់តែចាស់ណាស់ទៅហើយ។

ករណីសិក្សាទី ៥

តំបន់ទឹកថ្លា

២០ មិថុនា ២០០៥

នាងខ្ញុំឈ្មោះ លឹម សុខលីន មានអាយុ ២៤ឆ្នាំ ធ្វើការនៅរោងចក្រ LA. គ្រួសារខ្ញុំរស់នៅ ភូមិទួលព្រីច ស្រុកព្រៃឈរ ខេត្តកំពង់ចាម។ ខ្ញុំមានបងប្អូន ៦នាក់ (ប្រុស ៤ និងស្រី២) ហើយខ្ញុំជាកូនទី៤ ពុកម៉ែរបស់ខ្ញុំធ្វើស្រែចំការ។ ខ្ញុំមិនបានដឹងថាគ្រួសារខ្ញុំមានដីស្រែទំហំប៉ុន្មានទេគ្រាន់តែដឹងថាមានតិចតួចណាស់សំរាប់ធ្វើស្រែ ហើយផលស្រូវដែលបាននោះហូបមិនដែលគ្រប់ទេ ត្រូវទិញគេហូប រឺខ្ចីបុលគេស្ទើរតែរាល់ឆ្នាំ។

មុនពេលធ្វើការរោងចក្រខ្ញុំធ្វើស្រែនៅឯស្រុក តែដោយសារមានបងប្អូននៅភូមិជាមួយគ្នាគាត់បានមកធ្វើការមុនហើយពេលគេត្រឡប់ទៅភូមិវិញគេប្រាប់ថានៅភ្នំពេញមានរោងចក្របើកច្រើន ហើយត្រូវការរើសកម្មករ ដូចនេះខ្ញុំក៏សំរេចចិត្តចាកចេញពីស្រុកមកភ្នំពេញដើម្បីរកការងារធ្វើជាមួយគាត់ ហើយម្យ៉ាងទៀតដោយសារតែធ្វើស្រែក៏មិនសូវបាន ផលហើយពុកម៉ែជំពាក់លុយគេទៀត។ ខ្ញុំចូលធ្វើការតាំងពីឆ្នាំ ១៩៩៨ ពេលចូលធ្វើការដំបូង ខ្ញុំធ្វើនៅរោងចក្រ ភជឯ ផ្នែកប៉ាក់ដោយរង់ចាំអស់រយៈពេល ៣ខែ ប៉ុន្តែមុនពេលមកភ្នំពេញ ម្តាយខ្ញុំបានចងការប្រាក់គេអោយមកខ្ញុំសំរាប់ទុកជាសារហ៊ុយធ្វើដំណើរមករកការងារធ្វើ។ ទំរាំបានការងារធ្វើខ្ញុំបានឱ្យអ្នកដែលគេនាំធ្វើការនោះអស់ ១៤ដុល្លា ប៉ុន្តែខ្ញុំមិនអាចរើសយកផ្នែកដេរដែលខ្ញុំចង់ធ្វើនោះទេ។ គេឱ្យខ្ញុំធ្វើនៅផ្នែកប៉ាក់ ហើយផ្នែកនេះធ្វើការ ៣វេន វេនព្រឹកចាប់ផ្តើមពីម៉ោង ៦:៣០ ដល់ម៉ោង ៣:០០ ហើយសំរាកហូបបាយបានមួយម៉ោង។ វេនទី២ ចូលម៉ោង ៣:០០ ដល់ម៉ោង ១១:០០យប់ និងវេនទី៣ ចូលពីម៉ោង ១១ យប់ដល់ម៉ោង ៦:៣០ព្រឹក។ ក្នុងមួយខែ ខ្ញុំបើកលុយបាន ៦០ដុល្លា ទាំងលុយលើកទឹកចិត្ត។

នៅរោងចក្រនេះចំពោះផ្នែកប៉ាក់ បើកម្មករណាសុំច្បាប់ឈប់រហូតដល់៣ថ្ងៃទើបដាច់លុយព្រីម បើនៅផ្នែកផ្សេងដូចជាផ្នែកដេរដល់ទៅ៣ថ្ងៃកន្លះទើបដាច់លុយព្រីម (៥ដុល្លាជាលុយលើកទឹកចិត្តមកធ្វើការទៀងទាត់)។ ខ្ញុំមិនដឹងថាថៅកែរោងចក្រនេះមានជាតិសាសន៍អ្វីនោះទេ ហើយខ្ញុំក៏មិនដឹងច្បាស់ដែរថា រោងចក្រនេះផលិតម៉ាក់អីដែរ តែខ្ញុំធ្លាប់ឃើញអក្សរនេះ adidas ជាផ្លាក។ កម្មករម្នាក់ៗក្នុង៨ម៉ោង ត្រូវតែដេរឱ្យបានតាមគេកំនត់ មិនថាម៉ូតស្រួល រឺពិបាកនោះទេ ហើយនៅផ្នែកប៉ាក់ក៏ដូចគ្នាដែល បើសិនយើងប៉ាក់មិនបានគ្រប់កំណត់ទេ គេនិងស្តីអោយយើងជាមិនខាន។ នៅពេលប៉ាក់គឺមានគ្នា៣នាក់ អ្នកដើរម៉ាស៊ីនម្នាក់ អ្នកដាក់ពុម្ព និងអ្នកកាត់ព្រុយម្នាក់។ បើសិនជាយើងប៉ាក់បានគ្រប់កំណត់ គេមិនបានឱ្យលុយរង្វាន់ រឺប្រាក់លើកទឹកចិត្តអ្វីនោះទេ។ ហើយបើសិនជាខ្ញុំប៉ាក់បានគ្រប់កំណត់ PO លើកក្រោយនៅពេលដែល PO នេះចូលមកម្តងទៀត គឺគេនឹងតំឡើងចំនួនកំនត់លើសពីមុន នេះជាទំលាប់ទៅហើយកម្មករណាក៏ដឹងដែរ ។ ពេលចូលធ្វើការបើសិនយើងចូលយឺត ១០នាទី ២ទៅ៣ដង គេនឹងហៅយើងទៅប្រមាន។

ពេលសុំច្បាប់ម្ដងៗទំរាំតែសុំបានគឺពិបាកណាស់ត្រូវគេសួរដេញដោល ហើយថែមទាំងស្ដីឱ្យទៀត។ នៅក្នុងផ្នែកប៉ាក់ នេះបានទទួលចំណាត់ថ្នាក់ល្អលេខ១ ផ្នែកគំរូល្អគ្រប់ទាំងអស់ មិនថាសណ្ដាប់ធ្នាប់ រឺលក្ខខណ្ឌការងារទេ ប្រធានចិនប្រកាសប្រាប់អោយដឹង តែតាមពិតនោះគឺផ្នែកនេះលំបាកជាងគេនៅក្នុងរោងចក្រ។ ខ្ញុំធ្វើការនៅរោងចក្រនោះបាន៦ឆ្នាំក៏សំរេចចិត្តឈប់ធ្វើការនៅទីនោះ ព្រោះដោយសារតែការងារនៅផ្នែកនោះវាលំបាកពេក ម្យ៉ាងពេលខ្ញុំច្បាប់ម្ដងៗគេស្ដីឱ្យព្រមទាំងព្រមានថែមទៀត។ ខ្ញុំក៏សំរេចចិត្តទៅធ្វើការនៅរោងចក្រមួយទៀត តែដោយសារខ្ញុំគ្មានជំនាញនោះខ្ញុំត្រូវឱ្យលុយអ្នកដែលអាចនាំខ្ញុំចូលធ្វើការនោះអស់ ៥0ដុល្លា។ លុយដែលចំនាយដើម្បីចូលធ្វើការនៅរោងចក្រថ្មីនោះខ្ញុំបានមកពីការចងការប្រាក់គេ ។ ទោះបីជាខ្ញុំបានចូលធ្វើការនៅ PCCS អស់រយៈពេល ៦ឆ្នាំក៏ដោយ តែខ្ញុំគ្មានសល់លុយទេ ព្រោះនៅពេលដែលខ្ញុំបើកលុយម្ដងៗ ខ្ញុំត្រូវផ្ញើរទៅស្រុកដើម្បីជួយដល់គ្រួសារនិងមួយចំនែកទៀតសងបំណុលគេ។ ក្នុងគ្រួសារខ្ញុំប្រៀបដូចជាកូនច្បងគេម្នាក់ដែរ ព្រោះបងស្រីប្រុសទាំងបីនាក់រៀបការអស់ហើយ ដូចនេះពួកគាត់មិនបានជួយដល់គ្រួសារច្រើនដូចពីមុនទៀតទេ។

មុនដំបូងខ្ញុំគិតថាបើចូលរោងចក្រថ្មី ខ្ញុំត្រូវចំនាយលុយទៀតហើយ តែដោយសារខ្ញុំទ្រាំមិនបាននូវការដែលគេស្ដីឱ្យស្ទើរតែរាល់ថ្ងៃនោះ ហើយណាមួយខ្ញុំធ្វើនៅវេនយប់ មានការភ័យខ្លាចនៅពេលត្រឡប់មកផ្ទះ ដូចនេះខ្ញុំក៏សំរេចចិត្តតែម្ដងទៅថាត្រូវតែឈប់ ហើយសុខចិត្តខ្ចីលុយគេដើម្បីចូលធ្វើការនៅរោងចក្រថ្មី។ នៅរោងចក្រ PCCS នេះដែរគឺក៏អាចចាត់ទុកថាជារោងចក្រដែលមានលក្ខខណ្ឌការងារល្អគួរសមដែរ ព្រោះមានសហជីពច្រើន តែចំពោះផ្នែកប៉ាក់គ្មានសហជីពណាមួយដែលហ៊ានចូលទៅតវ៉ា រឺទាមទារអ្វីមួយឱ្យកម្មករនោះទេ។ ខ្ញុំបានចូលធ្វើការនៅរោងចក្រថ្មី នៅដើមឆ្នាំ២00៤ រោងចក្រនោះមានឈ្មោះថា LA វានៅមិនឆ្ងាយពីរោងចក្រចាស់ PCCS នោះទេ។ ចូលដំបូង៣ខែខ្ញុំជាកម្មករបណ្ដែត ហើយបន្ទាប់ពីនោះមកទើបក្លាយជាកម្មករពេញសិទ្ធ ពេលខ្ញុំធ្វើការជាកម្មករបណ្ដែតមួយខែ ខ្ញុំបានប្រាក់ខែ៤0ដុល្លា និងលុយព្រីម៥ដុល្លា សរុប៤៥ដុល្លា។ ឥលូវនេះខ្ញុំជាកម្មករពេញសិទ្ធ ហើយខ្ញុំធ្វើការនៅទីនេះអស់រយៈពេល១ឆ្នាំជាងមកហើយ ប្រាក់ខែដែលខ្ញុំបានគឺ៤៥ដុល្លា បូកទាំងលុយព្រីម៥ដុល្លាទាំងអស់បាន៥0ដុល្លា។ បើសិនបូកទាំងប្រាក់ថែមម៉ោងទៀតនោះ ប្រហែលជាបាន ៦0ដុល្លាក្នុងមួយខែ។

ក្នុងមួយថ្ងៃខ្ញុំត្រូវធ្វើការថែមម៉ោង២ម៉ោង បើសិនយើងមិនចង់ថែមម៉ោងក៏មិនអីដែល រោងចក្រមិនបង្ខំនោះទេ តែបើអាវប្រញាប់នាំចេញគេបង្ខំឱ្យថែមម៉ោង។ ចំពោះកម្មករពេញសិទ្ធ បើចង់ឈប់ត្រូវសុំច្បាប់២ថ្ងៃមុន ហើយជាទូទៅនៅពេលសុំឈប់ ខាងរោងចក្រគេកាត់លុយព្រីមអស់៥ដុល្លា។ តែចំពោះកម្មករបណ្ដែតវិញចូលធ្វើការយឺតតែ ១៥នាទីក៏ដាច់លុយព្រីម៥ដុល្លាដែរ ទោះបីជាពួកគេសុំច្បាប់ក៏ដោយ។ រោងចក្រនេះដេរតាមប្រព័ន្ធខ្សែទឹកហូរ ហើយពេលដេរគេកំនត់ បើសិនជាខ្ញុំដេរមិនបានគ្រប់ចំនួនកំនត់នោះ មេកន្ត្រៃដែលនៅក្រោមថៅកែនោះ នឹងហៅប្រធានក្រុមចិននិងប្រធានក្រុមខ្មែរទៅស្ដីឱ្យ។ ហើយបើមិនអញ្ចឹងទេ មេកន្ត្រៃនោះនឹងមកស្ដីអោយផ្ទាល់តែម្ដង។ ពេលត្រូវសុំច្បាប់ម្ដងៗ គឺត្រូវរកតំណាងកម្មករណាម្នាក់មកសុំអោយ បើមិនដូច្នោះទេខាងរោងចក្រនិងមិនអនុញ្ញាតច្បាប់អោយនោះទេ ហើយមានលំដាប់ថ្នាក់នៃការសុំ ដំបូងត្រូវទៅសុំអនុញ្ញាតិពីប្រធានខ្មែរ ហើយទៅប្រធានចិន និងមេកន្ត្រៃ។

នៅក្នុងរោងចក្រមានមណ្ឌលសុខភាពមួយដែលតែតូចចង្អៀតបន្តិច មានកម្មករសន្លប់ស្ទើរតែរាល់ថ្ងៃ ពេលសន្លប់រោងចក្រយកទៅពេទ្យឯកជន បើសិនជាការសន្លប់រយៈពេលយូរ តែបើសន្លប់ធម្មតាគឺទុកឱ្យសំរាក នៅក្នុងពេទ្យក្នុងរោងចក្រ ក្រោយពេលដឹងខ្លួនត្រូវទៅធ្វើការវិញ ហើយប្រសិនជាសន្លប់នៅមិនសូវមានកំលាំង ទើបគេអនុញ្ញាតិឱ្យមកផ្ទះ។ ពេលសន្លប់ម្តងៗខាងរោងចក្រគិតលុយឱ្យមិនបានកាត់លុយនោះទេ ចំពោះការងារធ្វើប្រចាំថ្ងៃគេបង្ខំណាស់ ហើយធ្វើរហូតគ្មានពេលសំរាកសោះ ធ្វើរហូតទាល់តែដល់ម៉ោងកន្លឹងរោទិ៍តែម្តងទើបគេឱ្យចេញ។ ពេលចេញហូបបាយថ្ងៃត្រង់កម្មករទាំងអស់ត្រូវរង់ចាំវាយបុងអោយហើយ ទំរាំរួចម្តងៗនោះស្ទើរតែមិនបានហូបបាយទេ ព្រោះថាត្រូវដល់ម៉ោងចូលវិញ ហើយម៉ាស៊ីនវាយបុងក៏មានតិច កម្មករវិញក៏មានច្រើនទៀត ហើយការវាយបុងធ្វើច្រើនដងណាស់ គឺដល់ទៅ៤ដង។

ខ្ញុំមិនដឹងថាថៅកែរោងចក្រ LA ជាជនជាតិអីនោះទេតែគ្រាន់តែដឹងថា ប្រធានគ្រប់គ្រងភាគច្រើន ជាជនជាតិចិន។ នៅរោងចក្រនេះខោអាវដែលដេរភាគច្រើនគឺម៉ាក GAP និង Old Navy ខ្ញុំមិនដឹងច្បាស់ថារោងចក្រនេះ មានកម្មករប៉ុន្មាននាក់ទេ គ្រាន់តែដឹងថាក្នុងមួយក្រុមមានកម្មករប្រហែលជា ៥០នាក់។ រោងចក្រនេះមានសហជីពចំនួន៣គឺ សហជីពសេរីកម្មករ សហជីពស៊ីខៅខ្វ និងមួយទៀតខ្ញុំមិនស្គាល់ឈ្មោះទេ ខ្ញុំមិនចូលជាសមាជិកសហជីពទេ តែកាលពីមុនខ្ញុំបានចូលជាសមាជិកសហជីពសេរីកម្មករ តែដោយសារសហជីពឈ្លោះតែគ្នា ដូចនេះខ្ញុំក៏សំរេចចិត្តឈប់ចូលតែម្តងទៅ។ ពេលខ្ញុំជាសមាជិករបស់សហជីពខ្ញុំមិនដែលបានទទួលវគ្គបណ្តុះបណ្តាលអ្វីនោះទេ ហើយគេក៏មិនធ្លាប់បានជួយអ្វីដល់ខ្ញុំនោះដែរ ព្រោះខ្ញុំមិនដែលមានបញ្ហាហើយម្យ៉ាងទៀត ខ្ញុំក៏មិនដែលឈឺទៀត។ តែខ្ញុំធ្លាប់ឃើញសហជីពដើររៃលុយពីកម្មករយកទៅឱ្យកម្មករដែលឈឺ តែតាមការពិតនោះសហជីពបានប្រាប់ថានឹងផ្តល់ឱ្យកម្មករណាឈឺ ដោយដកលុយសមាជិកភាព។

នៅពេលខ្ញុំបើកប្រាក់ខែម្តងៗ ខ្ញុំត្រូវផ្ញើទៅផ្ទះ២០ទៅ៣០ដុល្លាក្នុងមួយខែ និងទុកបង់ថ្លៃផ្ទះ ៥ដុល្លា ថ្លៃទឹកភ្លើង៥ដុល្លា ថ្លៃអង្ករ៥ដុល្លា និងទុកចាយ១៥ដុល្លា។ ខ្ញុំស្នាក់នៅផ្ទះជួលដែលមានបន្ទប់តូចមួយ ហើយបន្ទប់ទឹកគឺត្រូវប្រើរួមគ្នា បន្ទប់ទឹកមិនគ្រប់គ្រាន់នោះទេបើសិនជាមាន បងប្អូនមកលេងម្ចាស់ផ្ទះស្តីឱ្យថាគ្មានកន្លែងណាឱ្យស្នាក់នៅទេ។ ហើយបើសិនជាយើងអត់លុយឱ្យគេគ្រប់ចំនួននោះទេ គេមិនអនុញ្ញាតិឱ្យយើងនៅផ្ទះគេឡើយ។

ខ្ញុំចង់សន្សំលុយសំរាប់រៀនកាត់ម៉ូតខោអាវដែរ ប៉ុន្តែខ្ញុំមិនអាចសន្សំលុយទេ ព្រោះខ្ញុំត្រូវឱ្យលុយទៅពុកម៉ែដើម្បីផ្គត់ផ្គង់ក្រុមគ្រួសារ ព្រោះពួកគាត់មិនមានចំនូលអ្វីនោះទេ សូម្បីតែអង្ករហូបមិនគ្រប់មួយឆ្នាំផង ដូចនេះត្រូវទិញអង្ករគេហូប។ បើសិនរោងចក្របិទខ្ញុំប្រហែលជាមិនទៅស្រុកទេ គឺខ្ញុំត្រូវតែនៅភ្នំពេញបន្តទៀត ហើយរកការងារធ្វើតទៅទៀត បើសិនជាទៅស្រុកក៏គ្មានអ្វីធ្វើដដែល ព្រោះស្រែមានតិចតួចបំផុត ហើយទឹកក៏គ្មានទៀត ណាត្រូវចំនាយលុយទិញជីទៀត ហើយជីក៏កាន់តែឡើងថ្លៃ ដូចនេះបើទៅស្រុកវិញមិនដឹងបានលុយមកពីណាដើម្បីចិញ្ចឹមគ្រួសារនោះទេ

ដូច្នោះត្រូវតែរកការងារធ្វើការនៅភ្នំពេញបន្តទៀត។ បើទៅអនាគតខ្ញុំមានលទ្ធភាពមានលុយកាក់គ្រប់គ្រាន់ ខ្ញុំចង់បើកហាងកាត់ដេរតូចមួយ ព្រោះធ្វើការរោងចក្រយូរ ហើយកំលាំងក៏មិនអាចទាំទ្រ រឺធ្វើការបានយូរទៀតដែរ។ ហើយបើសិនជាខ្ញុំមានកូនខ្ញុំមានលទ្ធភាពខ្ញុំមិនចង់ឱ្យកូនធ្វើការរោងចក្រទេ ព្រោះវាពិបាកហើយប្រឈមនឹងជាតិគីមីដែលធ្វើឱ្យសុខភាពទ្រុឌទ្រោមបានដោយងាយ។

ករណីសិក្សាទី ៦

តំបន់ដង្កោ

ថ្ងៃទី ១០ មិថុនា ២០០៥

នាងខ្ញុំឈ្មោះ យ ធត មានអាយុ២០ឆ្នាំ ធ្វើការនៅរោងចក្រវៃវែល។ គ្រួសារខ្ញុំរស់នៅភូមិប្រាំបីធោម ឃុំពង្រ ស្រុករលាប្អៀ ខេត្តកំពង់ឆ្នាំង។ ខ្ញុំមានបងប្អូន ៥នាក់ (ប្រុស៣ និងស្រី២) ខ្ញុំរៀនបានត្រឹមថ្នាក់ទី ៤ ខ្ញុំគ្មានពុកទេ មានតែម៉ែ ហើយមានដីស្រែបន្តិចបន្តួចតែធ្វើហូបមិនគ្រប់គ្រាន់សំរាប់រយៈពេលមួយឆ្នាំនោះទេ។ កាលពីនៅឯស្រុក ខ្ញុំត្រូវទៅរៀនផង និងលក់នំផង និងពេលខ្លះជួយបោកខោអាវឱ្យគេ គេឱ្យលុយបន្តិចបន្តួច ហើយយកលុយនោះ ទៅទិញអង្ករនិងម្ហូបបានខ្លះដែរ។ ក្រោយមកខ្ញុំក៏ឈប់រៀនទៅស៊ីឈ្នួលលក់គុយទាវនៅហាងមួយបាន៥ម៉ឺនក្នុងមួយ ខែធ្វើបានតែមួយឆ្នាំប៉ុណ្ណោះខ្ញុំក៏ឈប់ ព្រោះម៉ែឱ្យខ្ញុំមកភ្នំពេញជាមួយអ្នកជិតខាងមករកការងារធ្វើនៅភ្នំពេញ តែ ពេលនោះខ្ញុំមិនចង់ទេ តែម៉ែបានអង្វរខ្ញុំថា បើកូនទៅធ្វើការនៅភ្នំពេញ កូននិងបានប្រាក់ខែច្រើនជាងធ្វើការនៅហាង គុយទាវ ហើយមានខោអាវស្អាតៗ សាច់ក៏សដែរ និងជួយសំរាលបន្ទុកគ្រួសារបានច្រើនជាងនេះ។ ដោយលឺគាត់ និយាយអញ្ចឹងខ្ញុំក៏សំរេចចិត្តមកភ្នំពេញ ម៉ែក៏បានលក់ដីស្រែមួយកន្លែងគឺគិតជាមាស៤ជី ហើយគាត់បានឱ្យ១០ម៉ឺន រៀលមកខ្ញុំយកមកភ្នំពេញ។

ពេលមកដល់ភ្នំពេញដំបូង ខ្ញុំមានការភ័យខ្លាចណាស់ ព្រោះខ្ញុំមិនដែលស្គាល់ មកបានមួយថ្ងៃក៏ទៅរៀនដេរ ខ្ញុំចំនាយ អស់៤ម៉ឺនទំរាំតែរៀនចេះដេរ។ បន្ទាប់មកខ្ញុំបានដើរធ្វើតេស្ត គឺគ្មានរោងចក្រណារើសយកជាកម្មករពេញសិទ្ធនោះទេ គឺមានតែរើសកម្មករបណ្តែត។ ដូចនេះខ្ញុំក៏ធ្វើជាកម្មករបណ្តែតនៅរោងចក្រ ហុងវ៉ា ពីរខែដំបូងខ្ញុំបើកលុយបាន ៦០ទៅ៦៥ដុល្លាក្នុងមួយខែ។ ខ្ញុំធ្វើបាន២ខែខាងរោងចក្រក៏រំសាយពីការងាដោយប្រាប់ថាគ្មានការងារអោយធ្វើទៀត នោះទេ បន្ទាប់ពីនោះមកខ្ញុំក៏រង់ចាំអស់រយៈពេលមួយអាទិត្យ ក៏បានធ្វើតេស្តជាប់នៅរោងចក្រ វៃវែល ចូលដំបូង លក្ខខណ្ឌការងារមិនសូវពិបាកនោះទេ ហើយដេរក៏មិនសូវបង្ខំប៉ុន្មានដែរ ហើយសុំច្បាប់ឈប់ក៏មិនពិបាកដែរ។ ចំពោះការទៅបន្ទប់ទឹក គឺគ្រាន់តែកត់លេខកាត ហើយបើយើងទៅយូរក៏គេមិនស្តីឱ្យនោះទេ។ តែឥលូវប្រែប្រួល ដូចជាបង្ខំឱ្យដេរលឿនជាមុន ហើយផលិតផលនីមួយៗត្រូវមានគុណភាពល្អ សុំច្បាប់ឈប់ក៏ពិបាក ទៅបន្ទប់ទឹក ទាល់តែមានសោរទើបគេឱ្យទៅ ហើយក្នុងមួយក្រុមមានគ្នាពី ៤៥ទៅ៥០នាក់ មានសោរបន្ទប់ទឹកតែ២ប៉ុណ្ណោះ។ ការងារមានច្រើនសំរាប់ផ្នែកដេរហើយកម្មករអាចថែមម៉ោងបាន តែផ្នែកតុកាត់គេមិនឱ្យថែមម៉ោងទេ ហើយទោះជាថែម ម៉ោងក៏ខាងរោងចក្រមិនគិតលុយឱ្យដែរ។ ផ្នែកបម្រើយការវិញគឺខាងរោងចក្រសូមឱ្យថែមម៉ោង ហើយគិតលុយទាំង លុយបាយ និងលុយថែមម៉ោង។ ពីមុនប្រាក់ខែរបស់ខ្ញុំ បាន៦៥-៧០ដុល្លា ហើយក្នុងមួយខែខ្ញុំអាចផ្ញើរទៅផ្ទះ ៤០- ៤៥ដុល្លា និងសល់ប៉ុន្មានខ្ញុំបែងចែក ថ្លៃផ្ទះ៥ដុល្លា ទឹក១ដុល្លា និងទុកទិញអង្ករម្ហូប និងទុកហូបចំនីបន្តិចបន្តួច។ តែឥលូវខ្ញុំគិតចង់ឈប់ធ្វើការនៅទីនេះហើយព្រោះប្រាក់ខែ បើកបានតិចពេកគឺបើកបានតែ ៥០-៥៣ដុល្លាប៉ុណ្ណោះក្នុង មួយខែ ដូចនេះលុយផ្ញើរទៅផ្ទះបានតិចទៅតាមហ្នឹងដែរ។

រោងចក្រនេះមានសហជីពពីរ គឺសហជីពសេរីកម្មករ និងសហជីពយុវជន។ ខ្ញុំចូលជាសមាជិកសេរីកម្មករ ហើយមួយខែខ្ញុំត្រូវបង់ ១០០០រៀល សំរាប់សមាជិកភាព តាំងពីធ្វើការនៅរោងចក្រនេះមកខ្ញុំមិនដែលមានរឿងរ៉ាវទៅពឹងឱ្យសហជីពជួយនោះទេ។ នៅក្នុងរោងចក្រនេះមានពេទ្យ តែឥលូវនេះគេយកមណ្ឌលពេទ្យនោះធ្វើជាកន្លែងអ៊ុតវិញ ហើយបានប្តូរទីតាំងទៅនៅជិតបន្ទប់ទឹកខាងក្រោយឆ្ងាយពីកន្លែងធ្វើការណាស់។ ពេលឈឺខ្ញុំមិនចូលចិត្តទៅសុំថ្នាំទេព្រោះឈឺអីក៏អោយតែថ្នាំហ្នឹងដែរ ខ្ញុំធ្លាប់មានជំងឺគ្រុនពោះវៀន ហើយបានទៅព្យាបាទពេទ្យនៅខាងក្រៅរោងចក្រអស់ប្រហែលជា ១០ដុល្លាដែរ។ រោងចក្រនេះមានម៉ាស៊ីនត្រជាក់ តែនៅតែក្តៅព្រោះម៉ាស៊ីនត្រជាក់ឧស្សាហ៍ខូចពេក។ បើថ្ងៃក្រោយរោងចក្របិទមែននោះ ខ្ញុំសំរេចចិត្តថាមិនទាន់ត្រលប់ទៅផ្ទះវិញទេ ព្រោះនៅផ្ទះគ្មានដីស្រែចំការសំរាប់ធ្វើដំណាំនោះទេ ខ្ញុំចង់នៅរកការងារដូចជាលក់បាយតាមហាងជាមួយគេ ដើម្បីយកប្រាក់ជួយឱ្យប្អូនៗរៀន និងសន្សំទុកខ្លួនឯងខ្លះ ដើម្បីធ្វើជាដើមទុនទុកថ្ងៃក្រោយ។

## ករណីសិក្សាទី ៧

## ឆ្នាំ២០០៥

នាងខ្ញុំឈ្មោះ ន ច ថ អាយុ២២ឆ្នាំ កើតនៅភូមិត្រពាំងរា ឃុំតាទុង ស្រុកដងទុង ខេត្តកំពត មានប្អូនស្រី១ និងប្រុស៣នាក់ ខ្ញុំជាកូនទី១ រៀនបានត្រឹមថ្នាក់ទី៤ ប្អូនទី១រៀនបានថ្នាក់ទី៧ ប្អូនទី២រៀនបានថ្នាក់ទី៤ ប្អូនទី៣រៀនបានថ្នាក់ទី២ ប្អូនទី៤រៀនបានថ្នាក់ទី១ ខ្ញុំមានតែម្តាយចំណែកឪពុកគាត់បានស្លាប់កាលពីឆ្នាំ២០០០។ គ្រួសារខ្ញុំជាកសិករមានដីស្រែចំនួន១ហិចតា។ នៅឆ្នាំ២០០០ ម្តាយខ្ញុំបានយកដីស្រែទៅបញ្ចាំបងប្អូនដើម្បីយកប្រាក់ធ្វើជាសោហ៊ុយដើម្បីទៅរស់នៅខេត្តកោះកុង ក្នុងតំលៃ ១៦០ដុល្លា ការផ្លាស់ទីលំនៅនេះកើតឡើងដោយសារតែក្រុមគ្រួសាររបស់ខ្ញុំត្រូវបានគេប៉ុនប៉ងធ្វើបាប រហូតដល់មានថ្ងៃមួយនោះនោះ មានគេឡើងទៅច្របាច់កម្តាយខ្ញុំដល់លើផ្ទះ។

ពេលទៅរស់នៅកោះកុងបាន៣ឆ្នាំ ក៏ផ្លាស់ទីលំនៅមករស់នៅខេត្តកំពង់ស្ពឺដោយការរកស៊ីរែកបង្អែមលក់ ឯកូន១របស់ខ្ញុំបានទៅស៊ីឈ្នួលលក់កំលាំងតាមផ្ទះអ្នកស្រុកនៅជិតភូមិ។ ឆ្នាំ២០០៥ ខែមិថុនា ខ្ញុំបានសំរេចចិត្តដោយខ្លួនឯងមកធ្វើការរោងចក្រ ពេលមកដល់ទីក្រុងមិនបានមួយថ្ងៃផងខ្ញុំក៏បានធ្វើការនៅ រោងចក្រ LA2 នៅទឹកថ្លា ដោយមិនបានចំណាយប្រាក់ទេ ព្រោះចិនជាអ្នកចេញមករើសផ្ទាល់ ហើយខ្ញុំក៏មិនបានស្គាល់អ្នកណាដែរធ្វើការនៅក្នុងនោះ ខ្ញុំធ្វើការនៅក្នុងរោងចក្រនេះបាន៩ខែហើយ ខ្ញុំជាកម្មករធ្វើការនៅផ្នែកតុកាត់ដែលមានគ្នាទាំងអស់ ៣៨នាក់ ហើយកម្មករនៅក្នុងរោងចក្រទាំងអស់មាន១៨០០នាក់។ ទោះជាកម្មករនៅក្នុងរោងចក្រច្រើនប៉ុណ្ណាក៏ដោយក៏ខាងរោងចក្រផ្តល់អោយបន្ទប់ទឹកត្រឹមតែ៥០ ប៉ុន្តែវាមិនគ្រប់គ្រាន់នោះទេសំរាប់កម្មករ ព្រោះឧស្សាហាមានកម្មកររអ៊ូរទាំអំពីរឿងបន្ទប់ទឹកនេះណាស់។ ខ្ញុំចូលដំបូងគឺមិនបានទទួលវគ្គហ្វឹកហ្វឺនអ្វីនោះទេពីរោងចក្រ ប៉ុន្តែពេលនោះខ្ញុំមានចិត្តសប្បាយរីករាយជាខ្លាំង ហើយមានអារម្មណ៍ភ័យផងអរផង ព្រោះខ្លាចចិនស្តីឱ្យ ខ្លាចចិនបណ្តេញចេញ ព្រោះវាមិនងាយរកការងារបានធ្វើនោះទេ អារម្មណ៍របស់ខ្ញុំភ័យខ្លាចខ្លាំងណាស់ក្នុងការមករស់នៅទីក្រុងភ្នំពេញ ហើយជាពិសេសនោះគឺភ័យខ្លាចក្នុងការធ្វើដំណើរត្រឡប់មកផ្ទះវិញនៅពេលចប់ធ្វើការនៅពេលយប់។

បន្ទាប់ពីបានធ្វើការនៅក្នុងរោងចក្រមក ខ្ញុំអាចជួយដោះស្រាយបញ្ហាក្នុងគ្រួសារបានខ្លះ ខ្ញុំបានផ្ញើរលុយទៅផ្ទះរាល់ខែហើយប្រាក់ខែគោលខ្ញុំគឺ ៤០ដុល្លា បូកនិងថែមម៉ោងផងនោះជាសរុបគឺបាន ៥០-៦០ដុល្លា ដែរក្នុងមួយខែ។ ខ្ញុំមិនបានស្រឡាញ់ការងារដែលប្រើដោយកំលាំងទេ ប៉ុន្តែដោយសារតែខ្ញុំគ្មានចំណេះវិជ្ជាអ្វីក្នុងខ្លួនទើបទ្រាំធ្វើវាទៅ ជារៀងរាល់ថ្ងៃខ្ញុំត្រូវធ្វើការ ពី១០-១៤ម៉ោង ហើយមានពេលសំរាកតិចតួចណាស់ ទាំងនេះក៏ដោយសារតែខ្ញុំត្រូវការលុយកាក់ដើម្បីផ្តល់អោយប្អូន១រៀនសូត្រ និងអោយ ម្តាយយកទៅសងបំណុលគេ ព្រោះអីគ្រួសារខ្ញុំជំពាក់គេច្រើនណាស់។

ខ្ញុំក៏ជាសមាជិកម្នាក់របស់សហជីពមួយនៅក្នុងរោងចក្រដែល សហជីពនិយាយថាបើសិនជាមានបញ្ហានៅ ក្នុងរោងចក្រខាងសហជីពអាចជួយដោះស្រាយអោយបាន ហើយខ្ញុំក៏ធ្លាប់ចូលរួមធ្វើកូដកម្មម្តងដែរក្នុង ការទាមទារលក្ខខណ្ឌការងារ

និងតំលៃបុងនៅក្នុងរោងចក្រ ហើយលទ្ធផលវិញនោះគឺយើងទទួលបានជោគជ័យ។ ខ្ញុំបានជួលបន្ទប់នៅជិតរោងចក្រ ហើយក្នុងបន្ទប់នោះខ្ញុំនៅគ្នា៣នាក់ ក្នុងមួយខែគឺតំលៃ ១៥ដុល្លា ហើយខ្ញុំត្រូវចំណាយថ្លៃទឹកភ្លើង ៥ដុល្លា (ភ្លើង១គីឡូវ៉ាត់១000រៀល) ក្នុងមួយខែ។ បន្ទប់មិនសូវមាំទេនោះទេ តូចចង្អៀតមិនមានខ្យល់អាកាសបរិបូណ៍ ប៉ុន្តែមានបន្ទប់ទឹកផ្ទាល់ដាច់ដោយឡែក ។ ពីផ្ទះជួលទៅកន្លែងធ្វើការខ្ញុំចំណាយពេលពេល១0នាទីក្នុងការដើរទៅ នៅពេលចេញពីធ្វើការពេលយប់មានការភ័យខ្លាចជាខ្លាំង ព្រោះធ្លាប់ជួបបញ្ហាម្តង នៅថ្ងៃនោះមានក្រុមជើងកាងមួយក្រុមបានដេញចាប់ ប៉ុន្តែពួកខ្ញុំបានរត់រួច។

ពេលព្រឹកខ្ញុំតែងញ៉ាំបាយស្រូបនៅមុខរោងចក្រតំលៃ ៥00៛ ពេលថ្ងៃត្រង់ក៏ញ៉ាំនៅមុខរោងចក្រដែរ បាយ៥00៛ និងសម្លរ៥00រៀល ដល់ពេលល្ងាចទិញបាយកញ្ចប់ ៥00៛ និងសម្លរ ៥00៛ យកមកញ៉ាំនៅផ្ទះ។ ក្រៅពីប្រាក់ខែខ្ញុំគ្មានចំណូលអ្វីផ្សេងទេ ដូច្នេះខ្ញុំត្រូវចាយវាយដោយសន្សំសំចៃក្នុង១ខែ ខ្ញុំចំណាយទៅលើការថែរក្សាសុខភាព ៤-៥ដុល្លា ការដើរលំហែរកាយម្តងៗអស់ ៣-៤ដុល្លា ចំណាយទៅផ្គត់ផ្គង់គ្រួសារអស់ប្រហែល ៣0-៤0ដុល្លា។ ខ្ញុំមិនបានសន្សំលុយទុកសំរាប់ខ្លួនឯងទេ ពីព្រោះប្រាក់ខែដែលបានត្រូវផ្ញើរទៅម្តាយ ដើម្បីគាត់ទិញអង្ករហូបបង់ថ្លៃសាលាប្អូនៗ និងចំណាយផ្សេងៗទៀតនៅក្នុងគ្រួសារ។

ខ្ញុំមិនបានយល់ដឹងពីច្បាប់ការងារ រឺក៏សិទ្ធិនោះទេនៅក្នុងរោងចក្រ។ ខ្ញុំធ្លាប់ឈឺម្តងដែរគឺវិលមុខ និងអស់កំលាំង ខ្ញុំបានទៅព្យាបាលពេទ្យក្នុងរោងចក្រ ប៉ុន្តែសេវាកម្មនៅទីនោះមិនសូវល្អទេ ព្រោះពេលទៅពិនិត្យម្តងៗ ពេទ្យនោះតែងនិយាយថាយើងធ្វើពុធជាឈឺ ។ បើយើងមានលុយទៅពេទ្យឯកជនវិញល្អជាង ប្រហែលជាចំណាយអស់ ៣-៤ដុល្លាប៉ុណ្ណោះ ប៉ុន្តែខ្ញុំគ្មានលុយសំរាប់ទៅពេទ្យឯកជនទេ ពេទ្យ ដែលមានសេវាល្អ គឺសំរាប់តែអ្នកមានលុយប៉ុណ្ណោះ។

ករណីសិក្សាទី ៨
តំបន់ដង្កោ
១៨.១២.២០០៥

ឈ្មោះ ច ន្ទ អាយុ ១៨ឆ្នាំ រៀននៅថ្នាក់ទី ៧ ចំងាយពីផ្ទះមកសាលារៀន ២គីឡូដី ជួនកាលដើរទៅ សាលារៀន ជួនកាលជិះកង់ទៅរៀន។ នាងមានបងប្អូន៥នាក់ នាងជាកូនទី២នៅក្នុងបន្ទុកគ្រួសារ ក្រុមគ្រួសាររស់នៅភូមិជោរី ឃុំក្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង។ ឪពុកម្តាយរបស់នាងជាកសិករ ហើយមានដីស្រែចំនួន ២ហិចតា គោ១ក្បាល និងក្របី៣ក្បាល។ កាលពីមុនការធ្វើស្រែហូបមិនសូវគ្រប់គ្រាន់ទេ ព្រោះតែត្រូវចំណាយច្រើនក្នុងការធ្វើវា ដីស្រែតែ ២ហិចតាត្រូវជីអស់ដល់ទៅ៥បាវ ពេលទិញជីជួនកាលអោយលុយគេ ជួនកាលជំពាក់គេខ្លះ ហើយដល់ខែច្រូតកាត់រួចរាល់ ទើបអោយស្រូវ ឬលក់ស្រូវដើម្បីសងថ្លៃជីគេវិញ។ នៅពេលដែលហូបមិនគ្រប់គឺត្រូវទៅចងការលុយគេខ្លះ សំរាប់ដោះដូរ រឺទិញម្ហូបអាហារនៅក្នុងគ្រួសារ។

មូលហេតុដែលធ្វើអោយនាងសំរេចចិត្តចាកចេញពីភូមិកំនើតមករកការងារធ្វើនៅទីក្រុងជាអ្នកភូមិ គឺដោយសារតែម្តាយ នាងមានជំងឺជាទំងន់ ហើយម្យ៉ាងទៀតគឺបញ្ហាជីវភាពខ្វះខាត ពេលមកភ្នំពេញម្តាយ របស់នាងបានទៅខ្ចីលុយបងប្អូនចំនួន ១២ម៉ឺនរៀល មកអោយនាងសំរាប់ធ្វើដំណើរ។ ពេលនាងមកដល់បាន១ថ្ងៃ នាងក៏បានធ្វើតេស្តជាប់នៅរោងចក្រ ចយហ្វូល។ នាងគិតថានៅក្នុងរោងចក្រនេះមានលក្ខខណ្ឌការងារល្អ ដូចជាការដេរមិនត្រូវបានបង្ខំនោះទេ ប៉ុន្តែមាន ចំនួនកំនត់ បើដេរគ្រប់កំណត់និងបានទទួលរង្វាន់ ហើយបើរោងចក្រតំរូវអោយថែមម៉ោងគឺត្រូវតែថែម ។

នាងក៏បានចូលជាសមាជិកសហជីព ហើយបានដឹងថានៅពេលដែលមានរឿងគេអាចជួយដោះស្រាយ បានដូចជាការសុំច្បាប់ រឺចូលរួមគ្នាក្នុងការតវ៉ា។ បន្ទាប់ពីធ្វើការនៅទីនោះបានប្រហែលជា៥ខែមក នាងក៏បានសំរេចចិត្តឈប់ធ្វើការ នៅទីនោះ ព្រោះតែប្រាក់ខែដែលបាននោះវាតិចតួច មិនអាចផ្គត់ផ្គង់ជីវភាព និងក្រុមគ្រួសារបាន ហើយម្យ៉ាងទៀតនៅ រោងចក្រចយហ្វូលនោះមិនសូវមានការងារធ្វើទេ ខាងរោងចក្រអោយឈប់សំរាកដោយកាត់លុយ ៥០%។ នាងបានធ្វើ ការនៅរោងចក្រកាណាឌីយ៉ាអាគារ២៣ C.M.C.W ដែលមានកូរ៉េជាថៅកែរោងចក្រ និងជនជាតិវៀតណាមជាអ្នក គ្រប់គ្រង រោងចក្រនេះមានច្បាប់ការងារតឹងណាស់ ភាគច្រើនថែមម៉ោងត្រឹមម៉ោង៦ ឬ៩យប់ ជួនកាលអាចទល់ភ្លឺ ។ ហើយប្រសិនបើដេរដល់ភ្លឺនោះ នៅថ្ងៃបន្ទាប់ខាងរោងចក្រអោយសំរាកត្រឹមតែកន្លះថ្ងៃនោះទេ គឺត្រូវចូលធ្វើការវិញ ហើយ ។ ពេលថែមដល់ម៉ោង៦ ខាងរោងចក្រអោយលុយបាយបាន១០០០៛ ម៉ោង៩យប់ បានលុយបាយ ១៥០០៛ ។ ខាងរោងចក្រតំរូវអោយដេរកំណត់ មួយក្រុមត្រូវចេញអាវអោយបាន ១៣០០អាវ បើមិនបានទេនោះ គេនឹងស្តីអោយ តែប្រសិនបើដេរគ្រប់គេអោយរង្វាន់ ចែកសាប៊ូដុសមុខ២ដុំ សាប៊ូកក់សក់២ដប ហ្វូមលាង មុខ១ដប។ ពេលសុំចេញ ម៉ោង៤គឺពិបាកណាស់ ខាងរោងចក្រគេមិនអោយចេញនោះទេ ព្រោះគេតំរូវអោយធ្វើការថែមម៉ោង ទោះបីជាឈឺក៏ ដោយក៏មិនអោយចេញដែរ តែគេអោយទៅសំរាកនៅកន្លែងមណ្ឌលពេទ្យនៅក្នុងរោងចក្រកន្លះម៉ោងដែល ដល់ពេលបាន

ធូរហើយត្រូវចូលធ្វើការវិញ។ នៅក្នុងរោងចក្រនេះពីមុនក៏មានសហជីព ប៉ុន្តែសហជីពនឹងពឹងមិនដែលបានទេ កម្មករភាគច្រើនគិតថាសហជីពបានស៊ីលុយថៅកែ ក្រោយមកក៏នាំគ្នាឈប់ចូលជាសមាជិកតទៅទៀតទៅ។ បន្ទាប់ពីធ្វើការនៅកាណាឌីយ៉ា បាន៥ខែនាងក៏បានឈប់ពីរោងចក្រនោះទៀត ហើយចូលធ្វើការនៅរោងចក្រ **ប្រាយស្តាយ** វេនយប់ម្តង នាងបាននិយាយថាចំពោះច្បាប់ការងារវិញគឺមិនទាន់តឹងតែងដូចនៅសាន់តិចដែលនៅក្បែរនេះពេកទេ ។នាងដេរស៊ីជាបុង ហើយតំលៃបុងឡើងចុះទៅតាមម៉ូដខោអាវ ចំពោះចំនួនដេរវិញគឺអត់មានកំណត់នោះទេ ប៉ុន្តែប្រសិនបើដេរខោអាវអត់គ្រប់ពេលខោអាវត្រូវនាំចេញនោះគឺខាងរោងចក្របង្ខំ។ ម៉ោងចូលធ្វើការសំរាប់វេនយប់គឺពីចូលម៉ោង៦ល្ងាច ចេញនៅម៉ោង៥កន្លះព្រឹក ប្រសិនជាថែមម៉ោងគឺបាន២ម៉ោង ការថែមម៉ោងខាងរោងចក្រគេគុណម៉ោងអោយពីលើបុង ហើយលុយបាយក៏គេគិតអោយ ហើយរួមជាមួយលុយឡានក៏គេគិតអោយដែរគឺក្នុងមួយខែបាន៥ដុល្លា។ សុំច្បាប់មិនសូវជាស្រួលប៉ុន្មានទេ ជួនបាន ជួនអត់បាន ក្នុងរោងចក្រនេះមានសហជីពតែនាងមិនទាន់បានចូលជាសមាជិកនៅឡើយទេ ព្រោះសហជីពទើបនឹងបង្កើតថ្មីដែរ។ កាលពេលនាងទើបនឹងចូលដំបូងនាងខំប្រឹងថែមម៉ោងនិងធ្វើការជាខ្លាំង ហើយប្រាក់ខែដំបូងរបស់នាងគឺបានរហូតដល់ ១០០ដុល្លា តែលុយពាក់កណ្តាលគឺត្រូវផ្ញើរទៅផ្ទះសំរាប់ ជួយដល់ម្ហូបអាហារផ្សេងៗ និងពាក់កណ្តាលទៀតគឺសំរាប់ទុកផ្គត់ផ្គង់ខ្លួនឯង បង់ថ្លៃផ្ទះ ទឹកភ្លើង ម្ហូបអាហារ និងទិញខោអាវបន្តិចបន្តួច។

ចាប់តាំងពីនាងបានចេញមកធ្វើការនៅរោងចក្រមកនាងគិតថាបានជួយធ្វើអោយជីវភាពគ្រួសាររបស់ នាងបានធូរស្រាលបន្តិច ទោះបីជាលុយនោះមិនសូវច្រើនក៏ដោយ។ នាងគិតថាប្រសិនជានៅថ្ងៃខាងមុខរោងចក្របិទ នាងអាចសន្សំប្រាក់សល់បន្តិចបន្តួចនោះ នាងនឹងទៅផ្ទះវិញ ព្រោះអីបំណងរបស់នាងគឺចង់បើកតូបតូចមួយល្មម ដើម្បីកាត់ម៉ូតខោអាវសំរាប់ចិញ្ចឹមជីវិតទៅថ្ងៃមុខ។

ករណីសិក្សា៩

តំបន់ទួលសង្កែ

ខែធ្នូ ២០០៥

ម រម អាយុ២៤ឆ្នាំ រៀបការរួចតែមិនទាន់បែកចេញពីគ្រួសារទេ កើតនៅភូមិបារ៉ាយ ឃុំខ្វិត ស្រុកព្រៃ ខេត្តកំពង់ចាម មានប្អូនស្រីម្នាក់ និងប្អូនប្រុស៣នាក់។ ឪពុកម្តាយខ្ញុំជាកសិករមានដីស្រែមាន១ហិចតា តែឆ្នាំនេះធ្វើស្រូវមិនបានគ្រប់គ្រាន់ទេ បានប្រហែលជា៥០ថាំងស្រូវ។ ពេលដែលធ្វើស្រែម្តងៗចំណាយអស់ច្រើនប្រហែលជា៣០-៤០ម៉ឺន ដីស្រែ១ហិចតានេះត្រូវប្រើជី២បាវ ហើយក្នុង១បាវតំលៃ៧០០០០៛ ហើយនិងត្រូវចំណាយលើការចាយវាយផ្សេងៗ ម្យ៉ាងទៀតក្នុង១ឆ្នាំៗគ្រួសាររបស់ខ្ញុំធ្វើបានស្រូវវស្សាម្តងប៉ុណ្ណោះ ។ ផ្ទះរបស់ខ្ញុំមានចិញ្ចឹមសត្វខ្លះដែរ ដូចជា គោ មាន់ ជាដើម។

ក្នុងមួយឆ្នាំៗផលស្រូវដែលធ្វើបានមកហូបមិនគ្រាន់នោះទេ យ៉ាងហោចណាស់ក៏ខ្វះប្រហែលជា៣ខែដែល ហើយជារៀងរាល់ឆ្នាំត្រូវទៅខ្ចីអ្នកភូមិហូបសិនទំរាំប្រមូលផលបាន។ ប្រសិនជាខ្ចីគេ១០ល្អីស្រូវ ត្រូវសងគេវិញ១១ល្អី។ ពេលដល់រដូវបុណ្យទានម្តងៗគឺត្រូវលក់ស្រូវខ្លះដើម្បីចូលរួមពិធី ព្រោះអីគ្រួសារខ្ញុំគ្មានលុយកាក់គ្រប់គ្រាន់នោះទេ ហើយក៏គ្មានមុខរបរអ្វីផ្សេងទៀតទេក្រៅពីធ្វើស្រែ ប៉ុន្តែឥឡូវនេះសមាជិក ក្នុងគ្រួសាររបស់ខ្ញុំបានចេញមករកការងារធ្វើ ២នាក់ហើយ គឺខ្ញុំនិងប្អូនស្រីរបស់ខ្ញុំ។ គ្រួសាររបស់ខ្ញុំធ្លាប់ខ្ចីលុយគេម្តងដែរ គឺខ្ចីពីអ្នកភូមិដូចគ្នាចំនួន ១០០,០០០៛ ហើយក្នុងមួយខែត្រូវសងការប្រាក់គេវិញ ១០ភាគរយ សំរាប់ការចំណាយផ្សេងៗនៅក្នុងផ្ទះ។

ខ្ញុំរៀនបានត្រឹមថ្នាក់ទី៥ ក៏សំរេចចិត្តឈប់រៀនចង់រកការងារធ្វើដើម្បីជួយគ្រួសារនិងអោយប្អូនៗ២នាក់ ទៀតរៀនបន្តព្រោះអីឃើញក្រុមគ្រួសារលំបាកពេក ហើយណាមួយខ្ញុំជាកូនស្រីបងនៅក្នុងគ្រួសារ។ ពេលមកដល់ទីក្រុងខ្ញុំបានដើរធ្វើតែស្តតាមរោងចក្រដើម្បីរកការងារធ្វើ ពេលនោះខ្ញុំស្នាក់នៅជាមួយអ្នកស្រុករបស់ខ្ញុំ ពួកគេមិនបានអោយខ្ញុំជួយចេញថ្លៃបន្ទប់ទេ គឺជួយចេញតែថ្លៃទឹកភ្លើងប៉ុណ្ណោះ។ ពេលដែលមកដល់ភ្នំពេញដំបូង ខ្ញុំមានអារម្មណ៍ភ័យខ្លាចណាស់ ព្រោះមិនដែលស្គាល់គេ ហើយមិនហ៊ានទៅណាមកណាទេ ពេលនោះខ្ញុំមានលុយតែ ៥០០០០រៀលប៉ុណ្ណោះដែលម្តាយខ្ញុំបានមកពីការខ្ចីគេ។ ក្រោយមកចំណាយអស់រយៈពេលជិតមួយខែ ក៏ធ្វើតេស្តជាប់នៅ រោងចក្រស្បែកជើង " **ស៊ូព្រីមមា** " ពេលដែលទទួលបានការងារនោះធ្វើ ខ្ញុំមានអារម្មណ៍សប្បាយ ហើយអរខ្លាំងណាស់។

ពេលព្រឹកចូលធ្វើការនៅម៉ោង ៧:០០-១១:៣០ សំរាកមួយម៉ោងហើយត្រូវចូលវិញនៅម៉ោង ១២:៣០-១៦:០០ សំរាកបានកន្លះម៉ោង ក៏ចូលធ្វើការថែមម៉ោងរហូតដល់ម៉ោង ៨:៣០យប់។ ពេលថ្ងៃត្រង់ញ៉ាំបាយនៅមុខរោងចក្រញ៉ាំគ្នា២នាក់ មួយពេលអស់ ១៥០០៛-២០០០៛ ពេលល្ងាច ធ្វើម្ហូបខ្លួនឯង។ ពេលចេញពីធ្វើការពេលយប់ខ្ញុំភ័យខ្លាចខ្លាំងណាស់ ព្រោះនៅតាមផ្លូវត្រឡប់មកផ្ទះជួលវិញនោះមានពួកជើងកាងច្រើនណាស់។

ខ្ញុំចូលធ្វើការនៅរោងចក្រនេះបាន២ឆ្នាំហើយ ហើយក៏មិនដែលផ្លាស់ប្តូររោងចក្រដែរ ហើយម្យ៉ាងទៀតខ្ញុំមិនមានចិត្តចង់ផ្លាស់ប្តូរផងទេ ខ្ញុំគិតតែធ្វើការដើម្បីជួយដល់ក្រុមគ្រួសារ។ នៅក្នុងរោងចក្រមាន កម្មករប្រហែលជា១០០០នាក់ ថៅកែជាជនជាតិចិនដីគោក ហើយមិនសូវមានកម្មករចូលជាសមាជិក សហជីពទេ ប៉ុន្តែសហជីពបានជួយកម្មករខ្លះដែរ។ រោងចក្រនេះពិបាកសុំច្បាប់ណាស់ បើឈប់១ថ្ងៃ គឺកាត់៧ដុល្លា បើសុំច្បាប់ពិសេសនឹងត្រូវដាច់បំណាច់ឆ្នាំ។ រោងចក្រមានបុគ្គលិកពេទ្យ២នាក់ តែពួកគេមានសំដីអាក្រក់ណាស់ ប្រសិនជាកម្មករណាឈឺនោះគឺត្រូវទៅសុំច្បាប់ពេទ្យ ហើយបន្តទៅសុំពីចិន រួចបន្តទៅផ្នែករដ្ឋបាល។ ហើយម្យ៉ាងទៀតថ្នាំនៅក្នុងរោងចក្រវិញមិនសូវល្អទេពេលលេបទៅគឹងងុយដេក។ ជួនកាលកម្មករសុំចេញម៉ោង៦ គេមិនព្រមអោយនោះទេ ប៉ុន្តែនៅតែមានកម្មករលួចចេញមុនម៉ោង៦ តែនៅថ្ងៃបន្ទាប់កម្មករនេះត្រូវបានគេហៅទៅព្រមាន និងហាមមិនអោយថែមម៉ោងរហូតដល់មួយខែ។ ពេលណាមានការងារច្រើនខាងរោងចក្រដាក់កំនត់អោយដេរច្រើន ហើយបើកម្មករណាដេរមិនគ្រប់ កំនត់នោះគឺត្រូវបានគេហៅទៅស្តីអោយ។ នៅក្នុងរោងចក្រនេះមានសហជីពឈ្មោះ "សេរីកម្មករ" ប៉ុន្តែខ្ញុំមិនបានចូលជាសមាជិករបស់សហជីពនោះទេ ខ្ញុំខ្លាចព្រោះចិនមិនចូលចិត្តសហជីព។ ពេលចូលធ្វើការដំបូងរោងចក្រនេះធ្លាប់មានកូដកម្មម្តងដែរ គឺទាមទារអោយកម្មករបណ្តែតក្លាយមកជាកម្មករពេញសិទ្ធិ ប៉ុន្តែការទាមទាររបស់កម្មករនោះគឺទទួលបរាជ័យ។ បន្ទាប់មកចិនបានបញ្ឈប់ការងារសន្តិសុខអស់៣នាក់ ព្រោះនៅពេលធ្វើការថែមម៉ោងចិនអោយកម្មករញ៉ាំបាយនៅក្នុងរោងចក្រ ប៉ុន្តែសន្តិសុខបើកទ្វារអោយកម្មករចេញមកក្រៅ។

ប្រសិនបើខ្ញុំធ្វើការថែមម៉ោងពេញមួយខែនោះគឺបានប្រហែលជា៧០ដុល្លា ហើយក្នុង១ខែខ្ញុំទុកចាយ ខ្លួនឯង ២០ដុល្លា តែបើខ្ញុំឈឺគឺចាយមិនគ្រាន់ទេ ព្រោះត្រូវចំណាយទៅលើថ្នាំជាញឹកញាប់ខ្ញុំតែងផ្តាសាយ ការចំណាយសរុបសំរាប់ទិញថ្នាំប្រហែលជា ៣០០០០រទំរាំតែជា ខ្ញុំគិតថាខ្ញុំត្រូវតែលេបថ្នាំដើម្បីកុំអោយឈឺធ្ងន់ ព្រោះខ្លាចខាតការងារ។ ចំណែកម្ចាស់ផ្ទះដែលខ្ញុំជួលនៅនោះគឺស្រួលទេ ខ្ញុំជួលនៅគ្នា៦នាក់គេគិតទាំងទឹកភ្លើង ៣៥ដុល្លាក្នុងមួយខែ ។ ខ្ញុំតែងផ្ញើរលុយទៅផ្ទះរាល់ខែ ២០-៣០ដុល្លា ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារដូចជា ទិញម្ហូប សងបំណុលគេ ខោអាវប្អូនរៀន ទិញជីដាក់ស្រែ។ ឥឡូវនេះខ្ញុំមិនបានជួយគាត់ដូចមុនទេ ព្រោះខ្ញុំមានគ្រួសារហើយ ប៉ុន្តែខ្ញុំផ្ញើរទៅគាត់បានខ្លះដែរ តែនៅមានប្អូនស្រីខ្ញុំម្នាក់ទៀតដែលបានជួយគាត់។ នៅថ្ងៃខាងមុខបើសិនជារោងចក្របិទ ខ្ញុំនឹងទៅផ្ទះវិញចិញ្ចឹមសត្វ ជ្រូក មាន់ ហើយបំណងប៉ុងប្រាថ្នារបស់គឺខ្ញុំចង់ក្លាយជាជាងកាត់ដេរនៅថ្ងៃអនាគត។

ករណីសិក្សាទី ១០

តំបន់ទួលសង្កែ

មិថុនា ២០០៥

នាងខ្ញុំឈ្មោះ ឡ ច ន មានអាយុ ២៥ឆ្នាំ ខ្ញុំរស់នៅក្នុងភូមិទី៣ ឃុំកងតានឹង ស្រុកកងមាស ខេត្តកំពង់ចាម ហើយខ្ញុំមានបងប្អូន ៨នាក់។ បងប្អូនបានរៀបការរួច ៣នាក់ នៅរៀន ២នាក់។ ឳពុកម្តាយខ្ញុំជាកសិករ ហើយនៅពេលដែលជីវភាពនៅក្នុងគ្រួសារកំពុងជួបបញ្ហាលំបាក ខ្ញុំក៏បានឈប់រៀនត្រឹម ថ្នាក់ទី៤ដើម្បីជួយធ្វើស្រែពួកគាត់ ហើយម្យ៉ាងវិញទៀតគ្រួសាររបស់ខ្ញុំក៏មិនមានលុយគ្រប់គ្រាន់សំរាប់អោយខ្ញុំរៀនសូត្រដែរ។ ពីមួយឆ្នាំទៅមួយឆ្នាំគ្រួសារខ្ញុំត្រូវចំណាយអស់ទុនជាច្រើនក្នុងការធ្វើស្រែជាមួយដីស្រែដែលមាន ៤ទៅ៥ហិតតា ហើយត្រូវប្រើជីអស់ ៥ទៅ៦បាវក្នុងមួយឆ្នាំ ក្នុងមួយបាវជីតំលៃ ៦០០០០៛ ទៅ ៧០០០០៛។ ហើយម្យ៉ាងត្រូវចំណាយលើការបូមទឹក និងជួលគេដកស្ទូង ទិន្នផលដែលបានមកត្រឹមតែ ២០០ទៅ៣០០ថាំង ប៉ុណ្ណោះ។ ផលស្រូវដែលបានមកនោះគឺអាចហូបគ្រប់មិនខ្វះខាតទេ បានត្រឹមរួចមួយឆ្នាំ។

នៅឆ្នាំ១៩៩៦ ខ្ញុំបានមកភ្នំពេញដើម្បីការងារធ្វើតាមរយៈបងប្អូននៅក្នុងភូមិ ខ្ញុំមកធ្វើការដោយខ្លួនឯង ដោយគ្មានអ្នកណាបង្ខំនោះទេ ព្រោះខ្ញុំគិតថានៅពេលដែលខ្ញុំមកធ្វើការ ខ្ញុំអាចជួយរំលែកទុក្ខលំបាករបស់ពួកគាត់បានខ្លះ ហើយនិងអាចសន្សំលុយកាក់បានខ្លះដែរ ហេតុនេះហើយក៏សំរេចចិត្តមករកការងារធ្វើ។ ពេលដែលខ្ញុំមកដល់ដំបូងនោះគឺត្រូវរង់ចាំអស់រយៈពេលកន្លះខែ ពេលនោះខ្ញុំមានលុយ២០ម៉ឺនរៀលដែលនៅក្នុងខ្លួន ដែលលុយនោះម៉ែរបស់ខ្ញុំគាត់បានមកពីការលក់កូនជ្រូកមួយក្បាល។ ក្នុងរយៈពេលដែលរង់ចាំនោះខ្ញុំបានស្នាក់នៅជាមួយបងប្អូន ហើយពួកគាត់មិនបានអោយខ្ញុំចេញលុយថ្លៃផ្ទះនោះទេ តែថ្លៃហូបចុកគឺខ្ញុំត្រូវចំណាយខ្លួនឯង។

កន្លះខែក្រោយមកខ្ញុំក៏បានចូលធ្វើការនៅក្នុងរោងចក្រ **សាំហាន់** ខ្ញុំចូលធ្វើការដំបូងឆ្នាំ១៩៩៦ ហើយពេលនោះក្នុងមួយខែខ្ញុំទទួលបានប្រាក់ឈ្នួល ១៥ដុល្លាប៉ុណ្ណោះ ប៉ុន្តែក្រោយមកក៏បានឡើងថែមទៀត។ ពេលចូលដំបូងគឺពិបាកណាស់ត្រូវឈររហូត ព្រោះខ្ញុំចូលធ្វើការផ្នែកតម្បាញ ហើយក្នុងមួយថ្ងៃខ្ញុំត្រូវត្បាញបានអាវពី៤ទៅ៥ នេះសំរាប់អាវស្រួលត្បាញ ប៉ុន្តែសំរាប់អាវពិបាកត្បាញវិញនោះក្នុងមួយថ្ងៃត្បាញបានតែ២ទៅ៣អាវតែប៉ុណ្ណោះ។ នៅកន្លែងធ្វើការឧស្សាហ៏ត្រូវប្រធានស្តីបន្ទោសអោយណាស់នៅពេលគេពិនិត្យឃើញអាវយើងធ្វើខុស។ ពេលមកធ្វើការដំបូងខ្ញុំមានអារម្មណ៍នឹកផ្ទះខ្លាំងណាស់ ពិសេសនៅពេលគេស្តីអោយ ខ្ញុំគិតថាបើនៅផ្ទះគ្មាននរណាមកស្តីបង្ខំឱ្យធ្វើការនោះទេ ហើយបើខ្ញុំនៅផ្ទះចង់ធ្វើក៏បានមិនធ្វើក៏បាន ព្រោះនេះវាជាសិទ្ធរបស់ខ្ញុំ។ ប៉ុន្តែនៅក្នុងរោងចក្រមិនអាចធ្វើតាមអំពើចិត្តបានទេ ហ៊ានតែធ្វើប្រាកដជាអត់ការងារធ្វើមិនខាន។ កម្មករភាគច្រើនត្រូវបានធ្វើការ ១០ម៉ោងក្នុងមួយថ្ងៃ ហើយរោងចក្រនេះដំនើរការ ២វេន គឺវេនថ្ងៃ និងវេនយប់។ ចំនែកអ្នកធ្វើការយប់គេមិនគុណលុយឱ្យទេ គឺវេនថ្ងៃ និងយប់ខាងរោងចក្រគេគិតឱ្យដូច

គ្នាទាំងអស់គឺគិតតំលៃអាវដែលត្បាញបាន។ ហើយតំលៃអាវថោកបំផុតគឺមួយបានត្រឹម ១២០០៛ បើអាវម៉ូតលំបាកមែនទែននោះគឺបានថ្លៃរហូតដល់៣៨០០៛ ក្នុងមួយអាវ។ ឥឡូវនេះចំពោះអាវពិបាកត្បាញក្នុងមួយថ្ងៃត្បាញបានតែ ៦ទៅ៧អាវ ហើយម៉ូតស្រួលត្បាញវិញអាចត្បាញបានពី ១០ទៅ១២អាវគិតទាំងការថែមម៉ោង។ ចំពោះប្រាក់ខែគោលបាន៤៥ដុល្លាក្នុងមួយខែ ហើយប្រាក់ខែរបស់ខ្ញុំជាមធ្យមបាន ៧០ទៅ៨០ ដុល្លាក្នុងមួយខែ។ ក្នុងមួយខែខ្ញុំផ្ញើរទៅផ្ទះបាន៣០ទៅ៤០ដុល្លា ហើយលុយដែលខ្ញុំផ្ញើទៅនោះម៉ែគាត់យកទៅទិញជី និងជួលគេដកស្ទូង និងចងដៃការ វីបុណ្យ ហើយត្រូវចំណាយ ទៅលើការរៀនសូត្ររបស់ប្អូនៗទៀត។

បន្ទប់ជួលខ្ញុំមានគ្នានៅ៣នាក់ មានតំលៃ១៥ដុល្លាក្នុងមួយខែ ត្រូវបង់ម្នាក់៥ដុល្លា ថ្លៃទឹកនិងភ្លើងម្នាក់ ចំណាយអស់៤០០០៛ទៅ៥០០០៛។ ក្នុងឆ្នាំ២០០៤ រហូតដល់ដើមឆ្នាំ២០០៥ ពួកខ្ញុំមិនសូវមានការងារធ្វើ ហើយមានការកែប្រែលក្ខខ័ណ្ឌការងារយ៉ាងច្រើនមានការកាត់បន្ថយចំនួនកម្មករ និងកាត់បន្ថយម៉ោងធ្វើការ តំលៃអាវធ្លាក់ចុះ និងពិបាកក្នុងការសុំច្បាប់ ថែមទាំងមានកម្មករឧស្សាហ៍សន្លប់ទៀតផង។ កម្មករធ្វើការពេញ ២ខែរហូតដល់ជិតថ្ងៃភ្ជុំបិណ្ឌត្រូវខាងថៅកែមិនបើកលុយឱ្យហើយកុហកតែរហូត អស់ពីថ្ងៃនេះ ថាថ្ងៃនោះ។ ក្រោយមកកម្មករនៅក្នុងរោងចក្រទាំងអស់បានធ្វើកូដកម្មទើបគេបើកប្រាក់ខែអោយ នៅពេលដែលបើកប្រាក់ ខែរួចខាងថៅកែរោងចក្រប្រាប់ថារោងចក្រត្រូវព្យួរ២ខែ ពេលនោះជួលពេលដែលកម្មករបើកលុយហើយនៅពេលល្ងាច ហើយលុះព្រឹកឡើងក៏ដល់ថ្ងៃភ្ជុំបិណ្ឌល្មមកម្មករក៏ត្រឡប់ទៅផ្ទះរៀងៗខ្លួនដោយមិនបានតវ៉ាអីដែរ ព្រោះអីម្នាក់ៗត្រូវការទៅផ្ទះចូលរួម ពិធីបុណ្យជាតិ។

ពីរខែក្រោយមកខ្ញុំនិងកម្មករផ្សេងៗទៀតបានចូលមកធ្វើការវិញ ប៉ុន្តែចូលថ្ងៃផ្សេងគ្នា អ្នកខ្លះមានការងារធ្វើ ខ្លះចូលចុះវត្តមានមួយអាទិត្យម្តង រហូតដល់ថ្ងៃទី ១០ ខែធ្នូ ត្រូវបើកលុយតែខាងរោងចក្រនិយាយថា ថ្ងៃទី១៥ទើបបើកលុយឱ្យ។ អ្នកដែលមានការងារធ្វើមិនហ៊ានតវ៉ាអីដែរ ព្រោះគេគិតឃើញថារោងចក្រទើប តែដំនើរការម្តងទៀតថ្មីៗ ហើយម្យ៉ាងការបង្វិលលុយក៏មិនទាន់ ហើយម្យ៉ាងទៀតនោះមិនសូវមានអ្នកកម្ម៉ង់ទិញ ដូចនេះកម្មករក៏ជាច្រើននាក់ក៏មិនបានថាអីដែររហូតដល់ខែកុម្ភៈថ្ងៃទី៥ ជាថ្ងៃត្រូវបើកលុយនោះ ខាងរោងចក្រមិនបានបើកលុយអោយទេ គេនិយាយថានិងបើកអោយនៅថ្ងៃទី ១០ ហើយដល់ថ្ងៃទី ១០ ក៏មិនឃើញបើកឱ្យគេ ថាចាំថ្ងៃទី ២០។ ពួកខ្ញុំចាំរហូតហើយកម្មករម្នាក់ៗអត់មានលុយញុំាបាយ អ្នកខ្លះអត់លុយឱ្យថ្លៃផ្ទះ ម្ចាស់ផ្ទះគេ មកទារលុយ ហើយចំពោះខ្ញុំវិញត្រូវកុហកគេបន្តរហូតព្រោះអីថៅកែរោងចក្រកុហកពួកខ្ញុំដែរ។ ក្រោយមកពួកយើងជាកម្មករបានធ្វើកូដកម្មនៅមុខរោងចក្រជារៀងរាល់ថ្ងៃដើម្បីទាមទារអោយបើកប្រាក់ខែអោយ ក្រៅពីការមិនបើកប្រាក់ខែអោយហើយនោះ ខាងរដ្ឋាភិបាលក៏មកគំរាមកំហែង ហើយហាមកម្មករមិនអោយឈរនៅមុខរោងចក្រទេ ប៉ុន្តែពួកយើងនៅតែទៅធ្វើ។ នៅថ្ងៃមួយនោះនៅពេលរសៀលប្រហែលម៉ោង២កម្មករដែលធ្វើ បាតុកម្មទាំងអស់បាននាំគ្នាធ្វើក្បួនដង្ហែទៅកាន់មុខរដ្ឋសភា ប៉ុន្តែពួកយើងត្រូវគេហាមឃាត់ត្រឹមរង្វង់មូលគល់ ស្ពានជ្រោយចង្វារ ដោយកំលាំងប៉ូលីស ប៉ូលីសទាំងនោះ បានស្ទាក់វ៉ៃ ពួកយើងនឹងដំបងឆក់ និងកាំភ្លើង ពួកគេបានបើកសោរកាំភ្លើង គំរាមកំហែង ហើយវ៉ៃ និងចាប់កម្មករខ្លះ យកទៅឃុំទាល់តែល្ងាចទើបលែងមកវិញ ប៉ុន្តែបានខាងអង្គការពលកម្មអន្តរជាតិបានមកជួយទើបគេដោះលែងមកវិញ ដល់ស្អែកឡើងពេលល្ងាច

គេបើកលុយឱ្យពីរខែ ចុងក្រោយហើយគេប្រាប់ថារោងចក្រព្យួរ២ឆ្នាំ។ នៅពេលបើកលុយហើយ ពួកខ្ញុំមិនយល់ព្រមនិងការព្យួរ រយៈពេល២ឆ្នាំដែលខាងរោងចក្រលើកឡើងនោះទេ ពួកខ្ញុំសុខចិត្តឈប់តែម្តងពីរោងចក្រ ហើយសុំអោយឱ្យថៅកែរោងចក្របង់លុយជំងឺចិត្តអោយ និងផលប្រយោជន៍ផ្សេងៗទៀតដែលត្រូវបានទទួលពេលបញ្ចប់កិច្ចសន្យា និងនៅពេលរោងចក្របិទ។ ពួកខ្ញុំបានធ្វើកូដកម្មបន្តទៀតតែគ្មានដំណោះស្រាយសោះអ្វីនោះទេ ទោះជាពួកខ្ញុំបានធ្វើជាពាក្យបណ្តឹងដាក់ទៅតុលាការ និងកន្លែងផ្សេងៗទៀតយ៉ាងណាក៏ដោយ ក៏ដូចជាមិនដំណោះស្រាយឡើយ ហើយក្នុងរយៈដែលពួកខ្ញុំធ្វើកូដកម្ម គឺរយៈពេលមួយដែលពិបាកខ្លាំងណាស់ ណាមួយត្រូវប៉ូលីសខាងរដ្ឋាភិបាល វ៉ៃនឹងដំបងឆក់ បាញ់ផ្សែងចេញទឹកភ្នែក ពួកគេបាញ់គំរាមពួកយើងឱ្យពួកយើងក៏បំបែកគ្នា ហើយគេឱ្យពួកខ្ញុំឈប់ធ្វើកូដកម្មទៅ ពួកគេមិនឱ្យយើងឈរនៅមុខរោងចក្រទេ បើកសិនជាយើងទៅឈរធ្វើកូដកម្មនៅមុខរោងចក្រ ទៀតនិងត្រូវប៉ូលីសវាយបែកមុខបែកមាត់មិនខានឡើយ ហើយសូម្បីតែមនុស្សស្រីក៏ពួកបូលីសទាំងនោះវាយដែរ គឺមានបងស្រីម្នាក់ត្រូវប៉ូលីសវាយចំកំភួនជើង។ ពួកខ្ញុំធ្វើកូដកម្មអស់រយៈពេលបីខែក្រោយមកក៏បានបែកគ្នាអស់ទៅព្រោះតែពួកខ្ញុំគ្មានលុយ ពួកខ្ញុំត្រូវរកការងារថ្មីធ្វើ និងអ្នកខ្លះត្រូវទៅផ្ទះ ហើយខ្ញុំក៏បានទៅផ្ទះដែរ ប៉ុន្តែរឿងក្តីខាងសហជីពគេបាននិយាយថាគេនៅតែដំនើរការដើម្បីជួយកម្មករតទៅទៀត។

ខ្ញុំទៅផ្ទះមួយរយៈដែរ ប៉ុន្តែដោយសារនៅផ្ទះខែហ្នឹងគ្មានអ្វីធ្វើ ខ្ញុំក៏បានមករកការងារធ្វើជាថ្មី។ រាល់ថ្ងៃខ្ញុំធ្វើការនៅរោងចក្រ **ឃីងហ្វីស** ខ្ញុំជាកម្មករដែលត្រូវរោងចក្រជួលម្តងម្កាល ដូចនេះខាងរោងចក្រអាចដកថ្ងៃណាក៏បានដែរ។ នៅក្នុងរោងចក្រថ្មីនេះច្បាប់ការងារពិបាកខ្លាំងណាស់ សុំច្បាប់មិនបានទេ ថ្ងៃបុណ្យ និងថ្ងៃអាទិត្យ ធ្វើការគេមិនគុណលុយឱ្យទេ ហើយធ្វើការមួយថ្ងៃត្រូវថែមដល់ម៉ោង ៦:០០ល្ងាច ហើយខ្ញុំបានលុយតែ ៦៥០០ ទៅ ៧០០០រៀល ក្នុងមួយថ្ងៃប៉ុណ្ណោះ។ ហើយប្រសិនបើរោងចក្រទាំងអស់បិទ ខ្ញុំនិងមិនទៅធ្វើការនៅជាយដែន រឺទៅក្រៅប្រទេសរកការងារថ្មីនោះទេ ខ្ញុំនឹងត្រឡប់ទៅស្រុកវិញដើម្បីរកស៊ី និងធ្វើអ្វីផ្សេង ដូចជា ត្បាញកន្ទេល ហូលផាមួង។

## ករណីសិក្សាទី១១

នាងខ្ញុំឈ្មោះ ឆង ស្រស មានអាយុ ២០ឆ្នាំ ។ គ្រួសារខ្ញុំរស់នៅភូមិវេះពោះ ឃុំខ្វាយ ស្រុកសំរោង ខេត្តតាកែវ។ ខ្ញុំមានបងប្អូន៥នាក់ (ប្រុស ៣ និងស្រី ២នាក់) ខ្ញុំរៀនត្រឹមថ្នាក់ទី ៦ ពុកម៉ែខ្ញុំជាអ្នកធ្វើស្រែ ហើយពេលទំនេរពីធ្វើស្រែពុកគាត់រត់ម៉ូតូឌុបបានលុយកាក់បានខ្លះដែរ។ គ្រួសារខ្ញុំមានដីស្រែមួយហិចតា តែធ្វើមួយឆ្នាំៗហូបមិនគ្រាន់ ទេ ហើយឆ្នាំមុនរាំងស្ងួតធ្វើស្រែមិនបានផលនោះទេ។

ខ្ញុំមកភ្នំពេញតាមរយៈបងថ្លៃ មូលហេតុដែលខ្ញុំមករកការងារនៅភ្នំពេញ គឺត្រូវការលុយដើម្បីជួយបងប្រុសឱ្យបានរៀននៅមហាវិទ្យាល័យ និងជួយដល់ក្រុមគ្រួសារព្រោះពុករត់ម៉ូតូឌុបតែម្នាក់ឯងរកមិនសូវបានទេ ដូចនេះដោយឃើញគ្រួសារមានការខ្វះខាតទើប សំរេចចិត្តមករកការងារធ្វើដោយខ្លួនឯង គ្មានអ្នកណាបង្ខំទេ។ មកភ្នំពេញដំបូងខ្ញុំមានការភ័យខ្លះដែរព្រោះមិនដែលមកសោះ។ មកបានមួយថ្ងៃរៀនដេរអស់៥ដុល្លា បន្ទាប់មកក៏ខ្ញុំដើរធ្វើតេស្តតាមរោងចក្រហើយក៏បានជាប់ជាកម្មករពេញសិទ្ធនៅរោងចក្រ **ខេនធើរេន** រហូតមកដល់ពេលនេះធ្វើបានមួយឆ្នាំហើយ។ រោងចក្រនេះដេរស៊ីបុងដេរមានការបង្ខំ បើមិនគ្រប់ចំនួនត្រូវប្រធានចិនស្តីឱ្យ ហើយបើចូលធ្វើការលើស១៥នាទីនោះ និងត្រូវខាងរោងចក្រកាត់លុយព្រីម៥ដុល្លាចេញពីប្រាក់ខែ។ ក្នុងមួយថ្ងៃខ្ញុំត្រូវធ្វើការថែមម៉ោង២ម៉ោង លើកលែងតែថ្ងៃអាទិត្យដែលបានសំរាក ហើយពេលបើកប្រាក់ខែក៏បានតិច ដេរមុនដំបូងបានថ្លៃដែរតែដល់ពេលយូរៗទៅ តំលៃបុងមានការធ្លាក់ចុះខាងរោងចក្រគេនិយាយថាយើងស្ទាត់ដៃហើយតំលៃបុងថោកក៏ ដេរបានច្រើនដែរ។

នៅក្នុងរោងចក្រមានសហជីពមួយ តែខ្ញុំមិនស្គាល់ឈ្មោះទេទើបតែបង្កើត ហើយនៅក្នុងរោងចក្រនេះមានកម្មករប្រហែលជា៤០០នាក់ ហើយពេលយើងទៅបន្ទប់ទឹកយូរមិនស្តីឱ្យទេ ។ នៅក្នុងរោងចក្រនេះមានបន្ទប់ទឹក ១៦ សំរាប់ស្រី ១០ សំរាប់ប្រុស២ សំរាប់អ្នកមានផ្ទៃពោះ និងសំរាប់ចិន ២។ នៅក្នុងរោងចក្រនេះមានការិយាល័យពេទ្យតូចមួយពេលឈឺខ្ញុំចូលចិត្តទៅសុំថ្នាំព្រោះលេបមានប្រសិទ្ធិភាពខ្លះដែរ។ ខ្ញុំធ្លាប់មានជំងឺគ្រុនពោះវៀន និងរលាកសួត ហើយទៅទេព្យខាងក្រៅ ចំណាយអស់អស់ប្រហែលជា១៥ដុល្លា ហើយទៅ៣ដងទំរាំតែជា ខ្ញុំត្រូវចាយលុយអស់ជិត៤០ដុល្លា។ ពេលឈឺខ្ញុំសុំច្បាប់មួយអាទិត្យខាងរោងចក្រគេបានកាត់លុយព្រីម និងលុយប្រចាំថ្ងៃរបស់ខ្ញុំ។ ចំពោះការសុំច្បាប់រៀបការវិញ មួយអាទិត្យគេកាត់ចេញពីបំណាច់ឆ្នាំ ហើយចំពោះច្បាប់ឈប់សំរាលកូនគេឱ្យឈប់៣ខែ ហើយគេគិតឱ្យ៥០ភាគរយ។ នៅថ្ងៃទី ៩ មិថុនា ២០០៥ ខាងរដ្ឋបាលបានប្រកាសថា នៅខែតុលាគេនឹងរំសាយកម្មករណាដែលគ្មានអត្តញ្ញាណប័ណ្ណ គឺគេរំសាយមិនបង់លុយឱ្យទេព្រោះគេថាបានជូនដំនឹងឱ្យយើងមុនហើយ។ ពេលគេរំសាយខ្ញុំពីការងារ ខ្ញុំមិនទាន់ចង់ទៅផ្ទះទេ គឺនៅដើរធ្វើតេស្តរោងចក្រផ្សេងដើម្បីរកការងារធ្វើរកលុយឱ្យបងប្រុសរៀនឱ្យបានចប់ ក្រែងមានការងារល្អធ្វើនិងគេ។ ហើយទោះជាទៅផ្ទះក៏គ្មានកំលាំងធ្វើស្រែហើយនឹងធ្វើការធ្ងន់ដូចមុនដែរ ព្រោះតាំងពីពេលចូលធ្វើការនៅរោងចក្រមកកំលាំងមានការចុះថយហើយឈឺរ៉ាំរ៉ៃរហូតមិនអាចធ្វើការធ្ងន់បានទេ។

ករណីសិក្សាទី១២

តំបន់មានជ័យ

០៩ មិថុនា ២០០៥

នាងខ្ញុំឈ្មោះ សេង ស្រីមុំ មានអាយុ ២១ឆ្នាំ គ្រួសារខ្ញុំរស់នៅភូមិតាងូវ ឃុំទឹកល្អក់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ។ ខ្ញុំមានបងប្អូន ៦នាក់ ខ្ញុំជាកូនទី៣នៅក្នុងគ្រួសារ ខ្ញុំបានរៀនត្រឹមថ្នាក់ទី៥ ពុកម៉ែខ្ញុំគាត់ជាកសិករពឹងផ្អែកទៅលើការធ្វើស្រែចំការ ហើយក្រៅពីធ្វើស្រែម្ដាយរបស់ខ្ញុំគាត់ជាអ្នកលក់បន្លែផងដែរ ។ ពុកម៉ែខ្ញុំគាត់មានដីស្រែ៣កន្លែង តែក្នុងមួយឆ្នាំធ្វើស្រែបានទិន្នផលតិចណាស់ដោយសារតែជួបប្រទះនិងគ្រោះរាំងរីងស្ងួត ដូច្នេះទិន្នផលដែលបានក្នុងមួយៗឆ្នាំ គឺមិនអាចគ្រប់គ្រាន់ក្នុងការផ្គត់ផ្គង់គ្រួសារនោះទេ។ កាលពី៥ឆ្នាំមុនមានដីស្រែច្រើនដែរ តែឪពុកខ្ញុំឈឺហើយប្រុសក៏ឈឺ ទើបម៉ែលក់ដើម្បីយកលុយមកមើលពួកគាត់។ តាំងពីបងខ្ញុំឈឺមកគ្រួសារខ្ញុំគ្មានអ្នករកចំណូលដើម្បីជួយដល់គ្រួសារនោះទេ ដោយសារឃើញគ្រួសារពិបាកពេក ទើបខ្ញុំសំរេចចិត្តឈប់រៀនតែម្ដង។

ពូជីដូនមួយម៉ែខ្ញុំបាននាំខ្ញុំចូលធ្វើការនៅរោងចក្រ ដោយសូកលុយគេអស់៥០ដុល្លា នៅរោងចក្រ MV ចាក់អង្រែក្រោម។ ពេលចូលដំបូងគេឱ្យរៀនដេរអាវសិន ហើយខ្ញុំបានប្រាក់ខែ៩ដុល្លា ជាទូទៅនៅក្នុងរោងចក្រនេះពេលកម្មករចូលដំបូងអត់ចេះដេរគេឱ្យរៀនដេររយៈពេលមួយអាទិត្យ បើនៅតែអត់ចេះដេរគេអត់យកអោយធ្វើការនោះទេ។ ខ្ញុំបានជាប់ជាកម្មករសាកល្បង(បណ្ដែត)រយៈពេល៣ខែ ក្រោយមកទើបគេឱ្យដូរកាតក្លាយជាកម្មករ ពេញសិទ្ធពេលនោះគេឱ្យប្រាក់ខែ៤០ដុល្លា។ នៅពេលមានអាវច្រើនខាងរោងចក្របង្ខំឱ្យថែមម៉ោង ហើយប្រសិនបើកម្មករហ៊ានអត់ថែមម៉ោងនោះ និងត្រូវខាងរដ្ឋបាល រឺប្រធានចិនហៅទៅស្ដីឱ្យជាមិនខាន។

នៅពេលឈឺសុំច្បាប់បានត្រឹម ២-៣ថ្ងៃប៉ុណ្ណោះ ប្រសិនបើចង់សុំមួយអាទិត្យត្រូវមានសំបុត្របញ្ជាក់ច្បាស់លាស់ពីមូលហេតុ បើមានជំងឺត្រូវយកសំបុត្រពេទ្យមកអោយខាងរោងចក្រ តែក្នុងកំឡុងឈឺនោះខាងរោងចក្រមិនបានគិតគូរប្រាក់ឈ្នួលអោយនោះទេ គេគិតប្រាក់ឈ្នួលអោយតែក្នុងករណីសំរាលកូនប៉ុណ្ណោះ ទទួលបានច្បាប់៣ខែ និងប្រាក់៧០ដុល្លា (៣ខែ) ហើយបើសិនរយៈពេល៣ខែហើយនៅតែធ្វើការមិនកើតគឺអាចបន្តឈប់រយៈពេលមួយខែទៀត តែគេអត់គិតលុយឱ្យទេ។ កាលពីមុនពេលមានអ្នកឈឺ រឺសន្លប់ ខាងរោងចក្រគេឧបត្ថម្ភឱ្យ ៥ដុល្លា តែឥលូវលែងមានការឧបត្ថម្ភទៀតហើយ ហើយពេលឈឺអ្វីក៏ដោយខាងរោងចក្រអោយថ្នាំតែដដែរៗ។ កាលពីមុនគេឱ្យកម្មករទាំងអស់ត្រូវធ្វើការឱ្យលឿន ហើយត្រូវធ្វើការថែមម៉ោង ខាងរោងចក្រគេនិងទូទាត់មើលថាតើក្នុងមួយថ្ងៃអ្នកដេរបានចំនួនកំនត់ប៉ុន្មានហើយប្រសិនបើអ្នកដេរមិនគ្រប់ចំនួនកំនត់ដែលគេដាក់អោយប្រចាំថ្ងៃនោះ អ្នកនិងត្រូវគេហៅទៅស្ដីអោយ ហើយនិងមានការគំរាមដេញចេញពីការងារទៀតផងក្នុងករណីអ្នកមិនកែប្រែ។ ហើយបើមានអ្នកតវ៉ាហ៊ានតវ៉ានោះក៏ត្រូវគេដេញចោលពីការងារដែរ។ ខាងរោងចក្រផ្ដល់ប្រាក់ឈ្នួលឱ្យ ១០ដុល្លា ក្នុងរយៈពេលមួយខែចំពោះកម្មករចូលថ្មី។

ខ្ញុំចូលជាសមាជិកសហជីព តែអត់ស្គាល់ឈ្មោះសហជីពទេគឺស្គាល់តែឈ្មោះប្រធាន គឺ ម៉ម ញឹម និងរស់ សុខ។ គេមិនដែលហៅទៅរៀនទេ។ ពេលខាងរោងចក្រដេញកម្មករចេញពីការងារនោះសហជីពមិនជួយដោះស្រាយទេ តែខាងរោងចក្របានទូទាត់ប្រាក់ឈ្នួលអោយខ្លះដែរទៅតាមឆ្នាំដែលបានធ្វើការ។ ទោះជាសហជីពមិនដោះស្រាយអោយគ្រប់រឿងក៏ដោយ តែមានតំណាងកម្មករនៅក្នុងរោងចក្រអាចជួយតថ្លៃតំលៃបុងអោយបានឡើងខ្លះដែរ តែចាប់ពីចូលឆ្នាំ ២០០៥នេះមក គ្រប់ការតវ៉ាគឺមិនបានផលសំរេចនោះទេ ហើយតំលៃបុងវិញក៏ចុះថោកជាងមុនទៅទៀត តែចំពោះការសុំច្បាប់វិញមានការងារស្រួលជាងមុន ព្រោះដោយសារតែខាងរោងចក្រមិនសូវមាន ខោអាវអោយកម្មករធ្វើនោះទេ ហើយការដេរក៏មិនសូវបង្ខំដូចមុនដែរ។ ខ្ញុំជាមនុស្សខ្មាស់អៀនច្រើនសូម្បីតែនិយាយរកគេមុនក៏មិនហ៊ានដែរ ហើយទោះបីគេមិត្តភក្តិបបួលទៅណាក៏អត់ហ៊ានទៅដែរ។

កាលពីចូលធ្វើការដំបូងខ្ញុំមិនបានលុយផ្ញើរទៅផ្ទះនោះទេ មានតែយកលុយពីផ្ទះមកវិញ ព្រោះបើកបានតែ៩ដុល្លា ហើយត្រូវបង់ថ្លៃផ្ទះ ដូចនេះចាយអត់គ្រាន់ទេ តែ១ខែ២ខែក្រោយមកខ្ញុំអាចផ្ញើរទៅផ្ទះបាន ៤០-៥០ដុល្លាដែរ។ លុយដែលផ្ញើរទៅឱ្យម៉ែនោះគឺគាត់យកទៅសងគេនៅសល់ខ្លះទុកទិញអង្ករសំរាប់ហូប។ រហូតមកដល់ពេលនេះខ្ញុំធ្វើការនៅទីនោះបាន៤ឆ្នាំហើយ តែសងគេមិនទាន់រួចទេទាំងការប្រាក់អ្នកនៅក្នុងភូមិ និងការធនាគារអេស៊ីលីដា។ ជារៀងរាល់ខែខ្ញុំទុកតែ ១៥-២០ដុល្លាប៉ុណ្ណោះសំរាប់ទុកចាយ សំរាប់បង់ថ្លៃផ្ទះ៥ដុល្លា និងថ្លៃព្យាបាលជំងឺមួយខែ។ នៅក្នុងបន្ទប់នៅគ្នា៤នាក់ខ្ញុំត្រូវចែកគ្នាចេញ ហើយម្យ៉ាងម្ចាស់ផ្ទះជាអ្នកស្រុកនៅភូមិជាមួយគ្នា ដូចនេះគាត់ហាក់ដូចជាស្និតស្នាលជាមួយពួកខ្ញុំបានច្រើន។

ខ្ញុំបានគិតហើយថាទោះរោងចក្រមានលក្ខខណ្ឌការងារលំបាកយ៉ាងណាក៏ដោយក៏ខ្ញុំនៅតែធ្វើវាដែរ ហើយទោះជាបានប្រាក់ខែប៉ុន្មានក៏ដោយ ឱ្យតែបានជួយដល់គ្រួសារគឺវាល្អណាស់ទៅហើយ ហើយខ្ញុំមិនគិតថាការងារនោះអាចរកបាននៅក្នុងប្រទេសតាមព្រំដែន រឺក៏ក្រៅប្រទេសនោះទេ ហើយទោះជារោងចក្រទាំងនោះមិនបានគោរពច្បាប់ការងាររឺរំលោភលើច្បាប់ក៏ខ្ញុំត្រូវតែធ្វើវា ព្រោះខ្ញុំចង់ជួយដល់ក្រុមគ្រួសារជាចាំបាច់។ ខ្ញុំគិតថាពេលមានការងារធ្វើយ៉ាងហោចណាស់ក៏សល់លុយខ្លះសំរាប់ជួយគ្រួសារដែរ ព្រោះខ្ញុំគ្មានជំរើសនោះទេ ទោះដឹងថាគ្រោះថ្នាក់ក៏ទៅដែរ។ ថ្ងៃក្រោយទៅបើខ្ញុំមានលុយច្រើន ខ្ញុំចង់បើកកន្លែងកាត់ដេរ ហើយនិងលក់អីវ៉ាន់ខ្លះនៅផ្ទះ។

ករណីសិក្សាទី១៤

ថ្ងៃទី ១៩ មិថុនា ២០០៥

នាងខ្ញុំឈ្មោះ សុខ រស់ មានអាយុ ២៤ឆ្នាំ រស់នៅ ភូមិព្រៃម៉ិច ឃុំព្រៃម៉ិច ស្រុកស្ទួង ខេត្តកំពង់ស្ពឺ។ ខ្ញុំមានបងប្អូន ៧នាក់ (ប្រុស ៤ និងស្រី ៣) ខ្ញុំជាកូនច្បង។ ពុកម៉ែខ្ញុំជាអ្នកធ្វើស្រែចំការ តែពុករបស់ខ្ញុំបានទៅ ចោលម៉ែតាំងពីចុងឆ្នាំ ១៩៨៩ ដោយសារទេគាត់មានប្រពន្ធចុង។

ក្នុងឆ្នាំ ២០០៤ ខ្ញុំបានមករកការងារធ្វើជាកម្មកររោងចក្រកាត់ដេរជាមួយបងប្អូននៅក្នុងភូមិ កាលនោះគាត់បានប្រាប់ថា មានគេជ្រើសរើសកម្មករជាច្រើននាក់អោយបំរើជាកម្មករកាត់ដេរ។ ពេលមកដល់ភ្នំពេញដំបូងទំរាំតែបានការងារធ្វើខ្ញុំ ត្រូវរង់ចាំអស់រយៈពេល ៣ខែ ទើបអាចធ្វើតេស្តជាប់នៅរោងចក្រមួយជិតផ្សារដីហ៊ុយក្នុង សង្កាត់ភ្នំពេញថ្មី។ កាលនោះខ្ញុំ បានធ្វើតេស្តជាប់ដោយខ្លួនឯងដោយគ្មានអស់លុយកាក់សំរាប់សូកគេនោះទេ ខ្ញុំចាំថាពេលធ្វើការដំបូងខ្ញុំមានការលំបាក ខ្លាំងណាស់ ហើយប្រាក់ខែដំបូងដែលខ្ញុំទទួលបានគឺ ៤០ដុល្លា តែខ្ញុំត្រូវចំណាយទៅលើការស្នាក់នៅអស់៤ដុល្លា ហើយត្រូវ ផ្ញើរទៅផ្ទះឱ្យប្អូនៗខ្លះសំរាប់ការសិក្សារបស់ពួកវា ដូចនេះលុយខ្លះដែលនៅសល់ខ្ញុំត្រូវចេះចាយត្បិតត្បៀត។ បន្ទាប់ពីធ្វើ ការបាន៣ខែ ខ្ញុំក៏ត្រលប់ទៅផ្ទះវិញព្រោះខាង រោងចក្រគេរំសាយកម្មករចេញ ដោយសារតែអត់មានខោអាវដេរ។ ក្រោយពីខ្ញុំទៅផ្ទះបានមួយខែមក ខ្ញុំត្រូវមកភ្នំពេញវិញម្តងទៀតហើយក៏ចូលធ្វើតេស្តជាប់នៅរោងចក្រឡាក់គីហ្សួន ខ្ញុំទទួលបានប្រាប់ឈ្នួល៤០ដុល្លាដដែល ហើយបន្ទប់ដែលខ្ញុំស្នាក់នៅតំលៃ២០ដុល្លាក្នុងមួយខែ មានគ្នានៅ៤នាក់ ដូចនេះ ម្នាក់ត្រូវចេញ៥ដុល្លា។

ខ្ញុំជាកម្មករដេរស៊ីបុង ហើយខ្ញុំធ្វើការក្នុងផ្នែកដេរម្ជុល១ នៅពេលដែលរោងចក្រនេះរៀបនឹងបិទទ្វារ ថៅកែបាន ប្រាប់ដល់កម្មករថារោងចក្រនៅតែដំណើរការជាធម្មតា តែដោយសារមានការផ្លាស់ជាខ្លាំងនៅក្នុងរោងចក្រ ដូចជាមិនសូវ មានការងារធ្វើ ហើយការបើកប្រាក់ដូចជាមិនស្រួវស្រួលនោះ កម្មករទាំងអស់ក៏បាននាំគ្នាធ្វើការតវ៉ាទាមទារប្រាក់ខែ និងអត្ថប្រយោជន៏ផ្សេងៗដែលត្រូវទទួលបានក្នុងកំឡុងពេលធ្វើការនៅក្នុងរោងចក្រនោះ ថៅកែមិនបានចេញមុខដោះ ស្រាយនោះទេ ដូច្នេះដំណោះស្រាយដែលអាចធ្វើទៅបាន គឺមានតែនាំគ្នាដេកយាមនៅមុខរោងចក្រ កុំឱ្យគេដឹកម៉ាស៊ីន ចេញទៅដោយស្ងាត់ៗ បន្ទាប់ពីមានសំពាធយ៉ាងខ្លាំងពីកម្មករ ថៅកែយល់ព្រមចេញមុខដោះស្រាយ។ នៅថ្ងៃទី ១៥ មករា ២០០៦ ដំណោះស្រាយនោះគឺកម្មករដែលធ្វើការបាន ១ឆ្នាំគេគិតឱ្យ៤៥ដុល្លា ហើយខ្ញុំធ្វើការបាន៤ឆ្នាំ គឺទទួលបាន ១៨០ដុល្លា។ នៅរោងចក្រនេះមានសហជីព២ គឺសហជីពសេរីកម្មករ និងសហព័ន្ធសហជីពយុវជនខ្មែរ។

ក្រោយរោងចក្រនេះបានបិទរួចមក ខ្ញុំប្រឈមមុខនិងការអត់ការងារធ្វើ ហើយខ្ញុំមានការព្រួយបារម្ភណាស់ ព្រោះត្រូវ ចំណាយជារៀងរាល់ថ្ងៃ ខ្ញុំខំស្វែងរកការងាររោងចក្រផ្សេងទៀតធ្វើ រយៈពេលមួយខែក្រោយមកទើប ខ្ញុំធ្វើតេស្តជាប់ ហើយបានចូលធ្វើការនៅរោងចក្រ LA II នៅខែកុម្ភះ ឆ្នាំ ២០០៥។

ចូលធ្វើការដំបូងខ្ញុំទទួលបានប្រាក់ឈ្នួល៤០ដុល្លាជាកម្មករបណ្តែត និងប្រាក់លើកទឹកចិត្ត៥ដុល្លាទៀត តែប្រាក់លើកទឹកចិត្តនិងត្រូវកាត់ផ្តាច់ប្រសិនជាខ្ញុំទៅធ្វើការអោយគេយឺត៥នាទី ហើយកិច្ចសន្យានិងផ្លាស់ប្តូរយៈពេល៦ខែម្តង។ នៅក្នុងរោងចក្រនេះខ្ញុំធ្វើនៅផ្នែកផុងម្ជុល១ ហើយជារៀងរាល់ថ្ងៃខ្ញុំត្រូវធ្វើការថែមម៉ោង២ម៉ោង ក្នុង២ម៉ោងខ្ញុំទទួលបានប្រាក់៣៥០០រៀល ប្រសិនបើតវ៉ាន់ប្រញាប់នាំចេញនោះ រោងចក្រនិងបង្ខំអោយធ្វើការអាចរហូតដល់ទល់ភ្លឺ។ លើកនេះបន្ទប់ដែលខ្ញុំជួលនោះនៅតែគ្នា២នាក់ប៉ុណ្ណោះ ហើយតំលៃវិញគឺ២៥ដុល្លា វាថ្លៃជាងមុនទៅទៀតតែដោយ គ្មានអ្នកនៅជាមួយច្រើននាក់ដូចលើកមុនក៏ចេះតែទាំនៅសិនទៅ។ ប្រាក់ឈ្នួលដែលខ្ញុំទទួលបានឥឡូវនេះគឺចាយមិនគ្រាន់ទេ ព្រោះការចំនាយមានការកើនឡើងជាងមុន ហើយតវ៉ាន់គ្រប់បែបយ៉ាងឡើងថ្លៃទាំងអស់ ណាមួយត្រូវផ្ញើរលុយទៅផ្ទះទៀត។ បើសិនជារោងចក្រនេះមិនមានការងាធ្វើទេនៅថ្ងៃមុន ខ្ញុំនិងដើររកការងារនៅរោងចក្រផ្សេងទៀតធ្វើបន្ត រឺអាចនិងត្រឡប់ទៅស្រុកវិញទៅជួយធ្វើស្រែពុកមែ ព្រោះគ្រួសារខ្ញុំជាកសិករក្រីក្រ។

**ករណីសិក្សាទី១៥**

**តំបន់នៅទឹកថ្លា**

**ថ្ងៃទី ២២ មិថុនា ២០០៥**

នាងខ្ញុំឈ្មោះ ស សយង មានអាយុ ២៤ឆ្នាំ ខ្ញុំធ្វើការនៅរោងចក្រ **មិថុនា** នៅផ្នែកបង្ហើយការ។ គ្រួសារខ្ញុំរស់នៅភូមិទួលព្រិច ឃុំមៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម នាងខ្ញុំមានបងប្អូន ៩នាក់ (ស្រី៧នាក់ និងប្រុស២នាក់) ខ្ញុំរៀនបានត្រឹមថ្នាក់ទី៤។ ពុកម៉ែរបស់ខ្ញុំជាកសិករធ្វើស្រែពឹងផ្អែកលើទឹកភ្លៀង ដោយសារតែគ្មានអ្នកណាជួយពួកគាត់ក្នុងការធ្វើស្រែ ហើយម្យ៉ាងខ្ញុំជាកូនច្បងក្នុងគ្រួសារទៀតនោះ ខ្ញុំក៏សំរេចចិត្តឈប់រៀន ដើម្បីជួយពួកគាត់។ គ្រួសារខ្ញុំមានដីស្រែតិចតួចណាស់ ផលស្រូវដែលទទួលបានក្នុងមួយឆ្នាំហូបមិនដែលគ្រប់ទេ ហើយក្នុងរដូវធ្វើស្រែម្តងៗគ្រួសារខ្ញុំបានខ្ចីលុយពីអ្នកចងការប្រាក់នៅក្នុងយកទៅទិញជីដាក់ស្រែ ហើយបំណុលនោះនៅមិនទានសង់គេរួចនោះទេ ពីមួយឆ្នាំទៅមួយឆ្នាំ ហេតុនេះហើយខ្ញុំក៏សំរេចចិត្តមករកការងារធ្វើជាកម្មកររោងចក្រកាត់ដេរនៅក្រុងភ្នំពេញ និងដោយសារតែបងជីដូនមួយប្រាប់ថានៅភ្នំពេញមានគេរើសកម្មករជាច្រើនអោយបំរើការ ដូច្នេះខ្ញុំក៏មកធ្វើជាមួយគាត់។ សព្វថ្ងៃនេះខ្ញុំរៀបការរួចហើយ។

ម៉ែរបស់ខ្ញុំបានទៅចងការលុយគេដើម្បីអោយខ្ញុំមកការងារធ្វើ ខ្ញុំមកដល់ត្រូវរង់ចាំអស់រយៈពេលមួយអាទិត្យទើបបានការងារធ្វើ ហើយត្រូវចំណាយលុយអស់ ១៥០ដុល្លា ហើយខ្ញុំត្រូវធ្វើការមួយឆ្នាំទើបសងលុយគេរួច ដោយសងរំលោះ។ រយៈពេល៣ខែដំបូងខ្ញុំនៅជាកម្មករបណ្តែតនៅឡើយទេ ខ្ញុំទទួលបានប្រាក់ឈ្នួល៣៥ដុល្លា និងបូកទាំងលុយព្រីម៥ដុល្លាទៀតគឺបាន៤០ដុល្លា បន្ទាប់ពី៣ខែមកខ្ញុំក៏ក្លាយជាកម្មករពេញសិទ្ធិ ហើយរហូតមកដល់ពេលនេះខ្ញុំធ្វើការបាន៦ឆ្នាំហើយ ប៉ុន្តែខ្ញុំដូចជាមិនបានមានសល់អ្វីសំរាប់ខ្លួនខ្ញុំនោះទេ។ ខ្ញុំធ្វើការនៅតុបត់ដោយគិតតាមតំលៃបុងទៅតាមម៉ូតអាវ បើម៉ូតពិបាកគេឱ្យតំលៃថ្លៃបន្តិច តែបើអាវស្រួលគឺឈ្នួលក៏បានថោកដែរ។ រោងចក្រនេះគេមិនដែលបង្ខំកម្មករឱ្យធ្វើការទេ ខ្ញុំធ្វើការរហូតទាល់តែដល់ម៉ោងចេញទើបបានឈប់ នៅផ្នែកតុបត់គេតំរូវអោយកម្មករទាំងអស់ត្រូវឈប់រហូត លើកលែងតែចំពោះអ្នកដែលផ្ទៃពោះទេដែលគេអនុញ្ញាតអោយអង្គុយ។

នៅរោងចក្រមិថុនានេះមានកម្មករធ្វើការ២វេនគឺវេនទី១ ចាប់ផ្តើមពីម៉ោង ៦:១៥នាទី ដល់ម៉ោង ២:១៥នាទី ហើយវេនទី២ ចាប់ពីម៉ោង២:១៥នាទី ដល់ម៉ោង១០:១៥នាទីយប់ ចំពោះវេនទាំង ២នេះ ខាងរោងចក្រតំរូវអោយឈប់សំរាកហូបបាយបានតែកន្លះម៉ោងទេ។ ចំពោះលុយព្រីម៥ដុល្លានោះ និងត្រូវកាត់ដាច់ចំពោះកម្មករណាដែលឈប់លើសពី៣ថ្ងៃ។ ការសុំច្បាប់មានភាពងាយស្រួលអាចសុំបានគេមិនស្តីឱ្យទេ តែចង់សុំច្បាប់ឈឺទាល់តែមានសំបុត្រមកពីមន្ទីរពេទ្យទើបគេអោយ។ រាល់ថ្ងៃខ្ញុំគិតតែធ្វើការមិនបានខ្វល់អ្នកផ្សេងប៉ុន្មាននោះទេ ធ្វើនៅរោងចក្រនេះ៦ឆ្នាំ ក៏មិនដឹងថារោងចក្រនេះមានកម្មករប៉ុន្មាននាក់ទេ ហើយផលិតម៉ាក់អ្វីក៏មិនដឹងដែរ តែខ្ញុំគ្រាន់តែដឹងថាមានថៅកែជាជនជាតិចិន។

នៅផ្នែកតុបត់នីមួយៗមានកម្មករ២៦នាក់ ហើយនៅផ្នែកផ្សេងៗទៀតក៏ប្រហាក់ប្រហែលគ្នាដែរ ដូចជាផ្នែកអ៊ុត ជាដើម។ នៅតុបត់នេះពួកយើងមិនហ៊ានអង្គុយនោះទេ ខ្លាចប្រធានក្រុមចិនដើរមកស្តីអោយ បើចង់អង្គុយទាល់តែអស់អាវទើបអង្គុយសំរាកបាន។ ជាធម្មតាតំលៃឡូសំរាប់ការបត់ គឺខាងរោងចក្របានប្រាប់ឱ្យកម្មករដឹងមុនដោយបិតប្រកាសដាក់លើក្តារខៀន។ នៅពេលចូលទៅធ្វើការនៅក្នុងរោងចក្រកម្មករមិនអនុញ្ញាតអោយយកនំ ចូលទៅញុំានោះទេ តែនៅតែមានអ្នកយកទៅ ហើយត្រូវលួចលាក់ហូបដោយមិនអោយគេឃើញ។ នៅក្នុងរោងចក្រនេះមានសហជីព៣២ ខ្ញុំចូលជាសមាជិកសហជីពបាន៦ឆ្នាំហើយ តែខ្ញុំដែលបានមិនស្គាល់សហជីពនោះទេ។ មួយខែខ្ញុំបង់លុយចំនួន១០០០រៀលជាសមាជិកភាពរបស់សហជីព ហើយលុយនោះគឺគេកាត់ក្នុងប្រាក់ខែរួចជា ស្រេច គេមិនដែលដើរយកពីកម្មករនោះទេ។ ខ្ញុំមិនដែលបានទទួលវគ្គបណ្តុះបណ្តាលអ្វីពីសហជីពឡើយ ហើយខ្ញុំក៏មិនដែលបានទទួលប្រាក់ឧបត្ថមពីសហជីពដែរ ព្រោះខ្ញុំមិនដែលឈឺ។ តែខ្ញុំធ្លាប់ឃើញកម្មករដទៃទៀតដែលឆ្លងទន្លេ គេអាចទទួលបាន៣០០០០រៀល ពីសហជីព។ ហើយខ្ញុំក៏មិនដែលឃើញ សហជីពហៅកម្មករ ដទៃទៀត ដែលជាកមាជិកខ្លួនទៅរៀនដែរ។

ខ្ញុំបានដឹងខ្លះៗដែរអំពីសិទ្ធិរបស់ខ្ញុំ គឺដឹងដោយសារកាលដែលខ្ញុំដាក់ច្បាប់ម្តងនោះគឺខ្ញុំដាក់ច្បាប់រៀបការបាន ៧ថ្ងៃ ខាងរោងចក្រកាត់លុយបំណាច់ឆ្នាំ ប៉ុន្តែមិនបានដាច់លុយព្រីមនោះទេ។ ហើយនៅពេលដែលកម្មករណាម្នាក់ត្រលប់ពីរៀបការមកវិញ ត្រូវភ្ជាប់ជាមួយរូបថតរៀបការមួយសន្លឹកទៅឱ្យបុគ្គលិកផ្នែកធនធានមនុស្ស។ កម្មករម្នាក់នោះនឹងទទួលបានប្រាក់ចំនងដៃ២០ដុល្លា ពីខាងក្រុមហ៊ុន ខ្ញុំក៏បានទទួលប្រាក់នោះដែរ។ ហើយនៅពេលដែលកម្មករណាម្នាក់ឈឺចង់សុំច្បាប់ពេទ្យ កម្មករម្នាក់នោះត្រូវទៅពិនិត្យឈាមនៅគ្លីនិកក្នុងរោងចក្រនោះ ព្រោះបើកម្មករយកសំបុត្រពេទ្យនៅខាងក្រៅរោងចក្រគេមិនទទួលស្គាល់នោះទេ ព្រោះខ្លាចថាកម្មករកុហក ដូចនេះកម្មករត្រូវពិនិត្យឈាម ហើយយកលិខិតនោះទៅរដ្ឋបាលគេនិងអនុញ្ញតច្បាប់តាមនោះ ដោយមិនដាច់លុយព្រីម រឺលុយធ្វើការប្រចាំថ្ងៃនោះទេ។ នៅពេលដែលកម្មករពោះធំសំរាលកូន គេអនុញ្ញាតឱ្យឈប់៣ខែ ដោយគិតលុយឱ្យ៥០ភាគរយ។ ហើយបើសិនជាកម្មករណាចង់សុំច្បាប់ទៅការបងប្អូន រឺមានធុរៈផ្សេងៗនោះ គេអាចសុំច្បាប់បានដោយប្រើបំណាច់ឆ្នាំ ហើយបើសិនជាអស់បំណាច់ឆ្នាំ កម្មករនោះនឹងដាច់លុយព្រីម ទោះបីជាឈប់កន្លះម៉ោង ក៏ដោយ។ ពេលខ្ញុំបើកប្រាក់ខែម្តងៗខ្ញុំទទួលបាន ៧០-៨០ដុល្លា គឺក្នុងនោះរួមមាន ប្រាក់ខែគោល ប្រាក់ថែមម៉ោង លុយបុងលុយព្រីម និងប្រាក់អតីតភាព តែប្រាក់ទាំងនោះត្រូវចំណាយទៅលើថ្លៃផ្ទះ ១២ដុល្លា និងថ្លៃភ្លើង ថ្លៃទឹក ១០០០០រៀល ថ្លៃម្ហូប ៣០ដុល្លា ហើយផ្ញើរទៅស្រុក ១០-២០ដុល្លា ក្នុងមួយខែ ដូចនេះ សំរាប់១ខែៗគឺសឹងតែ មិនគ្រាន់ទេ។

ចំនែកប្តីរបស់ខ្ញុំគាត់ធ្វើចំការនៅឯស្រុក ហើយប្រាក់ចំណូលវិញបានតិចតួចណាស់សឹងតែគ្មានផងខែខ្លះ។ ក្នុងចិត្តខ្ញុំចង់ឱ្យប្តីខ្ញុំមកធ្វើការនៅភ្នំពេញដែរ តែដោយសារការងារពិបាករកហើយត្រូវចំនាយលុយ ណាមួយចំពោះមនុស្សប្រុសត្រូវចំណាយលុយច្រើន ដូចនេះសព្វថ្ងៃនេះខ្ញុំត្រូវព្យាយាមសន្សំលុយច្រើនដើម្បីឱ្យប្តីខ្ញុំបានមកធ្វើការ នៅទីក្រុងហ្នឹងគេគ្រាន់ជួយទប់ទល់ជីវភាពគ្រួសារបានបន្ថែមទៀត។ តែពិបាកក្នុងការសន្សំលុយខ្លាំងណាស់ព្រោះទំនិញនៅទីផ្សារថ្លៃជាង

មុនខ្លាំងណាស់។  កាលពីមុនខ្ញុំពិបាកណាស់ណាត្រូវចិញ្ចឹមជីវិតនៅទីក្រុង  និងណាត្រូវផ្ញើរលុយទៅឱ្យពុកម៉ែដើម្បីសងបំណុលគេ ទិញជីដាក់ស្រែ និងផ្គត់ផ្គង់ប្អូនៗ តែឥលូវនេះខ្ញុំបានធូរស្រាលបន្តិចហើយដោយសារ ខ្ញុំមានប្អូនស្រី២នាក់ទៀតបានធ្វើការនៅរោងចក្រដែរ។  ខ្ញុំមិនគិតថាខ្ញុំអាចធ្វើការបានយូរប៉ុណ្ណានោះទេ  ព្រោះឥលូវនេះខ្ញុំកំពុងមានផ្ទៃពោះហើយនៅពេលដែលខ្ញុំសំរាលកូន គ្មានអ្នកណាមើលកូនឱ្យខ្ញុំទេ  ហើយបើសិនជាខ្ញុំឈប់ធ្វើការខ្ញុំគ្មានលុយសំរាប់ចិញ្ចឹមកូននិង គ្រួសារទេ។

ខ្ញុំនៅផ្ទះជួលតូចចង្អៀតតែបើសិនជាមានបងប្អូនមកលេងម្ចាស់ផ្ទះមិនដែលស្តីឱ្យនោះទេ  ហើយទោះជាខ្ញុំបង់លុយឱ្យយឺតប៉ុន្មានថ្ងៃក៏គេមិនដែលស្តីឱ្យនោះដែរ។  ខ្ញុំជួលផ្ទះឆ្ងាយពីកន្លែងធ្វើការពេលចេញពីធ្វើការយប់ខ្ញុំខ្លាចណាស់  តែខ្ញុំមិនដឹងធ្វើយ៉ាងណាទេព្រោះខ្ញុំត្រូវធ្វើការវេនយប់។  បើសិនជារោងចក្របិទខ្ញុំនឹងទៅស្រុកវិញ  ខ្ញុំដឹងថាមិនអាចធ្វើការបន្តទៀតបាននោះទេ  ព្រោះកំលាំងខ្សោយរបស់ខ្ញុំដូចជាចុះខ្សោយជាមុន  ហើយប្រសិនជារកការងារធ្វើនោះខ្លាចក្រែងវាមិនត្រូវជំនាញ។

ករណីសិក្សាទី១៦

តំបន់មានជ័យ

ថ្ងៃទី ១៦ មិថុនា ២០០៥

នាងខ្ញុំឈ្មោះ ហៅ សូនី មានអាយុ ១៨ឆ្នាំ សព្វថ្ងៃធ្វើការនៅរោងចក្រ **ម៉ុនជូតិច** ផ្នែកត្បាញ។ គ្រួសារខ្ញុំរស់នៅភូមិក្បឿងរាយ ឃុំក្បឿងរាយ ស្រុកកញ្ជ្រៀក ខេត្តព្រៃវែង។ គ្រួសារខ្ញុំមានសមាជិក៧នាក់។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៥ ក៏ឈប់ដោយសារម៉ែខ្ញុំជាស្រីមេម៉ាយហើយគ្មានអ្នកណាជួយមើលប្អូនៗ។ ខ្ញុំជាកូនទី ៥ ហើយបងស្រីទី១ មានប្ដីហើយគាត់ទៅរស់នៅផ្សេង។ បងប្រុសទី៤ នៅផ្ទះធ្វើស្រែជាមួយម៉ែ ហើយប្អូនប្រុសពៅនៅរៀន។ បងស្រីទី៣ និងខ្ញុំមករកការងារធ្វើនៅភ្នំពេញ។ ខ្ញុំឈប់រៀនដោយខ្លួនឯងព្រោះខ្ញុំ គិតថាចង់ជួយដល់គ្រួសារ តែនៅផ្ទះធ្វើតែស្រែហើយផុតពីធ្វើស្រែទៅនៅទំនេរមិនមានអ្វីធ្វើទេ ដូចនេះទើបខ្ញុំសំរេចចិត្តមករកការងារនៅភ្នំពេញដើម្បីបានលុយកាក់ខ្លះឱ្យម៉ែគាត់ទិញជីដាក់ស្រែ និងទិញម្ហូបអាហារបានខ្លះ។

នៅឯស្រែគ្រួសារខ្ញុំមានដីមួយហិចតាហើយក្នុងរដូវធ្វើស្រែខ្ញុំត្រូវចំណាយជីសរមួយបាវ និងជីខ្មៅមួយបាវ គិតទាំងបាចមុនស្ទូង និងពេលស្ទូង។ ជីសរមួយបាវថ្លៃ ៧ម៉ឺនរៀល និងជីរខ្មៅមួយបាវថ្លៃ ៨ម៉ឺនរៀល។ ខ្ញុំមិនបានដឹងថាក្នុងមួយឆ្នាំបានផលស្រូវប៉ុន្មានថាំងទេ តែខ្ញុំគ្រាន់ចំណាំថាពេលធ្វើបានផលច្រើន គឺអាចហូបគ្រប់សំរាប់រយៈពេលមួយឆ្នាំ តែបើធ្វើមិនសូវបានវិញនោះគឺមិនអាចហូបគ្រប់គ្រាន់នោះទេ ពេលនោះគឺត្រូវទិញអង្ករថែមហើយ។ តែពេលខ្លះខាតបានបងប្រុសទី២ទៅស៊ីឈ្នួលនៅប្រទេសថៃ គាត់បានផ្ញើរលុយកាក់ខ្លះមកឱ្យម៉ែយូរៗម្ដងដែរ គ្រាន់បានដោះស្រាយខ្លះ។ តែជួនកាលម៉ែគាត់ទៅខ្ចីលុយបងស្រីគាត់ ហើយពេលបងប្រុសទី២ផ្ញើរលុយមក ទើបគាត់សងគេវិញ។

ខ្ញុំមកធ្វើការដំបូងនៅភ្នំពេញ គឺស្រីជាអ្នកនាំមកពេលនោះខ្ញុំចំណាយទៅលើសោហ៊ុយអស់ ៦០០០រៀល តែបងខ្ញុំគាត់ចេញលុយអោយ។ ខ្ញុំមករង់ចាំរកការងារបាន ២ថ្ងៃ ខ្ញុំក៏បានការងារធ្វើដោយការដើរធ្វើតេស្ដដោយខ្លួនឯងបានជាប់នៅរោងចក្រ **មុនជូតិច** ជាកម្មករបណែរតផ្នែកតម្បាញ។ មុនដំបូងខ្ញុំធ្វើការបាន ១០ថ្ងៃ គេគិតលុយឱ្យបាន ២៣៤៥០រៀល ដោយធ្វើវេនថ្ងៃគឺចូលពីម៉ោង ១១:៣០ និងចេញម៉ោង ៨យប់ ហើយគេឱ្យចេញ ១:៣០ រសៀលសំរាប់សំរាកហូបបាយរយៈពេលតែកន្លះម៉ោងប៉ុណ្ណោះ។ ផុតពី១០ថ្ងៃ ខាងរោងចក្រឱ្យសាកល្បងកំឡុងពេល ៣ខែ ហើយទទួលប្រាក់ខែ ៣០ដុល្លា។ ៣ខែក្រោយមកគេឱ្យស៊ីប្រាក់ខែ ៤០ដុល្លា។ តាំងពីធ្វើការនៅទីនោះមកចិនមិនដែលស្ដីឱ្យទេ មានតែខ្មែរទេដែរស្ដីឱ្យបន្តិចបន្តួច ព្រោះគេគិតថាខ្ញុំមិនសូវចេះត្បាញ។ នៅរោងចក្រនេះមានភាពងាយស្រួលជាងរោងចក្រមិត្តភក្ដិរបស់ខ្ញុំ ការត្បាញវិញគ្មានចំនួនកំនត់នោះទេ ហើយការទៅបន្ទប់ទឹកយូរបន្តិចក៏មិនអ្នកណាថាឬស្ដីអោយដែរ។ តាំងពីចូលធ្វើការខ្ញុំមិនដែលមានជំងឺឈឺទេ។ ក្នុងរោងចក្រខ្ញុំមិនដឹងថាមានពេទ្យឬអត់នោះទេ ព្រោះខ្ញុំទើបតែចូល ហើយខ្ញុំក៏មិនដែលទៅសុំថ្នាំពេទ្យទេ។ ខ្ញុំមិនដឹងថារោងចក្រនេះមានសហជីពឬក៏អត់ទេ។ ពេលចេញពីធ្វើការខ្ញុំមិនសូវខ្លាចទេ ព្រោះទើបតែម៉ោង ៨ នៅមានមនុស្សច្រើនដើរតាមផ្លូវទៅមកៗ។

នៅបន្ទប់ជួលរបស់ខ្ញុំមានគ្នា ៧នាក់ ដូចនេះម្នាក់ចេញ ៣ដុល្លានិង៥០០រៀល ប៉ុន្តែខ្ញុំមិនដឹងថាគេគិតថ្លៃទឹកនៅក្នុងថ្លៃផ្ទះរឺក៏អត់ទេ គ្រាន់តែដឹងថាថ្លៃបន្ទប់អស់២០ដុល្លាក្នុងមួយខែ។ ចំនែកថ្លៃភ្លើងម្ចាស់ ផ្ទះគេជួយក្នុងមួយខែ ៣គីឡូវ៉ាត់ តែបើប្រើលើសគេគិតលុយថែម។ រាល់ថ្ងៃពេលដេកចង្អៀតណាស់ ពេលខ្លះខ្ញុំចង់ ទៅរកជួលបន្ទប់ផ្សេងដែរតែខ្លាចបែកគ្នា ព្រោះនៅទីនេះមានបងប្អូនច្រើន ខ្ញុំក៏សុខចិត្តនៅចង្អៀតចុះឱ្យតែបងប្អូននៅជួបជុំគ្នា និងបានឃើញគ្នារាល់ថ្ងៃព្រោះស្រួល ពេលឈឺមានគេជួយមើល។ ជារៀងរាល់ខែខ្ញុំខំចាយត្បិតត្បៀត គឺកន្លះខែខ្ញុំចាយអស់ ១៥០០០រៀលដើម្បីបានលុយច្រើន ផ្ញើរទៅអោយមែនៅឯស្រុក។ បើថ្ងៃមុខរោងចក្របិទអស់ ខ្ញុំគិតត្រលប់ទៅធ្វើស្រែជាមួយម៉ែនៅឯងស្រុកកំនើតវិញ។

## ករណីសិក្សាទី១៧

### តំបន់មានជ័យ

នាងខ្ញុំ អ៊ូ សុផល មានអាយុ ២៧ឆ្នាំ សព្វថ្ងៃធ្វើការនៅរោងចក្រ MV ហើយឥលូវនេះកូនប្រុសម្នាក់ អាយុ៧ឆ្នាំ។ គ្រួសារខ្ញុំរស់នៅភូមិស្ពានត្នោត ស្រុកជីក្រែក ខេត្តសៀមរាប។ គ្រួសារខ្ញុំទាំងអស់មាន ១០នាក់។ ខ្ញុំរៀនថ្នាក់ទី៧ក៏ឈប់រៀនដោយសារជីវភាពលំបាកពេកគ្មានប្រាក់សំរាប់រៀនបន្ត។ ពុកម៉ែជាអ្នកធ្វើស្រែចំការ ពួកគាត់មានដីស្រែមួយហិចតា ហើយក្នុងមួយឆ្នាំធ្វើស្រែប្រើជីអស់២បាវ ដែលមានឈ្មោះថាជីសនិងខ្មៅ។ ហើយជីមួយបាវតំលៃ៧៥០០០រៀល តែពីមុនមានតំលៃត្រឹមតែ ៥០០០០ទៅ៦០០០០រៀល។ ក្នុងមួយឆ្នាំបានផលមួយតោនក្នុងមួយហិចតា តែដោយមានសមាជិកច្រើនដូចនេះពួកយើងហូបមិនដែលបានគ្រប់ពេញមួយឆ្នាំនោះទេ បានត្រឹមតែ៧ទៅ៨ខែប៉ុណ្ណោះ នៅខ្វះពីបីទៅបួនខែទៀត។ ហើយនៅពេលខ្វះម្តងត្រូវទៅខ្ចីស្រូវគេយកមកហូប ប្រហែលជា ២បាវស្រូវ ដោយមួយបាវមានចំនួន១០០គីឡូអង្ករ ហើយគេយកការជាស្រូវ៥០គីឡូក្នុងមួយរដូវ។ ពីមុនម៉ែខ្ញុំក៏ធ្លាប់ទៅចងការមាសគេចំនួនបីជីកន្លះ គេយកការក្នុងមួយខែចំនួនមួយហ៊ុន។ ម៉ែគាត់ខ្ចីមាសគេដូរយកលុយឱ្យពុកទៅស៊ីឈ្នួលគេនៅប្រទេសថៃ តែទៅដល់ពាក់កណ្តាលផ្លូវត្រូវប៉ូលីសខ្មែរនៅព្រំដែនចាប់មិនឱ្យចូលទៅថៃ ហើយគេឱ្យគាត់ត្រលប់មកវិញ ប៉ូលីសព្រំដែនបានចាប់ទាំងមេខ្យល់ដែលនាំពុកទៅជាមួយផងដែរ។ គាត់ក៏ត្រលប់មកផ្ទះវិញដោយឱ្យមេខ្យល់នោះសងលុយមកវិញទាំងអស់ តែគេឱ្យបានតែ២ជីប៉ុណ្ណោះ។ ពេលត្រលប់មកផ្ទះវិញ ម៉ែក៏យកមាសដែលនៅសល់មកសងម្ចាស់គេវិញ តែនៅជំពាក់គេកន្លះជីទៀត។

ប្រហែល៣ខែក្រោយមក ខ្ញុំក៏ទៅចងការមាសគេ៣ជី ដើម្បីទៅស៊ីឈ្នួលគេនៅប្រទេសថៃដែរ គឺទៅធ្វើការជាកម្មករសំនង់ កាលនោះខ្ញុំទទួលបានប្រាក់មួយថ្ងៃ ១១០បាត ហើយខ្ញុំនៅទីនោះបាន ៦ខែ។ ហើយរយៈពេលធ្វើការគេឱ្យខ្ញុំធ្វើអ្នកលាយស៊ីម៉ង់ហើយចាប់ផ្តើមធ្វើការនៅម៉ោង ៧ព្រឹក ចេញនៅម៉ោង១២ថ្ងៃត្រង់។ ខ្ញុំស្នាក់នៅផ្ទះថៅកែសំនង់ ជារៀងរាល់ថ្ងៃខ្ញុំមានការភ័យខ្លាចជាខ្លាំង ខ្លាចតំរួតថៃមកចាប់ ព្រោះចូលទៅធ្វើការនៅទីនោះដោយ ខុសច្បាប់ សូម្បីតែដើរលេងក៏អត់ហ៊ានទៅដែរ វាមិនដូចកាលនៅស្រុកខ្ញុំចង់ទៅណាក៏បាននោះទេ។ តែមិនបានប៉ុន្មានខែក្រោយមកកម្មករខ្មែរជាច្រើននាក់ព្រមទាំងរូបខ្ញុំត្រូវបានប៉ូលីសថៃចាប់បាន ហើយគេក៏បញ្ជូនមកស្រុកខ្មែរវិញ។ ពេលមកដល់ផ្ទះខ្ញុំសល់លុយអាចល្មមសងនិងគេ ហើយក៏យកទៅសងគេអស់ទៅ។ កាលនោះខ្ញុំនៅសល់លុយ៤០០០បាត គ្មានការងារធ្វើគិតថានិងទិញម៉ូតូដើម្បីលក់ត្រីនៅតាមភូមិ តែមិនមានលុយគ្រប់ដើម្បីទិញម៉ូតូនោះទេ ពេលនោះខ្ញុំបានពិគ្រោះជាមួយក្រុមគ្រួសារហើយក៏បានលក់គោមួយបាន ៤ជី ដើម្បីទិញម៉ូតូ លក់បាន២ខែក៏ឈប់លក់ទៅ ព្រោះមិនសូវចំណេញ។ បន្ទាប់ពីនោះមកប្តីខ្ញុំក៏បានទៅប្រទេសថៃទៅធ្វើជាកម្មករ នេសាទអោយគេតែក៏បានបាត់រហូតបើគិតមកដល់ពេលនេះចំនួន៥ឆ្នាំហើយ អត់ឃើញគាត់ត្រលប់មកវិញទេ។ តែពេលគាត់ទៅថៃបានកន្លះខែ គាត់បានផ្ញើរលុយមកឱ្យខ្ញុំ៣០០០បាត ហើយ៣ខែក្រោយមកទៀត គាត់ក៏បានផ្ញើរលុយមក ៣០០០បាតទៀត។ ក្រោយមកក៏បាត់ដំនឹងគាត់សូន្យ ដល់សព្វថ្ងៃនេះហើយក៏មិនដែលលឺដំនឹងថាគាត់ស្លាប់ រឺរស់ទេ។

ខ្ញុំបានមកធ្វើការនៅរោងចក្រដោយសារខ្ញុំអត់មានលុយចាយ ហើយក៏ដាច់ចិត្តមករកការងារធ្វើការនៅភ្នំពេញ។ ពេលមកដំបូងខ្ញុំមានលុយ១២ម៉ឺនរៀល ដែលបានខ្ចីពីម្តាយមីង ពីស្រុកខ្ញុំមកដល់ភ្នំពេញត្រូវចំណាយអស់ ១២០០០រៀល។ ពេលមកដល់ភ្នំពេញដំបូង ខ្ញុំស្នាក់នៅផ្ទះជួលនៅចាក់អង្រែក្រោម។ មួយអាទិត្យក្រោយមកក៏បានការងារធ្វើដោយការដើរធ្វើតេស្តដោយខ្លួនឯងតាមរោងចក្របានជាប់នៅរោងចក្រ **ស្លុតវ៉ែល** ជាកម្មករបណ្តែតនៅផ្នែកកាត់ព្រុយ។ ធ្វើបានមួយអាទិត្យគេបើកលុយម្តងដោយគេឱ្យមួយថ្ងៃ ១,៧៥ដុល្លា ដូចនេះខ្ញុំបាន១២ដុល្លានិង៥០០រៀល ក្នុងរយៈពេលមួយអាទិត្យ។ កម្មករបណ្តែតដែលធ្វើការនៅរោងចក្រនេះគឺមួយអាទិត្យគេរំសាយម្តង តែខ្ញុំបានធ្វើនៅក្នុងរោងចក្របានចំនួន៣អាទិត្យក៏ត្រូវគេរំសាយពីការងារ ហើយនៅពេលរោងចក្រនេះពេលមានខោអាវធ្វើច្រើនទើបបានគេរើសម្តងទៀត។ បន្ទាប់ពីត្រូវគេរំសាយខ្ញុំក៏ត្រឡប់មកផ្ទះវិញបានកន្លះខែ បន្ទាប់មកក៏បានធ្វើតេស្តជាប់នៅរោងចក្រ **អ៊ីមវ៉ៃ** ហើយបានបំរើការនៅផ្នែកកាត់ព្រុយ ធ្វើបានកន្លះខែខាងរោងចក្រប្តូរអោយខ្ញុំទៅធ្វើនៅផ្នែកឆ្លុះ(ពិនិត្យ)។ ចូលដំបូងបានប្រាក់ឈ្នួល៣០ដុល្លាក្នុងមួយខែ ធ្វើបាន៣ខែក្រោយមកក៏ក្លាយជាកម្មករពេញសិទ្ធិហើយបានទទួលប្រាក់ឈ្នួល ៤៥ដុល្លាធ្វើនៅវេនថ្ងៃ។

ខ្ញុំត្រូវចាប់ផ្តើមធ្វើការនៅម៉ោង ៧ព្រឹក ចេញនៅម៉ោង ១១ព្រឹក ហើយចូលម្តងទៀតនៅម៉ោង ១២:៣០ ថ្ងៃត្រង់ហើយចេញនៅម៉ោង ៤:៣០រសៀល តែបើថ្ងៃខ្លះត្រូវថែមម៉ោងនោះគឺថែមដល់ម៉ោង៩យប់។ ខ្ញុំធ្វើការនៅរោងចក្រនេះខ្លាចមិនស្តីឱ្យណាស់ ព្រោះនៅពេលដែលខ្ញុំដេរយឺតរីក្រុមរបស់ខ្ញុំដេរមិនលឿននោះ ចិនដើរមកបង្ខំឱ្យពួកខ្ញុំដេរអោយលឿន ហើយទោះជាមានជំងឺក៏ដោយអោយតែត្រូវដល់ពេលនាំចេញខោអាវនោះគឺអោយយើងថែមម៉ោង ហើយប្រសិនបើកម្មករណាអត់ព្រមថែមម៉ោងនោះ នៅថ្ងៃបន្ទាប់ពេលចូលធ្វើការវិញ គឺច្បាស់ជាត្រូវចិនហៅទៅស្តីអោយជាមិនខាន។ តំលៃនៃការឆែករីឆ្លុះអាវក្នុងមួយឡូរគឺ ៤សេន ហើយក្នុងមួយថ្ងៃខ្ញុំឆែកអាវបានប្រហែលជា៥០ឡូ បើថែមម៉ោងដល់ម៉ោង ៩យប់បានប្រហែល៧០ឡូទៅ៨០ឡូ។ ពេលទៅបន្ទប់ទឹកគេកំនត់ នាទីឱ្យចូលគឺត្រឹមតែ ៥-១០ នាទី។ ពេលឈឺសុំច្បាប់ទាល់តែមានលិខិតបញ្ជាក់ពីពេទ្យទើបបានគេឱ្យឈប់ តែបើអត់មានសំបុត្រពេទ្យទេ ខាងរោងចក្រអោយច្បាប់ច្រើនបំផុត២ថ្ងៃ ហើយត្រូវគេស្តីអោយទៀតទំរាំបានច្បាប់។ បើកម្មករណាឈប់អត់ច្បាប់ ពេលត្រឡប់មកធ្វើការវិញត្រូវហៅទៅប្រមានដោយការផ្តិតមេដៃ១ ហើយបើមានមេដៃគ្រប់៣ដងនោះ និងត្រូវរោងចក្រដេញចោញពីការងារ។ ពេលឈឺធ្ងន់ធ្ងរនោះថៅកែរោងចក្រ អត់ចេញលុយមើលជំងឺឱ្យទេ យើងត្រូវចេញលុយមើលជំងឺដោយខ្លួនឯង។ ចំពោះការធ្វើការវិញគឺអត់មានកំនត់ទេ ព្រោះខ្ញុំត្រូវបានគិតលុយតាមចំនួនឡូដែរធ្វើបាន តែបើធ្វើការមិនលឿននោះទេត្រូវចិនស្តីអោយ។ ក្នុងរោងចក្រ មានសហជីពពីរ ឈ្មោះ ម៉ម ញឹម និង រស់ សុខ។ សហជីពមានការតវ៉ា និងជួយដល់កម្មករដែរដូចជារឿងសុំច្បាប់ និងតវ៉ាតំលៃឡូ ហើយពេលតវ៉ាបើថៅកែមិនព្រមទេនោះ សហជីពនឹងឱ្យកម្មករធ្វើកូដកម្ម។

ពេលយប់ចេញពីថែមម៉ោងខ្ញុំមានការភ័យខ្លាចនៅតាមផ្លូវត្រឡប់មកផ្ទះវិញ ជួនកាលមានអ្នកជិះម៉ូតូឆាប ពេលខ្លះក៏នាំគ្នាដើរផងរត់ផង ព្រោះពេលខ្លះស្ងាត់ណាស់ហើយបន្ទប់ដែលខ្ញុំជួលនោះវានៅឆ្ងាយពីកន្លែងធ្វើការដែរ បន្ទប់នោះថ្លៃ

២០ដុល្លាមួយខែហើយខ្ញុំនៅគ្នា៣នាក់ វាជាបន្ទប់មួយតូចចង្អៀត ពេលងូតទឹកក៏ពិបាក អោយតែថ្ងៃអាទិត្យគឺមិនសូវមានទឹកងូតទេ ហើយម្យ៉ាងទៀតម្ចាស់ផ្ទះជួលក៏មានការរើសអើងនឹងពួកខ្ញុំជាកម្មករដែរ។ ពួកខ្ញុំដែលនៅជាមួយគ្នាត្រូវជួយគ្នាចេញថ្លៃបន្ទប់ ដោយម្នាក់ចេញ៦ដុល្លានិង៣០០០រៀលក្នុងមួយខែ។ ពេលបើកប្រាក់ខែម្តងៗបានប្រហែលជា៨០ដុល្លា ហើយក្នុងមួយខែខ្ញុំត្រូវចំណាយអស់ ៦០ដុល្លា សំរាប់ថ្លៃផ្ទះម្ហូបនិងថ្នាំសង្កូវផ្សេងៗ ហើយត្រូវផ្ញើរទៅផ្ទះមួយខែ ២០ដុល្លាទៀត សំរាប់កូនរៀន និងអោយម៉ែទិញម្ហូប។ ទៅថ្ងៃមុខប្រសិនបើរោងចក្របិទអស់ខ្ញុំមិនចង់ត្រលប់ទៅផ្ទះវិញទេ គឺចង់ដើររកការងារធ្វើបន្តនៅភ្នំពេញ។

ករណីសិក្សាទី១៨

តំបន់បាក់ខែង

ថ្ងៃទី ២៥ មិថុនា ២០០៥

នាងខ្ញុំឈ្មោះ គ ស្រី រស់នៅភូមិអូរតោ ឃុំសំពោងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម។ ខ្ញុំមានបងប្អូន ៤នាក់ (ប្រុស ១ និងស្រី ៣នាក់)។ ពុកម៉ែសព្វថ្ងៃ ជាអ្នកធ្វើស្រែ បងស្រីទី២ បានរៀបការរួចហើយ ហើយប្អូនប្រុសពៅ នៅរៀនថ្នាក់ទី៤ បងប្រុសនៅផ្ទះឈឺគាត់ធ្វើការធ្ងន់មិនកើតទេ។ គ្រួសារខ្ញុំមានដីស្រែ ២ហិចតា ហើយក្នុងមួយឆ្នាំត្រូវចំនាយទៅលើការធ្វើស្រែអស់ប្រហែលពី៤០ទៅ៥០ម៉ឺនរៀល ហើយបើស្រូវល្អពេលប្រមូលផលបានប្រហែលពី ១៥០ទៅ១៦០ថាំង តែបើមិនល្អបានផលប្រហែលជា ១០០ថាំង។ ផលស្រូវដែលទទួលបានហូបអត់គ្រប់ទេ ពេលខ្វះក៏ទៅបុលស្រូវគេយកមកហូប ហើយបើខ្ចីគេ១ត្រូវសងគេវិញ២ នេះទាំងដើមនិងការសំរាប់មួយរដូវ។

ដោយសារជីវភាពគ្រួសារខ្វះខាតធ្វើស្រែអត់សូវបាន ហើយរកអ្វីធ្វើក៏មិនបាននោះ នៅឆ្នាំ២០០០ ខ្ញុំក៏សំរេចចិត្តមករកការងារធ្វើជាកម្មករោងចក្រ។ ពេលមកដល់ដំបូងខ្ញុំបានដើរធ្វើតេស្តតាមរោងចក្រមួយអាទិត្យពេញ តែខ្ញុំធ្វើតេស្តមិនជាប់ទេ ពេលនោះខ្ញុំក៏ត្រលប់ទៅស្រុកវិញដើរស៊ីឈ្នួលគេ ហើយឱ្យតែគេជួលធ្វើខ្ញុំធ្វើទាំងអស់គឺលក់ កំលាំងពលកម្មមួយថ្ងៃបានប្រាក់៣៥០០រៀល។ កន្លះខែក្រោយមកបងប្អូនក៏ហៅមកវិញ ខ្ញុំក៏ដើរធ្វើតេស្តតាមរោងចក្ររយៈពេល២អាទិត្យទៀតតែនៅតែអត់បានការងារធ្វើទៀត ពេលនោះខ្ញុំបានសុំស្នាក់នៅជាមួយបងស្រី ដែលធ្វើការនៅរោងចក្រសាំហាន់។ ពេលមករកការងាធ្វើនោះម៉ែខ្ញុំបានខ្ចីលុយពីមីងឱ្យយកមក៥ម៉ឺន និងលុយបងខ្លះ ដល់ដើរតេស្តមិនបានបងស្រីក៏សុំប្រធានប្លុកនៅរោងចក្រសាំហាន់ ឱ្យចូលធ្វើការនៅរោងចក្រនោះដោយអត់អស់លុយទេ។

ពេលចូលធ្វើការនៅក្នុងរោងចក្រ **សាំហាន់** ដំបូងបានប្រាក់ខែ ១០ដុល្លា ពេលនោះជារយៈពេលហ្វឹកហាត់ការងារ។ ធ្វើបាន២ខែ ខ្ញុំបានឡើងប្រាក់ខែដល់ ៤០ដុល្លា ធ្វើការនៅរោងចក្រគឺចាប់ផ្តើមចូលនៅម៉ោង ៧ព្រឹក ចេញម៉ោង ១២ថ្ងៃ និងចូលម្តងទៀតនៅម៉ោង១រសៀល ហើយចេញនៅម៉ោង ៦ល្ងាច ហើយទោះជាថែមម៉ោងក៏ដោយ ក៏គ្មានបានប្រាក់ដែរ តែរោងចក្រគេគិតលុយបុងអោយ ហើយរោងចក្រមានបាយឱ្យហូបក្នុងរោងចក្រ។ នៅបន្ទប់ ជួលមួយខែតំលៃ ១២ដុល្លា ទឹកភ្លើងអស់ជាង៣ដុល្លា ហើយពួកខ្ញុំនៅគ្នា៤នាក់។ ពេលណាមានការងារធ្វើច្រើន ប្រាក់ខែបានពី៨០ទៅ៩០ដុល្លា ហើយជារៀងរាល់ថ្ងៃខ្ញុំត្រូវធ្វើការមួយថ្ងៃរយៈពេល១០ម៉ោង បូកទាំងការថែមម៉ោង២ម៉ោង។ ហើយក្នុងមួយខែផ្ញើរទៅផ្ទះបានពី ៥០ទៅ៦០ដុល្លា និងនៅសល់ប៉ុន្មានគឺគ្រាន់ទុកពេលឈឺ និងទិញសំភារៈផ្ទាល់ខ្លួនខ្លះ។ ពេលផ្ញើរលុយទៅផ្ទះម្តងៗគឺត្រូវផ្ញើរទៅតាមបងប្អូននៅក្នុងភូមិ តែជួនកាលម៉ែគាត់មកលេងក៏យកលុយទៅតែម្តងទៅ។ លុយដែលផ្តល់ទៅផ្ទះគឺម៉ែគាត់យកទៅដើម្បីដោះស្រាយជីវភាពប្រចាំថ្ងៃ ដូចជាទិញម្ហូប អង្ករ ឱ្យប្អូនៗរៀន ពេលឈឺខ្លះទៅនិងយកទៅធ្វើស្រែខ្លះ បានលុយនេះម៉ែគាត់មិនសូវចងការអ្នកភូមិ។

នៅក្នុងរោងចក្រនេះមាន២វេនគឺវេនថ្ងៃ និងវេនយប់ ហើយកម្មករទាំងអស់ត្រូវធ្វើការផ្លាស់ប្តូរវេនគ្នាគឺ វេនយប់ ១ខែ និងវេនថ្ងៃ ១ខែ ដោយគ្មានការតវ៉ានោះទេ ក្រោយពីខ្ញុំធ្វើការនៅរោងចក្រសាំហាន់បាន២ឆ្នាំក៏សំរេចចិត្ត ឈប់ព្រោះខ្ញុំនេះឧស្សាហ៍ឈឺពេក ណាមួយមិនអាចទ្រាំទ្រនិងការប្តូរវេនម្តងថ្ងៃម្តងយប់បាន ហើយកាលនោះនៅក្នុងរោងចក្រនៅមិនទាន់មានសហជីពទេ។ នៅពេលសុំច្បាប់ម្តង១គឺត្រូវដាច់លុយព្រឹមអស់៥ដុល្លាហើយ រោងចក្រនេះមិនដែលអោយទេលុយអតីតភាព និងបំណាច់ឆ្នាំ។ បន្ទាប់ពីឈប់ធ្វើការពីរោងចក្រក៏ត្រឡប់ទៅនៅផ្ទះបានវិញ នៅផ្ទះឯស្រុកបាន២ឆ្នាំក៏ត្រលប់មករកការងារធ្វើវិញម្តងទៀត ពេលនោះខ្ញុំត្រូវដើរធ្វើតេស្តប្រហែលមួយអាទិត្យ ក៏បានជាប់នៅរោងចក្រ រ៉ូស៊ីង ហើយរោងចក្រនេះដំណើរការ២វេន គឺវេនថ្ងៃនិងវេនយប់ដូចរោងចក្រមុនអញ្ចឹង។ ខ្ញុំចូលដំបូងជាកម្មករបណ្តែតបានប្រាក់ខែសរុប៤៥ដុល្លា បូកនិងប្រាក់លើកទឹក៥ដុល្លា ក្នុងកំឡុងពេលនេះបើធ្វើការមិនល្អ ឬមានកំហុស ខាងរោងចក្រអាចបញ្ឈប់ពីការងារគ្រប់ពេលវេលា។ បន្ទាប់មកខ្ញុំបានក្លាយជាកម្មករពេញសិទ្ធិខាងរោងចក្របានដូរកាតមួយទៀតគឺពណ៌ខៀវអោយខ្ញុំ ពេលនោះខ្ញុំទទួលបានប្រាក់ឈ្នួល ៤៥ដុល្លា ហើយមានលុយលើកទឹកចិត្ត៥ដុល្លា សរុបគឺ៥0ដុល្លា។ ក្នុងករណីដែលរោងចក្រមានខោអាវច្រើននោះប្រាក់ខែ ខ្ញុំអាចឡើងដល់ជាង ១០០ដុល្លា។ ខ្ញុំធ្វើការនៅវេនថ្ងៃកន្លះខែ និងវេនយប់កន្លះខែ។ ក្នុងមួយថ្ងៃថែមម៉ោង២ម៉ោង ខ្ញុំមិនបានដឹងថារោងចក្រនេះផលិតម៉ាក់អ្វីនោះទេ ខ្ញុំក៏ជាសមាជិកសហជីពដែល តែមិនដឹងថាសហជីពឈ្មោះស្អីទេ ហើយក្នុងមួយខែខាងរោងចក្របានកាត់១០00រៀល អោយទៅសហជីព។ នៅក្នុងរោងចក្រការសុំច្បាប់ពីប្រធានក្រុមចិនមានភាពងាយស្រួលទេ បើសុំច្បាប់៣ថ្ងៃនិងត្រូវដាច់លុយព្រឹម៥ដុល្លា។

ប្រធាននៅក្នុងរោងចក្រតំរូវអោយដេរអោយលឿន ហើយបើក្រុមណាដេរបានលឿននោះនិងទទួលបានប្រាក់រង្វាន់ ហើយគេចែកអោយជារៀងរាល់អាទិត្យ។ នៅរោងចក្រសាំហាន់ និងរ៉ូស៊ីង ស្រដៀងគ្នាចំពោះលក្ខខណ្ឌការងារ ប៉ុន្តែនៅរោងចក្ររ៉ូស៊ីងថ្ងៃបុណ្យ បើមានខោអាវប្រញាប់នាំចេញនោះ ប្រធានចិនស្នើរកម្មករឱ្យធ្វើការថែមម៉ោង តែបើកម្មករមិនធ្វើក៏មិនអីដែរ។ រហូតមកដល់ពេលនេះខ្ញុំធ្វើការនៅរោងចក្រ **រ៉ូស៊ីង** បានជាងមួយឆ្នាំហើយ ហើយខ្ញុំនៅតែផ្ញើរលុយទៅផ្ទះរាល់ខែដូចកាលមុនអញ្ចឹង។ ខ្ញុំគិតថាថ្ងៃក្រោយរោងចក្រនេះបិទខ្ញុំនឹងត្រលប់ទៅស្រុកវិញ ខ្ញុំមិននៅរកការងារក្នុងទីក្រុងទៀតទេព្រោះខ្ញុំមានអារម្មណ៏ធន់ទ្រាន់និងការងារនេះណាស់ តែប្រហែលជាអាចធ្វើឱ្យគ្រួសារខ្ញុំលំបាកជាងមុនដោយសារបាតបង់ប្រាក់ចំណូលមួយភាគ។

ករណីសិក្សាទី ១៩

តំបន់ទួលសង្កែ

ថ្ងៃទី ១៦ មិថុនា ២០០៥

នាងខ្ញុំឈ្មោះ ពេញ កុសល អាយុ ២៥ឆ្នាំ រស់នៅភ្នំពេញ ខ្ញុំមានបងប្អូន៦នាក់ (ប្រុស១ និងស្រី៥) នាងខ្ញុំជាកូនទី២នៅក្នុងគ្រួសារ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៥ ក៏ឈប់រៀន ព្រោះគ្រួសារមានជីវភាពខ្វះខាត។ ឪពុកខ្ញុំរត់ម៉ូតូឌុប ម្តាយខ្ញុំនៅផ្ទះ ហើយដោយឃើញឪពុកចាស់ និងឧស្សាហ៍ឈឺញឹកញាប់ ខ្ញុំក៏សំរេចចិត្តចូលធ្វើការក្នុងរោងចក្រ ដើម្បីជួយរកចំនូលដើម្បីផ្គត់ផ្គង់ក្រុមគ្រួសារ។ ឪពុកម្តាយខ្ញុំមិនជំទាស់ និងការដែលខ្ញុំសំរេចចូលធ្វើការនៅរោងចក្រនោះទេ។

ខ្ញុំបានចូលធ្វើការជាកម្មកររោងចក្រការ់ដេរនៅឆ្នាំ ១៩៩៦ នៅរោងចក្រ **សាំហាន់** ផ្នែកតម្បាញ។ ប្រាក់ខែដំបូងរបស់ខ្ញុំគឺ ៣០ដុល្លា ហើយពេលចូលដំបូងខ្ញុំមានការលំបាកយ៉ាងខ្លាំងព្រោះមិនទាន់ចេះត្បាញ។ គេមិនគិតជាប្រាក់ខែឱ្យទេ គឺគិតទៅតាមតំលៃបុងតែមានចំនួនកំនត់ ប្រធានចិនបានប្រាប់ថាបើត្បាញរយៈពេល ២ខែនៅមិនបានគ្រប់ចំនួនដែលបានកំនត់នោះទេនឹងត្រូវរំសាយពីការងារ។ លក្ខខ័ណ្ឌការងារមានការពិបាកខ្លាំង សុំច្បាប់ឈប់មួយថ្ងៃរោងចក្រកាត់លុយ ៥ដុល្លា។ ទៅបន្ទប់ទឹកញឹកញាប់មិនបាន ពេលឈឺសុំមកផ្ទះក៏មិនបាន គេឱ្យទៅសុំថ្នាំពេទ្យនៅក្នុងរោងចក្រ ទោះជាឈឺអ្វីក៏ដោយគ្រូពេទ្យឱ្យថ្នាំដូចៗតែគ្នា ខ្ញុំលេបថ្នាំនោះមិនដែលត្រូវនឹងជំងឺរបស់ខ្ញុំទេ។ នៅក្នុងរោងចក្រមានសហជីព២ គឺសហជីពសាមគ្គីភាព និងសហជីពស៊ីខៅខ្វ។ ខ្ញុំមិនបានចូលសហជីពទេដោយសារសហជីពទាំងនោះមិនសូវបំរើឱ្យកម្មករនោះទេ នៅពេលដែលមានបញ្ហាម្តងៗនៅក្នុងរោងចក្រ ដូចជាតវ៉ាតំលៃអាវ និងបញ្ហាផ្សេងៗមិនដែលបានសំរេចនោះទេ។ ខ្ញុំគិតថាសហជីពភាគច្រើនជួយថៅកែ មិនជួយកម្មករនោះទេ។

ប្រាក់ខែជាមធ្យមបូកនឹងថែមម៉ោងដល់ម៉ោង៦យប់ ដោយគិតតាមតំលៃបុងបានតែ ៦០ដុល្លា។ ប្រាក់ឈ្នួលដែលបើកបានមកខ្ញុំបានឱ្យម្តាយខ្ញុំទាំងអស់ តែពេលត្រូវចាយក៏សុំគាត់មកវិញខ្លះ រាល់ថ្ងៃ គាត់យកលុយហ្នឹងទៅទិញរបស់របរអង្ករ បង់ថ្លៃទឹកភ្លើង ប្អូនរៀន និងសំភារៈប្រើប្រាស់ក្នុងផ្ទះ។ ក្រោយមកខ្ញុំបានរៀបការជាមួយបុរសម្នាក់ដែលធ្វើការនៅរោងចក្រជាមួយគ្នា បន្ទាប់ពីមានផ្ទៃពោះខ្ញុំក៏បានឈប់ធ្វើការពីរោងចក្រនោះ ហើយប្តីខ្ញុំក៏ឈប់ធ្វើការដែរ គាត់បានទៅរកស៊ីជាមួយម្តាយគាត់នៅបាត់ដំបង គឺគាត់ទៅរត់តូម្ហូបការឱ្យគេ។ ចំនែកខ្ញុំត្រូវបានពុកម៉ែជាអ្នកចិញ្ចឹមនៅភ្នំពេញ នៅពេលដែលសំរាលកូនខ្ញុំអត់មានលុយទេ ឪពុករបស់ ខ្ញុំក៏ទៅខ្ចីលុយ គេហើយយកប្លង់ផ្ទះទៅបញ្ចាំគេ។ ហើយនៅពេលគ្មានលុយដើម្បីសងគេគ្រួសារខ្ញុំក៏សំរេចលក់ផ្ទះឱ្យគេទៅ ពេលនោះគ្រួសារខ្ញុំមិនបានមើលនិងអានកិច្ចសន្យានោះទេ ព្រោះគេសរសេរថានឹងឱ្យលុយថ្លៃផ្ទះមួយខែ ១០០ដុល្លា។ ហើយលុយដែលគេឱ្យថ្លៃផ្ទះមកបន្តិចម្តងៗ យកមកចាយរាល់ខែ។ ចុងបញ្ចប់លុយក៏អស់ ហើយផ្ទះក៏អស់ដែរ។ បន្ទាប់មកពុកម៉ែក៏មានរឿងឈ្លោះគ្នារហូតដល់លែងលះគ្នា ពុកខ្ញុំគាត់បានទៅនៅឯវត្តនៅខេត្តប៉ៃលិន។ ពេលកូនខ្ញុំបានបួនខែខ្ញុំក៏ចូលធ្វើការក្នុងរោងចក្រសាំហាន់វិញ។ ធ្វើការបានមួយឆ្នាំ

ប្តីខ្ញុំក៏មកយកខ្ញុំទៅនៅបាត់ដំបងវិញ ដោយម៉ែខ្ញុំអត់មាននរណាផ្តល់លុយចិញ្ចឹមគាត់ និងប្អូនតូចៗជាច្រើននាក់ទៀត គាត់ក៏ ខ្ចីលុយគេមកចាយ លុះដល់គេមកទារលុយគាត់អត់លុយសងគេ ក៏ធ្លាក់ខ្លួនឈឺរហូតស្លាប់ទើបខ្ញុំដឹងដំនឹង ហើយខ្ញុំបានមកធ្វើបុណ្យសពអោយគាត់ ពេលរួចរាល់ហើយខ្ញុំក៏ត្រលប់ទៅនៅជាមួយប្តីរបស់ខ្ញុំវិញ តែប្តីខ្ញុំជាមនុស្សខិលខូច ដើរតាមមនុស្សជក់ម៉ាយប់អាច្រាត្រទើបចូលផ្ទះ ហើយវាយធ្វើបាបខ្ញុំជារៀងរាល់ថ្ងៃ។

ឥលូវនេះខ្ញុំកំពុងដើររកការងារធ្វើនៅទីក្រុងហើយគិតថាបើមានលុយនិងរករៀនជំនាញកាត់ដេរ ហើយបើមានលុយគ្រប់គ្រាន់និងយកកូនពីបាត់ដំបងមកនៅជាមួយ។

ករណីសិក្សាទី២០

ខែសីហា-១៥-២០០៤

ស.ខ មានអាយុ២៦ឆ្នាំ សព្វថ្ងៃនាងជាកម្មករផ្នែកកាត់ដេរនៅរោងចក្រ **វីវីល** នៅខ័ណ្ឌដង្កោ រាជធានីភ្នំពេញ។ នាងមានស្រុកកំនើតនៅឃុំប៉ុងឬស្សី ស្រុកបាទី ខេត្តតាកែវ ។ នាងជាកូនទី៦នៅក្នុងគ្រួសារមួយក្នុងចំណោមបងប្អូន៨នាក់ ប៉ុន្តែបងប្អូនរបស់នាងបានរៀបការអស់៦នាក់ហើយ នៅសល់តែរូបនាងនិងប្អូនពៅប៉ុណ្ណោះ ដែលមិនទាន់រៀបការ។ គ្រួសារ របស់នាងមានដីស្រែបន្តិចបន្តួចដែល សំរាប់ធ្វើស្រែ ប៉ុន្តែផលស្រូវដែលបានមក គឺមិនគ្រប់គ្រាន់ឡើយសំរាប់ផ្គត់ផ្គង់គ្រួសារនោះទេ។ នាងបានឈប់រៀនត្រឹមថ្នាក់ទី៤ ពីព្រោះតែគ្រួសាររបស់នាងគ្មានលទ្ធភាពផ្គត់ផ្គង់ការសិក្សាឱ្យនាងរៀនបន្តទៀត។ ឪពុកម្តាយរបស់នាងបានឈ្លោះប្រកែកគ្នាជារៀងរាលខ្ទុំថ្ងៃក៏ ព្រោះតែពួកគាត់ទាំងពីរស្រវឹងស្រា ឪពុកស្រវឹងទឹកត្នោតជូរ ហើយម្តាយស្រវឹងសុរា។

> រយៈពេល៦ឆ្នាំក្រោយមកនេះ គ្មានយប់ណាមួយដែលខ្ញុំមិនយំ មិនគិតដល់គ្រួសារនោះទេ ខ្ញុំមិនដែលទទួលបាននូវភាពកក់ក្តៅម្តងណាឡើយ រឿងទាំងនេះកើតមានចំពោះក្រុមគ្រួសាររបស់ខ្ញុំចាប់តាំងពីម្តាយរបស់ខ្ញុំគាត់ចាប់ផ្តើម ញៀនស្រាមកម្ល៉េះ ហើយវាជាហេតុមួយដែលធ្វើអោយគាត់លែងគ្រប់គ្រងអារម្មណ៍គាត់បាន។

ម្តាយរបស់នាងគិតតែពីផឹកស្រាតែម្យ៉ាងគត់ បាយទឹកក៏គាត់លែងឃ្លាន តែមិនយូរប៉ុន្មានរូបគាត់ក៏បានធ្លាក់ខ្លួនឈឺជាទំងន់។ ស.ន និងបងប្អូន បានយកម្តាយទៅអោយគ្រូខ្មែរព្យាបាល ជាដំបូងពួកនាងអោយ៣០,០០០រៀលទៅគ្រូខ្មែរនោះសំរាប់ការពិនិត្យ ហើយនិងលុយ៣០,០០០ទៀតសំរាប់ថ្នាំមួយឆ្នាំងទៀត។ ម្តាយរបស់នាងហូបអស់៦ឆ្នាំងទើបបានជាសះស្បើយ ហើយលុយដែលបានមកសំរាប់ព្យាបាលជំងឺនោះគឺបងប្អូននាងបានលក់គោមួយក្បាល ប៉ុន្តែនៅពេលដែលគាត់បានជាហើយនោះ គាត់បានទៅហូបស្រាវិញដដែរ។

មានម្តងមួយនោះនាងបានលុតជង្គងសុំអង្វរម្តាយ ដើម្បីឱ្យគាត់ឈប់ហូបស្រាតទៅទៀត តែម្តាយរបស់នាងវិញមិនបានស្តាប់ និងមិនអាណិតដល់ពួកនាងនោះទេ។ មិនយូរប៉ុន្មានពុករបស់នាងក៏បានក្លាយខ្លួនជាមនុស្សវិកលចរិតទៀត។ រឿងហេតុទាំងអស់នេះហើយដែលបណ្តាលអោយនាងសំរេចចិត្តមករកការងារធ្វើនៅភ្នំពេញជាកម្មកររោងចក្រកាត់ដេរ។ ស.ន បានមករកការងារធ្វើជាមួយមិត្តភក្តិរបស់នាងនៅក្នុងភូមិ នាងក៏បានធ្វើតេស្តជាប់នៅរោងចក្រវីវីល។ នាងបានគិតថា ទោះបីការងារនោះលំបាកយ៉ាងណាក៏ដោយក៏រូបនាងត្រូវតែខិតខំតស៊ូ អត់ធ្មត់ ប្រឹងប្រែង ដើម្បីក្រុមគ្រួសារនៅឯភូមិស្រុក។ ធ្វើការនៅរោងចក្រនោះមិនយូរប៉ុន្មាននាងក៏បានក្លាយជាកម្មករពេញសិទ្ធិជាមួយនឹងប្រាក់ខែគោល ៤៥ដុល្លាបូកបន្ថែមនិងប្រាក់លើកទឹក៥ដុល្លាទៀត ហើយប្រសិនបើជានាងធ្វើការថែមម៉ោងទៀតនោះ នាងប្រហែលជាបានទទួលប្រាក់សរុបទាំងអស់ ៦០ ទៅ ៧០ដុល្លា។ ខាងរោងចក្រដាក់កំនត់ថា បើសិនជាកម្មករណាម្នាក់មានជំងឺ រឺសុំច្បាប់នោះលុយលើកទឹកចិត្តដែលត្រូវបាន៥ដុល្លាក្នុងមួយខែនោះនិងត្រូវកាត់ ហើយបូកទាំងប្រាក់ខែប្រចាំថ្ងៃទៀតផង។ ប្រាក់ខែដែលបានបើកមកនោះត្រូវចំណាយទៅវិញតែមួយភ្លែតប៉ុណ្ណោះ ហើយខែខ្លះវិញនោះនាងត្រូវទៅខ្ចីលុយគេចាយទៀតផង

បន្ទប់ដែលនាងស្នាក់នៅនោះប្រហែលជា២,៥ម៉ែត្រ បួនជ្រុង ជាបន្ទប់មួយតូចចង្អៀត មានកំដៅក្តៅខ្លាំង ហើយពិបាកដេកខ្លាំងណាស់ អ្នកដែលស្នាក់នៅក្នុងបន្ទប់នោះមានគ្នា៤នាក់ តំលៃ២០ដុល្លាក្នុងមួយខែ។ ដោយសារតែបន្ទប់នោះតូចពេកជាហេតុធ្វើអោយនាងឧស្សាហ៍ស្ទះខ្យល់ណាស់។

ក្រៅពីឧស្សាហ៍ស្ទះខ្យល់ ខ្ញុំមានជំងឺធ្លាក់ស និងលើសឈាមទៀតផង។ ខ្ញុំមិនដឹងជាអាចទ្រាំទ្រជាមួយការងារ នៅក្នុងរោងចក្រនោះដល់ពេលណានោះទេ។ ហើយប្រសិនជាខ្ញុំមិនខិតខំធ្វើការនោះវិញ មិនដឹងជាក្រុមគ្រួសាររបស់ខ្ញុំនឹង ទៅជាយ៉ាងណានោះទេ។ នៅពេលដែលខ្ញុំទៅលែងផ្ទះម្តងៗ ខ្ញុំមានការពិបាកចិត្តយ៉ាងខ្លាំង និងមិនចង់មើលឃើញស្ថានភាពដែលធ្វើអោយខ្ញុំឈឺចាប់នោះទេ។ ចាប់តាំងពីបានធ្វើការនៅរោងចក្រ **វៃវៃល** មកមិនដែលហ៊ានចេញដើរទៅណាមកណានោះទេក្រៅពីធ្វើការ ទោះបីជាថ្ងៃសំរាកក៏ដោយនាងសុខចិត្តសំងំនៅតែក្នុងបន្ទប់។ នាងគិតឃើញថាបើសិនជានាងដើរចេញទៅក្រៅនោះគឺត្រូវចំណាយលុយ ហើយរូបនាងមិនដែលហ៊ានទិញចំនីអាហារឆ្ងាញ់សំរាប់បរិភោគនោះទេ សូម្បីតែល្បៀកបំពាក់ក៏អញ្ចឹងដែរ។ ទាំងនេះក៏ដោយសារតែនាងត្រូវចេះសន្សំសំចៃដើម្បីជួយដល់ក្រុមគ្រួសារនៅឯផ្ទះ។

ធ្វើការជាយូរឆ្នាំមកហើយនាងមិនដែលបានលឺពីការបញ្ចប់កូតានៅចុងឆ្នាំ២០០៤ នោះទេ តែបានត្រឹមលឺសូរខ្លះៗពិមិត្តភក្តិថារោងចក្រនិងត្រូវបិទទ្វារ។ នាងមានការព្រួយបារម្ភជាខ្លាំងព្រោះតែខ្លាចក្រែងមិនមានការងារធ្វើ ហើយបានគិតក្នុងចិត្តថាប្រសិនជាត្រឡប់ទៅផ្ទះវិញនោះក៏មិនមានការងារធ្វើនោះដែរ ព្រោះស្រុករបស់នាងភាគច្រើនត្រូវប្រឈមមុខនឹងគ្រោះរាំងរីងស្ងួត ហើយឥឡូវនេះការធ្វើស្រែត្រូវដាក់ជីទើបបានផល។ ម្យ៉ាងវិញទៀតរូបនាងក៏មានជំងឺ ហើយពុកម៉ែនៅស្រុកក៏សុទ្ធតែមានជំងឺទៀត តើអោយនាងសង្ឃឹមអ្វីទៅ?

> នៅពេលដែលខ្ញុំគិតដល់បញ្ហាក្នុងជីវិតក្រុមគ្រួសារម្តងៗនោះ ខ្ញុំមិនចង់មានជីវិតរស់នៅលើលោកនេះឡើយ។ ខ្ញុំចង់តែស្លាប់អោយផុតទៅទេ ដើម្បីអោយរឿងរ៉ាវទាំងប៉ុន្មានត្រូវបញ្ចប់ទៅដែរ។

មិត្តភក្តិខ្លះបានដឹងពីរឿងជីវិតរបស់នាង ហើយពួកគេបានលោងលោមថា កុំគិតខ្លីអោយសោះ មិនមែនមានតែរូបនាងទេដែលមានបញ្ហានៅក្នុងជីវិត និងក្រុមគ្រួសារ មានមិត្តភក្តិយើងជាច្រើននាក់ទៀតក៏មិនខុសពីនាងប៉ុន្មានដែរ ត្រូវតែរឹងប៉ឹងឡើង មានតែខ្លួនយើងទេទើបអាចជួយខ្លួនយើងបាន។ នាងនិយាយថាខ្ញុំមិនដឹងជាទៅជាយ៉ាងណានោះទេប្រសិនជាខ្ញុំធ្លាក់ខ្លួនឈឺវិញនោះព្រោះខ្ញុំមិនដែលមានលុយកាក់ច្រើននៅជាប់និងខ្លួននោះទេ។

ករណីសិក្សាទី ២១
តំបន់ទួលសង្កែ
ខែវិច្ឆិកា ២០០៥

ស.ន មានអាយុ២២ឆ្នាំ រស់នៅស្រុកកំពុងក្តី ខេត្តសៀមរាប។ មានបងប្អូន៤នាក់ ស្រី៣ ប្រុស១នាក់ នាងជាកូនច្បង ក្នុងគ្រួសារ រៀនបានត្រឹមថ្នាក់ទី៥។ ឪពុកម្តាយរបស់នាងជាកសិករ មានដីស្រែមួយហិតតា ហើយប៉ុន្មានឆ្នាំមកនេះការធ្វើស្រែមិនសូវបានផលនោះទេ ព្រោះអីការធ្វើស្រែនេះត្រូវចំណាយលុយជាច្រើន ជាពិសេសទៅលើជី ដាក់ស្រែ ដែលជីទាំងនោះកាលពីនេះគឺតំលៃត្រឹមតែ៦០,០០០រៀលនោះទេ ប៉ុន្តែវាបានឡើងថ្លៃដល់ទៅ ៧០,០០០រៀលក្នុងមួយបាវ ហើយត្រូវចំណាយអស់ប្រហែលជា៣០០,០០០ រៀល។ នៅពេលដែលក្រុមគ្រួសារមានបញ្ហាប្រឈមមុខនិងភាពខ្វះខាត ហើយម្យ៉ាងវិញទៀតឪពុករបស់នាងបានបំផ្លិចបំផ្លាញទ្រព្យសម្បត្តិជាច្រើននៅក្នុងផ្ទះ ដោយសារតែគាត់ទៅធ្វើការនៅជាកម្មករនេសាទ ត្រីនៅប្រទេសថៃ ហើយភាគច្រើនដែលគាត់ទៅគឺមានបញ្ហា ពេលខ្លះរហូតដល់ជាប់គុកក៏មាន ហើយម្តាយ របស់នាងបានលក់ដីស្រែយក លុយទៅលួសគាត់មកវិញ រាល់លើកដែលគាត់ទៅគឺមិនបានប្រាក់កំលៃមកផ្ទះវិញទេ ពួកគាត់ទាំងពីរឧស្សាហ៍ឈ្លោះទាស់គ្នាណាស់សឹងតែរាល់ថ្ងៃ ដោយសារតែឪពុករបស់នាងផឹកស្រាស្រវឹង ដូច្នេះនាងបានសំរេចចិត្តមកធ្វើការជាកម្មកររោងចក្រនៅភ្នំពេញ "ឪពុកម្តាយខ្ញុំមិនចង់អោយ ខ្ញុំមករកការងារធ្វើនោះទេ " ។ នាងបានធ្វើតេស្តជាប់នៅរោងចក្រ **តេវេតិច** ផ្នែកកាត់ព្រុយ ហើយនៅទីនោះនាងបានជួបមិត្តភ័ក្ត្រ ដែលនៅភូមិស្រុកជាមួយនាង។ នាងធ្វើការនៅរោងចក្រនេះប្រហែលជាជិតមួយឆ្នាំ ហើយក៏ឈប់ធ្វើការទៅ ។

នៅក្នុងរោងចក្រមានលក្ខខណ្ឌការងារតឹងរឹងណាស់ បង្ខំកម្មករថែមម៉ោង ហើយពិបាកសុំច្បាប់ ដេរមានចំនួនកំនត់ខ្ពស់ បើមិនខំប្រឹងដេរអោយគ្រប់កូតាដែលកំនត់ទេនោះ និងត្រូវហៅទៅព្រមាន រឺផ្តិតមេដៃមួយជាមិនខាន។ នាងគិតថា " នាងធ្វើការក្នុងមួយថ្ងៃស្ទើរតែខ្សោះខ្លួនអស់ទៅហើយ " ។ នៅក្នុងរោងចក្រនេះមានសហជីព៧២ ប៉ុន្តែមិនដែលបានជួយកម្មករនោះទេ។ ជារៀងរាល់ខែនាងទទួលបានប្រាក់ឈ្នួលពី ៥០ ទៅ ៦០ដុល្លា ហើយលុយនោះត្រូវបានបែងចែកផ្ញើទៅផ្ទះនៅឯភូមិប្រហែលជា ១៥ ទៅ ២០ដុល្លា ជារៀងរាល់ខែសំរាប់ជួយដល់ការចំណាយផ្សេងៗ និងជាពិសេសសំរាប់ការសិក្សារបស់ប្អូនៗ និងពេលមានបុណ្យទានផ្សេងៗ។ ចំណែកលុយដែលនៅសល់នោះគឺសំរាប់ចំណាយទៅលើថ្លៃទឹក ភ្លើង ម្ហូបអាហារប្រចាំថ្ងៃ និងរបស់របរប្រើប្រាស់ផ្សេងៗ ប៉ុន្តែនៅពេលដែលធ្លាក់ខ្លួនឈឺវិញនោះត្រូវខ្ចីលុយពីមិត្តភ័ក្ត្រ រឺក៏ចង់ការពីអ្នកដ៏ទៃ ក្នុង៥ដុល្លាការ១ដុល្លា ហើយត្រូវសងវិញពេលដែលបើកប្រាក់ឈ្នួល។ ហេតុផលដែលឈប់ពីរោងចក្រតេវេតិច ដោយសារតែរោងចក្រអត់សូវមានការងារអោយធ្វើ ក្នុងមួយអាទិត្យធ្វើការបាន ៣-៤ថ្ងៃប៉ុណ្ណោះ នៅពេលដែលមិនសូវមានការងារធ្វើដូចនេះហើយនាងក៏ឈប់ធ្វើការ ហើយទទួលបានប្រាក់ខែត្រឹមតែ៥០ដុល្លា។ ពេលនោះនាងក៏ត្រឡប់មកផ្ទះវិញសិន ពេលនៅបានមួយរយៈហើយនោះប្រហែលជាមួយខែ នាងបានទៅស៊ីឈ្នួលបំរើតាមផ្ទះគេម្តង ដោយក្នុងមួយខែ នាងបានប្រាក់ខែត្រឹមតែ ៥០,០០០ប៉ុណ្ណោះ នាងជាអ្នកធ្វើម្ហូបម្ចាស់ផ្ទះស្រួល និងចិត្តល្អ តែនាងគិត

ថាប្រាក់ខែដែលបានមកតិចតួចណាស់ ហើយម្យ៉ាងទៀតនាងត្រូវត្រឡប់មកផ្ទះវិញដើម្បីជួយច្រូតម៉ែ ដូច្នេះក៏ឈប់ធ្វើការនោះទៅ។

ឥឡូវនេះនាងបានត្រឡប់មកធ្វើការជាកម្មកររោងចក្រម្តងទៀតហើយ ប៉ុន្តែអត់ទាន់រកបានធ្វើនោះទេ " ខ្ញុំដឹងថាការងារនៅផ្ទះមានការងារស្រួលជាងការធ្វើការនៅក្នុងរោងចក្រប៉ុណ្ណោអ្វីដែលសំខាន់នោះគឺថា ដើម្បីជួយដលគ្រួសារនោះ ទោះជាលំបាកយ៉ាងណាក៏សុខចិត្តទ្រាំដែរ " ។ នាងនៅជាមួយបងប្អូននៅភូមិក្នុងបន្ទប់មួយ៥នាក់ ហើយពួកគេមិនបានអោយនាងចេញលុយនោះទំរាំតែនាងអាចរកការងារបានធ្វើ។ នាងគិតថាបើនាងរកការងារមិនបានធ្វើទេនោះ និងត្រូវត្រឡប់ទៅផ្ទះវិញហើយដើម្បីរកមុខរបរផ្សេងទៀតធ្វើ ។ បទពិសោធន៍ដែលឪពុកនាងមានជាគំរូដល់ល្អមួយដល់រូបនាងក្នុងការមិនសំរេចចិត្តទៅធ្វើការជាកម្មករកាត់ដេរនៅប្រទេសម៉ាលេស៊ី " ខ្ញុំមិនទៅនោះទេព្រោះខ្លាចគេបោកប្រាស់យកទៅលក់ "។

## ករណីសិក្សាទី ២២

## ខែកុម្ភៈ ២០០៥

ខ្ញុំឈ្មោះ ស,ភ អាយុ២៩ឆ្នាំ រស់នៅភូមិតាំងក្រូច ឃុំសានគរ ស្រុកកំពង់សា្វយ ខេត្តកំពុងធំ។ មានបងប្អូន៤នាក់ ប្រុស២,ស្រី២នាក់ ខ្ញុំជាកូនច្បង រៀនបានត្រឹមថ្នាក់ទី៤ ហើយត្រូវបានឈប់រៀនដោយសារតែអត់មានអ្នកណាជួយមើលប្អូនៗ ហើយម្តាយមានផ្ទៃពោះចិត្តឆ្លងទន្លេ ចំណែកឯឪពុកខ្ញុំវិញគាត់ពិការជើងម្ខាង ដោយសារតែជាន់មីនព្រោះគាត់ជាទាហាន ហេតុដូចនេះហើយខ្ញុំត្រូវឈប់រៀនដើម្បីជួយមើលប្អូនៗ និងជួយធ្វើស្រែចំការខ្លះ។ ឪពុកម្តាយខ្ញុំពួកគាត់អត់មានដីស្រែទេ គ្រួសារខ្ញុំជួលដីស្រែគេដើម្បីបង្កបង្កើនផល ប្រសិនបើជួលដីធំគេយក៦ថាំងក្នុងមួយរដូវ គ្រួសារខ្ញុំមានដីចំការ១ហិតតាដែរសំរាប់ដាំឪឡឹក ហើយដីនេះបានមកពីការរាន ដីព្រៃ។ កាលខ្ញុំអាយុប្រហែលជា១២-១៣ឆ្នាំ ខ្ញុំបានទៅស្រែដើម្បីភ្ជួរដី ប៉ុន្តែពេលនោះខ្ញុំខំទប់នង្គ័ល ដែរតែទប់អត់សូវជាប់ប៉ុន្មាននោះទេ ហើយនៅពេលខ្លះគោវាអត់ព្រមដើរទៅមុខទេ ខ្ញុំបានខំព្យាយាមអោយវា ដើរទៅមុខនៅពេលដែលវាដើរទៅមុខខ្ញុំទប់នង្គ័លអត់ជាប់វាក៏របូតទៅមុតជើងរបស់គោ ហើយនៅពេលដែលខ្ញុំមកដល់ផ្ទះវិញឪពុករបស់ខ្ញុំគាត់បានស្តីបន្ទោសអោយខ្ញុំជាខ្លាំង។ ការធ្វើស្រែហូបមិនដែរបានគ្រប់គ្រាន់នោះទេ ។ បន្ទាប់មកខ្ញុំក៏បានដើរស៊ីឈ្នួលស្ទូងគេពីរនាក់បងប្អូនក្រែងអាចជួយគ្រួសារបានខ្លះ ក្នុងមួយថ្ងៃបានស្រូវ២តៅ តែបើយកលុយគឺម្នាក់បាន២០០០រៀល ។ លុយដែលបានមកក្រៅពីជួយដល់គ្រួសារខ្លះនោះខ្ញុំបានសន្សំវិញខ្លះ រហូត ដល់តែបាន២ម៉ឺនរៀលខ្ញុំក៏សំរេចចិត្តមករកការងារធ្វើនៅទីក្រុង។

នៅពេលដែលខ្ញុំមានអាយុបាន១៨ឆ្នាំ ខ្ញុំបានទៅស៊ីឈ្នួលនៅផ្ទះគេនៅជិតផ្សារអូរឬស្សី ម្ចាស់ផ្ទះបុរសជាអ្នកនេសាទ ហើយប្រពន្ធជាគ្រូពេទ្យ។ គ្រួសារនេះមានចរិតលក្ខណៈល្អ។ ក្នុងមួយឆ្នាំពួកគាត់ទិញខោអាវអោយខ្ញុំ២កំប្លេដែរ។ ខ្ញុំបានទទួលប្រាក់ឈ្នួលមួយខែ៣ម៉ឺនរៀល ហើយប្រាក់នោះខ្ញុំបានសន្សំទុកបាន២រឺ៣ខែទើបផ្ញើរលុយមកផ្ទះម្តង ប៉ុន្តែខ្ញុំនៅទីនោះមិនបានប៉ុន្មានឆ្នាំនោះទេ ខ្ញុំក៏ឈប់ធ្វើការហើយត្រឡប់មកផ្ទះវិញ។ នៅផ្ទះមិនបានមួយថ្ងៃផង ខ្ញុំក៏បានសុំឪពុកម្តាយខ្ញុំមកធ្វើការនៅរោងចក្រ ពួកគាត់មិនយល់ទាស់និងខ្ញុំនោះទេ។ ខ្ញុំមកភ្នំពេញម្តងទៀតនៅឆ្នាំ២០០០ ខ្ញុំបានដើរធ្វើតេស្តតាមរោងចក្រប្រហែលជា២ខែទើបអាចរកការងារ បានធ្វើខ្ញុំជាប់នៅរោងចក្រ **ញ៉ូអរវ៉េន** អាគារទី១៥កាណាឌីយ៉ា។ ក្រោយពីបានធ្វើការបាន២-៣ ថ្ងៃមក ខ្ញុំអត់មានលុយចាយនោះទេ ពេលចេញសំរាកអាហារថ្ងៃត្រង់ខ្ញុំក៏អង្គុយនៅមុខរោងចក្រ មានមិត្តភក្តិគេសួរខ្ញុំដែលថា អត់ញ៉ាំបាយទេរឺ? ខ្ញុំក៏ឆ្លើយតបថាខ្ញុំអត់ទាន់ឃ្លានទេ តែតាមពិតខ្ញុំឃ្លានណាស់ ចង់ហូបណាស់តែ ខ្ញុំអត់មានលុយមួយរយរៀលទេ។

ប្រាក់ខែជាកម្មករបណ្តែតដំបូងខ្ញុំបានត្រឹមតែ៣៥ដុល្លាប៉ុណ្ណោះ ការងារនេះខ្ញុំធ្វើបានជាងមួយឆ្នាំតែនៅ តែអត់ទាន់ពេញសិទ្ធិនៅឡើយ ហេតុដូចនេះក៏នាំគ្នាតវ៉ាទាមទារខាងរោងចក្រអោយកម្មករដែលធ្វើការយូរមក ហើយនោះក្លាយជាកម្មករពេញសិទ្ធ និងទាមទារប្រាក់៤៥ដុល្លាក្នុងមួយខែ។ ការតវ៉ានោះគ្មានសហជីពជាមេជាកើយនោះទេ គឺកម្មកររួមគ្នាតវ៉ាដោយខ្លួនឯង។ ក្នុងម៉ោងធ្វើការងារ គេអត់អោយនិយាយគ្នាលេង រឺយកនំទៅហូបក្នុងរោងចក្រឡើយ ប្រសិនបើយើង

ល្មើសហ៊ានយកចូលហើយគេឃើញនោះ គេនិងបញ្ជូនអោយទៅខាងរដ្ឋបាល ហើយខាងរដ្ឋបាលនឹងធ្វើការព្រមាន ដោយស្តីឱ្យរឺក៏ព្រមានដោយផ្តិតមេដៃ។ ប្រសិនបើខាងរោងចក្រគេប្រញាប់នាំចេញខោអាវនោះ គេមិនបានអនុញ្ញាតច្បាប់ឱ្យយើងនោះទេ ទោះបីជាច្បាប់ឈឺក៏ដោយ។ ប្រធានចិនពេលខ្លះក៏អោយច្បាប់ ហើយមានពេលខ្លះក៏មិនសុីញ៉េអោយ បើឈឺត្រូវគេទាររកសំបុត្រពីមន្ទីរពេទ្យយកមកបញ្ជាក់ ហើយទោះបីជាមានលិខិតស្នាមបញ្ជាក់រឺគ្មានក៏ដោយក៏ត្រូវកាត់លុយលើកទឹកចិត្ត៥ដុល្លា (លុយលើកទឹកចិត្ត) និងលុយប្រចាំថ្ងៃដែរ ។ តែក្រោយពេលបង្កើតសហជីពមក សហជីពអាចតវ៉ានិងជួយដោះស្រាយអោយកម្មករបានខ្លះដែរ ដូចជាពេលកម្មករមានសំបុត្រពេទ្យមកបញ្ជាក់ពីមូលហេតុឈឺនោះ មិនត្រូវបានគេកាត់លុយនោះទេ។ ពេលរោងចក្រតំរូវអោយថែមដល់ម៉ោង១២យប់ ហើយយើងមិនព្រមថែមម៉ោងទេនោះ ចិននឹងហៅទៅស្តីអោយហើយប្រមានម្តង ប្រសិនបើមានការព្រមានបីដង គឺត្រូវបណ្តេញចេញដោយស្វ័យប្រវត្តិ។ រោងចក្រនេះភាគច្រើនផលិតអោយម៉ាក **Adidas Banana Public, Berkerfex, Billabong** ។

ប៉ុន្មានខែមុន កម្មករត្រូវថែមម៉ោងរហូតទល់ភ្លឺ លុះស្អែកឡើងគេអោយសម្រាករយះពេលត្រឹមតែ៤ម៉ោងប៉ុណ្ណោះ ដល់ម៉ោង១២ថ្ងៃត្រង់ត្រូវចូលធ្វើការវិញ។ បើកម្មករធ្វើការមួយយប់ពេញរោងចក្រគិតលុយអោយ៤ដុល្លា គិតពីម៉ោង១០យប់រហូតដល់ម៉ោង៧ព្រឹក។ ជាធម្មតា កម្មករធ្វើការ ចេញនៅម៉ោង៨.៣០យប់។

កាលពីដំបូងខ្ញុំធ្វើការនៅផ្នែកកាត់ព្រុយ តែក្រោយមកគេផ្លាស់ខ្ញុំអោយទៅខាងវ៉ៃឡេវ រហូតមកដល់ពេលនេះ ខ្ញុំធ្វើការនៅផ្នែកនេះបានប្រហែល២ឆ្នាំហើយ។ ខ្ញុំធ្លាប់វ៉ៃត្រូវដៃម្តងដែរ កាលពី៣-៤ខែមុន រោងចក្របានអោយឈប់សំរាកព្យាបាលរបួសហើយចេញលុយថ្លៃព្យាបាល២០ដុល្លា។ ពេលនោះខ្ញុំអត់បានសម្រាកទេ ព្រោះអាណិតចិនអត់មាននរណាជួយវ៉ៃឡេវក៏មកធ្វើការវិញធម្មតា។ ចិននោះស្រួលណាស់ មិនដែលស្តីអោយខ្ញុំទេ ពេលថែមម៉ោងគាត់សួរខ្ញុំមុនថា ព្រមថែមម៉ោងរឺមិនព្រមថែមស្រេចតែចិត្តរបស់ខ្ញុំ។ ក្នុងមួយឆ្នាំខ្ញុំទៅលេងផ្ទះ២ដងដែរ ដោយទៅម្តងៗត្រូវចំណាយអស់ពី ២០-៣០ដុល្លារបស់ទិញអីវ៉ាន។ ក្រៅពីវ៉ៃឡេវត្រូវដៃទៅ ខ្ញុំមិនដែលមានជំងឺអ្វីទៀតទេ ហើយក៏មិនដែលទៅឱ្យគ្រូពេទ្យពិនិត្យដែរ។

បន្ទប់ដែលខ្ញុំជួលនៅកាលពីមុនពិបាកណាស់ ពេលចេញចូលមានគេយាម។ បើមានកាន់អីវ៉ាន់អី ត្រូវអ្នកយាមឆែកសួរដេញដោលសិនទើបអោយយកចូល បើចូលអត់អីទេតែបើចេញគេសួរច្រើនដូចជា អ្នកស្នាក់នៅបន្ទប់ណា? មានបង់លុយថ្លៃបន្ទប់ជួលហើយរឺនៅ ហើយប្រសិនបើមិនទាន់បង់លុយអោយគេទេនោះគេមិនអោយចេញទេ។ ហើយពេលបង់លុយឈប់ជួលបន្ទប់នោះត្រូវមានអ្នកធានាផ្តិតមេដៃទើបគេឱ្យចេញ។ មុនពេលដែលខ្ញុំរើចេញពីកន្លែងនោះ ខ្ញុំត្រូវបានគេឱ្យផ្តិតមេដៃចំនួនពីរដង ។

ក្នុងមួយខែខ្ញុំទុកលុយចាយតែ២០ដុល្លាប៉ុណ្ណោះ។ ជួនពេលខ្លះខ្ញុំចាយវាយមិនគ្រាន់នោះទេ ខ្ញុំត្រូវខ្ចីលុយកាក់ខ្លះពីមិត្តភក្តិ តែពួកគេអត់យកការប្រាក់ពីខ្ញុំទេ។ ជារៀងរាល់ខែខ្ញុំត្រូវផ្ញើលុយទៅផ្ទះប្រហែលជា៣០ដុល្លា សំរាប់អោយម៉ែគាត់ចាត់

ចែងការចាយវាយខ្លះនៅក្នុងផ្ទះ។ ខ្ញុំមិនដែលហ៊ានសួរគាត់ថា គាត់យកលុយនោះទៅចំណាយលើអ្វីខ្លះនោះទេ តែគាត់ប្រាប់ខ្ញុំខ្លះដែរថា លុយនោះយកទៅសងគេខ្លះនិងរឿងចាយវាយក្នុងផ្ទះខ្លះ។ ខ្ញុំគិតថាការងារធ្វើនៅផ្ទះត្បិតអីតែពិបាកមែន តែខ្ញុំមានសេរីភាព មានពុកម៉ែជួយមើលថែទាំ តែការងារនៅក្នុងរោងចក្រវិញគឺមានអារម្មណ៍ភ័យខ្លាច ពេលចេញពីធ្វើការ ហើយជាពិសេសនៅពេលយប់។ ខ្លាចមួយទៀតគឺបាត់បង់ការងារធ្វើនិងត្រូវចិនស្តីអោយ។ ខ្ញុំដឹងថាធ្វើការនៅក្នុងរោងចក្រធ្វើអោយសុខភាពទ្រុតទ្រោម។ ខ្ញុំចូលជាសមាជិកសហជីពស៊ីខៅឌូ ជាងមួយឆ្នាំហើយ គេអត់ដែលនាំទៅរៀនអីទេទាក់ទងនិងច្បាប់ការងារ។ ហើយលុយជាសមាជិកភាព នោះត្រូវកាត់ចេញពីប្រាក់ឈ្នួលជារៀងរាល់ខែ ហើយទោះជាចង់ដកខ្លួនក៏មិនដឹងជាធ្វើយ៉ាងណាទេ។

មានរឿងហេតុមួយបានកើតឡើងចំពោះខ្ញុំ ហើយវាជារឿងមួយដែលមិនអាចបំភ្លេចបាន មុនពេលកើតរឿងខ្ញុំមានអារម្មណ៍ភ័យខុសប្លែកពីធម្មតា យប់នោះថ្ងៃទី១១ ខែ០១ឆ្នាំ២០០៥ ម៉ោង៨.៣០ ពេលចេញពីថែមម៉ោងនៅរោងចក្រខ្ញុំភ័យណាសខ្ញុំមិនដឹងយ៉ាងម៉េចទេក្នុងខ្លួនខ្ញុំចេះតែភ័យ នៅពេលដែលខ្ញុំដើរដាច់ហ្វូងពីកម្មករដ៏ទៃទៀត ហើយបានដើរតាមផ្លូវដ៏សែនស្ងាត់តែ២នាក់បងប្អូន ពេលនោះមានមនុស្សប្រុស២នាក់ចេញមកស្កាត់ផ្លូវរបស់ខ្ញុំ ខ្ញុំឃើញសភាពការមិនល្អក៏នាំគ្នារត់ទាំង២នាក់បងប្អូន ពួកវាក៏រត់មកតាមខ្ញុំ ខ្ញុំគិតអីមិនឃើញទេ ប្រុសម្នាក់នោះបានចាប់ទាញយកខ្ញុំទៅ ហើយអាម្នាក់ទៀតវាចាប់ប្អូនជីដូនមួយរបស់ខ្ញុំខ្ទប់មាត់ហើយស្រវារកលុយ។ ពេលបានលុយខ្លះហើយ ប្អូនខ្ញុំវាក៏ប្រតាយប្រតប់វិញរួចក៏រួចខ្លួនហើយរត់ទៅបាត់ទៅ ហើយវាក៏ស្រែកអោយគេមកជួយខ្ញុំ.។ ប្រុសម្នាក់នោះបានវាយខ្ញុំមានដៃចំពោះខ្ញុំក៏សន្លប់បាត់ទៅ ខ្ញុំមិនបានដឹងរឿងហេតុបន្តទៀតយ៉ាងណានោះទេ តែក្រោយមកអ្នកជិតខាងបានមកជួយទាន់ពេលរួចក៏បានបញ្ជូនខ្ញុំទៅពេទ្យឯកជនមួយកន្លែង ខ្ញុំសម្រាកនៅក្នុងមន្ទីរអស់រយៈពេល៩ថ្ងៃ ហើយចំពោះការចំណាយព្យាបាលបានខាងរោងចក្រជាអ្នកចេញអោយទាំងអស់ ។ បន្ទាប់មកខាងសហជីពក៏ជួយដោះស្រាយនឹងដាក់ពាក្យបណ្តឹងទៅអាជ្ញាធរដែនដីនៅក្នុងតំបន់ បន្ទាប់ពីហេតុការណ៍នេះប៉ុន្មានថ្ងៃកន្លងផុតទៅ ប៉ូលីសក៏ចាប់បានជនសង្ស័យនៅថ្ងៃទី៣០-០១-២០០៥ បន្ទាប់មកប៉ូលីសនោះបានមកផ្តាំផ្ញើរនៅជិតផ្ទះជួលរបស់ខ្ញុំ ដោយអោយខ្ញុំទៅមើលមុខជនសង្ស័យទាំងនោះ។ ស្អែកឡើងខ្ញុំបានប្រញាប់ទៅជួបខាងសហជីព សហជីពបានប្រាប់ថាថ្ងៃបន្តិចគេនឹងជូនទៅមើល។ ប៉ុន្តែគ្មាននរណាជូនខ្ញុំទៅនោះទេ ស្អែកឡើងខ្ញុំបានទៅម្តងទៀត សហជីពក៏និយាយថាចាំគេទូរស័ព្ទទៅសហព័ន្ធសិន ក្រោយមកខ្ញុំរង់ចាំអស់ជាច្រើនថ្ងៃមិនមានដំណឹងអ្វីសោះ ខ្ញុំបានទៅសួរជាលើកចុងក្រោយគេបាននិយាយថាគេគ្មានពេលទេ គេរវល់ណាស់ បើខ្ញុំចង់ដាក់ពាក្យបណ្តឹងផ្សេងទៀតដោយខ្លួនឯងអាចដាក់បាន។ ខ្ញុំខឹងខ្លាំងណាស់សហជីពខ្លាំងណាស់ ហើយក៏ខឹងជនល្មើសខ្លាំងណាស់ដែរ ចិត្តរបស់ខ្ញុំចង់ប្តឹងអោយពួកវាទាំងនោះជាប់គុក និងសងជំងឺចិត្តដល់ខ្ញុំ ។ ខ្ញុំក៏បានទៅអង្គការអាដហុកអោយគេជួយដល់ខ្ញុំក្នុងការប្តឹងផ្តល់ គេបានចាត់បុគ្គលិក២នាក់អោយជួយដោះស្រាយក្នុងរឿងនេះ តែរហូតមកដល់ពេលនេះហើយនៅមិនទាន់មានតំរយអ្វីនៅឡើយទេ។

ករណីសិក្សាទី ២៣

ថ្ងៃទី ២០ មេសា ២០០៥

នាងខ្ញុំឈ្មោះ ផ.ស.រ មានអាយុ ២៤ឆ្នាំ។ គ្រួសារខ្ញុំរស់នៅភូមិអង្គរវាំង ឃុំបឹងត្រាចខាងជើង ខេត្តតាកែវ។ ខ្ញុំធ្វើការនៅរោងចក្រ **វីវែល** ស្ថិតនៅតាមបណ្តោយផ្លូវវែងស្រេង ក្នុងខ័ណ្ឌដង្កោរ។ ខ្ញុំមកធ្វើការជាកម្មកររោងចក្របាន ២ឆ្នាំហើយ។ ខ្ញុំបានចូលធ្វើការនៅរោងចក្របន្ទាប់ពីខ្ញុំបានរៀបការរួច ខ្ញុំមានបងប្អូន៦នាក់ ពួកគេនៅរៀននៅឡើយទេ។ គ្រួសាររបស់ខ្ញុំមានដីស្រែមួយហិចតា និងគោ ជ្រូក មាន់។ នៅស្រុករបស់ខ្ញុំគឺប្រើទឹកចេញពីអណ្តូង ហើយគ្មានអគ្គិសនីទេ។ ចំពោះម្ហូប យើងទៅទិញនៅផ្សារថ្នល់បត់។

នៅពេលមកធ្វើការដំបូងគឺពុកម៉ែរបស់ខ្ញុំជាអ្នកសំរេចចិត្តឱ្យមក មុននិងបានការងារធ្វើខ្ញុំត្រូវរង់ចាំអស់រយៈពេល ២ខែ ទើបអាចធ្វើតេស្តជាប់ ពេលនោះខ្ញុំមានអារម្មណ៏អរផងភ័យផងមិនដឹងជាបែកបទនៅក្នុងរោងចក្រវាយ៉ាងណានោះទេ ហើយម្យ៉ាងទៀតខ្ញុំមកទីក្រុងតែម្នាក់ឯង ហើយជាលើកដំបូងដែលខ្ញុំចេញឆ្ងាយពីផ្ទះផងដែរ។

នៅក្នុងរោងចក្រដែលខ្ញុំធ្វើការសព្វថ្ងៃគឺធ្លាប់មានភ្ញៀវចុះមកមើលដែរ តែខ្ញុំមិនបានដឹងថាគេមកពីណានោះទេ។ ក្នុងក្រុមរបស់ខ្ញុំមានកម្មករ ៤៨នាក់ ហើយខ្ញុំធ្វើផ្នែកជំនួយការ ។ នៅក្នុងរោងចក្រមានបន្ទប់ទឹក ៣៥ សំរាប់ប្រុស ១២ និងស្រី ២៣ ខ្ញុំគិតថាប្រើគ្រប់គ្រាន់។ ពេលមានបញ្ហានៅក្នុងរោងចក្រខ្ញុំតែងតែទៅប្រាប់តំណាងកម្មករ រឺសហជីព។ ខ្ញុំធ្លាប់ចូលរួមធ្វើបាតុកម្ម ហើយលទ្ធផលបានសំរេចខ្លះមិនបានសំរេចខ្លះ។ ពេលខ្លះខ្ញុំភ័យខ្លាចបាត់បង់ការងារណាស់ ព្រោះវាពិបាកក្នុងការស្វែងរកការងារធ្វើមែនទែនពេលនេះ ខ្ញុំមិនដែលធ្លាប់បានទទួលការ បណ្តុះបណ្តាលជំនាញអ្វីទេ ទាំងខាងសហជីព និងខាងថៅកែរោងចក្រ។

ខ្ញុំស្នាក់នៅក្នុងបន្ទប់ជួលមាន៤នាក់ ស្ថិតក្នុងភូមិព្រៃល្វា ហើយថ្លៃបន្ទប់២០ដុល្លា ហើយពួកខ្ញុំត្រូវចេញម្នាក់ ៥ដុល្លា។ តែថ្លៃទឹកមិនអស់លុយទេព្រោះម្ចាស់ផ្ទះជួលអោយប្រើទឹកអណ្តូង ថ្លៃភ្លើងគេយកមួយខែ២គីឡូ ប៉ុន្តែមានគេសំអាតបន្ទប់ឱ្យ ថែមទាំងអាចទទួលភ្ញៀវបានដោយសេរី។ នៅក្នុងបន្ទប់ជួលមានទូរទស្សន៏ ដែលម្ចាស់ផ្ទះដាក់អោយមើលទាំងអស់គ្នា។ ខ្ញុំត្រូវចំនាយពេលកន្លះម៉ោងក្នុងការធ្វើដំណើរពីផ្ទះជួលទៅរោងចក្រដោយ ជិះឡានឈ្នួលដាក់ខែ ក្នុងមួយខែត្រូវបង់អោយគេ៥ដុល្លា។ ខ្ញុំចំណាយ ១០ដុល្លាក្នុងមួយខែ សំរាប់ពិនិត្យសុខភាព និង ៥ដុល្លា សំរាប់ការដើរកំសាន្ត។ ក្រៅពីប្រាក់ខែ ខ្ញុំគ្មានចំណូលផ្សេងទៀតទេ។

ពេលព្រឹកខ្ញុំហូបបបរអស់ ៥០០រៀល នៅមុខរោងចក្រ និងពេលថ្ងៃក៏ហូបបាយនៅមុខរោងចក្រដែរ។ ឯពេលល្ងាចខ្ញុំចំណាយអស់ ១៥០០រៀលទិញម្ហូបធ្វើដោយខ្លួនឯង។ នៅថ្ងៃបុណ្យជាតិខាងរោងចក្រមិនបានបង្ខំអោយធ្វើការថែមម៉ោងនោះទេ គឺគេឱ្យឈប់សំរាក។ រាល់ថ្ងៃខ្ញុំសប្បាយចិត្ត ព្រោះខ្ញុំមានការងារធ្វើហើយមានលុយច្រើនជាងមុន។

នៅក្នុងរោងចក្រខ្ញុំមិនដែលដេរស៊ីបុងនោះទេ ហើយពេលថែមម៉ោងខ្ញុំទទួលបាន ១២០០រៀល ក្នុងមួយម៉ោង។ ប្រាក់ខែគោលរបស់ខ្ញុំ ៤៥ដុល្លា តែបូក ប្រាក់ថែមម៉ោង និងប្រាក់លើកទឹកចិត្ត បានប្រហែល ៦០ទៅ៦៥ដុល្លាក្នុងមួយខែ។ តាមពិតទៅ ខ្ញុំស្រលាញ់ការងារដោយប្រើកំលាំង ព្រោះវាជាញើសឈាមរបស់ខ្ញុំ។ មួយថ្ងៃខ្ញុំធ្វើការ ៨ទៅ១០ម៉ោង ព្រោះខ្ញុំត្រូវថែម២ម៉ោង ខ្ញុំចូលចិត្តធ្វើការថែមម៉ោង ព្រោះបានលុយច្រើនតែមានពេលសំរាកខ្លះដែរ។ រោងចក្រខ្ញុំធ្វើការតែមួយវេនទេ ព្រោះខ្ញុំមិនដែលដូរវេនទេ តែបើសិនជាដូរវេនមែននៅថ្ងៃមុនខ្ញុំចូលចិត្តធ្វើការវេនថ្ងៃជាង។

ខ្ញុំមិនសូវដឹងពីការឈប់សំរាកនោះទេ។ ច្បាប់ឈឺខ្ញុំដឹងខ្លះដែលគឺមានពី៣ថ្ងៃទៅមួយអាទិត្យ ហើយច្បាប់សំរាលកូន ៩០ថ្ងៃ ថែមទាំងគិតប្រាក់ឱ្យ ៥០ភាគរយ និងប្រាក់បន្ទាប់បន្សំ។ ខ្ញុំដឹងពីច្បាប់ឈប់ដែលទាក់ទងនឹងបញ្ហាគ្រួសារ ដូចជាស្លាប់ត្រូវបាន ៣ថ្ងៃ និងរៀបការមួយអាទិត្យ។ ខ្ញុំធ្លាប់គ្រុនពោះវៀនហើយទៅព្យាបាលនៅមន្ទីរពេទ្យ។ នៅក្នុងរោងចក្រមានពេទ្យដែរតែសេវាមិនសូវល្អនោះទេ។ ខ្ញុំមិនចូលចិត្តទៅពិនិត្យសុខភាពពេទ្យនៅក្នុងរោងចក្រទេ ព្រោះពេលឈឺអ្វីក៏បានថ្នាំហ្នឹង១ ដូចគ្នា។ សេវាព្យាបាលដែលល្អជាងគេគឺមានតែពេទ្យឯកជន។

ក្នុងមួយខែខ្ញុំផ្ញើរទៅផ្ទះ៣០ដុល្លា។ តែខ្ញុំមិនដែលបានសន្សំលុយទុកខ្លួនឯងទេ ព្រោះពុកម៉ែជាអ្នកគ្រប់គ្រងការចាយវាយក្នុងគ្រួសារ។ ហើយលុយដែលផ្ញើរទៅគាត់ចំណាយទៅលើការទិញម្ហូប ទិញជីដាក់ស្រែ ប្អូនទៅរៀន និងទិញម៉ាស៊ីនបូមទឹក និងទិញចំនីជ្រូកជាដើម។ ហើយតាំងពីខ្ញុំចូលធ្វើការរោងចក្រមកខ្ញុំអាចជួយដំគ្រួសារបានច្រើនមែនទែន។

ពេលមានបញ្ហាខ្ញុំទៅពិភាក្សាជាមួយមិត្តភក្តិ ហើយគេអាចជួយខ្ញុំបានខ្លះដែរ។ ខ្ញុំចូលជាសមាជិករបស់សហជីពបានមួយឆ្នាំ ពីព្រោះខ្ញុំគិតថាពេលមានបញ្ហាគេជាអ្នកជួយដោះស្រាយបញ្ហាអោយ។ ខ្ញុំមិនដឹងថាក្នុងរោងចក្រដែលខ្ញុំធ្វើការសព្វថ្ងៃមានសហជីពមានប៉ុន្មានទេ តែខ្ញុំចូលជាសមាជិកសហជីពសេរីកម្មករ។ ខ្ញុំមិនបានដឹងពីគោលបំនងរបស់សហជីពទេ ហើយខ្ញុំក៏មិនស្គាល់អ្នកគ្រប់គ្រងសហជីពដែរ។ ក្នុងមួយខែខ្ញុំចំណាយ ១០០០រៀលអោយជាសមាជិកភាព របស់សហជីព តែខ្ញុំមិនដឹងគេយកទៅធ្វើអីនោះទេ។

ករណីសិក្សាទី២៤

ថ្ងៃទី ២៥ មេសា ២០០៥

នាងខ្ញុំឈ្មោះ ជ រ ណា មានអាយុ ២៣ គ្រួសារខ្ញុំរស់នៅខេត្តកំពង់ចាម ខ្ញុំមានបងប្អូន ៣នាក់ (ប្រុស ២ និងស្រី១) ខ្ញុំជាកូនទី ៣។ ម៉ែខ្ញុំមានអាយុ ៥០ គាត់ជាកសិករ គ្រួសារខ្ញុំមានដី ១៣អា កាលពីមុនគ្រួសារខ្ញុំធ្វើស្រែដែល ប៉ុន្តែឥលូវនេះលែងធ្វើទៀតហើយ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី ៥ ហើយឈប់រៀន ដោយសារម៉ែឈឺមានជំងឺបេះដូង។ គាត់បានឱ្យខ្ញុំដើរលក់នំផ្លែអាយជំនួសគាត់ ហើយមួយថ្ងៃចំនេញបានប្រហែលជា ២០០០រៀល។ មួយថ្ងៃខ្ញុំទិញអង្ករ ១គីឡូ ១០០០ និងម្ហូប ១០០០រៀល តែខ្ញុំនៅតែជាមួយម៉ែប៉ុណ្ណោះ ព្រោះបងប្រុសនៅជាមួយពុក។ ខ្ញុំលក់បាន២ឆ្នាំ ក៏ប្តូរទៅលក់អំពៅសាង និងនំស៊ីយ តាមបេនឡានៅផ្សារព្រៃទទឹង ហើយមួយថ្ងៃ បាន៣០០០-៤០០០ រៀល។ ខ្ញុំលក់បាន២ឆ្នាំដែរ តែក្រោយមកលក់លែងដាច់ដោយសារតែមានអ្នកលក់កាន់តែច្រើនឡើងៗ ហើយក៏មិនសូវចំនេញ នោះទេដូចនេះ ក៏សំរេចចិត្តឈប់លក់តទៅទៀត។

ក្នុងកំឡុងឆ្នាំ១៩៩៧ ខ្ញុំបានសុំម៉ែមកនៅជាមួយគេ(ធ្វើការតាមផ្ទះ) ពេលនោះម៉ែគាត់ឥតមានជំទាស់ទេ ការងារដែល ខ្ញុំធ្វើនៅផ្ទះនោះមានដូចជាបោស សំអាតផ្ទះ បោកខេអាវ ខ្ញុំគិតថាវាអាចបានលុយកាក់ខ្លះសំរាប់ជួយម្តាយរបស់ខ្ញុំ ហើយ ក្នុងមួយខែបានប្រាក់ឈ្នួល ៥០០០០រៀល តែធ្វើបានមួយឆ្នាំប៉ុណ្ណោះក៏ត្រលប់មកផ្ទះវិញព្រោះម៉ែអត់សូវស្រួល ជំងឺរបស់ គាត់រើឡើងវិញ បន្ទាប់ពីខ្ញុំនៅមើលថែគាត់បានមួយរយៈប្រហែលជា២ខែក្រោយមកខ្ញុំក៏មករកការងារធ្វើនៅរោងចក្រ ជាមួយអ្នកភូមិ។ ខ្ញុំបានអោយលុយ៣០ដុល្លាទៅអ្នកនាំចូលធ្វើការ ហើយលុយនោះខ្ញុំបានខ្ចីបុលគេ៣០ដុល្លា ដោយមាន ការប្រាក់៣ដុល្លាក្នុងមួយខែ។ ប្រាក់ខែដំបូងរបស់ខ្ញុំបានត្រឹមតែ៣០ដុល្លាប៉ុណ្ណោះ ខ្ញុំត្រូវសងរំលោះទៅម្ចាស់បំណុល រហូតដល់៣ខែទើបសងគេរួច ហើយប្រាក់ខែដែលបើកមកខ្ញុំត្រូវផ្ញើរទៅអោយម៉ែក្នុងមួយខែ១០ដុល្លា និងសល់១០ដុល្លា ទុកបង់ថ្លៃផ្ទះ ៣ដុល្លា និង ៧ដល្លា ទុកទិញម្ហូប។ ពេលចូលធ្វើការដំបូងខ្ញុំចាយមិនគ្រប់ទេ បានទៅខ្ចីឯង្គរមិត្តភក្តិហូប ទំរាំដល់ថ្ងៃបើកប្រាក់ខែបានទើបសងបំណុលគេវិញខ្លះ។

រហូតមកដល់ពេលនេះខ្ញុំបានធ្វើការនៅរោងចក្រ **ម៉ៃទិស្តិចត្រា** បាន៥ឆ្នាំហើយ ក្នុងរយៈពេល២ឆ្នាំមុនដំបូងខ្ញុំបាន ក្លាយទៅជាប្រធានផ្នែកដេរ ហើយបានទទួលប្រាក់ខែ៦០ដុល្លា តែបូកទាំងថែមម៉ោងប្រហែល១០ថ្ងៃ រឺរាល់ថ្ងៃអាទិត្យ ពេញមួយខែបានប្រហែល ៧០-៨០ ដុល្លា ហើយបានផ្ញើរឱ្យទៅម៉ែនៅឯស្រុកប្រហែល ៤០-៥០ដុល្លាដែរ។

ខ្ញុំបានរៀបការនៅឆ្នាំ ២០០៣ ហើយប្តីខ្ញុំជាអ្នកធ្វើការនៅរោងចក្រជាមួយខ្ញុំ តែយើងបានស្គាល់គ្នាតាំងពីឆ្នាំ ២០០០ ហើយពួកយើងក៏បានសំរេចចិត្តរៀបការតែម្តងទៅ។ ខ្ញុំបានលឺពីរឿងកូតាធ្វើឱ្យខ្ញុំព្រួយបារម្ភខ្លាំងណាស់ តែខ្ញុំអត់គិតថា រោងចក្រនិងត្រូវបិទទ្វារនោះទេ។ ហើយទាល់ដល់ពេលបិទទ្វារអញ្ចឹងទើបខ្ញុំដឹងថាវាពិបាកយ៉ាងណា ឥឡូវនេះខ្ញុំពិបាក ចិត្តណាស់ ព្រោះយើងជាអ្នកទទួលរងចិញ្ចឹមម៉ែពុកទាំងសងខាង។ មុននឹងបិទទ្វារខាងរោងចក្រឱ្យកម្មករសាញ៉េបុងក្នុង

មួយអាទិត្យម្តងតាំងពីខែធ្នូមកម្ល៉េះ ហើយគេឱ្យប្រាក់ខែតែ៥០ភាគរយប៉ុណ្ណោះអស់រយៈពេល២ខែ បន្ទាប់មកគេប្រកាសថារោងចក្រត្រូវព្យួរការងារ២ខែ។ ហើយខាងក្រសួងសង្គមកិច្ចនិយាយថាឱ្យរោងចក្រផ្អាកបាន២ខែដែរ ហើយចាំមើលបើមានគេមកកុម្ម៉ង់ទើបបន្តដំនើរការឡើងវិញ តែនៅថ្ងៃទី១៨ គេប្រាប់ខ្ញុំថានឹងមានការប្រជុំមួយនៅរោងចក្រ ពេលខ្ញុំមកប្រជុំនាយកក្រុមហ៊ុនថារោងចក្រក្ស័យធន មិនអាចដំណើរការបានទៀតទេ ដូចនេះសុំរំសាយកម្មករទាំងអស់ពីរោងចក្រ។ ហើយគេបានគិតប្រាក់ឱ្យកម្មករ ទៅតាមឆ្នាំ អ្នកដែលធ្វើការ : ចាប់ពី ៦ខែ ទៅ ២ឆ្នាំ បាន ៤៥ដុល្លា គុណនឹង ១,៥ ។ ហើយចាប់ពី ២ឆ្នាំ ទៅ ៤ឆ្នាំ បាន ៤៥ដុល្លា គុណនឹង ១,៧ ។ ចាប់ពី ៤ឆ្នាំ ទៅដល់ ៦ឆ្នាំ បាន ៤៥ដុល្លា គុណនឹង ២ និងចាប់ពី ៦ឆ្នាំ ទៅដល់ ១០ឆ្នាំ បាន ៤៥ដុល្លា គុណនឹង ២,៥។ ហើយខ្ញុំទទួលបាន ៧០ដុល្លា គុណនឹង ២ ហើយបូកនឹងប្រាក់ឧបត្ថម ៧០ដុល្លា ដល់ប្រធានក្រុម ដូចនេះ ខ្ញុំទទួលបាន ២១០ដុល្លា។

នៅក្នុងរោងចក្រមានសហជីព៣ គឺវាំយនភ័ណ្ឌកាត់ដេរ CCAWDO, FTU។ តែអត់មានសហជីពណាជួយទាមទារឱ្យកម្មករទេ។ ឥលូវនេះខ្ញុំកំពុងដើររកការងារធ្វើបន្ត ខ្ញុំអត់បានត្រឡប់ទៅផ្ទះវិញទេ ព្រោះបើទៅផ្ទះគឺពិបាកដោយសារតែអ្នកផ្ទះរំពឹងមកលើខ្ញុំ ហើយម្យ៉ាងទៀតបងប្រុស២នាក់រៀបការអស់ហើយ ពួកគាត់នៅជាមួយប្រពន្ធរបស់គាត់ ហើយបានជូនលុយកាក់ម៉ែម្តងម្កាលដែរ តែអោយនៅពេលដែលមានបុណ្យទានតែប៉ុណ្ណោះ។

ករណីសិក្សាទី ២៥

តំបន់ទួលសង្កែ

ថ្ងៃទី ១៧ មេសា ២០០៥

នាងខ្ញុំឈ្មោះ ស ណា មានអាយុ ២០។ គ្រួសារខ្ញុំរស់នៅភូមិជ្រោយ ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ខ្ញុំរៀនបានត្រឹមថ្នាក់ទី៦។ ខ្ញុំមានបងប្អូន៣នាក់ (ប្រុស ២ ស្រី១) តែបងប្រុសទីមួយគាត់រៀបការបែកចេញពីគ្រួសារហើយ។ ម៉ែខ្ញុំជាស្រីមេម៉ាយ ដោយសារតែឪពុករបស់ខ្ញុំបានចុះចោលផ្ទះតាំងពីម៉ែរបស់ខ្ញុំមានកូនក្នុងពោះបាន៣ខែម្លេះ។ កាលពីមុនគ្រួសារខ្ញុំមានដីស្រែដែលតែពេលពួកខ្ញុំឈឺ គាត់ខ្ចីលុយគេដើម្បីយកលុយមកមើលជំងឺ ហើយម៉ែគ្មានលុយសងគេ គាត់ក៏សំរេចចិត្តលក់ដីស្រែ ដីផ្ទះ ដើម្បីសងគេនិងសងថ្លៃថ្នាំពេទ្យផងដែរ។ ពេលនោះគ្រួសារខ្ញុំគ្មានដីសំរាប់នៅទៀតទេ គ្រួសារខ្ញុំត្រូវបានទៅនៅជាមួយបងប្អូនខាងម៉ែ យាយនិងម៉ែខ្ញុំបានទៅស៊ីឈ្នួលគេបានមួយថ្ងៃ៥០០០រៀល ទុកសំរាប់ទិញអង្ករ ម្ហូប និងថ្លៃសាលា របស់ពួកខ្ញុំរៀន។ ពេលនេះម៉ែបានសន្សំសងគេខ្លះ និងនៅជំពាក់គេខ្លះទៀតប្រហែលជា ៤០០០០រៀល។ ម៉ែធ្លាប់ខ្ចីលុយពីអង្គការដែរ តែខ្ញុំអត់ដឹងអង្គការអីទេ។ ពីមុនម៉ែចិញ្ចឹមសត្វដែរតែអត់ត្រូវកាក់កក់ទេក៏ឈប់ចិញ្ចឹមទៅ។

ក្រោយមកដោយសារតែឃើញម៉ែពិបាកពេក ខ្ញុំក៏សំរេចចិត្តឈប់រៀនដើម្បីរកការងារធ្វើនៅទីក្រុង ហើយខ្ញុំមកការងារធ្វើជាមួយបងប្អូនជីដូនមួយ គាត់បានជួយអោយខ្ញុំបានធ្វើការនៅរោងចក្រជាមួយគាត់ គាត់មិនបានយកលុយខ្ញុំនោះទេ ប៉ុណ្ណែះមុននិងចូលធ្វើការរោងចក្រគេតំរូវអោយពិនិត្យសុខភាព ខ្ញុំក៏ចំណាយលុយអស់ប្រហែល១ម៉ឺនរៀលជាង។ ខ្ញុំបានចូលធ្វើការនៅរោងចក្រដេរស្បែកជើង **ម៉ែកណេតហ្វិតវេរ** ហើយខ្ញុំធ្វើការនៅទីបាន៤ឆ្នាំមកហើយ។ រោងចក្រនេះចូលនៅម៉ោង៧ព្រឹក ចេញនៅម៉ោង១២ និងចូលម៉ោង១ ចេញនៅម៉ោង៤ ហើយខ្ញុំបានលុយបាយ ៦០០០រៀល ដែលក្នុងមួយខែ ហើយប្រាក់ខែគោល ៤៥ដុល្លា គិតក្នុងមួយខែសរុបបានប្រហែល ៧០ដុល្លា។

ពេលខ្លះខ្ញុំត្រូវធ្វើការថែមដល់ម៉ោង ១០យប់ ហើយពេលឈឺក្បាលរឺចុកពោះគេមិនឱ្យឈប់ទេ គឺគ្រាន់តែឱ្យថ្នាំលេបរួចហើយសំរាកមួយភ្លែតក៏ត្រូវចូលធ្វើការវិញ ទោះពេលខ្លះខ្ញុំធុញនិងការងារ ឬនឿយហត់ខ្លះក៏ដោយ ក៏ខ្ញុំនៅតែសប្បាយចិត្តព្រោះខ្ញុំអាចមានការងារធ្វើដូចគេឯង ហើយម្យ៉ាងវិញទៀតរោងចក្រដែលខ្ញុំធ្វើការនោះក៏ស្រួលទៀត ដោយខ្ញុំមិនចាំបាច់ចេញទៅរកបាយនៅខាងក្រៅរោងចក្រហូបទេ គឺខាងរោងចក្រមានកង់ទីនសំរាប់លក់ហូប អាហារអោយកម្មករគ្រប់គ្នា ហើយខ្ញុំបានហូបបាយនៅទីនោះជារៀងរាល់ខែ ក្នុងមួយខែគេយក១១ដុល្លា។ ថៅកែរោងចក្របានធ្វើផ្ទះឱ្យនៅដូចនេះខ្ញុំមិនចាំបាច់ចំណាយក្នុងការជួលផ្ទះនោះទេ។ ពេលដំបូងឡើយដែលមានការងារក្នុង រោងចក្រនេះខ្ញុំផ្ទះជួលនៅតែក្រោយមកខ្ញុំបានសុំរោងចក្រម្តងជាពីរដង ទើបគេអនុញ្ញាតអោយខ្ញុំទៅនៅផ្ទះដែលគេផ្តល់អោយនោះ។ មួយខែខ្ញុំចំណាយអស់២៥ដុល្លា ខ្ញុំមិនសូវហ៊ានដកប្រាក់ខែចាយទេព្រោះខ្ញុំត្រូវសន្សំដើម្បីផ្ញើរទៅផ្ទះ ហើយក្នុងមួយខែផ្ញើរទៅផ្ទះប្រហែល ៤០-៥០ដុល្លាអោយទៅម៉ែ ហើយគាត់បានយកលុយនោះទៅទិញអង្ករ ម្ហូប និងឱ្យលុយប្អូនទៅរៀន ប៉ុន្តែម៉ែនៅ

ឱ្យផ្ទះគាត់បានធ្វើនំលក់ខ្លះដែរ មួយថ្ងៃបានប្រហែល៧០០០-៨០០០រៀល ហើយលុយចំណេញខ្លះពីលក់នំគាត់បានសន្សំ ហើយឥឡូវនេះគាត់បានទិញដីភូមិដីចំការ និងឈើសំរាប់ធ្វើផ្ទះបានខ្លះៗដែរ ។

នៅក្នុងរោងចក្រនេះគេកាក់លុយមួយថ្ងៃ៧ដុល្លា លុយលើកទឹកចិត្ត(លុយព្រឹម)៥ដុល្លា និងលុយឈ្នួលប្រចាំថ្ងៃ២ដុល្លា ចំពោះកម្មករណាដែលសុំច្បាប់ឈឺ រឺចង់សំរាក តែគេអោយច្បាប់កូនខ្ចីរហូតដល់៣ខែជាមួយនិងប្រាក់ខែ៥០ភាគរយ ។ ខ្ញុំមិនចូលជាសមាជិកសហជីពទេ ព្រោះបងខ្ញុំមិនឱ្យចូលទេ ហើយម្យ៉ាងទៀតខ្ញុំក៏មិនស្គាល់ឈ្មោះសហជីពអីដែរ ប៉ុន្តែ សហជីពបានជួយកម្មករ ដូចជាទាមទារមិនអោយការថែមម៉ោងនៅថ្ងៃសៅរ៍ និងថ្ងៃបុណ្យ ។

បើសិនជារោងចក្របិទខ្ញុំនឹងត្រលប់មកនៅផ្ទះដើម្បីធ្វើចំការវិញ និងជួយការងារនៅផ្ទះ ។

ករណីសិក្សាទី ២៦

ថ្ងៃទី ២៥ មេសា ២០០៥

អ វ ឌ មានអាយុ២២ឆ្នាំ ធ្វើការនៅរោងចក្រ**ម៉ែទិស្តិចត្រា** គ្រួសារខ្ញុំរស់នៅភូមិចំបកមាស ស្រុកមុខកំពូល ខេត្តកណ្តាល។ ខ្ញុំមានបងប្អូន៦នាក់ (ប្រុស២ ស្រី៤) ហើយខ្ញុំជាកូនទី៣ ឪពុកខ្ញុំអាយុ៥៨ និងម៉ែខ្ញុំអាយុ៥៣។ ខ្ញុំបានរៀនត្រឹមថ្នាក់ទី៩ប៉ុណ្ណោះ ហើយត្រូវឈប់រៀនដើម្បីជួយគ្រួសារធ្វើស្រែចំការ ព្រោះតែស្ថានភាពគ្រួសារមានការលំបាកពេក ហើយណាមួយម៉ែក៏មានជំងឺបេះដូងទៀត ។ ចំណែកឪពុករបស់ខ្ញុំវិញគាត់បានធ្វើការវះកាត់២ដង ដោយសារតែគាត់មានជំងឺពោះវៀនដុះខ្នែង ពេលនោះម្តាយរបស់ខ្ញុំគាត់បានទៅខ្ចីលុយគេ១៦០០ដុល្លាជាមួយនិងការប្រាក់១០ភាគ រយក្នុងមួយខែដើម្បីមើលជំងឺរបស់ពុក ។ តែក្រោយមកដោយសារតែពិបាកក្នុងសងការប្រាក់គេពេកនោះម្តាយរបស់ខ្ញុំ គាត់បានលក់ដីស្រែដែលមាន១ហិចតានោះទៅ គាត់លក់បាន៣០០០ដុល្លាហើយបានយកលុយនោះទៅសងគេបំនុលគេខ្លះដែរ ។ បន្ទាប់មកពួកគាត់ក៏បានចំណាយទៅលើការចងដៃការកូនអស់២នាក់ ក្នុងមួយនាក់២០០ដុល្លា។

ក្រោយមកប្អូនខ្ញុំ២នាក់បានមករកការងារធ្វើ ហើយបានជាប់នៅរោងចក្រ **ហ្គោស៊ីង** ប្អូនស្រីធ្វើនៅផ្នែកជួស និងប្អូនប្រុសធ្វើការនៅផ្នែកតម្បាញ។ ប្រាក់ខែពួកគេបាន៣០ដុល្លាដោយគិតជាបុង ហើយត្រូវបង់ថ្លៃទឹកភ្លើង និងនៅសល់ម្នាក់ប្រហែលជា១០ដុល្លាដែរ ។ បងស្រីខ្ញុំ២នាក់ដែលបានរៀបការរួចហើយក៏បានចូលធ្វើការនៅរោងចក្រ ហ្គោស៊ីង នោះដែរ។ ពេលប្អូនស្រី និងប្អូនប្រុសចូលធ្វើការនៅរោងចក្រនោះដំបូង ពួកគេបានឱ្យលុយអ្នកដែលអាចនាំចូលទៅធ្វើការ ប្អូនស្រីរបស់ខ្ញុំចំណាយអស់២៥ដុល្លា ហើយប្អូនប្រុសអស់៧០ដុល្លា។

នៅចុងខែមីនា កម្មករនៅក្នុងរោងចក្រហ្គោស៊ីងបាននាំគ្នាឈប់ធ្វើការ ព្រោះថៅកែរោងចក្រឱ្យតំលៃបុងទាបពេក គឺមួយខែបានតែ១៦-២០ដុល្លាប៉ុណ្ណោះ។

បន្ទាប់ពីខ្ញុំឈប់រៀនបានមួយខែ ក៏ចូលធ្វើការនៅរោងចក្រតាមមិត្តភក្តិរបស់បងស្រីខ្ញុំ នៅរោងចក្រម៉ែទីស្តិចត្រា ពេលខ្ញុំចូលដំបូងខ្ញុំបានខ្ចីលុយគេ ៥០០ដុល្លាដើម្បីទិញម៉ូតូសំរាប់ជិះទៅធ្វើការ ហើយរយៈពេលមួយឆ្នាំទើបខ្ញុំសងគេរួចជាមួយនិងការប្រាក់ក្នុងមួយខែ ១០ភាគរយ។ ប្រាក់ខែដំបូងរបស់ខ្ញុំគឺត្រឹមតែ ៤០ដុល្លាប៉ុណ្ណោះ តែបន្ទាប់ពី៣ខែក្រោយមកខ្ញុំបានទទួលប្រាក់ខែ ៤៥ដុល្លា និងប្រាក់លើកទឹកចិត្ត៥ដុល្លា សរុបគឺបាន៥០ដុល្លាក្នុងមួយខែ។ ប្រសិនជាខ្ញុំធ្វើការថែមម៉ោងទៀតនោះក្នុងមួយខែគឺបាន ប្រហែលជា៧០ដុល្លា គឺមួយថ្ងៃត្រូវថែមម៉ោងពី៣-៤ម៉ោង (ពេលណាមានការងារច្រើន)។ ប្រាក់ខែរបស់ខ្ញុំជារៀងរាល់ខែ ក្រៅពីចំណាយលើការចាយវាយផ្សេងៗទៅ គឺត្រូវផ្ញើឱ្យម៉ែជាអ្នកទុកដាក់ ទុកសំរាប់ផ្គត់ផ្គង់ជីវភាពគ្រួសារ ហើយប្រសិនជាខ្ញុំត្រូវការទិញរបស់របរអ្វីនោះ ខ្ញុំត្រូវសុំពីគាត់វិញ ជួនពេលខ្លះក៏បានទិញហើយពេលខ្លះក៏អត់ដែរ។ ពេលខ្លះខ្ញុំមានអារម្មណ៍តូចចិត្តដែរ ប៉ុន្តែខ្ញុំបានដឹងថាដោយសារតែគាត់ត្រូវការលុយសំរាប់ជួយដល់ក្រុមគ្រួសារជាចំបង។

ជារៀងរាល់ថ្ងៃខ្ញុំចំណាយតិចតួចណាស់ ពេលបាយខ្ញុំញុំនៅមុខរោងចក្រ មួយពេលអស់តែ៧០០រៀលប៉ុណ្ណោះ។ ពេលខ្លះខ្ញុំថែមម៉ោងដល់ម៉ោង ១០យប់។ ធ្វើនៅទីនេះបានមួយឆ្នាំ រោងចក្របានអោយលុយអតីតភាព ២ដុល្លា ហើយមួយឆ្នាំក្រោយមកទៀតឡើងបាន ៣ដុល្លា។

ក្រោយមករោងចក្រក៏ផ្អាកដំណើរការបណ្ដោះអសន្ន ខ្ញុំទទួលបានប្រាក់ខែត្រឹមតែ ៥០ភាគរយប៉ុណ្ណោះ ប្រហែលជា ៣៥ដុល្លា ចាប់តាំងពីខែធ្នូរហូតដល់ខែមេសា បន្ទាប់ខាងរោងចក្រក៏បានប្រកាសបិទទ្វារដោយមូលហេតុរោងចក្រក្ស័យធន ខាងរោងចក្រក៏បើកប្រាក់អោយសរុបទាំងប្រាក់រំសាយ ១៤០ដុល្លា និងលុយបំណាចឆ្នាំ ៥១ដុល្លា គឺបាន ១៩១ដុល្លា។ តែខ្ញុំគិតថាវាមិនសក្តិសមទេ ប៉ុន្តែខ្ញុំមិនដឹងថាគេគិតយ៉ាងម៉េចឱ្យខ្ញុំទេ។ ហើយលុយនេះខ្ញុំបានឱ្យទៅម៉ែ។

ខ្ញុំបានចូលជាសមាជិកសហជីព NIFTAC ហើយតំណាងសហជីពដើរប្រមូលលុយតាមក្រុម។ ហើយលុយដែលបានពីលក់ដីនៅសល់បន្តិច និងលុយដែលខ្ញុំបើកបាន យកទៅទិញគោសំរាប់ដោះទាល់ពេលក្រោយ។ ឥលូវខ្ញុំកំពុងរកការងារធ្វើ ពេលខ្ញុំរកបានហើយ ខ្ញុំនឹងដើររកការងារឱ្យប្អូនៗខ្ញុំម្តង។ ខ្ញុំធ្លាប់ចូលរួមធ្វើបាតុកម្ម ២ដង។ ខ្ញុំចង់ទៅធ្វើការនៅ Malasia ប៉ុន្តែគ្រួសារខ្ញុំមិនឱ្យទៅ។

ខ្ញុំគិតថាចង់ទិញកីយកមកត្បាញនៅផ្ទះ ព្រោះប្អូនខ្ញុំជាអ្នកត្បាញ ហើយម៉ែខ្ញុំក៏ចេះត្បាញ។ បើពេលណាខ្ញុំមិនមានលុយចាយ ហើយពេលឈឺ ខ្ញុំមានលុយមកពីណា ដើម្បីព្យាបាល។

ករណីសិក្សាទី ២៧
តំបន់មានជ័យ
ថ្ងៃទី ០៥ មេសា ២០០៥

ទ អ មានអាយុ២២ឆ្នាំ រស់នៅភូមិដូនតោ ឃុំសំពងជ័យ ស្រុកជើងព្រៃ ខេត្តកំពង់ចាម ។ ខ្ញុំមានបងប្អូន ៦នាក់ (ប្រុស៣ និងស្រី៣) ហើយខ្ញុំជាកូនទី៥។ បង៧៣នាក់មានគ្រួសារអស់ហើយ និងសព្វថ្ងៃនៅតែបងប្រុសទី៤ម្នាក់ធ្វើការជាកម្មករសំណង់ និងប្អូនស្រីពៅម្នាក់នៅផ្ទះជាមួយពុកម៉ែ។ គ្រួសារខ្ញុំជាអ្នកធ្វើស្រែ ហើយមានដីស្រែ៣ហិចតា។ ខ្ញុំបានឈប់រៀននៅថ្នាក់ទី៧ ។

គ្រួសារខ្ញុំពឹងផ្អែកទៅលើការធ្វើស្រែសំរាប់ផ្គត់ផ្គង់ជីវិភាពគ្រួសារ ហើយការធ្វើស្រែពឹងលើទឹកភ្លៀងទៀត។ ក្នុងមួយរដូវ១ បើបានផលច្រើនគឺអាចហូបគ្រប់ តែបើឆ្នាំណាធ្វើមិនសូវបានគឺហូបមិនគ្រប់ទេសំរាប់រយៈពេលមួយឆ្នាំ នៅពេលមិនគ្រប់គឺត្រូវទៅខ្ចីគេ ឬ បណ្តាក់គេយកមកហូបសិនទំរាំតែដល់ពេលឆ្នាំក្រោយពេលប្រមូលផលបានទើបសងគេទាំងការទាំងដើមវិញ។ គ្រួសារខ្ញុំមិនមានមុខរបរអីក្រៅពីធ្វើស្រែទេ។ ក្នុងមួយរដូវធ្វើស្រែគ្រួសារខ្ញុំប្រើជី ២ប្រភេទ គឺជីរស (ជីអ៊ុយរ៉េ) និងជីខ្មៅ (ជីដី) ហើយក្នុងមួយឆ្នាំត្រូវប្រើជីអស់ ៤បាវ (ជីរខ្មៅ ៣បាវ និងជីរស ១បាវ)។ ហើយបើបានផលល្អស្រូវបាន ៣០០ថាំង តែបើស្រូវមិនសូវល្អបានត្រឹមតែ ១៥០ថាំងប៉ុណ្ណោះ។ ពេលត្រូវការចាយវាយអ្វីក៏ដោយ ក៏ត្រូវលក់ស្រូវដែរ តែដល់ពេលណាធ្វើស្រែមិនបាន ហើយត្រូវសងគេពីឆ្នាំមុនទៀត គ្រួសារខ្ញុំត្រូវទៅខ្ចីលុយគេនៅក្នុងភូមិ ហើយដើម្បីចិញ្ចឹមសត្វ តែបើចិញ្ចឹមមិនបានគឺត្រូវខាតហើយក៏ត្រូវទៅខ្ចីលុយគេបន្តទៀតរហូតដល់សងគេលែងរួច ហើយការប្រាក់នៅភូមិគឺ ១០ ភាគរយ។

ពេលម៉ែខ្ញុំសំរេចចិត្តឱ្យខ្ញុំ និងបងប្រុសទី៤ ឈប់រៀន ហើយពួកខ្ញុំក៏បានមកភ្នំពេញមកនៅជាមួយប្អូនស្រីសាច់ឆ្ងាយរបស់គាត់ដើម្បីរកការងារធ្វើ។ ពេលមកខ្ញុំមានលុយ ១០ម៉ឺនរៀល ដោយសារខ្ញុំស៊ីឈ្នួលច្រូតស្រូវប្រាំងឱ្យគេ។ ពេលជិះឡានមកអស់១ម៉ឺន ហើយពេលមកដល់ភ្លាម ខ្ញុំដើរធ្វើតេស្តខ្លួនឯងអស់រយៈពេល ៣ថ្ងៃ ក៏ធ្វើតេស្តជាប់នៅរោងចក្រ **តេវ៉ាតិច** គេយកទៅបង្រៀនមួយអាទិត្យ ហើយបើមួយអាទិត្យរៀនមិនចេះគេមិនយកទេ តែបើចេះក៏គេមិនគិតលុយឱ្យសំរាប់មួយអាទិត្យហ្នឹងដែរ។

នៅក្នុងរោងចក្រនេះមួយក្រុមមាន ២នាក់ គឺចិន និងឥខ្មែរ ប៉ុន្តែប្រធានខ្មែរកាចជាងចិន។ ពេលសុំច្បាប់ពិបាកណាស់ ហើយពេលដែលឈឺជិតសន្លប់សុំច្បាប់ក៏គេមិនឱ្យឈប់ដែរ តែគេឱ្យទៅដេកពេទ្យនៅក្នុងរោងចក្រ ហើយពេលដែលគ្រាន់បើគេឱ្យទៅធ្វើការវិញ។ ពេលឈឺមានសំបុត្រពេទ្យទើបគេគិតលុយឱ្យ តែបើអត់សំបុត្រពេទ្យគេមិនគិតលុយឱ្យទេ។ ពេលឈឺខ្លាំងនៅក្នុងរោងចក្រគេដេញឱ្យយើងទៅផ្ទះ និងទៅពេទ្យតែគេមិនគិតលុយឱ្យទេ។ នៅទីនេះមានសហជីព ២ គឺ សេរីកម្មករ និងមួយទៀតអត់ស្គាល់ឈ្មោះ។ រាល់ពេលមានបញ្ហាសហជីពអត់ជួយដោះស្រាយឱ្យទេ។

ខ្ញុំធ្វើការនៅផ្នែកត្បាញអាវ ខាងរោងចក្រគិតអោយដោយស៊ីឡូ រីតំលៃឡូ គឺ៨ដុល្លាសំរាប់ឡូតូច និង៩ដុល្លាសំរាប់ឡូធំ នេះគឺតំលៃថ្លៃបំផុតហើយ បើថោកបំផុតគឺ២.៥ដុល្លា។ មួយឡូត្រូវធ្វើការ៣ថ្ងៃទើបបាន ២.៥ដុល្លា បើឡូ៨ដុល្លាវិញ ៥ទៅ៦ថ្ងៃទើបធ្វើរួច។ ក្នុងមួយខែខ្ញុំបើកប្រាក់ខែបាន ៨០-៩០ដុល្លា បើតិចបំផុត៥០ដុល្លា។ ចូលធ្វើការម៉ោង ៦:៣០ព្រឹក ចេញម៉ោង ១១:៣០ និងចូលវិញម៉ោង ១២:៣០ ចេញម៉ោង ៣:៣០ អត់ថែមម៉ោង តែបើថែមម៉ោងវិញដល់ម៉ោង ៥:៣០ល្ងាច។ នៅក្នុងរោងចក្រនេះមាន៣វេន ហើយពេលកូតាបញ្ចប់លក្ខខណ្ឌការងារនៅក្នុងរោងចក្រវិតតែពិបាកជាងមុន តំលៃឡូចុះថោកហើយប្រព័ន្ធការងារក៏មានការកែប្រែដែរគឺត្រឹមតែជា២វេន ហើយខាងរោងចក្របានរំសាយកម្មករ ១០០នាក់ តែបានគុណលុយពាក់កណ្តាលឱ្យដែរ ចំនែកអ្នកចូលថ្មីគេទុកទាំងអស់ គេរំសាយកម្មករណាដែលពូកែតវ៉ា។ ចំនែកការងារសំបូរតែនៅក្នុងផ្នែកត្បាញ តែផ្នែកផ្សេង១ទៀតអត់សូវមានការងារធ្វើនោះទេ។

ពេលខ្ញុំបើកលុយខ្ញុំផ្ញើរទៅផ្ទះ ៥០ដុល្លា និងទុក៣០ដុល្លា សំរាប់ថ្លៃផ្ទះ ទឹកភ្លើង និងទុកចាយខ្លះ។ លុយដែលផ្ញើរទៅផ្ទះម៉ែយកទៅសងបំណុលគេខ្លះ តែនៅតែជំពាក់គេទៀតរហូតមកដល់ឥឡូវ។ ហើយសព្វថ្ងៃនេះបន្ទប់ដែលបានជួលនោះមានតំលៃ ២០ដុល្លា មានគ្នានៅ៤នាក់ ហើយម្នាក់ត្រូវបង់៥ដុល្លា។ បន្ទប់ដែលជួលនោះគឺតូចចង្អៀត គ្មានអនាម័យ ហើយម្ចាស់ផ្ទះវិញគាត់មិនបានធ្វើអោយមានបរិយាកាសល្អនោះទេដឹងតែពីការទារលុយ គ្មានសុវត្ថិភាព គ្មានការទុកចិត្ត ពេលធ្វើការតែងតែបារម្ភនៅផ្ទះជួលក្រែងរបស់របរនៅផ្ទះនោះត្រូវគេឡើងយកអស់។

នៅថ្ងៃអនាគតពេលរោងចក្របិទខ្ញុំនឹងត្រឡប់ទៅផ្ទះវិញ ដើម្បីធ្វើស្រែចំការហើយបើធ្វើស្រែមិនបាននោះ ខ្ញុំអាចនឹងមកភ្នំពេញវិញដើម្បីរកការងារធ្វើបន្តទៀត មិនថាការងារអ្វីទេក៏សុខចិត្តធ្វើដែលលើកលែងតែធ្វើជាស្ត្រីរកស៊ីផ្លូវទេ។

ករណីសិក្សាទី ២៨

ថ្ងៃទី ១៨ មេសា ២០០៥

នាងខ្ញុំឈ្មោះ អ ផល្ល មានអាយុ ២២ឆ្នាំ ខ្ញុំមានការងារធ្វើការនៅរោងចក្រ **ហុងវ៉ា** ឥឡូវនេះ។ គ្រួសារខ្ញុំរស់នៅភូមិអ្វូ ឃុំត្រាំត្រស ស្រុកបសែត ខេត្តកំពង់ស្ពឺ។ ខ្ញុំមានបងប្អូន ៦នាក់ ហើយពួកគេធ្វើស្រែទាំងអស់គ្នា ខ្ញុំឈប់រៀន ថ្នាក់ទី៣។ គ្រួសារខ្ញុំ មានដីស្រែមួយហិចតា និងគោ ២។ គ្រួសារខ្ញុំប្រើទឹកដែលដងពីអណ្តូង ហើយគ្មានអគ្គីសនីទេ។ ក្នុងមួយថ្ងៃគ្រួសារខ្ញុំ ត្រូវចំណាយអស់ ២០០០រៀល។

អ្នកដែលសំរេចចិត្តឱ្យខ្ញុំចូលធ្វើការនៅក្នុងរោងចក្រគឺម៉ែរបស់ខ្ញុំ បន្ទាប់ពីមានការងារធ្វើមកខ្ញុំធ្លាប់បានផ្លាស់ប្តូររោងចក្រម្តងដោយសារតែរោងចក្រមួយនោះអត់មានការងារធ្វើ។ ដំបូងឡើយខ្ញុំធ្វើការនៅរោងចក្រ **ប្រាំមួយជាន់** ហើយខ្ញុំបានទទួលប្រាក់ខែ ៤៥ដុល្លា មុននិងបានធ្វើការខ្ញុំបានរង់ចាំអស់ពេលរយៈមួយខែ ដោយការធ្វើតេស្តខ្លួនឯងហើយគ្មានអស់លុយទេ។ សំរាប់ការចាយវាយក្នុងមួយខែ ខ្ញុំត្រូវអស់២៥ដុល្លា។ ខ្ញុំធ្លាប់បានទទួលការបណ្តុះបណ្តាលពីអង្គការស្ត្រីដែរ ដោយការបណ្តុះបណ្តាលនោះម្តងមានរយៈពេល៤ម៉ោង អង្គការនោះគេជួយអត់មានបង់លុយនោះទេ។

ខ្ញុំភ័យខ្លាចអត់មានការងារធ្វើណាស់ ហើយភ័យថារោងចក្របិទច្បាស់ជាអត់មានការងារធ្វើហើយ និងខ្លាចគេណាស់ប្រសិនជាត្រូវបានគេបណ្តេញចេញពីការងារ ហើយម្យ៉ាងទៀតពេលមានការងារធ្វើអ្វីដែលភ័យមួយទៀតនោះគឺភ័យខ្លាចនឹងជើងកាងខ្លាចពួកវាចាប់យកទៅលក់។ ពេលខ្ញុំបានធ្វើនៅក្នុងរោងចក្រខ្ញុំសប្បាយរីករាយណាស់ ព្រោះខ្ញុំអាចជួយដោះស្រាយជីវភាពគ្រួសារបានខ្លះដូចជា ឱ្យប្អូនៗទៅរៀន និងជួយម៉ែសងបំណុលគេ។

កាលពីខ្ញុំធ្វើការនៅរោងចក្រមុន គឺខ្ញុំធ្វើនៅផ្នែកតម្បាញ ប៉ុន្តែខ្ញុំមិនដឹងថារោងចក្រនេះផលិតម៉ាក់អ្វីទេ ហើយខ្ញុំធ្វើនៅរោងចក្រនោះអស់រយៈពេល៥ឆ្នាំមក ហើយក៏មិនបានដឹងថាតំលៃបុង និងតំលៃថែមម៉ោងប៉ុន្មានដែរ ព្រោះគេមិនដែលប្រាប់ខ្ញុំទេ។ ខ្ញុំទទួលប្រាក់ឈ្នួលបាន ៤៥ដុល្លាក្នុងមួយខែ ហើយបើបូកនឹងថែមម៉ោងនឹងលុយលើកចិត្តទាំងអស់បានប្រហែលជា ៦០ដុល្លា។ ខ្ញុំស្រលាញ់ការងារណាដែលប្រើកំលាំងព្រោះវាជាការងារដែលសុច្ចរិត មិនកេងប្រវ័ញ្ចលើនរណាម្នាក់ឡើយ។ នៅក្នុងរោងចក្រនេះគឺធ្វើការតែមួយវេន ក្នុងមួយថ្ងៃខ្ញុំធ្វើការ ១០ម៉ោង បូកនិង ការថែម ២ម៉ោង ជាទូទៅខាងរោងចក្រអោយសំរាកមួយម៉ោងសំរាប់អាហារថ្ងៃត្រង់ ខ្ញុំចូលចិត្តធ្វើការថែមម៉ោងព្រោះ ខ្ញុំចង់បានលុយច្រើន។

ខ្ញុំមិនដែលដឹងពីច្បាប់ឈប់សំរាកទេហើយសូម្បីតែពេលឈឺក៏អត់បានដឹងច្បាស់ដែរ។ ពេលឈឺទៅសុំច្បាប់គេ ហើយបើគេអត់ឱ្យក៏ទៅធ្វើការវិញ។ ខ្ញុំធ្លាប់គ្រុនពោះវៀនម្តងដែរ តែពេលនោះខ្ញុំបានទៅពេទ្យឯកជនដោយខ្លួនឯង ហើយខាងរោងចក្រមិនបានជួយចេញលុយកាក់ខ្លះដល់ខ្ញុំនោះទេ។ ខ្ញុំមិនចង់ទៅពេទ្យនៅក្នុងរោងចក្រទេ ព្រោះសេវាសុខភាពមិនល្អ

ហើយគ្រូពេទ្យសំដីអាក្រក់។ ពេលខ្ញុំឈឺខ្លាំងព្យាបាលម្តងអស់ប្រហែល ៧០-១០០ដុល្លា តែបើឈឺតិចតួចអស់ប្រហែល ៥-១០ដុល្លា។ ខ្ញុំគិតថាសេវាកម្មសុខភាពរបស់ពេទ្យឯកជនល្អជាងពេទ្យរដ្ឋ។

នៅពេលខ្ញុំមានបញ្ហាខ្ញុំតែងតែទៅរកមិត្តភក្តិដែលនៅជិតបន្ទប់ខ្ញុំពិភាក្សាគ្នា តែពេលមានបញ្ហានៅក្នុងរោងចក្រវិញ គឺខ្ញុំទៅរកតំណាងកម្មករ និងប្រធានសហជីពដើម្បីឱ្យគេជួយយើង។ ខ្ញុំធ្លាប់ចូលរួមបាតុកម្មដែរតែមិនបានសំរេចនោះទេ។ នៅក្នុងរោងចក្រនេះចូលធ្វើការនៅម៉ោង៨ព្រឹក ចេញម៉ោង១២ ហើយចូលវិញនៅម៉ោង១ថ្ងៃ ចេញម៉ោង៥ល្ងាច តែបើថែមម៉ោងត្រូវដល់ម៉ោង៧យប់។ ពេលខ្លះខ្ញុំអត់ថែមម៉ោងទេ ហើយខាងរដ្ឋបាលបានមកសួរខ្ញុំហេតុអ្វីមិនថែមម៉ោង ហើយខ្ញុំបានប្រាប់ថាសុំអត់ថែមនោះទេ ព្រោះផ្លូវចូលទៅផ្ទះខ្ញុំអត់មានសុវត្ថិភាពទេ ។

បន្ទប់ដែលខ្ញុំជួលមានគ្នានៅ ២នាក់ ក្នុងម្នាក់ត្រូវចំណាយថ្លៃផ្ទះ ៥ដុល្លា ហើយទឹកវិញប្រើអស់មួយខែ ៧ពាង។ ខ្ញុំអត់បានទៅធ្វើការចំនួន២ថ្ងៃ នៅពេលចូលធ្វើការវិញ ខាងរដ្ឋបាលប្រាប់ថាឈប់អោយថែមម៉ោងទៀតហើយ ហើយត្រូវចូលធ្វើការនៅម៉ោង៧ព្រឹក ចេញម៉ោង ១០:៥០ និងចូលម៉ោង ១១:៥០ ចេញម៉ោង ៤ល្ងាច។ ហើយរោងចក្រថែមទាំងមានសហជីព២ទៀតផង គឺសេរីកម្មករ និងឯករាជ្យប្រជាធិបតេយ្យ តែខ្ញុំអត់ចូលជាសមាជិកទេ។ នៅរោងចក្រនេះមានលុយព្រីម៥ដុល្លាមួយខែ និងលុយឡានមួយថ្ងៃ ៨០០រៀល ហើយបើថែមដល់ម៉ោង ៦ល្ងាច គេឱ្យលុយបាយ ១០០០រៀល។ គេដេរខោកាប៊យ ផ្លាក Camel & Hatred។ ឥលូវអត់សូវមានការងារធ្វើទេ ពេលគេបញ្ចប់កូតា។ ពេលរោងចក្របិទ ខ្ញុំនឹងទៅរកការងារដោយខ្លួនឯង និងរៀនកាត់ដេរម៉ូត ដើម្បីចិញ្ចឹមជីវិតទៅថ្ងៃអនាគត។

ករណីសិក្សាទី២៩
ថ្ងៃទី ២៣ មេសា ២០០៥

នាងខ្ញុំឈ្មោះ ជ រដ ហើយគ្រួសារខ្ញុំរស់នៅ ភូមិបឹងក្អែក ឃុំពាមមានជ័យ ស្រុកពាមរក ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូន ៤នាក់ ហើយខ្ញុំជាកូនទី២។ ខ្ញុំរៀនថ្នាក់ទី ១២ នៃវិទ្យាល័យពាមរក។ ពុកម៉ែខ្ញុំជាអ្នកចំការ មានដាំដំណាំដូចជា សណ្តែកដី សណ្តែកបាយ ពោត ល្ង ត្រប់ ។ល។

ដោយសារតែដាំដំណាំមិនសូវបានផល ព្រោះគ្មានភ្លៀងដូចនេះធ្វើឱ្យដំណាំទាំងនោះក្រៀមស្វិតងាប់អស់រលីង។ ដោយសារតែឃើញក្រុមគ្រួសារមិនបានទទួលផលពីបីឆ្នាំផ្ទួន១ ខ្ញុំក៏សំរេចចិត្តមករកការងារធ្វើនៅឯទីក្រុងភ្នំពេញ ដើម្បីជួយដល់ក្រុមគ្រួសារពេលដែលកំពុងខ្វះខាត។ ពេលនោះខ្ញុំបានមកភ្នំពេញតាមអ្នកជិតខាងនៅជាប់ផ្ទះ ដែលបានមកធ្វើការយូរហើយណាស់មក ខ្ញុំមកដំបូងមិនចេះដេរទេ តែខ្ញុំបានចូលធ្វើតេស្តនៅរោងចក្រ **សាន់តិច** ផ្នែករៀបចំផ្តុំខោអាវ។ ខ្ញុំជាកម្មករបណ្តែតវេនថ្ងៃ ហើយខ្ញុំធ្វើការបាន ៤ខែ។

ខ្ញុំដឹងថានៅក្នុងរោងចក្រនេះមានសហជីព តែខ្ញុំមិនបានដឹងពីច្បាប់ការងារនោះទេ។ បន្ទាប់មករោងចក្រអត់មានការងារធ្វើនោះទេ ខាងរោងចក្របានរំសាយកម្មករបណ្តែតដោយទូទាត់ប្រាក់ឈ្នួលអោយ។ ជាទូទៅកម្មករត្រូវចូលធ្វើការនៅម៉ោង ៦:៣០ព្រឹក ចេញម៉ោង ២:៣០ល្ងាច បើថែមម៉ោង គឺធ្វើការរហូតដល់ម៉ោង៥:៣០ល្ងាច ហើយបើគិតទាំងប្រាក់ឈ្នួលថែមម៉ោងទៀតនោះក្នុងមួយថ្ងៃកម្មករបណ្តែតអាចទទួលបាន ២,៥ដុល្លា។

ពេលខ្ញុំឈប់ធ្វើការនៅ **សាន់តិច** ខ្ញុំក៏ចូលធ្វើការនៅរោងចក្រ **ហុងវ៉ា** ជាកម្មករបណ្តែតនៅផ្នែកឃ្លាំងបានត្រឹមមួយខែប៉ុណ្ណោះ ។ ប្រាក់ខែដែលខ្ញុំទទួលបានបូកទាំងថែមម៉ោងដល់៦ល្ងាចគឺ៦០ដុល្លា។ ខ្ញុំមិនចូលជាសមាជិកសហជីពទេ ព្រោះខ្ញុំជាកម្មករបណ្តែត។ ពេលអត់មានការងារធ្វើខាងរោងចក្រក៏បានរំសាយកម្មករបណ្តែតចេញ បន្ទាប់ពីត្រូវបានគេរំសាយខ្ញុំក៏ទៅធ្វើតេស្តជាប់ នៅរោងចក្រពោធិចិនតុង ខ្ញុំក៏បានធ្វើការនៅទីនោះរហូត ដល់ពេលឥឡូវនេះខ្ញុំជាកម្មករពេញសិទ្ធផ្នែក QC។ ខ្ញុំបានជួលផ្ទះនៅផ្សារបំបែក ហើយពេលទៅធ្វើការគឺខ្ញុំមានកង់សំរាប់ជិះទៅ ហើយកង់នោះខ្ញុំបានសន្សំលុយទិញវា។

ជារៀងរាល់ថ្ងៃបើខ្ញុំធ្វើការថែមម៉ោងដល់៦ល្ងាច ខាងរោងចក្រមិនបានឱ្យលុយបាយនោះទេ តែបើថែមម៉ោងដល់៩យប់ រឺ១០យប់ ទើបគេឱ្យលុយបាយ ១០០០ រៀលសំរាប់ទិញបាយហូប។ ខ្ញុំអត់ដឹងច្បាស់ពីសហជីពទេព្រោះខ្ញុំទើបតែចូលថ្មី ហើយរោងចក្រនេះក៏ទើបតែបើកដែរ។ រោងចក្របង្ខំឱ្យកម្មករធ្វើការថែមម៉ោង ៩-១០យប់ ហើយមានថ្ងៃខ្លះគេបង្ខំឱ្យថែមម៉ោងដល់ ១១យប់ក៏មានដែរ តែពេលថែមម៉ោងយប់មានឡានជូនមកផ្ទះវិញ និងមានលុយបាយ១០០០រៀល។ រាល់ថ្ងៃរោងចក្របង្ខំឱ្យធ្វើការតាមចំនួយដែលគេបានកំនត់ ប្រសិនបើកម្មករណាម្នាក់ធ្វើមិនបានតាមកំនត់នោះ និងត្រូវខាងរោងចក្រស្តីឱ្យមិនខាន ហើយទោះជាកម្មករខំពន្យល់ពីហេតុផលយ៉ាងណាក៏ដោយក៏គេមិនព្រមស្តាប់នោះដែរ។

ហើយរូបខ្ញុំក៏ជាកម្មករម្នាក់ដែលគេឧស្សាហ៍ស្តីអោយដែល ដោយសារតែពិបាកពេកខ្ញុំទ្រាំមិនបាន ខ្ញុំក៏សំរេចចិត្តឈប់ធ្វើការនៅទីនោះទៅ។

បន្ទាប់ពីនោះមកខ្ញុំបានទៅរៀនដេរអោយបានស្ទាត់ជាងមុន ហើយខ្ញុំក៏ទៅធ្វើតេស្តជាប់នៅរោងចក្រ **ចយហ្វូល** ផ្នែកដេរជាទូទៅពេលចូលធ្វើដំបូង ខាងរោងចក្រទុកជាកម្មករបណ្តែកសិន តែនៅពេលដែលខំធ្វើការអោយគេបានល្អ ហើយរោងចក្រនោះមិនការងារធ្វើមិនឈប់នោះ គេនិងអោយក្លាយជាកម្មករពេញសិទ្ធមិនខាន ហើយរហូតមកដល់ពេលនេះខ្ញុំបានធ្វើការនៅរោងចក្រនេះជាងមួយឆ្នាំមកហើយ។ នៅក្នុងរោងចក្រនេះមានសហជីព ប៉ុន្តែខ្ញុំមិនបានចូលជាសមាជិកនោះទេ។ ពេលសុំច្បាប់ម្តងៗរោងចក្រមិនសូវឱ្យច្បាប់ទេ ព្រោះគ្មានអ្នកណាគេមកជំនួសកន្លែងធ្វើការ ក្រៅពីនេះខ្ញុំក៏បានដឹងខ្លះៗដែលទាក់ទងនិងការសុំច្បាប់រៀបការ ខាងរោងចក្រគេឱ្យឈប់បានមួយអាទិត្យ ហើយចំពោះច្បាប់លំហែមាតុភាព៣ខែវិញ រោងចក្រគិតលុយឱ្យពាក់កណ្តាលដែលរហូតដល់ពេលចូលធ្វើការវិញ។ ប្រសិនបើធ្វើការថែមម៉ោងដល់៦ល្ងាចគេឱ្យលុយបាយ១០០០រៀល ហើយបើថែមម៉ោងដល់ ៩យប់ គេអត់ឱ្យលុយបាយទេ គឺគេយកលុយបាយយើងទៅទិញបាយតែម្តង ហើយគេថែមមីមួយកញ្ចប់ពីលើឱ្យ។

ដោយសាររោងចក្រនេះអត់មានការងារធ្វើ គេឱ្យកម្មករសំរាក ៤-៥ថ្ងៃ តែបន្ទាប់មកគេបន្តទៅដល់ ១០ថ្ងៃ ហើយគេគិតឱ្យពាក់កណ្តាល តែបើអ្នកមានបំណាច់ឆ្នាំ គេកាត់បំណាច់ឆ្នាំ តែបើអស់បំណាច់ឆ្នាំ គេកាត់លុយថ្ងៃយើងកន្លះថ្ងៃ។ ដូច្នោះធ្វើឱ្យខ្ញុំមិនអាចផ្ញើរលុយទៅផ្ទះបានច្រើនដូចមុនទេ ពេលនោះខ្ញុំក៏សំរេចចិត្តឈប់ធ្វើការនៅរោងចក្រនោះ ហើយដើរធ្វើតេស្តរកការងាររោងចក្រផ្សេងធ្វើ បន្ទាប់មកខ្ញុំបានទៅធ្វើតេស្តនៅរោងចក្រ ***វីរវីល*** ហើយជាប់ជាកម្មករធ្វើនៅផ្នែកដេរខោរគំរូ នៅទីនោះខ្ញុំក៏មិនបានចូលជាមានសហជីពដែរ។ នៅផ្នែកផ្សេងៗទៀតមានការពិបាក និង តឹងរឹងជាខ្លាំងដូចជាការសុំច្បាប់ ហើយនិងមានចំនួនកំណត់ក្នុងការដេរប្រចាំថ្ងៃទៀតផង លើកលែងតែផ្នែកគំរូដែលខ្ញុំធ្វើគឺមិនសូវតឹងរឹងនោះទេ កម្មករអាចលេងសើច រឺនិយាយលេងបាន។ ខ្ញុំអាចសុំច្បាប់បានគ្មាននរណាបង្អំទេ ហើយរោងចក្រមិនបានដេញដោលនោះទេ។

ខ្ញុំគិតថាបើរោងចក្រមួយនេះបិទទ្វារនៅថ្ងៃមុន ខ្ញុំនិងត្រលប់ទៅស្រុកវិញទៅប្រកបរបរលក់ដូរបន្តិចបន្តួច និងដាំបន្លែគ្រប់មុខ ព្រមទាំងចិញ្ចឹមមាន់ទា ជាលក្ខណះគ្រួសារសំរាប់ហូប និងនៅសល់ទុកលក់ខ្លះ ដើម្បីចិញ្ចឹមជីវិតទៅថ្ងៃអនាគត។

ករណីសិក្សាទី ៣០

ថ្ងៃទី ២៥ មេសា ២០០៥

នាងខ្ញុំឈ្មោះ វុន មានអាយុ ៣១ឆ្នាំ។ គ្រួសារខ្ញុំរស់នៅភូមិព្រៃកតាបែន ឃុំព្រៃកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល។ ខ្ញុំមានបងប្អូន៦នាក់ ហើយខ្ញុំជាកូនទី៥។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៤ (១៩៩២) ដោយសារជីវភាពលំបាកពេក ហើយណាមួយបង១ សុទ្ធតែប្រុស១ ហើយនៅពេលនោះពួកគាត់រត់គេចពីទាហ៊ាន ដូច្នេះខ្ញុំក៏បានឈប់រៀនដើម្បីជួយធ្វើស្រែពុកម៉ែ។ ខ្ញុំរៀបការនៅឆ្នាំ ១៩៩៣ ហើយមានកូន៣នាក់ (ប្រុស១ ស្រី២) ពេលដែលរៀបការនោះគឺម៉ែជាអ្នកបង្ខំឱ្យខ្ញុំរៀបការ ខ្ញុំមិនបានស្រលាញ់នោះទេ។ បន្ទាប់ពីការហើយពុកម៉ែបានចែកដីស្រែអោយ ១៤អា ហើយក្នុងមួយឆ្នាំធ្វើស្រែបានត្រឹម ៥០០គីឡូអង្ករប៉ុណ្ណោះ តែហូបអត់ដែលគ្រប់ទេខ្វះប្រហែលជា ៣ខែក្នុងមួយឆ្នាំ។ ធ្វើស្រែត្រូវដាក់ជី ៣បាវ អស់ ៦៧០០០រៀល ទិញសាំង ១៨ម៉ឺន ជួលគោគេអស់ ៤០០០រៀល ជួលត្រាក់ទ័រ អស់ ៨០០០០រៀល ដើម្បីធ្វើស្រែប្រាំង។ ក្រៅពីធ្វើស្រែគ្រួសាររបស់ខ្ញុំបានដាំដំណាំខ្លះ ដូចជាស្ពៃ... ។ល។ ហើយលក់ស្ពៃម្តងចំនេញបាន ប្រហែល៣០០០រៀល តែពេលខ្លះចូលដើមក៏មានដែរ។

ដោយសារតែស្ថានភាពជីវភាពគ្រួសារមានការលំបាកខ្ញុំក៏បានសំរេចចិត្តមកធ្វើការនៅដើមឆ្នាំ២០០០ ដោយទុកកូនអោយម៉ែជួយមើលថែ ។ ដំបូងខ្ញុំបានចូលធ្វើនៅរោងចក្រ **ម៉ៃទិស្ថិចត្រា** ផ្នែកឆែកដេរករ។ ពេលចូលធ្វើការនៅរោងចក្រឱ្យគេអស់៤០ដុល្លា (អ្នកដែលបានធ្វើការមុនគេនាំចូល)។ ហើយខ្ញុំក៏បានខ្ចីលុយគេដោយការប្រាក់ ៤ដុល្លាក្នុងមួយខែ។ ប្រាក់ខែដំបូងរបស់ខ្ញុំគឺ ៣០ដុល្លា ពេលនោះខ្ញុំចាយវាត្បិតត្បៀតណាស់ព្រោះខ្ញុំត្រូវសងបំណុលគេវិញខ្លះទៀត ហើប្រហែលជា ២-៣ខែ ទើបសងគេរួច។ ពេលខ្ញុំបានការងារខ្ញុំមានអារម្មណ៏ថាសប្បាយចិត្តដែលអាចរកលុយបានច្រើន ប៉ុន្តែនឿយហត់ខ្លាំងណាស់ហើយណាលុយក៏ បានតិចទៀត ដូច្នេះមុនពេលចូលធ្វើការខ្ញុំត្រូវ ខ្ញុំបានឆ្លៀតយកក្រអៅឈូក និងកូនស្ពៃ ត្រកួនទៅលក់នៅមុខរោងចក្រ។

កាលពីមុនខ្ញុំមិនដែលនឹកថារោងចក្រនឹងបិទទ្វារនោះទេ ព្រោះរវល់តែធ្វើការដើម្បីរកលុយ គិតថាបើមានការងារធ្វើនិងមានប្រាក់ខែជារៀងរាល់ខែ។ ខ្ញុំដឹងយ៉ាងច្បាស់ថាពេលមានការងារធ្វើនៅក្នុងរោងចក្រគឺគ្រាន់បើជាងពេលមិនទាន់ចូលរោងចក្រ ហើយអាចមានលុយចាយបានគ្រប់គ្រាន់ជាងមុន ហើយពេលយប់ខ្ញុំបានឆ្លៀតទៅធ្វើការនៅរោងចក្រនៅភ្នំពេញ ក្នុងមួយយប់ធ្វើការ ២ម៉ោង ខ្ញុំអាចដេរអាវបាន ៣ឡូតំលៃ១០,០០០រៀល។ ទោះជាមានលុយអាចចាយបាយគ្រប់គ្រាន់ជាងមុនក៏ដោយ តែនៅពេលដែលកូនឈឺ ខ្ញុំត្រូវទៅចងការប្រាក់គេយកមកមើលជំងឺកូន ហើយនិងសងគេវិញនៅពេលដែលបើកប្រាក់ខែ និងចំណេញពីការលុយបន្ថែមបង្ការខ្លះនោះ។ នៅពេលដែលមានជំងឺ ពេលខ្លះខ្ញុំសុំច្បាប់ ហើយពេលខ្លះសុំច្បាប់អត់បានទេ។ ជាទូទៅពេលសុំច្បាប់ ខាងរោងចក្រគេកាត់លុយបំណាច់ឆ្នាំ តែបើមានសំបុត្រពេទ្យគឺអត់ដាច់លុយទេ។

ខ្ញុំបានចូលជាសមាជិកសហជីព NIFTUC បានប្រហែលជា ២ឆ្នាំមកហើយ ដោយក្នុងមួយខែត្រូវបង់សមាជិកភាពឱ្យគេ ១000រៀល។ ខ្ញុំចូលជាសហជីព ព្រោះខ្ញុំគិតថាសហជីពអាចជួយបានពេលដែលរោងចក្រគាបសង្កត់ និងធ្វើការទាមទារផ្សេងៗ។ តាំងពីចូលជាសមាជិកសហជីពមកខ្ញុំមិនដែលត្រូវបានគេហៅទៅរៀននោះទេ។ ហើយផ្ទុយទៅវិញពេលទាមទារតំលៃឡូសហជីពមិនដែលបានជួយទាមទារឱ្យទេ គឺកម្មករនាំគ្នាទាមទារដោយខ្លួនឯង។

អ្វីដែលខ្ញុំបានដឹងច្រើនដូចជាច្បាប់ការងារនិងពត៌មានផ្សេងៗទាក់ទងនឹងវិស័យកាត់ដេរនោះ គឺបានដឹងដោយសារមណ្ឌលព័ត៌មានមួយកន្លែងដែលនៅជិតកន្លែងធ្វើការរបស់ខ្ញុំ ហើយខ្ញុំឧស្សាហ៏បានរៀន និង ទទួលពត៌មានផ្សេងៗ ដូចជាក្រមប្រតិបត្តិរបស់ក្រុមហ៊ុនផ្លាកសញ្ញាធំៗមានដូចជា GAP ហើយគេបានប្រាប់ថានៅពេលកូតាបញ្ចប់រោងចក្រមួយចំនួនអាចនិងត្រូវបិទទ្វារ តែពេលនោះខ្ញុំអត់ជឿនោះទេ ព្រោះរោងចក្រដែលខ្ញុំធ្វើការវាធំណាស់ ខ្ញុំគិតថាវាមិនចេះតែងាយបិទនោះទេ ។ តែចាប់ពីខែ១២ ឆ្នាំ២00៤ មកខាងរោងចក្រមិនសូវមានការងារធ្វើនោះទេ គឺមួយខែធ្វើបាន ១អាទិត្យ រឺកន្លះខែ ខ្ញុំអត់បានដឹងថាមូលហេតុអីបានជាមិនសូវមានការងារធ្វើនោះទេ។ ចាប់ពីថ្ងៃទី ២២ កុម្ភះ ២00៥ រហូតដល់ ១៨ មេសា ២00៥ រោងចក្រប្រាប់ថាបិទនៅថ្ងៃ ទី ២២ មេសា ២00៥ ហើយពេលបិទគេអត់បានគិតលុយសងជំងឺចិត្តឱ្យទេ ខាងរោងចក្រគិតឱ្យតាមឆ្នាំដែលបានធ្វើការដូចជា អ្នកដែលបានធ្វើពី ៦ខែទៅដល់ ២ឆ្នាំ គឺគុណនឹង ១,៥ បាន៦៧,៥ ដុល្លាបូកទាំងប្រាក់បំណាច់ឆ្នាំ។ ហើយអ្នកធ្វើចាប់ពី ២ឆ្នាំ ដល់៤ឆ្នាំ គឺគុណនឹង ១,៧ បាន១៣៣ដុល្លា រឺ១៣៦ដុល្លាបូកទាំងបំណាច់ឆ្នាំ ៣៥ដុល្លា រឺ៣៦ដុល្លា។ ពេលឃើញលុយគេបើកឱ្យបានប៉ុណ្ណឹងខ្ញុំស្ទើរតែដាច់ខ្យល់ស្លាប់។ កម្មករទាំងអស់អត់បានដឹងថារោងចក្របិទទេ ហើយនៅពេលដែលកម្មករមកដល់រោងចក្រនៅថ្ងៃ ២២ មេសា ២00៥ ស្រាប់តែឃើញប៉ូលីសរាយតាំងពីក្នុងទៅដល់ក្រៅរោងចក្រ គឺពង្រាយគ្រប់កន្លែង ព្រោះពេលនោះគឺជាថ្ងៃទូទាត់លុយឱ្យកម្មករ ខាងរោងចក្រធ្វើដូចនេះព្រោះគេខ្លាចកម្មករធ្វើបាតុកម្ម សូម្បីតែសួរពួកចិនពីរឿងលុយដែលបាត់ ក៏វាអត់ដឹងដែរ ព្រោះប្រធានចិនដែលធំជាងគេនោះបាន ចេញទៅបាត់ គឺនៅសល់តែចិនតូចតាចនៅក្នុងរោងចក្រត្រៀមបើកលុយអោយ។

ពេលដឹងថារោងចក្របិទខ្ញុំមានអារម្មណ៏រន្ធត់ ភ័យព្រួយ ពិបាកមែនទែន ណាមួយនឹងឃើញដល់អ្នកដែលនៅមណ្ឌលបាននិយាយ ហើយឥលូវនេះខ្ញុំទទួលស្គាល់ថាអ្វីដែលគេបានប្រាប់ខ្ញុំគឺពិតណាស់ជាត្រូវគ្រប់ម៉ាត់។ ខ្ញុំគិតថាបើសិនជាខ្ញុំអត់មានការងារធ្វើនោះ តើខ្ញុំបានលុយពីណាដើម្បីជួយផ្គត់ផ្គង់គ្រួសារទៅ ម្យ៉ាងទៀតការលក់ដូររបស់ខ្ញុំវិញក៏មិនសូវដាច់ដូចមុនដែល កម្មករបានចេញពីកន្លែងនោះអស់ហើយ ពយកគេបានទៅរកការងារធ្វើនៅកន្លែងផ្សេងទៀត។

ខ្ញុំបានសំរេចចិត្តលែងប្តីហើយ ព្រោះគាត់អត់បានជួយរកប្រាក់ចំណូលដល់គ្រួសារនោះទេ ហើយនៅពេលដែលខ្ញុំរកលុយអត់សូវបានគាត់បានបង្កអោយមានរឿងរកាំរកូសក្នុងគ្រួសារ ហើយម្យ៉ាងទៀតគាត់គិតតែផឹកស្រាស្រវឹងរាល់ថ្ងៃ ដល់ពេលដែលខ្ញុំទ្រាំលែងបានក៏សំរេចចិត្តលែងគ្នាទៅ។ សព្វថ្ងៃខ្ញុំខំស្វែងរកការងារធ្វើនៅរោងចក្រផ្សេងៗ តែមានការលំបាកណាស់ព្រោះខ្ញុំអត់ចេះដេរ ហើយកាលពីមុនរោងចក្រខ្ញុំជារោងចក្រត្បាញ។ ប្រសិនបើខ្ញុំអត់មានការងារធ្វើ អ្នកដែលត្រូវ

រងគ្រោះនោះគឺមានច្រើននាក់ណាស់ ព្រោះឥលូវនេះខ្ញុំមានកូន៣នាក់ និងម្ដាយមីងចាស់ម្នាក់ ហើយខ្ញុំត្រូវដើរតួជាប្រពន្ធផងនិងប្ដីផងសំរាប់កូនៗរបស់ខ្ញុំ ដូច្នោះខ្ញុំត្រូវតែតស៊ូបន្តទៀតដើម្បីស្វែងរកការងារ ទោះបីជាលំបាកប៉ុណ្ណាក៏ទ្រាំធ្វើដែរឱ្យតែបានការងារធ្វើ។ ពី ១០ឆ្នាំមុន និងឥលូវនេះគឺខុសគ្នាឆ្ងាយណាស់ សំរាប់ខ្ញុំស្អីក៏ត្រូវចងការគេដែល សូម្បីលុយចងដៃការគេ ទិញម្ហូប ហើយពេលខ្លះក៏ជំពាក់គេ ហើយទំរាំរកបានមកទើបសងរំលួសគេវិញ ។ ពេលខ្ញុំពោះធំខ្ញុំធ្លាប់សន្លប់ ២-៣ដងដែលនៅក្នុងរោងចក្រ កាលនោះដោយសារតែពេលចេញពីធ្វើការខ្ញុំហូបមិនបានគ្រប់គ្រាន់។

ករណីសិក្សាទី ៣១

តំបន់ដង្កោ

ថ្ងៃទី ២៧ កក្កដា ២០០៥

ខ្ញុំឈ្មោះ ឃ.គ.ហ មានអាយុ៣៧ឆ្នាំ។ គ្រួសារខ្ញុំរស់នៅភូមិកញ្ចំ ឃុំកញ្ចំ ស្រុកពារាំង ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូន៥នាក់ ជាកូនទី៤ក្នុងគ្រួសារ ហើយខ្ញុំរៀនបានត្រឹមថ្នាក់ទី៨។ ម្តាយរបស់ខ្ញុំគាត់ចាស់ហើយ ខ្ញុំគ្មានឪពុកទេព្រោះគាត់បានស្លាប់តាំងពីខ្ញុំនៅតូចម្ល៉េះ។ គ្រួសាររបស់ខ្ញុំមានដីស្រែ ២ហិចតា ប៉ុន្តែម្តាយខ្ញុំលែងធ្វើស្រែកើតទៀតហើយ ដោយសារតែគាត់ជរាណាស់ទៅហើយ អ្នកដែលជួយធ្វើស្រែបានគឺប្អូនស្រីរបស់ខ្ញុំនិងប្តីរបស់នាង ។ ការធ្វើស្រែមួយឆ្នាំ១ទទួលបានផលមិនគ្រប់គ្រាន់សំរាប់ហូបចុកនោះទេ ណាមួយពេលធ្វើម្តង១គឺត្រូវខ្ចីលុយគេសំរាប់ចំណាយផ្សេង១ ពីបងប្អូននៅជិតខាងគេមិនបានយកការប្រាក់នោះទេ ពេលខ្លះត្រូវខ្ចីស្រូវគេមកហូបទៀត តែត្រូវសងគេវិញនៅពេលប្រមូលផលបាន (ខ្ចីគេមួយតៅពេលសងវិញ២តៅ)។ ខ្ញុំមិនអាចជួយធ្វើស្រែបានទេ ព្រោះខ្ញុំពិការជើងតាំងពីកំនើតមកម្ល៉េះ (ដើរកើតតែមិនល្អ)។

ទោះបីជាខ្លួនខ្ញុំពិការក៏ដោយតែនៅពេលដែលឃើញគ្រួសារពិបាកពេក ខ្ញុំក៏សំរេចចិត្តមករកការងារធ្វើខ្ញុំបានគិតថាទោះបីការងារអ្វីក៏ដោយក៏ខ្ញុំធ្វើដែរឱ្យតែបានប្រាក់ដើម្បីជួយផ្គត់ផ្គង់ដល់គ្រួសារ។ ពេលចេញពីភូមិដំបូងខ្ញុំមានលុយតែមួយម៉ឺនរៀលគត់ប៉ុណ្ណោះ ហើយខែនោះជាខែទឹកឡើង ទឹកបានលេចពេញភូមិ ដូច្នេះខ្ញុំត្រូវជិះទូកឆ្លងទឹកម្តង រួចទៅជិះរទេះសេះហើយទៅដេកនៅស្ពែពនមួយយប់ លុះព្រឹកឡើងខ្ញុំជិះកាណូតមកដល់ច្បារអំពៅ ហើយខ្ញុំមានបងបង្កើតជាអ្នករត់ម៉ូតូឌុបនៅច្បារអំពៅគាត់បានដឹកខ្ញុំទៅម្តុំពេទ្យចិន ។ ពេលនោះខ្ញុំរកការងារមិនបានធ្វើទេហើយលុយក៏អស់ទៀត ប៉ុន្តែខ្ញុំបានអ៊ុំជួយ គឺទៅហូបបាយនៅផ្ទះគាត់ដែលនៅជិតផ្សារច្បារអំពៅ។

ពេលរកការងារមិនបានខ្ញុំក៏សំរេចចិត្តទៅផ្ទះវិញ ហើយពេលទៅបានកន្លះខែខ្ញុំលក់កូនគោបានលុយ២ម៉ឺនរៀលហើយក៏ត្រលប់មករកការងារនៅភ្នំពេញម្តងទៀត ។ ខ្ញុំយកលុយមកទាំងអស់ក្នុងគោលបំណង មករកការងារធ្វើនៅអង្គការ។ ពេលមកដល់ខ្ញុំចុះនៅពេទ្យចិន ហើយដើររហូតដល់ខាងត្បូងវិមានឯករាជ្យវត្តថាន់ ហើយមានអង្គការនៅក្នុងនោះឈ្មោះម៉ារីណុល ហើយពេលចូលទៅដល់អ្នកនៅទីនោះសួរខ្ញុំថាមកធ្វើអី? ហើយខ្ញុំឆ្លើយថាមករកការងារធ្វើ តែគេនិយាយតបថាមិនយកទេ។ តែពេលនោះខ្ញុំបានជួបប្រធានអង្គការម្នាក់ឈ្មោះ តាម៉ាក់ និងស្រីម្នាក់ ឈ្មោះ ផាត ធី។ ហើយតានោះបានសួរខ្ញុំថាស្រុកកំនើតនៅឯណា? ហើយគេបានកត់ឈ្មោះខ្ញុំ និងប្រាប់ខ្ញុំថាមួយខែទៀតទើបគេយក គេថែមទាំងប្រាប់ថាបើនៅស្រុកស្រែគេមិនយកទេ ដូច្នោះ ខ្ញុំបានកុហកគេថា ខ្ញុំរស់នៅខេត្តកណ្តាលទើបគេយកខ្ញុំ។

មួយខែក្រោយមកខ្ញុំក៏បានចូលធ្វើការនៅទីនោះ ជាដំបូងគេឱ្យរៀនវាយអង្គលីលេខខ្មែរ ហើយក្រោយមកទើបគេឱ្យវាយជាភាសាអង់គ្លេសរហូតដល់៦ខែទើបចប់។ គេឱ្យលុយមួយអាទិត្យ ១៥០០០រៀល ក្នុងរយៈពេល ៣ខែដំបូង ហើយ

បន្ទាប់មកគេឱ្យ ៤០ដុល្លាក្នុងមួយខែ ។ ខ្ញុំធ្វើការបានមួយឆ្នាំកន្លះក៏ចប់អាណិត្តទៅ ហើយខ្ញុំក៏ត្រលប់មកផ្ទះវិញ។ ៣ឆ្នាំក្រោយមក ខ្ញុំក៏ត្រលប់មករកការងារធ្វើវិញម្តងទៀត។

ខ្ញុំមានក្មួយប្រុសម្នាក់វាបានទាក់ទងមិត្តភក្រ្តិដែលវាស្គាល់ អោយគេជួយខ្ញុំហើយនាំទៅធ្វើជាអ្នកចាំផ្ទះឱ្យគេ ក្នុងមួយខែបាន១០ដុល្លា ខ្ញុំបានធ្វើនៅទីនោះត្រឹមតែ៦ខែប៉ុណ្ណោះ បន្ទាប់មកប្អូនម្ចាស់ផ្ទះក៏សុំយកទៅបាត់ដំបង ឱ្យជួយបង្រៀនអក្សរខ្មែរដល់កូនក្មេង និងធ្វើជាអ្នកធ្វើម្ហូប។ គេឱ្យមួយខែ ១០ដុល្លាដដែល ហើយខ្ញុំធ្វើបាន៦ខែក៏ត្រលប់មកផ្ទះម្ចាស់មុនវិញ។ ខ្ញុំនៅបានកន្លះខែក៏លឺដំនឹងថាបងស្រីរបស់ខ្ញុំគាត់ស្លាប់ ហើយខ្ញុំក៏ត្រលប់ទៅផ្ទះវិញទៅធ្វើបុណ្យអោយគាត់។ ២ឆ្នាំក្រោយមកខ្ញុំក៏មកវិញដើម្បីរកការងារធ្វើ ហើយខ្ញុំក៏បញ្ចាំដីស្រែអស់កន្លះហិចតាបាន ១០ម៉ឺន។ តែខ្ញុំយកតែ៦ម៉ឺនរៀលប៉ុណ្ណោះ គឺខ្ញុំទុកឱ្យម៉ែ ៤ម៉ឺន។

ខ្ញុំបានទៅរកការងារធ្វើនៅអង្គការ អិន ស៊ី ឌី ភី ហើយអង្គការនេះបាននាំខ្ញុំចូលធ្វើការនៅរោងចក្រ ***វែរវែល*** នៅផ្នែករដ្ឋបាល។ ចូលដំបូងគេឱ្យខ្ញុំដេរតែខ្ញុំមិនចេះដេរទេ ប្រធានក្រុមបានរុញខ្ញុំពីក្រុមមួយទៅក្រុមមួយទៀត ពេលនោះខ្ញុំមានការភ័យខ្លាចណាស់ ព្រោះខ្ញុំខ្លាចគេដេញចេញពីការងារ។ ខ្ញុំធ្វើការបាន ៣ខែ គេក៏ឱ្យខ្ញុំក្លាយជាកម្មករពេញសិទ្ធ។

នៅរោងចក្រនេះដេរម៉ាក់លីវ៉ាយ ចាប់តាំងពីខ្ញុំបានធ្វើការនៅរោងចក្រនេះមកខ្ញុំមិនដែលគិតចង់ប្តូររោងចក្រទេ ហើយខ្ញុំធ្វើការនៅទីនេះបាន៦ឆ្នាំហើយ។ ពេលណាខ្ញុំធ្វើការមិនគ្រប់ចំនួនគេ គេហៅទៅស្តីឱ្យម្តងម្កាលដែរ ហើយសូម្បីផ្នែករដ្ឋបាលក៏ស្តីឱ្យខ្ញុំដែរដោយមិនគិតថាខ្ញុំពិការទេ។ ប្រាក់ឈ្នួលដែលខ្ញុំបានក្នុងមួយខែនោះ គឺប្រហែលជា ៧០ដុល្លារាប់បញ្ចូលទាំងការថែមម៉ោង ប៉ុន្តែបើអត់ថែមម៉ោងគឺប្រហែលជា ៥៥ដុល្លាប៉ុណ្ណោះ ។ ខ្ញុំអត់ដឹងថាទេថាថៅកែក្នុងរោងចក្រនេះជាជនជាតិអ្វីនោះទេ តែដឹងថាមានសហជីព មួយគឺសហជីពសេរីកម្មករ ខ្ញុំក៏បានចូលជាសមាជិកសហជីពដែរ។

ជារៀងរាល់ខែខ្ញុំបានផ្ញើរលុយកាក់ខ្លះប្រហែលជា ៣០ដុល្លា សំរាប់ជួយផ្គត់ផ្គង់ដល់គ្រួសារនៅឯស្រុក ហើយលុយទាំងនោះសំរាប់ចំណាយទៅលើការដាក់ជីស្រែ ថ្នាំសង្កូវខ្លះសំរាប់ម្តាយខ្ញុំ និងការជួសជុលផ្ទះសម្បែងខ្លះ។ ក្នុងមួយខែខ្ញុំចំណាយអស់ប្រហែលជា ៤០ដុល្លា សំរាប់ថ្លៃផ្ទះជួល ទឹកភ្លើង ម្ហូបអាហារ និងការចំណាយផ្សេងៗទៀត។ អ្នកដែលនៅម្តុំផ្ទះជួលនេះមិនមានការរើសអើងចំពោះខ្ញុំទេ ទោះបីជាគេដឹងថារូបខ្ញុំនេះជាមនុស្សពិការក៏ដោយ ពួកគេរាប់អានខ្ញុំដូចជាបងប្អូនអញ្ចឹង។

ខាងរោងចក្រមានគំរោងគិតចង់ដកអ្នកអនាម័យចេញ ដោយទុកឱ្យកម្មករធ្វើអនាម័យដោយខ្លួនឯងនៅ លើម៉ាស៊ីនដេររបស់ខ្លួន តែពេលនោះអ្នកអនាម័យនិងកម្មករមិនព្រមនោះទេ ។ នៅពេលធ្វើកូដកម្មម្តងៗមិនឃើញ មានអ្វីកែប្រែនោះទេទោះជារឿងការងារបង្ខំ រឺក៏អ្នកអនាម័យក៏ដោយ ហើយនៅពេលដែលចូលទៅធ្វើការវិញនោះ គឺគេបង្ខំអោយធ្វើការលើសដើម ហើយផ្នែកអនាម័យនោះគេថានិងដោះស្រាយ។

ខ្ញុំបានលឺខ្លះដែលពីរឿងកូតា ខ្ញុំបានឃ្លាំមើលថាតើនិងមានអ្វីកើតឡើងបន្ទាប់កូតាត្រូវបានបញ្ចប់នោះ ជាក់ស្តែងដូចជាស្ថានភាពនៅក្នុងរោងចក្ររបស់ខ្ញុំ **(វីវីល)** ពិតជាមានការផ្លាស់ប្តូរច្រើនមែនដូចជាពួកយើង ត្រូវបានគេដាក់ចំនួនកូតាខ្ពស់ជាងមុនក្នុងមួយថ្ងៃ ១០០០ខោ ដូច្នេះយើងត្រូវខំប្រឹងធ្វើការអោយខ្លាំងជាងដែរ ការសុំច្បាប់មានការពិបាក លុះត្រាដែលមានលិខិតបញ្ជាក់ពីប្រធានផ្នែកទើបយើងអាចឈប់បាន បើមិនដូច្នោះទេគឺមិនអាចឈប់បាននោះទេ ។

នៅថ្ងៃខាងមុខខ្ញុំមានការភ័យខ្លាំងណាស់ ប្រសិនជារោងចក្រត្រូវបានបិទទ្វារមែននោះ ព្រោះអីរូបខ្ញុំជាជនពិការមិនដឹងថាមានរោងចក្រណាក្រៅពីនេះគេនិងទទួលខ្ញុំអោយធ្វើការនោះទេ។ ខ្ញុំគិតថានិងត្រឡប់ទៅស្រុកវិញ ខ្ញុំចង់លក់ដូរអីវ៉ាន់បន្តិចបន្តួចនៅឯស្រុក ហើយម្យ៉ាងទៀតខ្ញុំអាចនៅជិតបងប្អូនគ្រាន់អាចជួយគ្នាពេលឈឺថ្កាត់អី ហើយខ្ញុំសង្ឃឹមថានិងមានចិញ្ចឹម ជ្រូក មាន់ ទា សំរាប់ចិញ្ចឹមជីវិតទៅអនាគត ។

ករណីសិក្សាទី ៣២

ថ្ងៃទី ១៩ កក្កដា ២០០៥

នាងខ្ញុំឈ្មោះ ន ណ រស់នៅភូមិជោរីទី២ឃុំក្រញូង ស្រុកកំចាយមារ ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូន៥នាក់ហើយខ្ញុំជាកូនទី២។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី១២នៃវិទ្យាល័យកំចាយមារ សាលារៀននៅឆ្ងាយពីផ្ទះរបស់ខ្ញុំដែរ តែខ្ញុំមានកង់មួយសំរាប់ជិះទៅសាលា។ គ្រួសារខ្ញុំមានដី១ហិចតាកន្លះតែស្រែនោះនៅឆ្ងាយពីផ្ទះណាស់ ហើយពេលទៅធ្វើម្តងៗ គឺត្រូវទៅនៅទីនោះប្រហែលជា ៧-១០ថ្ងៃ ក្រុមគ្រួសាររបស់ខ្ញុំបានជួលស្រែ គេខ្លះបន្ថែមទៀតនៅជិតផ្ទះជារៀងរាល់ឆ្នាំ ។ ស្រែដែលជួលគេធ្វើនោះពេលច្រូតកាត់ហើយ ត្រូវអោយស្រូវទៅម្ចាស់គេខ្លះ ហើយស្រូវដែលសល់បន្តិចបន្តួចនោះទុកគឺសំរាប់ហូប ប៉ុន្តែប្រសិនជាមានទឹកជំនន់នោះ គ្រួសារខ្ញុំគ្មានបានផលស្រូវអីបន្តិចនោះទេ។ គ្រួសារខ្ញុំមានគោ៤ក្បាល គឺមេ២និងកូន២។

មានម្តងនោះឪពុករបស់ខ្ញុំគាត់មានជំងឺជាទំងន់ ម្តាយរបស់ខ្ញុំបានលក់គោអស់មួយក្បាលដើម្បីមើលជំងឺគាត់ ហើយថែមទាំងខ្ចីលុយពីបងប្អូនខ្លះទៀត។ កាលនោះខ្ញុំក៏ប្រលងធ្លាក់ថ្នាក់ទី១២ទៀត ខ្ញុំពិបាកចិត្តខ្លាំងណាស់ មិនដឹងត្រូវធ្វើយ៉ាងណានោះទេ ហើយមិត្តភក្តិខ្ញុំភាគច្រើនក៏មករកងារធ្វើនៅភ្នំពេញទៀត ដូច្នេះខ្ញុំក៏សំរេចចិត្តមករកការងារធ្វើនិងគេ ពេលនោះគឺមកជាមួយបងប្អូននៅក្នុងភូមិ អ្នកដែលមានការងារធ្វើរួមហើយ ខ្ញុំមកដំបូងមានលុយត្រឹមតែ ១០ម៉ឺនរៀលគត់។ ខ្ញុំបានមកនៅជាមួយបងប្អូនមួយរយៈ ហើយបានរៀនដេរអស់កន្លះខែដែរមុននិងដើរធ្វើតេស្តតាមរោងចក្រ ប៉ុន្តែខ្ញុំនៅតែមិនអាចរកការងារបានធ្វើ ខ្ញុំបានចំណាយអស់លុយកាក់ដែលយកមកពីផ្ទះ ហើយថែមទាំងខ្ចីលុយគេអស់២០ដុល្លាទៀតផង។

បន្ទាប់មកខ្ញុំក៏ធ្វើតេស្តជាប់នៅរោងចក្រ **វៃវៃល** ពេលចូលធ្វើការនៅរោងចក្រនេះត្រូវខាងរោងចក្របង្ខំអោយធ្វើការយ៉ាងខ្លាំងដោយមិនគិតថាអ្នកចូលថ្មីរឺក៏អ្នកចាស់ទេ គេគិតថាសុទ្ធតែអ្នកចេះដេរទាំងអស់។ ខ្ញុំធ្វើការខាងតិះ ខ្ញុំត្រូវចិនបង្ខំឱ្យធ្វើគ្រប់ចំនួនតាមការកំនត់ដែលគេដាក់អោយ។ ពេលខ្ញុំតិះមិនទាន់ត្រូវគេស្តីអោយ ហើយកម្មករទាំងអស់ត្រូវចូលមុន ១៥នាទី ដើម្បីកុំឱ្យខោក្នុងរោងចក្រគរច្រើនពេក។ ខ្ញុំមិនដែលថែមម៉ោងទេ គឺខ្ញុំចេញម៉ោង ៣:៣០ ពេលព្រឹកខ្ញុំត្រូវចូលដល់ក្នុងរោងចក្រនៅម៉ោង៦:៤៥នាទី ព្រោះរោងចក្រត្រូវបិទទ្វារ ហើយពេលចូលភ្លាមខ្ញុំត្រូវទៅធ្វើការភ្លាម ព្រោះខ្លាចមិនទាន់គេ។

រោងចក្របានអោយសោរ២ក្នុងមួយក្រុមសំរាប់ទៅបន្ទប់ទឹកដែលមានកម្មករប្រហែលជា ៤០នាក់។ ពេលចូលដំបូងខ្ញុំមិនហ៊ានទៅបន្ទប់ទឹកទេព្រោះខ្ញុំអត់ស្គាល់ ខ្ញុំទ្រាំរហូតដល់មួយអាទិត្យទើបខ្ញុំស្គាល់ថាបន្ទប់ទឹកនៅកន្លែងណា។ ពេលធ្វើការបាន១១ថ្ងៃ ចិនបើកលុយឱ្យបាន២៥ដុល្លា តែខ្ញុំពុំទាន់សងគេទេ គឺទុកលុយនេះសំរាប់ចាយខែបន្ត។ ខ្ញុំត្រូវរើផ្ទះមកនៅជិតរោងចក្រ។ ការរស់នៅផ្ទះជួលខ្ញុំមានការពិបាកណាស់ ម៉ោង៨គត់គេបិទភ្លើងឈប់អោយប្រើទៀតហើយ ចំណែកង

ម្ចាស់ផ្ទះជួលវិញក៏ចិត្តអាក្រក់ និងមិនសូវចូលចិត្តកម្មករដែលមកជួលផ្ទះទេ។ ពេលមានបងប្អូនមកលេងម្តងៗវិញ គេទៅសួរដេញដោលច្រើនណាស់ ហើយជួនកាលពេលបងប្អូនយើងមកសួររកគេឆ្លើយថាមិនស្គាល់ រឺមិនដឹងតែម្តង។ ខ្ញុំគិតថាប្រសិនជារោងចក្របិទទ្វាររមែននៅថ្ងៃមុន ខ្ញុំនិងត្រលប់ទៅផ្ទះវិញ ហើយធ្វើស្រែជាមួយគ្រួសារវិញ ។ ខ្ញុំគិតថាខ្ញុំ និងទិញម៉ាស៊ីនកិនស្រូវ១ នឹងចិញ្ចឹមជ្រូកខ្លះ ។ បើខ្ញុំមានម៉ូតូខ្ញុំនឹងទៅទិញស្រូវយកមកកិន ហើយលក់អង្ករតិចតួច និងចិញ្ចឹមមាន់ទាខ្លះ ទុកសំរាប់ចិញ្ចឹមជីវិតទៅថ្ងៃអនាគត។

ករណីសិក្សាទី ៣៣
តំបន់ព្រៃទា
ថ្ងៃទី០៣ ខែ០២ ២០០៦

ត្រា ជាក្មេងស្រីម្នាក់អាយុ១៨ ឆ្នាំ មានបទពិសោធន៏ធ្វើការក្នុងរោងចក្រនៅភ្នំពេញបាន ៣ឆ្នាំមកហើយ ។ ក្រុមគ្រួសាររបស់ខ្ញុំរស់នៅខេត្តកំពង់ចាម ម្តាយជាមេផ្ទះ ឪពុកជាទាហាន ហើយនិងមានប្អូនប្រុសម្នាក់ ប៉ុន្តែឪពុករបស់ខ្ញុំបានស្លាប់អស់រយ:ពេល១០ឆ្នាំមកហើយ ដោយសារការឆក់ខ្សែភ្លើង ។ ក្រោយមកដោយសារតែស្ថានភាពគ្រួសារលំបាកហើយមិនមានមុខរបរពិតប្រាកដ ម្តាយរបស់ខ្ញុំបានសំរេចចិត្តលក់ផ្ទះដើម្បីមករស់នៅទីក្រុង គិតថានឹងអាចមានមុខរបរជាក់លាក់មួយដើម្បីចិញ្ចឹមជីវិត ។ ក្រុមគ្រួសាររបស់ខ្ញុំបានមករស់នៅជាមួយបងប្អូននៅភ្នំពេញ ហើយលុយដែលលក់ផ្ទះបាននៅឯស្រុក បានទិញដីសំរាប់ធ្វើផ្ទះនៅ ។ ប្អូនប្រុសខ្ញុំរៀនបានថ្នាក់ទី៣ ហើយវាមានអាយុ១០ឥឡូវនេះ ។ ម្តាយរបស់ខ្ញុំបានលក់បង្អែមនៅមុខរោងចក្ររកប្រាក់ដើម្បីជួយគ្រួសារ នឹងអោយពួកខ្ញុំទៅរៀនសាលា ក្នុងមួយថ្ងៃគាត់អាចចំណេញបាន ៥០០០រៀល ។ ការរកស៊ីវាមិនបានគ្រប់គ្រាន់សំរាប់ការចំណាយនោះទេ ជាហេតុធ្វើអោយខ្ញុំសំរេចចិត្តឈប់រៀនត្រឹមថ្នាក់ទី៦ ហើយចូលធ្វើការងារក្នុងរោងចក្រ ពេលនោះម្តាយរបស់ខ្ញុំ គាត់ឥតទំទើសនិងខ្ញុំនោះទេ ។

ចូលធ្វើការដំបូងខ្ញុំបានចំណាយលុយអោយទៅអ្នកដែលនាំចូលអស់ ២០ដុល្លា ខ្ញុំអត់ចាំឈ្មោះរោងចក្រនោះទេ តែខ្ញុំដឹងត្រឹមថាវាជាសាខារបស់រោងចក្រធំមួយ ខ្ញុំបានធ្វើការនៅទីនោះបានជិតមួយឆ្នាំ ជាមួយនិងប្រាក់កំរៃប្រចាំខែប្រហែល៤០ដុល្លា ព្រោះតែតំលៃបុងនៅក្នុងរោងចក្រនេះវាទាបពេក ហើយម្យ៉ាងវិញទៀតនៅក្នុងរោងចក្រនេះគ្មានសហជីពក៏គ្មានតំណាងនោះទេ នឹងគ្មានកម្មករហ៊ានតវ៉ានោះទេ ភាគច្រើនសូម្បីតែថ្ងៃអាទិត្យក៏ត្រូវធ្វើការដែរ ។ ដោយសារតែមានការគាបសង្កត់ពីរោងចក្ររឿងថែមម៉ោងទាំងថ្ងៃអាទិត្យនេះហើយ ទើបខ្ញុំសំរេចចិត្តឈប់ធ្វើការនៅទីនោះ ។ មិនយូរប៉ុន្មានខ្ញុំក៏ចូលធ្វើការនៅរោងចក្រ **ឈាវយ៉ូ** ដំបូងជាកម្មករបណ្តែតសំរាប់រយ:ពេល៣ខែ កំឡុងពេលនោះខ្ញុំមិនដែលហ៊ានសុំច្បាប់ឈប់នោះទេ ព្រោះខ្លាចគេបញ្ឈប់ពីការងារ ។ ក្រោយក្លាយជាកម្មករពេញសិទ្ធិមានម្តងនោះខ្ញុំបានសុំច្បាប់ទៅមើលម្តាយឈឺធ្ងន់រយ:ពេល៣ថ្ងៃ តែគេអោយខ្ញុំត្រឹមតែ២ថ្ងៃប៉ុណ្ណោះព្រោះខ្ញុំសុំត្រឹមតែមេ កន្រ្តៃចិនដែលជាអ្នកគ្រប់គ្រង មិនបានសុំទៅប្រធានធំនោះទេ ។ នៅពេលដែលមានអ្នកឈឺ ហើយការសុំច្បាប់កាន់តែច្រើនឡើងៗ ខាងរោងចក្របានអោយរដ្ឋបាលធ្វើការតាមដានលើកម្មករដែលសុំច្បាប់ ព្រោះខ្លាចមានការបន្លំ អ្នកខ្លះអត់ឈឺទៅតែសុំសំបុត្រពេទ្យមកបញ្ជាក់ដើម្បីបានច្បាប់សំរាក ។

រោងចក្រឈាវយ៉ូនេះអត់សូវមានការងារធ្វើទេនៅដើមឆ្នាំ២០០៥ រហូតមកដល់ឆ្នាំ២០០៦នេះ ប្រាក់ឈ្នួលបានប្រហែល៤០ទៅ៥០ដុល្លារួមទាំងលុយព្រីម៥ដុល្លាសំរាប់អ្នកធ្វើនៅផ្នែកដេរ តែផ្នែកចល័តវិញនោះបានត្រឹមតែ២០ទៅ៣០ដុល្លាក្នុងមួយខែគឺស្មើនឹង៥០ភាគរយនៃប្រាក់ឈ្នួល ហើយពួកគេត្រូវខាងរោងចក្រអោយត្រឡប់ទៅផ្ទះជាញឹកញាប់ ព្រោះតែ

មិនត្រូវមានការងារធ្វើច្រើនដូចមុន។ រហូតមកដល់ពេលនេះរោងចក្រនេះមានកម្មករប្រហែល ១៨០០នាក់ ក្នុងនោះដែលមានកម្មករបំរើការ៦ផ្នែក ដូចជាៈ ផ្នែកដេរ តុកាត់ សាប់ ត្រួតពិនិត្យ កាត់ប្រុយ អ៊ុត វាយឡេវ និងស្រេះ។

មួយខែក្រោយនេះខ្ញុំអាចទទួលបានប្រាក់ឈ្នួលប្រហែលជិត៨០ដុល្លា ដោយសារតែរោងចក្រមានការងារអោយធ្វើ ហើយរួមផ្សំទាំងប្រាក់ថែមម៉ោងដល់ម៉ោង៦ល្ងាចទៀត ពេលថែមម៉ោងខាងរោងចក្រផ្តល់អោយ ១០០០រៀល សំរាប់ថ្លៃបាយ ហើយពេលខ្លះរហូតដល់ម៉ោង៨យប់ គេអោយសរុប១៥០០រៀល។ ដោយសារតែមានកម្មករច្រើននៅក្នុងរោងចក្រ គេបានបែងចែកជាក្រុមតូចៗដោយមានប្រធានក្រុមម្នាក់ជាអ្នកមើលការខុសត្រូវ ប៉ុន្តែខ្ញុំមានអារម្មណ៍បានប្រធានក្រុមខ្មែរភាគច្រើនមិនបានកាន់ជើងខ្មែរនោះទេ ដូចជាមានមិត្តភ័ក្តខ្ញុំម្នាក់ឈឺ នាងមិនបានដេរអោយលឿនដូចដែលខាងរោងចក្រចង់បាននោះទេ ពេលដែលចិនសួរនាំហេតុអ្វីបានជាអ្នកដេរយឺតម្ល៉េះ ប្រធានក្រុមនោះមិនបានជួយទេ ថែមទាំងស្តីអោយនាង ហើយប្រាប់ចិនថានាងខ្ជិល តែបន្ទាប់ពីចិនមើលមុខវាដឹង ហើយក៏ដើរចេញទៅដោយមិនថាអីឱ្យនោះទេ។

ខ្ញុំជាសមាជិកសហជីពមួយដែលធ្វើការបំរើកម្មករនៅក្នុងរោងចក្រនេះ គេប្រាប់ថានិងជួយដោះស្រាយបញ្ហាទំនាស់នៅក្នុងរោងចក្រជាមួយចិន និងបញ្ហាសុំច្បាប់។ សហជីពនោះមានឈ្មោះថាសាមគ្គីអភិវឌ្ឍន៏កម្មករនៃរោងចក្រឈាវយ៉ូ ដែលមានប្រធាន ឈ្មោះ សែម យូរ៉ាក់ផាន់។ ខ្ញុំបានដឹងថាសហជីពនេះមានសមាជិកទាំង ប្រហែល១៧០០នាក់ហើយ ជារៀងរាល់ខែគេអត់ដែលដើរប្រមូលលុយពីកម្មករនោះទេ គឺគេសុំខាងគណនេយ្យកាត់លុយចេញពីប្រាក់ខែរបស់កម្មករផ្ទាល់តែម្តង។ នៅពេលនេះសហជីព និងតំណាងបានកំពុងតែធ្វើការតវ៉ាតំលៃបុង ដែលពីមុន ១០០ខោ ស្មើ ២០០០រៀល តែឥឡូវខាងរោងចក្របានបញ្ចុះអោយត្រឹមតែ១២០០រៀលប៉ុណ្ណោះ គេបាននិយាយនិងផ្តល់លទ្ធផល៣ថ្ងៃខាងមុខនេះ។ ខ្ញុំគិតថាទោះបីជាមិនបានក៏ពួកយើងគ្មានជំរើសនោះទេ គឺត្រូវតែដេរអោយគេដដែល។ ចំពោះផ្នែកខ្ញុំគេកំនត់អោយដេរក្នុងមួយថ្ងៃអោយបាន៦០០ ហើយបើយើងដេរអត់គ្រប់ក្នុងរយៈពេល៣ថ្ងៃ នោះគេហៅទៅប្រមានដោយការស្តីឱ្យម្តង។ ថៅកែរោងចក្រឆ្លាតណាស់គេដឹងថាផ្នែកណាដែលទន់ខ្សោយ ដូចជាផ្នែកកាត់ព្រុយ និងត្រួតពិនិត្យ ដូច្នេះត្រូវបានគេបង្ខំអោយថែមម៉ោងរហូតដល់ម៉ោង១១យប់ ហើយពេលខ្លះរហូតទល់ភ្លឺក៏មាន តែពួកគេអត់ហ៊ានតវ៉ានោះទេ ព្រោះខ្លាចបាត់បង់ការងារធ្វើ ហើយណាមួយទៀតចង់បានលុយផងដែរ។

ឥឡូវនេះខ្ញុំចាប់ផ្តើមមានអារម្មណ៍ថាមុនឆ្នាំ២០០៥ សហជីពអាចធ្វើការទាមទារតវ៉ាបានច្រើនសំរាប់កម្មករ តែឥឡូវនេះវិញអត់សូវបាននោះទេ ជួនបានជួនអត់បាន។ តែគួរអោយឆ្ងល់ដែល ខ្ញុំបានឃើញតំណាងកម្មករ រដ្ឋបាល នឹងគណនេយ្យត្រូវរ៉ូវគ្នាណាស់។

សព្វថ្ងៃនេះខ្ញុំរស់នៅជាមួយអ៊ុំខាងម្ដាយរបស់ខ្ញុំនៅជិតរោងចក្រ ហើយជារៀងរាល់ខែខ្ញុំបានអោយថ្លៃផ្ទះគាត់ចំនន្ទ ៥ដុល្លា និងថ្លៃម្ហូបអាហារចំនួន៣0,000រៀលគឺសំរាប់តែអាហារពេលល្ងាចតែប៉ុណ្ណោះ។ ខ្ញុំធ្វើការនៅរោងចក្រទើបតែបាន៣ឆ្នាំ ប៉ុណ្ណោះតែខ្ញុំមានអារម្មណ៏ធន់ថប់និងរោងចក្រណាស់ អត់មានសេរីភាព និងសុខភាពក៏មិនសូវល្អប៉ុន្មានដែរ។ ខ្ញុំបានគិត ហើយប្រសិនបើមួយឆ្នាំទៀតខ្ញុំអាចសន្សំលុយកាក់បានខ្លះ ខ្ញុំគិតទៅដេរជាមួយបងស្រីជីដូនមួយរបស់ខ្ញុំហើយ គាត់ធ្វើការ នៅហាងកាត់ដេរសំលៀកបំពាក់ម៉ូតមួយនៅផ្សារដេប៉ូ នៅទីនោះនិងមានសេរីភាពជាងធ្វើការនៅរោងចក្រ ។

ករណីសិក្សាទី ៣៤
វិច្ឆិកា ២០០៥

ក សរន អាយុ២៨ឆ្នាំ មានស្រុកកំណើតនៅសំរោងក្អែរ ឃុំសំរោង ស្រុកកៀនស្វាយ ខេត្តកណ្តាល។ នាងមានបងប្អូន៧នាក់ ប្រុស៤នាក់ ស្រី៣នាក់។ នាងជាកូនទី១ បានរៀបការ ហើយមានកូន២នាក់ ។ កូនបងមានអាយុ១០ឆ្នាំ រីឯកូនប្អូនអាយុ៩ឆ្នាំ។ប៉ុន្តែនាងបានលែងលះគ្នាហើយដោយសារតែគាត់ខឹងប្តីរបស់ គាត់មិនចេះរកស៊ីអ្វីទេ ហើយខ្ជិលទៀត។ ប្តីគាត់មានមុខរបរជាជាងធ្វើឡានហើយមិនដែលសល់លុយកាក់អ្វីសោះ ចាយវាយខ្ជះខ្ជាយមិនខ្វាយខ្វល់អ្វីទាំងអស់។ នៅពេលដែលប្តីឈឺ នាងបានចំណាយលុយអស់ជាច្រើនក្នុងការថែរក្សា និងព្យាបាលគាត់។ នាងនៅផ្ទះជាមួយឪពុកម្តាយនាង ហើយបានជួយដាំបន្លែបង្ការដោយមិនដែលមានពេលទំនេរសោះ ទាំងនេះគឺដើម្បីតែជីវភាពគ្រួសារ។ នាងមិនសូវខ្វះខាតក្នុងការហូបចុកទេ ព្រោះគ្រួសារនាងអាចបានផលច្រើនពីការដាំបន្លែ តែក្រោយមកនាងមិនអាចប្រមូលផលបន្លែបានដូចមុនដោយសារតែពេលធ្វើម្តងៗមានចំណាយច្រើនជាងមុន នាងក៏សំរេចចិត្តមកធ្វើការនៅភ្នំពេញជាកម្មករបណ្តែតនៅរោងចក្រ **វីវីល** ពេលនោះដោយសំណាងល្អគេទទួលនាងធ្វើការដោយមិនអស់កំរៃអ្វីទេ ។ នាងធ្វើការនៅវេនយប់នៅក្នុងរោងចក្រ នាងគិតថាធ្វើអ្វីក៏ធ្វើបានដែលអោយតែបានលុយ។

*"នៅពេលដែលធ្វើការដំបូង ខ្ញុំត្រូវបានគេកំនត់អោយធ្វើការទៅតាមការកំណត់របស់គេ បើមិនអាចធ្វើទៅតាមដែលអ្វីគេបញ្ជានោះទេ ខ្ញុំនឹងត្រូវគេស្តីអោយ រឺក៏អាចបណ្តេញចេញពីការងារ។ ពួកគេបញ្ជាអោយខ្ញុំដិនអង្កាំនៅលេ រ៉ូបអោយបាន២០រ៉ូបក្នុង១ម៉ោង ហើយក្នុង១ថ្ងៃទទួលបានប្រាក់៩២០០រៀល ដោយចូលធ្វើការពីម៉ោង៦ល្ងាចចេញ ម៉ោង៤ភ្លឺ និងសំរាក១ម៉ោងជាមួយបាយ១កញ្ចប់។"*

នៅរោងចក្រប្រសិនបើកម្មករណានៅផ្ទះឆ្ងាយគេនឹងមានឡានជូនទៅផ្ទះ ចំពោះខ្ញុំវិញបានជួលផ្ទះនៅជាមួយបងប្អូនដោយក្នុងមួយបន្ទប់តំលៃ២០ដុល្លា។ ក្នុងមួយបន្ទប់មានមនុស្សពី៨ទៅ៩នាក់ អ្នកខ្លះអត់មានការងារធ្វើទេ អ្នកខ្លះត្រូវដេកក្នុងបន្ទប់ដែលគ្មានអនាម័យប្រកបដោយបរិយាកាសអាប់អួល ជួនកាលអត់មានទឹកជួនកាលមាន ហើយត្រូវដេកផ្ទាល់នឹងអដ្ឋ។

*" ខ្ញុំធ្វើការនៅវីវីលបានរយះពេល៣ខែក៏ត្រូវឈប់ដោយសារតែរោងចក្ររំសាយកម្មករ និងអត់មានអ្វីធ្វើទេ។ ក្រោយមកក៏ទៅធ្វើនៅរោងចក្រហុងវ៉ាខាងត្រួតពិនិត្យ និងអ៊ុត។ ខ្ញុំធ្វើជាកម្មករបណ្តែតមិនកំនត់ទេ ត្រូវធ្វើការពីម៉ោង៤រហូតដល់ម៉ោង១២យប់ និងត្រូវថែមម៉ោងដល់ម៉ោង៦ព្រឹក ហើយអត់មានបានឡានជូនទៅទេ។ បើយើងធ្វើការថែមម៉ោងយើងអាចទទួលបាន៤ដុល្លា។ ការងារនៅក្នុងរោងចក្រនោះឥតទៀងទាត់ទេ ជួនកាលធ្វើបាន១អាទិត្យទៅ២អាទិត្យ រឺ១ខែ ក៏ត្រូវរំសាយចេញពីការងារ ហើយខាងរោងចក្រគេធ្វើការរើសកម្មករថ្មីទៀត។ មានពេលខ្លះដែលខ្ញុំចេញពីធ្វើការនៅពេលពាក់កណ្តាលយប់ម៉ោង១២ ខ្ញុំមានអារម្មណ៍ភ័យខ្លាចដោយម្តងៗ នោះមានពួកក្រុមស្ទាវបានជិះម៉ូតូដេញ*

*តាមឆាបខ្ញុំ ។ អស់រយៈពេល៣ឆ្នាំដែលខ្ញុំធ្វើការនៅរោងចក្រ* ***ហុងវ៉ា*** *ខាងផ្នែកអ៊ុតកាត់ជាកម្មករបណ្ដែត ។ ដំបូងឡើយខ្ញុំធ្វើនៅអាគារខាងក្រោយខាងផ្នែកអ៊ុតកាត់បានរយៈពេល២ខែ រួចក៏ត្រូវគេរំសាយទៀត ។ នៅពេលដែលរោងចក្រខ្វះកម្មករខាងដេរកែខោ និងដេរផ្លាក ខ្ញុំក៏ចូលទៅដេរនៅទីនោះម្ដងទៀត ។ ចិនប្រាប់អោយកត់បុងអោយបានច្រើនទើបយកទៅដាក់បុង ប៉ុន្តែនៅពេលដែលយកបុងច្រើនទៅដាក់ មេក្រុមស្រែកថាដាក់អីក៏ច្រើនម្ល៉េះ តែពេលនោះបានអ្នករួមការងារគេជួយចែករំលែកយកបុងនោះខ្លះ ដូចនេះខ្ញុំមិនសូវត្រូវគេស្ដីឱ្យច្រើន ។"*

នាងធ្វើការបាន២០ថ្ងៃទទួលបានប្រាក់ខែ៧០ដុល្លា ហើយធ្វើនៅទីនោះបានតែ២ខែប៉ុណ្ណោះក៏ត្រូវគេរំសាយពីរោងចក្រទៅដោយសារគេមិនចូលចិត្តកម្មករបណ្ដែត ។ បន្ទាប់មកនាងបានដើរធ្វើតេស្តតាមរោងចក្រដើម្បីស្វែងរកការងារធ្វើទៀត *"ក្រោយមកខ្ញុំក៏មកធ្វើការនៅរោងចក្រយូរ៉ូបភៀនខាងផ្នែកដេរដោយស៊ីប្រាក់ខែ និងដេរអត់មានកំណត់ទេ តែបើលើសភាគរយគេអោយលុយរង្វាន់ ។ នៅពេលថែមម៉ោងខ្ញុំអាចធ្វើរឺមិនធ្វើតាមតែចិត្តចង់ ខាងរោងចក្រអត់បានបង្ខំនោះទេ តែពេលខ្លះនៅពេលដែលគេត្រូវការខោអាវប្រញាប់ខ្ញុំអាចត្រូវធ្វើការថែមម៉ោងរយៈពេលប្រហែលជា៨ម៉ោងក៏មាន ។ នៅពេលដែលថែមម៉ោង ខ្ញុំអាចទទួលលុយបាន១០០០រៀលជាមួយបាយមួយកញ្ចប់ នឹងបង្អែម ហើយនិងមានឡានជូនទៅផ្ទះ ។ "*

អ្វីដែលពិបាកគឺនៅពេលដែលសុំច្បាប់ឈប់សំរាកម្ដងៗគឺត្រូវគេកាត់ប្រាក់ខែ រីឯនៅពេលដែលឈឺទាល់តែមានសំបុត្រពេទ្យបញ្ជាក់ទើបគេអនុញ្ញាតអោយឈប់ ប៉ុន្តែលុយវាយបុង៤ដុល្លាត្រូវគេកាត់ តែគេឱ្យជមនួសនៅប្រាក់២ដុល្លាសំរាប់ថ្ងៃឈឺ ។ ចំណែកឯច្បាប់រៀបការវិញមានរយៈពេល១អាទិត្យ និងច្បាប់លំហែមាតុភាពគឺបានតែ៥០ភាគរយនៃប្រាក់ឈ្នួលប្រចាំខែ ។ បើទៅបន្ទប់ទឹកវិញគឺអត់មានកំណត់ម៉ោងទេ ពេលទៅតែងតែទៅជាក្រុមពី១០ទៅ១២នាក់ដោយយកកាតទៅជាមួយ តែបើអត់កាតក៏អាចទៅបានដែរ ។ ខ្ញុំធ្វើការនៅរោងចក្រយូរ៉ូបភៀនបាន២ឆ្នាំ ២ខែ បន្ទាប់រោងចក្រនេះក៏ត្រូវបានបិទទ្វារ ។ រោងចក្របានបង់លុយអោយកម្មករ តាមច្បាប់ទាំងអស់ ។

ក្រោយមកខ្ញុំក៏ទៅរកធ្វើការនៅរោងចក្រផ្សេងទៀតគឺរោងចក្រ **វាយធិច** នៅម្ដុំស្ទួនវឌ្ឍនៈ ដែលទើបតែធ្វើហើយគេរើសកម្មករជាច្រើននាក់ ប៉ុន្តែអត់ទាន់បើកដំណើរការទេ ប្រហែលជាដាច់ខែ១១ ឆ្នាំ២០០៥ ទើបគេចាប់ផ្ដើមដំណើរការ ។ រោងចក្រនេះមានថៅកែហ្វីលីពីន និងម៉ាឡេស៊ីហើយការជ្រើសរើសកម្មករគឺមិនសូវខុសពីរោងចក្រដ៏ទៃទៀតនោះទេ សូម្បីតែអ្នកមិនសូវចេះដេរក៏គេយកដែរ ។

*"ទៅថ្ងៃមុខខ្ញុំមានគោលបំណងបើកតូបលក់ឥវ៉ាន់ និង កាត់ដេរខោអាវខ្លះជាការបន្ទាប់បន្សំ និងអាចចិញ្ចឹមជ្រូកមាន់ទា ហើយបើអាចទៅរួច នឹងមានការចិញ្ចឹមត្រីទុកគ្រាន់ផ្គត់ផ្គង់ជីវភាពគ្រួសារ ។ ខ្ញុំមិនចង់អោយកូនរបស់ខ្ញុំដូចជាខ្ញុំទេ*

*ខ្ញុំចង់អោយវាអាចរៀនបានខ្ពង់ខ្ពស់នោះវានឹងមិនពិបាកដូចជាខ្ញុំដែលត្រូវធ្វើកម្មកររោងចក្រដោយទទួលបានកំរៃតិចតួច មិនគ្រប់គ្រាន់ក្នុងការចិញ្ចឹមជីវិត ។”*

ករណីសិក្សាទី ៣៥

ខែវិច្ឆកា ឆ្នាំ២០០៥

ប មុំ អាយុ២០ឆ្នាំ រស់នៅភូមិបាក់ធ្មេញ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ នាងមានបងប្អូន៤នាក់ប្រុស៣នាក់ និងស្រីម្នាក់។ នាងជាកូនពៅគេ ចំណែកឯបងប្រុសរបស់នាង២នាក់រៀបការអស់ហើយ នៅសល់តែម្នាក់ទេ។ នាងរស់នៅជាមួយឪពុកម្តាយនាងដោយប្រកបរបរធ្វើស្រែចំការ។ កាលពីមុនឪពុកម្តាយនាងមានដីស្រែ២ហិចតា តែនៅពេលដែលកូនប្រុស២នាក់រៀបការគ្មានអ្វីអោយ ក៏ចែកដីស្រែម្នាក់កន្លះហិចតាដើម្បីគ្រាន់ផ្គត់ផ្គង់ជីវភាពគ្រួសារ។ កាលពីនៅមានស្រែ២ហិចតា នៅពេលធ្វើស្រែម្តងៗគឺត្រូវប្រើជីអស់២បាវដោយក្នុងមួយបាវចំណាយអស់៤ម៉ឺនរៀល។ "*នៅផ្ទះខ្ញុំមានគោ៩ ក្បាល ដែលភាគច្រើនកំរនរណាមានគោច្រើនដូចជាផ្ទះខ្ញុំណាស់ ផ្ទះខ្លះមិនមានគោ១ក្បាលផង។ ពួកខ្ញុំមិនដែលចងការគេទេ។ ឪពុករបស់ខ្ញុំជាជាងធ្វើទ្វារបង្អួច ដោយមានម៉ាស៊ីនអាឈើមួយ។ មិនយូរប៉ុន្មានម៉ាស៊ីននោះត្រូវរដ្ឋគេរឹបអូសយកទៅ។*" ក្រោយមកឪពុករបស់នាងចាញ់បោកគេដោយការលេងល្បែង ត្រូវគេដាក់ថ្នាំសណ្តំ និងជំពាក់បំណុលគេរហូតត្រូវលក់គោដើម្បីសងគេទាំងអស់។ ចាប់តាំងពីពេលនោះមកការធ្វើស្រែមិនដែលបានហូបគ្រប់គ្រាន់ទេ ត្រូវទៅខ្ចីលុយគេរឺក៏ខ្ចីអង្ករគេជាប្រចាំ។ នៅពេលដែលខ្ចីគេ៥ថាំងស្រូវគេយកការ១ថាំង។

"*កត្តាដែលធ្វើអោយគ្រួសារខ្ញុំជួបនៅបញ្ហានេះក៏ដោយសារតែការ ប្រើប្រាស់ជីគីមីដែលត្រូវចំណាយលុយទៅទិញអស់លុយជាច្រើន។ កាលពីមុនការធ្វើស្រែម្តងៗគ្រួសារខ្ញុំប្រើតែជីធម្មជាតិទេ ហើយមិនដែលមានបញ្ហាហូបមិនគ្រប់គ្រាន់ទេ។ ម្យ៉ាងវិញទៀតដោយសារតែគ្រោះធម្មជាតិគឺស្រែត្រូវលិច ទឹកបណ្តាលអោយស្រែមិនទទួលបានទទួលផលអ្វីទេ។*"

ដោយសារតែបញ្ហាជីវភាពគ្រួសារដែលតំរូវអោយនាងត្រូវសំរេចចិត្តចាកចេញពីភូមិកំណើតរបស់នាងមករកការងារធ្វើនៅរោងចក្រកាត់ដេរនៅទីក្រុងភ្នំពេញ។ ដោយការមិនដឹងច្បាប់ការងារនាងបានធ្វើការជាកម្មករបណ្តែត នៅក្នុងរោងចក្រអស់ចំនួន៦រោងចក្រហើយ។ ក្រោយមកក៏មកធ្វើការនៅក្នុងរោងចក្រ **កាមេចិច** ដោយបានធ្វើជាបុគ្គលិកពេញសិទ្ធិបាន១ឆ្នាំ ហើយច្បាប់ការងារនៅទីនោះវាល្អជាងរោងចក្រពីមុនដែលនាងបានធ្វើការ។ បើថ្ងៃណាមានខោអាវដេរបានច្រើនប្រាក់កំរៃនឹងបានតាមនឹង ខែខ្លះនាងអាចរកបាន១០ដុល្លា រឺ២០ដុល្លាបន្ថែមលើប្រាក់ឈ្នួលដែលត្រូវទទួលបានជារៀងរាល់ខែ ដោយបូកនឹងប្រាក់លើកទឹកចិត្តផងដែរ (វាជាប្រាក់ដែលកម្មករមកធ្វើការទៀងម៉ោងមិនដែលយឺតយ៉ាវ និងមិនដែលឈប់សោះនោះកម្មករនោះនឹងទទួលបានលុយលើកទឹកចិត្តនេះ ហើយកម្មករភាគច្រើនហៅថាជាលុយព្រីម)។ បើចង់សុំច្បាប់ឈប់គឺអាចឈប់បាន រដ្ឋបាលអនុញ្ញាតិអោយឈប់១អាទិត្យចុះក្រោមដោយអត់កាត់ លុយទេតែកម្មករដែលឈប់នឹងមិនបានទទួលលុយព្រីមនោះទេ ។ នៅពេលដែលរោងចក្រត្រូវការខោអាវប្រញាប់ គេនឹងអោយកម្មករថែមម៉ោងរហូតដល់ម៉ោង៩យប់ រឺរហូតដល់ភ្លឺដោយក្នុង១ម៉ោងគេអោយតែ ៣០០រៀលទេ។ នៅពេលដែលកម្មករមិនព្រមថែមម៉ោងនោះថៅកែនឹងស្តីអោយ ដូច្នេះពួកគេត្រូវបង្ខំចិត្តធ្វើការបន្ថែមម៉ោងទៅតាមអ្វីដែលរោងចក្រត្រូវការ។

*" នៅពេលដែលខ្ញុំសុំឈប់ធ្វើការនៅរោងចក្រនេះ គេកាត់ប្រាក់ខែចុងក្រោយរបស់ខ្ញុំដោយមិនបានបើកអោយខ្ញុំទេ ។ ខ្ញុំក៏សំរេចចិត្តមកធ្វើការនៅរោងចក្រ* ***ម៉ាកាឡូត៩*** *ហើយច្បាប់នៅទីនោះគឺមានភាពតឹងតែងណាស់ ។ រាល់ពេលដែលសុំច្បាប់ម្តង១គឺពិបាកណាស់ទំរាំតែអោយច្បាប់ម្តង១គឺគេសួរដេញដោលច្រើនណាស់ ។ ហើយថែមម៉ោងម្តង១បានលុយតែ១000រៀលទេ ។ ការដេរមានការកំណត់បើកម្មករដេរមិនគ្រប់ការកំណត់ទេនោះ នឹងត្រូវគេដេញចេញ រឺត្រូវគេស្តីអោយយ៉ាងខ្លាំង ។"*

កម្មករចង់បង្កើតសហជីពរបស់គេ ប៉ុន្តែថៅកែមិនព្រមអោយបង្កើតសហជីពដោយខ្លួនឯងទេ ដូចនេះកម្មករមិនហ៊ានតវ៉ាជាមួយថៅកែរឺទាមទារនោះទេ ។ ពេលដែលបើកប្រាក់ខែ៥0ដុល្លា រឺ៦0ដុល្លានោះនាងអាចផ្ញើរលុយទៅឱ្យអ្នកផ្ទះ១0ទៅ២0ដុល្លាដែរ ហើយស្ថានភាពរស់នៅក្នុងគ្រួសាររបស់នាងបានគ្រាន់បើដោយសារបានលុយខ្លះពីការធ្វើការរោងចក្ររបស់នាង។ ចំណែកឯលុយនៅសល់គ្រាន់សំរាប់ផ្គត់ផ្គង់ខ្លួនឯង ដោយត្រូវចំណាយទៅលើការជួលផ្ទះ ទិញចំណីអាហារ ថ្លៃទឹក ថ្លៃភ្លើង ជាដើម ។ បន្ទប់ជួលមានសភាពចង្អៀត គ្មានអនាម័យ និងរញ៉េរញ៉ៃខ្លាំង ។
នៅខែណាដែលនាងឈឺ ខែនោះគឺមិនមានលុយសំរាប់ផ្ញើរទៅផ្ទះនោះទេ ព្រោះត្រូវចំណាយលុយថ្លៃព្យាបាល។ ទៅថ្ងៃមុខនាងចង់ត្រឡប់ទៅផ្ទះវិញដើម្បីប្រកបរបរកាត់ដេរខោអាវតិចតួច និងលក់បន្លែខ្លះ១គ្រាន់ដើម្បីចិញ្ចឹមជីវិត ។

## ករណីសិក្សាទី ៣៦

## តំបន់ដង្កោ

ត្រេនជាក្មេងស្រីអាយុ១៦ឆ្នាំ នាងមានបងប្អូន៣នាក់ ស្រី២ និងប្រុស១នាក់។ ឪពុករបស់នាងជាប៉ូលីស ហើយម្តាយជាមេផ្ទះ។ នាងរៀនបានថ្នាក់ទី៧ នាងបានសំរេចចិត្តឈប់រៀនដោយសារតែជីវភាពគ្រួសាររបស់នាងមានបញ្ហា គ្មានលុយគ្រប់គ្រាន់អោយនាងទៅរៀន ហើយផ្ទួនពេលនិងប្អូនពៅប្រុសរបស់មានជំងឺទៀត ដូច្នេះនាងក៏សំរេចចិត្តឈប់រៀន ហើយគិតចង់រកការងារធ្វើដើម្បីសំរាលជីវភាពគ្រួសារ។ ថ្ងៃមួយពូរបស់នាងបានទៅលេងផ្ទះគាត់ក៏ជាកម្មកររោងចក្រដែល នាងបានសុំពូរបស់នាងមកជាមួយដើម្បីរកការងារធ្វើជាកម្មកររោងចក្រ នាងដឹងថាអាយុរបស់មិនទាន់គ្រប់នឹងអាចចូលធ្វើការរោងចក្របានទេ តែនាងបានទៅខ្ចីសៀវភៅគ្រួសាររបស់សាច់ ញាតិរបស់នាងម្នាក់ដើម្បីបានចូលធ្វើការនៅភ្នំពេញ ។ នាងបានត្រូវរងចាំរហូតដល់មួយអាទិត្យទើបពូរបស់នាងបានសុំអោយចូលធ្វើការជាមួយគាត់បាននៅរោង **ចក្រចយហ្វ** បានដោយគ្មានអស់ប្រាក់ទេ។

ខ្ញុំធ្វើការនៅទីនោះបានរយៈពេលមួយខែ ជាកម្មករបំណែ្តតដោយទទួលបាន៤០ដុល្លាក្នុងមួយខែ បានធ្វើជាអ្នកពិនិត្យសំលៀកបំពាក់ ក្រុមរបស់នាងបានត្រូវប្រធានក្រុមហៅអោយទៅប្រជុំ ដោយប្រាប់ថាក្នុងម៉ោងធ្វើការត្រូវឈរអោយត្រង់ហើយមិនត្រូវលែងសើចនោះទេ។ ពីបីថ្ងៃដំបូងនាងបានប្រាប់មិត្តភិក្តិនៅជិតបន្ទប់ថាតាំងពីចូលធ្វើការ នៅរោងចក្រមកខ្ញុំដូចជាធាត់ជាងមុន តែតាមពិតនាងពិតអត់ដឹងថាជើងរបស់នាងត្រូវហើមដោយសារតែការឈរឥតឈប់ឈរពេញមួយថ្ងៃនោះឡើយ ។ មានថ្ងៃមួយនោះនាងឈឺពោះយ៉ាងខ្លាំងហើយនាងបានទៅសុំច្បាប់គេចេញមកផ្ទះវិញនៅម៉ោង៤ល្ងាច តែប្រធានក្រុមគាត់មិនបានអនុញ្ញាតិអោយនោះទេ ដូច្នេះនាងត្រូវបង្ខំចិត្តធ្វើការទាំងឈឺរហូតទាល់តែដល់ម៉ោងកំនត់ ហើយជានិច្ចកាល នាងត្រូវធ្វើការរហូតដល់ម៉ោង៦ល្ងាចដោយបូកទាំងការធ្វើការថែមម៉ោង២ម៉ោងបន្ថែមទៀត។

បន្ទាប់ពីបើកបានប្រាក់ខែជាលើកដំបូង នាងមានការសប្បាយរីករាយនិងរំភើបយ៉ាងខ្លាំង ហើយលុយមួយចំណែកនាងបានផ្ញើរទៅអោយម្តាយនៅឯស្រុកហើយទុកខ្លះសំរាប់បង់ថ្លៃបន្ទប់, ការហូបចុកនិងការស្នាក់នៅ។ តែពីបីថ្ងៃក្រោយមកនាងក៏បានធ្លាក់ខ្លួនឈឺជាទំងន់ ហើយបានទៅសុំច្បាប់ពីរោងចក្រចំនួន១០ថ្ងៃ តែគេប្រាប់ថាអោយខ្ញុំបានតែ៧ថ្ងៃប៉ុណ្ណោះ។ នាងបានត្រឡប់ទៅផ្ទះនៅឯស្រុកដើម្បីព្យាបាលជំងឺ ដោយចំណាយអស់៣០,០០០រៀល ហើយលុយនោះម្តាយរបស់នាងគាត់បានខ្ចីពីឈ្មួញនៅក្នុងភូមិដោយអោយការប្រាក់៣,០០០រៀលក្នុងមួយខែ។

ការព្យាបាលរបស់នាងត្រូវបានចំណាយពេលអស់ចំនួន ១១ថ្ងៃ ពេលដែលខ្ញុំត្រឡប់មកធ្វើការវិញអ្នកនៅក្នុងក្រុមរបស់នាងគេបានប្រាប់នាងថាប្រធានក្រុមបានបញ្ឈប់នាងពីការងារហើយ ព្រោះគេអនុញ្ញាតិអោយតែ៧ថ្ងៃ តែរូបនាងបែរជាឈប់រហូតដល់ទៅ១១ថ្ងៃ ។ នាងមានការភ័យព្រួយ នឹងបារម្ភយ៉ាងខ្លាំង ហើយពិបាកចិត្តណាស់ព្រោះនាងលែងមានលុយ

ផ្ញើអោយម្តាយនៅស្រុកទៀតហើយ ដូច្នេះម៉ែរបស់នាងអាចនឹងមិនមានលុយសងគេវិញនោះទេ ព្រោះគាត់បានជំពាក់គេ៣០០ដុល្លា។ លុយទាំងអស់ដែលបានជំពាក់គេនោះនាងអត់ហ៊ានសួរម្តាយនាងថាគាត់គេខ្ចីគេយកទៅធ្វើអ្វីខ្លះនោះទេ។

ឪពុកម្តាយនាងពួកគាត់គ្មានដីស្រែសំរាប់ធ្វើស្រែទេ ដូច្នេះពួកយើងជានិច្ចកាលតែងតែទិញអង្ករគេហូបជាប្រចាំ ឪពុករបស់នាងវិញគាត់ឧស្សាហផឹកស្រាដែរ ហើយពេលគាត់ស្រវឹងម្តងៗគាត់បានឈ្លោះប្រកែកជាមួយម្តាយនាងយ៉ាងខ្លាំង ពេលឃើញពួកគាត់ឈ្លោះគ្នា នាងមានការពិបាកចិត្តខ្លាំងណាស់មិនដឹងជាធ្វើយ៉ាងណាទេ នាងគិតតែម្យ៉ាងគត់គឺចងឈប់រៀន។

នៅទីក្រុងមានការរញ្ជៀវញ៉ៅណាស់ ហើយក៏ស្ងាត់ណាស់ដែរនៅពេលកម្មករត្រឡប់ទៅផ្ទះវិញ នៅពេលដែលពួកគេសំរាកមិនដូចជានៅក្នុងភូមិនោះទេ ទោះបីជាគ្មានលុយកាក់សំរាប់ចាយវាយតែដូចជាមានសេរីភាពច្រើន ហើយមានអារម្មណ៏សប្បាយចិត្តពោះបាននៅជិតបងប្អូន តែនៅទីក្រុងវិញដូចជានៅក្នុងគុកអញ្ចឹង។ ខ្ញុំបានសំរេចចិត្តថានៅរង់ចាំប្រហែលជាមួយខែទៀត បើនៅតែមិនអាចរកការងារបានធ្វើខ្ញុំនិងត្រឡប់ទៅផ្ទះវិញ។ ហើយបើទៅផ្ទះវិញគឺមានតែដើរស៊ីឈ្នួលគេធ្វើស្រែ ព្រោះនៅស្រុកគ្មានការងារធ្វើជាក់លាក់ បើសិនជាទៅស៊ីឈ្នួលគេអាចនិងបាន៣,៥០០រៀលក្នុងមួយថ្ងៃរួមទាំងអាហារ២ពេល ព្រឹកនិងថ្ងៃត្រង់, រឺក៏អាចទៅធ្វើការងារផ្សេងៗទៀតដូចជាចាំទទួលទំពីផ្សារ ដើរលក់រែកងនឹងបានប្រាក់កាក់ខ្លះសំរាប់ចិញ្ចឹមជីវិត។

ខ្ញុំមានការសោកស្តាយខ្លាំងណាស់ពេលដែលខ្ញុំសំរេចចិត្តថាឈប់រៀន ព្រោះខ្ញុំចង់ក្លាយជាគ្រូបង្រៀនម្នាក់តែគ្មានសង្ឃឹមនោះទេ បើមានឱកាសខ្ញុំនិងខំចាប់យកអោយបាន។

ករណីសិក្សាទី ៣៧

ស្ត្រីម្នាក់អាយុ៤១ឆ្នាំ នាងមានកូន៣នាក់ ស្រី២ និងប្រុស១ គាត់រស់នៅខេត្តព្រៃវែង ស្រុកកំពង់លាវ កូនស្រីច្បង មានអាយុ១៦ឆ្នាំ រៀនបានថ្នាក់ទី៧។ កូនស្រីច្បងរបស់នាងបានសំរេចចិត្តថាឈប់រៀនដោយសារតែបញ្ហាជីវភាព និងទីទាល់ក្រ។ កូនរបស់នាងបានសំរេចចិត្តមករកការងារធ្វើនៅភ្នំពេញជាកម្មកររោងចក្រកែ្រងគ្រាន់បានជួយសំរាល ជីវភាពក្នុងក្រុមគ្រួសារខ្លះ ម្យ៉ាងវិញទៀតការធ្វើស្រែរបស់នាងមិនបានទទួលផលនោះទេព្រោះតែត្រូវបានជួបប្រទះនឹង គ្រោះរាំងរីកស្ងួតក្នុងកំឡុងប៉ុន្មានឆ្នាំកន្លងមកនេះ។ គ្រួសាររបស់នាងមានដីស្រែជិត១ហិតាដែរ។ ក្រៅពីការធ្វើស្រែ ចំការគ្រួសារនាងមានចិញ្ចឹមមាន់ ជ្រូកខ្លះដែរ គ្រាន់តែដោះដូរពេលត្រូវការចាំបាច់។

នាងបាននិយាយថា ដោយសារតែភាពរាំងរីកស្ងួតនិងក្តៅហួតហែងអ្នកភូមិជាច្រើនបានធ្លាក់ខ្លួនឈឺជាទំងន់ អ្នកខ្លះ បានត្រូវទៅចងការគេដើម្បីមើលជំងឺ អ្នកខ្លះទៀតក៏ខ្ចីគេដើម្បីធ្វើស្រែចំការដែរ តែមិនឃើញថានិងអាចសងគេវិញបានទេ មានតែបានបាត់បង់ដីស្រែចំការដើម្បីសងបំណុលគេ ព្រោះការខ្ចីខ្លះដំបូងពីបណ្តាអង្គការដូចជាអេស៊ីលីដា រឺប្រាសាក់ ដែលពួកគេយកការថោកជាងអ្នកចងការប្រាក់ក្នុងភូមិត្រឹមតែ៣%ប៉ុណ្ណោះក្នុងមួយខែ តែត្រូវតែមានការដាក់បញ្ចាំងប្លង់ ដី។ បើសិនយើងជាអ្នកក្រគឺត្រូវរងចាំខ្ចីបន្តពីអ្នកដែលគេអាចមានលទ្ធភាពខ្ចីផ្ទាល់ ហើយគេនឹងយកមកចងការអោយក្នុង អាត្រាការប្រាក់ខ្ពស់ជាងបន្តិច។

នាងក៏នៅជំពាក់គេ៣០០ដុល្លាដែល ដោយត្រូវបង់ការប្រាក់១៥ដុល្លាក្នុងមួយខែ លុយដែលនាងខ្ចីនោះគឺយកមកទៅ ដោះស្រាយជីវភាពគ្រួសារខ្លះ មើលជំងឺកូនប្រុសពៅរបស់នាង និងការចាយវាយរបស់កូនស្រីច្បងក្នុងការមករកការងារ ធ្វើនៅទីក្រុង។ នាងយល់ឃើញថាបើគ្មានរោងចក្រទេប្រហែលជាពិបាកខ្លាំងណាស់ ព្រោះការធ្វើស្រែចំការអត់បានផល ទេឥឡូវនេះ ហើយអ្នកភូមិភាគច្រើនមានជីវភាពធូរធារជាងមុនដោយសារតែពួកគេមានកូនស្រីធ្វើ ការនៅទីក្រុងជា កម្មកររោងចក្រ ។ ដូច្នេះហើយនៅក្នុងភូមិឥឡូវនេះមានតែចាស់ៗទេដែលនៅចាំផ្ទះ ព្រោះកូនស្រីត្រូវចេញរកការងារធ្វើ ជាកម្មកររោងចក្រកាត់ដេរ ហើយកូនប្រុសចេញមករកការងារធ្វើដែលជាកម្មករសំណង់ ។ នាងបានដឹងដែលថាពេល ដែលកូនអ្នកភូមិត្រឡប់ទៅផ្ទះម្តងៗគេតែងតែនិយាយប្រាប់ពីការងារនៅក្នុងរោងចក្រថាពិបាកណាស់ តែគ្រួសាររបស់គេ និយាយថាត្រូវតែទ្រាំព្រោះបើមិនខំប្រឹងប្រែងធ្វើការទេគឺមិនអាចជួយដល់ជីវភាពគ្រួសារទេ ហើយបើគ្មានរោងចក្រ ប្រហែលជាពួកយើងត្រូវស្លាប់អស់ហើយ។

*ខ្ញុំដឹងថាកូនពិបាកណាស់ធ្វើការនៅទីក្រុងតែមិនដឹងត្រូវធ្វើយ៉ាងណាទេ កូនវាសំរេចចិត្តខ្លួនឯងដោយសារតែវាអាណិតដល់ គ្រួសារ។ គ្រូនៅសាលារៀនបានមកផ្ទះខ្ញុំពីបីដងដែរថាអោយកូនរបស់ខ្ញុំត្រឡប់ទៅរៀនវិញព្រោះ កូនខ្ញុំវារៀនពូកែ ណាស់ ខ្ញុំមកភ្នំពេញលើកនេះយកអង្ករមកអោយវា ហើយក៏ចង់អោយវាត្រឡប់ទៅផ្ទះវិញដែរ តែវាមិនព្រមត្រឡប់ទៅ វិញទេ។*

បើនៅតែធ្វើស្រែទៀតគឺរឹតតែជំពាក់គេច្រើនឡើងព្រោះនាងត្រូវចំណាយយ៉ាងច្រើនដូចជាត្រូវទិញជី ថ្នាំ ពូជ ទឹក តែត្រូវជួលគោក្របីគេ ហើយពេលផលបានមកវិញមិនគ្រប់សងគេទេ មើលទៅដូចជាគ្មានអនាគតរុងរឿងប៉ុន្មានទេ។

## ករណីសិក្សាទី ៣៨

សនមានអាយុ៥៨ឆ្នាំ ជាម្តាយរបស់កម្មករម្នាក់, នាងមានស្រុកកំណើតនៅខេត្តកំពង់ចាម។ កូនស្រីរបស់គាត់ធ្វើការនៅរោងចក្រ **ស៊ីឡាំងហួរ** ដែលមានទីតាំងនៅបឹងទំពុន។ កូនស្រីរបស់គាត់មកធ្វើការជាកម្មករនៅភ្នំពេញនោះប្រហែលជា៦, ៧ខែ មកហើយ។ កូនរបស់គាត់មិនបានរៀនទេ ព្រោះជីវភាពគ្រួសាររបស់គាត់ក្រីក្រខ្លាំងពេក ហើយកូនស្រីរបស់គាត់ត្រូវនៅជួយធ្វើកិច្ចការផ្ទះជំនួសគាត់ ដោយទុកអោយបងៗប្រុសរបស់នាងបន្តការសិក្សា ហើយសូម្បីតែខ្លួនគាត់ជាម្តាយក៏ចេញទៅរកការងារធ្វើការដែរ។

បន្ទាប់ពីកូនបងៗរបស់គាត់រៀបការរួចហើយ ពួកគេបានបែកទៅនៅផ្សេង ហើយនាងនៅផ្ទះតែពីនាក់កូនស្រីប៉ុណ្ណោះ។ ដោយសារតែនាងមានជំងឺប្រចាំកាយ ដូច្នេះនាងបានខ្ចីលុយគេយ៉ាងច្រើនសំរាប់ព្យាបាលជំងឺ ដោយមិនមានអ្វីសងគេវិញ នាងបានលក់ដីស្រែរបស់នាងដើម្បីយកប្រាក់សងគេ ហើយកូនស្រីរបស់នាងបានសំរេចចិត្តមករកការងារធ្វើនៅភ្នំពេញ ដើម្បីរកប្រាក់ចិញ្ចឹមគ្រួសារ និងជួយបង់ថ្លៃថ្នាំពេទ្យផង។ ដំបូងកូនរបស់នាងបានធ្វើការនៅតាមផ្ទះគេបានប្រាក់ខែត្រឹមតែ៥០,០០០រៀលក្នុងមួយខែ តែបន្ទាប់មកកូនស្រីរបស់នាងក៏ឈប់ធ្វើការនៅផ្ទះគេ ហើយមករកការធ្វើនៅរោងចក្រ ហើយប្រាក់ដំបូងនោះបានត្រឹមតែ៥០,០០០រៀលប៉ុណ្ណោះ វាមិនបានគ្រប់គ្រាន់ក្នុងការចាយវាយនិងជួយបង់ថ្លៃថ្នាំសង្កូវសំរាប់រូបនាងនោះទេ។

ហើយឥឡូវនេះវិញកូនស្រីរបស់នាងទទួលបានប្រាក់ខែច្រើនជាមុនអាចជួយនាងបានច្រើន វាគ្រាន់បើជាងកាលនៅធ្វើការតាមផ្ទះអោយគេដំបូងនោះ តែកូនស្រីរបស់នាងបានប្រាប់នាងថា " ការងាររោងចក្រលំបាកណាស់ព្រោះចិនបង្ខំឱ្យដេរអោយបានច្រើននិងលឿនទៀត ហើយពេលនាងដេរមិនគ្រប់ចំនួនកំនត់ត្រូវគេហៅទៅព្រមាន រឺស្តីអោយ។ ហើយពេលសុំច្បាប់ម្តងៗ ពិបាកខ្លាំងណាស់ទោះមានជំងឺបែបណាក៏ដោយគឺសំរេចទៅលើចិត្តរបស់គេថាអោយរឺមិនអោយ បើគេសប្បាយចិត្តគេអនុញ្ញាតអោយ តែបើគេមិនសប្បាយចិត្តគេមិនអនុញ្ញាតអោយនោះទេ ក្នុងមួយថ្ងៃនាងត្រូវធ្វើការ៨ម៉ោងទៅដល់១៦ម៉ោង។ ប្រាក់ខែរបស់នាងត្រូវ បែងចែកអោយឱ្យថ្លៃបន្ទប់ជួល ទឹក ភ្លើង ហើយមានខែខ្លះត្រូវចំណាយទៅលើការព្យាបាលជំងឺទៀតផង។ មួយខែនាងអាចផ្ញើរទៅអោយគាត់បានប្រហែល ១០ដុល្លា ទៅ២០ដុល្លាដែរ ហើយលុយទាំងនោះអាចជួយគាត់ទិញថ្នាំខ្លះសំរាប់មើលជំងឺរបស់គាត់។

គាត់គិតថាប្រសិនបើកូនរបស់គាត់លែងមានការងារធ្វើនៅរោងចក្រទៀត ប្រហែលជាជីវិតរបស់គាត់មិនដឹងជាទៅជាយ៉ាងណានោះទេ ព្រោះមួយខែៗមានតែចំណាយ ចំណែកឯចំណូលគឺគ្មានសោះ ហើយទំនិញវិញកាន់តែឡើងថ្លៃ ចំណែកដីស្រែក៏គ្មាន ហើយទោះបីជាមានដីស្រែក៏មិនអាចធ្វើបានដែរ ព្រោះបើមិនជួបទឹកជំនន់ក៏ជួបគ្រោះរាំងរីកស្ងួតដែរ ធ្វើស្រែត្រូវតែដាក់ជីទើបអាចទទួលបានទន្និផលល្អ តែជីមានតំលៃកាន់តែថ្លៃឡើងៗ ហើយបើមិនដាក់ជិទេនឹងគ្មានបានទទួលផលអ្វីទាំងអស់។

នាងនិយាយបន្តថាបើកូនរបស់នាងត្រឡប់ទៅផ្ទះវិញក៏មិនមានអ្វីធ្វើ  ហើយអាចរកចំណូលបានសំរាប់គ្រួសារដែល  មានតែលក់កំលាំងនិងដើរស៊ីឈ្នួលគេប៉ុណ្ណោះ ។

## ករណីសិក្សាទី ៣៩

ទុំ មានអាយុ២១ឆ្នាំ នាងធ្វើការនៅរោងចក្រ **ម៉ៃទីស្តិចត្រា** ផ្នែកផុត។ នាងមានស្រុកកំនើតនៅស្រុកបាធាយ ខេត្តកំពង់ចាម។ នាងមានបងប្អូន៩នាក់ នឹងជាកូនទី៦ក្នុងគ្រួសារ។ គ្រួសាររបស់នាងមានដីស្រែតែបន្តិចបន្តួចប៉ុណ្ណោះ ហើយផលដែលទទួលបានពីការធ្វើស្រែមិនបានគ្រប់គ្រាន់ក្នុងការហូបចុកទេ គឺត្រូវតែទិញអង្ករគេហូបជារៀងរាល់ឆ្នាំ។ ប្អូននាងពីនាក់នៅរៀននៅឡើយ ហើយម្តាយរបស់នាងក៏មានជំងឺជាទំងន់ទៀត ជាជំងឺប្រចាំកាយ។

នាងនឹងបងស្រីរបស់នាងធ្វើការរោងចក្រ ដោយសារនៅផ្ទះមិនមានមុខរបរអ្វីធ្វើដើម្បីរកប្រាក់ចំណូលអោយបានគ្រប់គ្រាន់សំរាប់ជួយសំរាលបន្ទុកគ្រួសារ។ គ្រួសាររបស់នាងជាអ្នកធ្វើស្រែ បើធ្វើស្រែមិនបានមិនដឹងជារកការងារអ្វីធ្វើក្រៅពីធ្វើការនៅរោងចក្រនោះទេ ហើយអ្នកភូមិនិងក្មេងស្រីភាគច្រើន បានចាកចោលភូមិកំនើតមកធ្វើការជាកម្មកររោងចក្រកាត់ដេរគ្រប់ៗគ្នា ហើយបានបន្សល់ទុកតែមនុស្សចាស់ៗនៅចាំភូមិ។

នាងមានការព្រួយបារម្ភជាខ្លាំងបន្ទាប់ពីនាងបានដឹងថានៅចុងឆ្នាំ២០០៤ នេះកូតាត្រូវបានបញ្ចប់ពីប្រទេសកម្ពុជាហើយមិនដឹងថាកម្មករប៉ុន្មាននាក់ត្រូវអត់ការងារធ្វើ ដោយសារតែរោងចក្រត្រូវផ្លាស់ប្តូរទៅប្រទេសផ្សេងៗ រឺក៏ត្រូវបិទ ចុះតើក្រុមគ្រួសាររបស់នាងនិងត្រូវទៅជាយ៉ាងណា? ហើយប្រសិនបើនាងត្រឡប់ទៅស្រុកវិញក៏មិនដឹងជាមានការងារអ្វីសំរាប់ធ្វើដែរ មានតែដើរស៊ីឈ្នួលគេ ហើយបើធ្វើស្រែក៏ត្រូវចំណាយយ៉ាងច្រើនដែរ ដូចជា ត្រូវ ទិញជី ទឹក ថ្នាំសំលាប់សត្វល្អិត, ជួលគេភ្ជួរ...។

ធ្វើការនៅក្នុងរោងចក្រនាងមិនដែលត្អូញត្អែរម្តងណាទេ ទោះជាត្រូវធ្វើដល់យប់ជ្រៅយ៉ាងណាក៏ដោយ សំខាន់គឺអាចជួយដល់គ្រួសារនាងបានគឺគ្រប់គ្រាន់ណាស់។ មានថ្ងៃមួយនោះម៉ាស៊ីនបងស្រីរបស់នាងខូចអ្នកជួសជុលបាន មកធ្វើវាតែវានៅតែដើរមិនសូវល្អគឺវាតឹងពេក បងស្រីរបស់នាងក៏អង្គុយយំយ៉ាងខ្លាំង ព្រោះខ្លាចមិនមានលុយសំរាប់ជួយដល់ម្តាយដែលកំពុងតែមានជំងឺ បើគ្មានលុយទេសំរាប់ព្យាបាលជំងឺម្តាយនាងទេ គាត់និងត្រូវទៅខ្ចីលុយគេ ហើយបើខ្ចីលុយគេគឺពួកនាងនិងត្រូវធ្វើការទ្វេរដងថែមទៀត ដើម្បីសងគេព្រោះពួកនាងដឹងថាការប្រាក់ថ្លៃខ្លាំងណាស់។

នាងក៏ចង់រកស៊ីលក់ដូរដែលតែអត់មានដើមទុន ហើយបើមានដើមទុនក៏ពិបាកដែលព្រោះគ្មានទីផ្សារគ្រប់គ្រាន់។

ករណីសិក្សាទី ៤០

តំបន់ ដង្កោ

ថ្ងៃទី ១៩ កញ្ញា ២០០៥

នាងខ្ញុំឈ្មោះ អ ម ឪ អាយុ២៩ឆ្នាំ មិនទាន់បានរៀបការទេ គ្រួសារមានសមាជិក១០នាក់ បងប្អូន៧នាក់ ម៉ែពុក និងយាយម្នាក់។ ខ្ញុំជាកូនទី២ ចំនែកកូនច្បងបង្អស់ជាមនុស្សស្រី ខ្ញុំមានស្រុកកំណើតនៅភូមិជ្រោយដង ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

គ្រួសាររបស់ខ្ញុំប្រកបរបរចិញ្ចឹមជីវិតដោយធ្វើស្រែ និងចំការ ដោយមានដីស្រែ២កន្លែង ដីចំការ២កន្លែង ប៉ុន្តែមិនសូវបានគ្រប់គ្រាន់ទេ ។ បើតិចបានត្រឹម ១០បាវ បើច្រើនគឺបានពីមួយតោនទៅពីរតោន ហើយនៅពេលធ្វើបានច្រើនឪពុកម្តាយរបស់ខ្ញុំគាត់បានលក់វា ហើយយកលុយនោះទៅអោយគេខ្ចី ដោយយកការជាស្រូវវិញនៅពេលអ្នកដែលខ្ចីនោះទទួលបានផលនៅរដូវច្រូតកាត់ ។ ក្រៅពីធ្វើស្រែឪពុកម្តាយរបស់ខ្ញុំក៏ធ្វើចំការខ្លះដែលដូចជា ដំាឡូ សណ្តែក ពោត ប៉ុន្តែផលច្រើននោះមានតែសណ្តែកប៉ុណ្ណោះ ។ ក្នុងមួយឆ្នាំៗផលពីចំការដែលលក់បានប្រហែលជា ១០០,០០០រៀល បើគិតទាំងថ្លៃជួលគេភ្ជួរ ថ្លៃជី និងកម្លាំងពលកម្មផងនោះ គឺលើសពី ១០០,០០០រៀលទៅទៀត ។

ឪពុកខ្ញុំបានចូលជាសមាជិកសមាគមន៏មួយ ដែលសមាគមន៏តំរូវអោយមានការសន្សំលុយទុកនៅទីនោះ ហើយពេលដែលសមាជិកក្នុងក្រុមត្រូវការលុយនោះគេអាចខ្ចីបាននៅក្នុងករណីចាំបាច់ ។ ឪពុកខ្ញុំបានខ្ចីលុយ ២,០០០,០០០រៀល នោះដើម្បីយកមកធ្វើជារោងម៉ាស៊ីនកិនស្រូវ ហើយគេយកការ ១,០០០រៀល ក្នុង១០០,០០០រៀល ប៉ុន្តែបានបង់ខាតទុនលើម៉ាស៊ីនកិនស្រូវនោះទាំងអស់ ដូច្នេះហើយដើម្បីសងបំណុលគេគ្រួសារខ្ញុំបានដាំកក់សំរាប់ត្បាញកន្ទេលយកទៅលក់ហើយក្នុងមួយថ្ងៃត្បាញកន្ទេលបានបួន ហើយមួយឆ្នាំលក់បាន២០០,០០០រៀល ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏នៅតែសងគេមិនបានរួចដែល។ បន្ទាប់មកឪពុកម្តាយខ្ញុំបានទៅខ្ចីលុយបងប្អូន៥០០ដុល្លា (មិនមានការប្រាក់ទេ) ដើម្បីទិញគោយន្តយកមកច្នៃសំរាប់ដឹកទឹកលក់ ហើយបានទិញធុងទឹកពីរទៀត ធុងមួយតម្លៃ១០០ដុល្លា ដោយសារលុយមិនគ្រប់គ្រាន់ក៏ទៅចងការលុយគេ ២០០ដុល្លា (ការ ១០%ក្នុង១០០ដុល្លា) សំរាប់យកគេបង្គ្រប់ទិញគោយន្ត ។

ខ្ញុំបានរៀនត្រឹមថ្នាក់ទី៨ប៉ុណ្ណោះ ដោយសារតែប្រឡងធ្លាក់ ហើយម្យ៉ាងទៀតម៉ែបាននិយាយថាទោះជារៀនក៏មិនដែលនឹងបានធ្វើការងារធំដំដែរ កូនគេនៅក្នុងភូមិទៅរកការងារធ្វើអស់ហើយ ក្រោយពីលឺម្តាយនិយាយដូចនេះមកខ្ញុំក៏បានសំរេចចិត្តឈប់រៀននៅឆ្នាំ១៩៩៦ ហើយក៏មករកការងារធ្វើនៅក្នុងឆ្នាំនោះឯង។

ដើម្បីមកភ្នំពេញរកការងារធ្វើ ម៉ែបានលក់ជ្រូកហើយឱ្យលុយខ្ញុំ ១០០,០០០រៀល ជិះរ៉ឺម៉កអស់១០ដុល្លា ពេលមកដល់ភ្នំពេញដំបូងស្នាក់នៅជាមួយយាយសាច់ឆ្ងាយម្នាក់នៅម្តុំវង្វង់មូលតាខ្មៅ ដោយចេញថ្លៃម្ហូបអាហារនិងថ្លៃផ្ទះដោយខ្លួនឯង ប៉ុន្តែខ្ញុំបាននៅរៀនធាក់ម៉ាស៊ីនជាមួយគាត់មួយរយៈដោយមិនបានបង់លុយកាក់អោយគាត់នោះទេ ។

មួយអាទិត្យក្រោយមក ទើបបានការងារធ្វើនៅរោងចក្រ **តប្រាំបី** ដោយត្រូវឱ្យលុយអ្នកនាំចូលអស់១៥ដុល្លា ។ លុយ ១០០,០០០រៀលមកពីផ្ទះនោះចាយមិនគ្រាន់ទេ ដូច្នេះខ្ញុំបានខ្ចីលុយគេចាយសិនទំរាំដល់ថ្ងៃបើកប្រាក់ខែ ។ នៅរោងចក្រតប្រាំបី ខ្ញុំធ្វើការនៅខាងផ្នែកដេរម្ជុលមួយ តែពេលចូលដំបូងខ្ញុំមិនបានដឹងថា គេគិតប្រាក់ខែឱ្យយ៉ាងម៉េចនោះទេ ដល់ពេលធ្វើការបានកន្លះខែ គេឱ្យប្រាក់ខែគិតតាមបុងបាន៣០ដុល្លា ក្រោយពីធ្វើការបាន៣ខែ ខ្ញុំទទួលប្រាក់ខែបាន៧០-៨០ដុល្លាក្នុងមួយខែ ។ ពេលណាដែលមានខោអាវដេរប្រញាប់គេបង្ខំយើងឱ្យដេរតាមចំនួនកំណត់ បើមិនប្រញាប់គេមិនកំណត់ចំនួនទេ តែយើងត្រូវខំខ្លួនឯងដើម្បីបានចំនួនបុងច្រើន ។

ពេលទៅបន្ទប់ទឹកយូរគេអត់ស្តីអោយទេ ហើយនៅក្នុងរោងចក្រគ្មានពេទ្យសំរាប់ព្យាបាលពេលកម្មករមានរបួសនោះទេ ។ នៅពេលមានធុរៈម្តងៗគឺពិបាកណាស់ក្នុងការសុំច្បាប់ណាស់ទំរាំតែគេអនុញ្ញាតអោយ ហើយខ្ញុំអាចសុំច្បាប់បានត្រឹមតែមួយថ្ងៃប៉ុណ្ណោះ បើសិនជាសុំពីរថ្ងៃនឹងកាត់លុយលើកទឹកចិត្ត និងលុយប្រចាំថ្ងៃ ។ តាំងពីធ្វើការមកខ្ញុំមិនដែលមានកម្មករសន្លប់ទេ ប៉ុន្តែចំពោះខ្ញុំគឺធ្លាប់មានជំងឺក្តៅខ្លួនបន្តិចបន្តួច ហើយបើមានកម្មករណាមានគ្រោះថ្នាក់នៅក្នុងរោងចក្រត្រូវចេញទៅពេទ្យខាងក្រៅដើម្បីព្យាបាល ហើយក្រុមហ៊ុននឹងជួយចេញថ្លៃព្យាបាល ។ រោងចក្រនេះធ្វើការតែមួយវេនគឺវេនថ្ងៃ ចាប់ផ្តើមពីម៉ោង៧ព្រឹក ចេញម៉ោង៤រសៀល បើមានថែមម៉ោងគឺត្រឹមម៉ោង៩យប់ ប៉ុន្តែធ្លាប់បានធ្វើការថែមដល់ម៉ោង១យប់ម្តងដែរ ។

ថ្ងៃមួយនៅតាមផ្លូវពេលត្រឡប់ពីធ្វើការថែមម៉ោង៩យប់នោះ ខ្ញុំមានអារម្មណ៍ភ័យយ៉ាងខ្លាំង ព្រោះមានគ្នាតែពីរនាក់មិត្តភក្តិក៏បបួលគ្នាកាន់ដៃហើយរត់រហូតមកដល់ផ្ទះ ។ មានអ្នកធ្វើការរោងចក្រជាមួយគ្នាម្នាក់ ត្រូវពួកជើងកាងស្ទាក់វាយនៅតាមផ្លូវពេលត្រឡប់មកពីធ្វើការថែមម៉ោង៩យប់ និងយកលុយព្រមទាំងរបស់របរដែលនៅជាប់នឹងខ្លួនអស់រលីង ហើយនាងបានយំខ្លាំងណាស់ ។ នៅខណៈពេលនោះ ឆ្នាំ១៩៩៧ រោងចក្រមិនទាន់មានសហជីពទេ ។

ដោយសារព្រឹត្តិការណ៍ ៦-៧ កក្កដា ១៩៩៧ ខ្ញុំបានឈប់ធ្វើការនៅរោងចក្រ **តប្រាំបី** ហើយត្រឡប់ទៅផ្ទះវិញ កាលនោះធ្វើការបានត្រឹមតែមួយឆ្នាំប៉ុណ្ណោះ ហើយបានសល់លុយ៥ជីមាសដែរ ។ ក្រោយពេលទៅផ្ទះបានបីថ្ងៃក៏បានចូលធ្វើការនៅរោងចក្រ **ក្តារបន្ទះ** ថៅកែជនជាតិកូរ៉េ តែគ្មានអស់លុយកាក់សូកគេចូលនោះទេ ព្រោះបានមិត្តភក្តិជាអ្នកណែនាំ ហើយនៅទីនោះខ្ញុំការធ្វើជាអ្នកកត់ចំនួនឈើ។ ចូលធ្វើការខែដំបូងបានប្រាក់ឈ្នួល ១២០,០០០រៀល បីខែក្រោយបើកបាន ១៥០,០០០រៀល ។ ល័ក្ខខ័ណ្ឌការងារនៅរោងចក្រនេះល្អ ប៉ុន្តែធ្វើការបានតែ៧ខែក៏ឈប់

ព្រោះរោងចក្រគ្មានឈើនាំចូលមកទៀតទេ ដូច្នេះកម្មករក៏នាំគ្នាធ្វើបាតុកម្ម ហើយនៅពេលនោះដែរកម្មករក៏បានសុំបើកប្រាក់ខែផ្តាច់ តែមុនដំបូងថៅកែមិនចង់បើកឱ្យទេ តែក្រោយមកក៏យល់ព្រមតាមសំណើរកម្មករ ។

បន្ទាប់ពីឈប់ធ្វើការនៅទីនោះបាន២ខែ ខ្ញុំក៏បានត្រឡប់មករកការងារធ្វើនៅភ្នំពេញជាថ្មីម្តងទៀត ហើយស្នាក់នៅជាមួយយាយម្តុំរង្វង់មូលតាខ្មៅនោះដដែល ។ មកដល់បានបីថ្ងៃមិត្តភក្តិក៏បាននាំទៅធ្វើការនៅរោងចក្រ **គីនតាយ** ផ្នែកដេរម្ជុលពីរ ចូលដំបូងបានប្រាក់ឈ្នួល ៤០ដុល្លា បីខែក្រោយក៏បានចូលជាកម្មករពេញសិទ្ធិ បានប្រាក់ខែ ៤៥ដុល្លា ។

នៅឆ្នាំ១៩៩៨ រោងចក្របង្ខំអោយកម្មករដេរកំណត់ដោយមួយថ្ងៃត្រូវដេរឱ្យ បាន៤០០-៥០០ បើដេរមិនបាននឹងត្រូវគេស្តីឱ្យតែប្រាក់ខែ គឺគិតធម្មតា ។ ធ្វើការថែមម៉ោង៩ ជារៀងរាល់ថ្ងៃ ទោះថ្ងៃបុណ្យក៏ធ្វើការដែរ ។ ពេលនោះនៅក្នុងរោងចក្រ គឺមានតំណាងកម្មករ និងសហជីពគឺមានតែមួយទេ គឺC-CAWDU ទោះជាកម្មករមានបញ្ហាអ្វីក៏ពួកគេតែងតែជួយដោះស្រាយឱ្យកម្មករបានសំរេចដែរ ហើយដោយសារតែសហជីព និង តំណាងកម្មករចូលទៅតវ៉ាជាមួយរោងចក្រនោះហើយទើបល័ក្ខខ័ណ្ឌការងារបានល្អប្រសើរជាងមុន ។ ប៉ុន្តែមិនយូរប៉ុន្មានតំណាងកម្មករទាំងនោះក៏ត្រូវបានគេគុណលុយអោយហើយក៏ឈប់ពីរោងចក្រអស់ទៅ ក្រោយមកទៀតកម្មករបីអាគារក៏ឈប់ទៀត ដោយពួកគេក៏ត្រូវបានរោងចក្រគុណលុយឱ្យដែរ ។ បន្ទាប់មកគេក៏រំលែកកម្មករនៅផ្នែកដេរមកដាក់រាយនៅផ្នែកទាំងបីនោះខ្លះនិងរើសថែមខ្លះ ។ ពីមុននៅផ្នែកដេរ មាន២៤ក្រុម ដល់ឆ្នាំ២០០៥ នៅសល់តែ១៦ក្រុមទេ ។

សព្វថ្ងៃគេចង់បង្ខំកម្មករឱ្យធ្វើការដូចមុន ដោយកៀបកម្មករបន្តិចម្តងៗ ដេរកំណត់ចំនួនហើយបង្ខំដេរឱ្យបានលឿនធ្វើការតែមួយវេនប៉ុណ្ណោះ ផ្នែកដេរមិនដែលធ្វើការថែមម៉ោងទេ ចេញត្រឹមម៉ោង៤រសៀល តែផ្នែកបម្រើយការគឺចេញម៉ោង៩យប់ ។ នៅពេលមានខោអាវប្រញាប់ គេឱ្យផ្នែកបោកគក់សំរាកតែ៥នាទីទេ តែបីផ្នែកទៀតសំរាកកន្លះម៉ោង ។ កម្មករដែលចូលធ្វើការដំបូងបានប្រាក់ខែ៤០ដុល្លា បីខែក្រោយ៤៥ដុល្លា តែមានកិច្ចសន្យាមួយឆ្នាំរំសាយម្តង បើគេពេញចិត្តគេទុកឱ្យធ្វើការបន្ត ។ រោងចក្រអនុញ្ញាតអោយកម្មករប្រើថ្ងៃឈប់បំណាច់ឆ្នាំបាន លុះត្រាតែកម្មករនោះឈឺឬមានធុរៈសំខាន់ចាំបាច់ ដូចជារៀបការច្បាប់៧ថ្ងៃ សំរាប់កម្មករដែលសំរាលកូនគេបើកប្រាក់ខែឱ្យមុន និងច្បាប់ឈប់បីខែ តែបើក្រោយបីខែធ្វើការមិនទាន់បានទេអាចសុំបន្ត១ខែទៀតបាន គេមានលុយសំរាប់ទឹកដោះគោក្នុងមួយខែ៥ដុល្លាចំពោះកូនរបស់កម្មករដែលមានអាយុ១ខួប ។

បើកម្មករមានគ្រោះថ្នាក់នៅក្នុងម៉ោងការងារក្រុមហ៊ុននឹងចេញថ្លៃព្យាបាល តែឥឡូវនេះរោងចក្រមានកំណត់តឹងរ៉ឹងបើឈឺធ្ងន់ ឬគ្រោះថ្នាក់ធ្ងន់ក្រុមហ៊ុនជួយចេញតែ១០០ដុល្លាទេ ។ ចំណែកកម្មករដែលមានផ្ទៃពោះ គេឱ្យចេញមុនម៉ោង៥នាទី ហើយសន្តិសុខជាអ្នកចុចបុងឱ្យ តែបើគេចាប់បានកម្មករណាដែលគ្មានផ្ទៃពោះ ហើយចេញមុនម៉ោង៣នាទីឬ៥នាទីគេនឹងហៅទៅផ្តិតមេដៃព្រមាន បើគ្រប់បីដងគេនឹងធ្វើតាមច្បាប់របស់គេ តែមិនដឹងថាច្បាប់របស់គេនោះយ៉ាងម៉េចទេ កម្មករមិនដែលដឹងច្បាប់អ្វីទេ ព្រោះច្បាប់ទាំងនោះថៅកែក្រុមហ៊ុនជាអ្នកដាក់ខ្លួនឯង ។

ខ្ញុំធ្វើការនៅរោងចក្រ **គីនតាយ** បាន២ឆ្នាំ ក៏ឈប់ត្រឡប់ទៅផ្ទះ ដោយសារមានជំងឺពកករ ថ្លៃព្យាបាលអស់ ៨០០ដុល្លា ដោយម៉ែបានលក់ជ្រូក និងទ្រព្យសម្បត្តិក្នុងផ្ទះទាំងអស់ មិនត្រឹមតែប៉ុណ្ណោះ ម៉ែបានទៅខ្ចីលុយ បងប្អូនថែមទៀត តែមិនដឹងប៉ុន្មានទេ ហើយក៏នៅជំពាក់បំណុលគេ ដល់សព្វថ្ងៃនេះឯង ។

ក្រោយពីព្យាបាលជំងឺអស់រយៈពេល២ឆ្នាំមក ខ្ញុំក៏ត្រឡប់មកធ្វើការនៅរោងចក្រ **គីនតាយ** វិញ ដោយបានប្រាក់ខែ ៤៥ដុល្លា (១.៧៣ដុល្លា) ធ្វើការទីនោះបាន២ឆ្នាំក្រោយមក គេតំឡើង១.៨ដុល្លាទៀត រហូតមកដល់សព្វថ្ងៃនេះ ។ ពេលខ្ញុំត្រឡប់មកវិញ សហជីពC-CAWDU ហាក់ដូចជាមិនសូវអើពើដោះស្រាយបញ្ហានានាឱ្យកម្មករទេ ដូច្នេះឥឡូវនេះ កម្មករមិនសូវមានជំនឿលើសហជីពទៀតទេ ។ មិនត្រឹមតែប៉ុណ្ណោះរោងចក្រ គឺមានថែមទូវសហជីពមួយទៀតឈ្មោះ យុវជនខ្មែរ ហើយមិនដឹងថាសហជីពថ្មីនេះយ៉ាងណាទេ ព្រោះទើបតែចូលធ្វើការនៅក្នុងរោងចក្រនេះបាន៣ខែប៉ុណ្ណោះ ។

ចំណែកបន្ទប់ជួលវិញខ្ញុំនៅគ្នា៣នាក់ បង់មួយខែ២០ដុល្លា ភ្លើងមួយគីឡូ១០០០រៀល ប៉ុន្តែម្ចាស់ផ្ទះវិញមុខមិនសូវរីកទេ ពេលណាពួកខ្ញុំមិននៅគេបិទភ្លើងក្នុងបន្ទប់ឡើងងងឹតសូន្យ ហើយដំបូលផ្ទះវិញ ពេលមានភ្លៀងទឹកសាចលេចពេញបន្ទប់ ពួកខ្ញុំក៏បានប្រាប់ម្ចាស់ផ្ទះដែរតែគេមិនបានអើពើ រឺក៏ជួសជុលឱ្យឡើយ ។ ពួកខ្ញុំចង់ដូរទៅជួលកន្លែងផ្សេងដែរតែខ្លាច ព្រោះផ្ទះនេះនៅជិតរោងចក្រ ។

កាលពីមុនខ្ញុំធ្លាប់បានផ្ញើរលុយទៅផ្ទះមួយខែ៥០ដុល្លា តែឥឡូវនេះមិនដែលបានផ្ញើរទៅទេ ព្រោះពេលបើកមកឱ្យតែ ថ្លៃផ្ទះ ម្ហូបអាហារ និងទិញអ្វីៗផ្សេងទៀតមិនចង់គ្រាន់ផង សរុបទៅក្នុង១ខែខ្ញុំចាយតែម្នាក់ឯង អស់ជាង៤០ដុល្លាឯណោះ ដូច្នេះមួយខែៗមិនដែលសល់លុយទេ ។ ពេលខ្ញុំមិនបានផ្ញើរលុយទៅផ្ទះបែបនេះ ម៉ែក៏យ៉ាប់ដែរព្រោះគាត់ពឹងលើខ្ញុំទាំង ស្រុងទៅហើយ ។

ធ្វើការតាំងពីឆ្នាំ១៩៩៨ មកដល់សព្វថ្ងៃនេះ ខ្ញុំគ្មានសល់អ្វីទេ គឺបានត្រឹមតែជួយម៉ែដោះស្រាយជីវភាពគ្រួសារប៉ុណ្ណោះ ។ ទៅថ្ងៃអនាគតបើរោងចក្របិទខ្ញុំនឹងត្រឡប់ទៅស្រុកវិញហើយលក់ដូរបន្តិចបន្តួច តែក៏ចង់រកស៊ីធំដំនឹងគេដែរ ប៉ុន្តែគ្មាន ដើមទុនឡើយ ។

ករណីសិក្សាទី ៤១

តំបន់មានជ័យ

ថ្ងៃទី ២២-២៣ កញ្ញា ២០០៥

នាងខ្ញុំឈ្មោះ គ ស ង អាយុ២១ឆ្នាំ មិនទាន់រៀបការទេ គ្រួសារមានសមាជិក៧នាក់ បងប្អូន៥នាក់ ស្រី២ ប្រុស៣ ខ្ញុំជាកូនទី២ ហើយបងទី១ប្រុសរៀបការរួចទៅរស់នៅខាងប្រពន្ធ ចំណែកឯប្អូនៗនៅរៀនទាំងអស់ ។ ពួកយើងរស់នៅជាមួយពុកម៉ែ នៅភូមិចំបក់ ឃុំចំបក់ ស្រុកព្រែកប្រសប់ ខេតក្រចេះ ។

គ្រួសាររបស់ខ្ញុំប្រកបរបរធ្វើស្រែចំការ យើងមានដី៣កន្លែង (មិនដឹងទំហំដី) ។ ក្នុង១ឆ្នាំៗធ្វើស្រូវបានគ្រប់សំរាប់បរិភោគតែមិនបានសល់ឡើយ តែក៏មានឆ្នាំខ្លះធ្វើស្រូវមិនបានផលដែរ ក្រៅពីធ្វើស្រែម៉ែរបស់ខ្ញុំបានលក់បន្លែបន្តិចបន្តួចដើម្បីទិញស្រូវអង្ករ នឹងម្ហូបអាហារខ្លះសំរាប់បរិភោគ ហើយម៉ែក៏ធ្លាប់ខ្ចីលុយពីបងប្អូនដើម្បីដោះស្រាយជីវភាពគ្រួសារផងដែរតែមិនដែលមានការប្រាក់ឡើយ ។

ឆ្នាំ២០០៣ ក្រោយពេលប្រឡងធ្លាក់ថ្នាក់ទី៩ ខ្ញុំក៏ឈប់រៀនដោយសារកាលនោះជីវភាពគ្រួសារមិនសូវធូរធារផង ណាមួយចង់ជួយដោះស្រាយជីវភាពគ្រួសារផងនោះ ខ្ញុំក៏សំរេចចិត្តឈប់រៀនដើម្បីមករកការងារធ្វើនៅទីក្រុង ពេលនោះខ្ញុំមកភ្នំពេញតាមរយៈមិត្តភក្តិដែលនៅស្រុកជាមួយគ្នា ។ ពុកម៉ែបានយកលុយដែលពួកគាត់បានសន្សំទុក ៧០ដុល្លា មកឱ្យខ្ញុំសំរាប់ឱ្យខ្ញុំធ្វើដំណើរមកភ្នំពេញ ។ មកដល់ភ្នំពេញដំបូង ខ្ញុំបានចូលធ្វើតេស្តនៅរោងចក្រ **តាក់ហ្វាត** អ្នកដែលនាំខ្ញុំចូលធ្វើតេស្តបានប្រាប់ថាប្រសិនបើខ្ញុំធ្វើតេស្តជាប់គេនឹងយកលុយ ប៉ុន្តែខ្ញុំធ្វើតេស្តអត់ជាប់ឡើយ ព្រោះខ្ញុំគ្មានអត្តសញ្ញាណប័ណ្ណ ដូច្នេះខ្ញុំក៏មិនចាំបាច់បង់លុយឱ្យគេដែរ ។ ក្រោយមកខ្ញុំក៏ដើរធ្វើតេស្តនៅកន្លែងផ្សេងៗទៀតប្រហែល៤-១០ថ្ងៃ ទើបមានអ្នកស្គាល់ម្នាក់បាននាំខ្ញុំចូលទៅធ្វើតេស្តនៅរោងចក្រ **M&V** ព្រោះគេស្គាល់ប្រធានក្រុម តែត្រូវបង់លុយគេ៥០ដុល្លាជាមុន រួចគេឱ្យខ្ញុំពាក់កាតអ្នកចាស់ (កម្មករផ្សេង) ដើម្បីចូលទៅរៀនដេរនៅក្នុងរោងចក្រ ។ ក្រោយពីរៀនដេរបាន៥ថ្ងៃ ថៅកែរោងចក្រគេមកមើលគេមិនទទួលខ្ញុំធ្វើការទេ ព្រោះគេដឹងថាមានគេយកលុយពីខ្ញុំ តែអ្នកដែលយកលុយខ្ញុំនោះចង់ឱ្យខ្ញុំទៅធ្វើតេស្តម្តងទៀត ព្រោះគេមិនចង់ឱ្យលុយមកខ្ញុំវិញទេ តែខ្ញុំអត់ព្រមគេក៏អោយលុយមកខ្ញុំវិញ ។

បន្ទាប់មកខ្ញុំក៏ទៅធ្វើតេស្តនៅរោងចក្រផ្សេងៗទៀត ដូចជា នៅតាខ្មៅ ជំពូរវ័ន្ត ប៉ុន្តែធ្វើមិនដែលជាប់សោះគឺអស់តែលុយធ្វើសាហ៊ុយទៅប៉ុណ្ណោះ ។ ៣-៤ខែក្រោយមកទៀត ខ្ញុំក៏ចាយលុយអស់ ទើបបានចូលជាកម្មករបណ្តែតនៅរោងចក្រ **ញូញៀន** បានប្រហែលជា១ខែ ក៏បើកលុយដើម្បីដោះស្រាយសោហ៊ុយទៅផ្ទះវិញ ។

ក្រោយពីនៅផ្ទះបាន ២ខែ គិតថាខ្ចាស់គេណាស់ដូច្នេះខ្ញុំក៏មកភ្នំពេញម្តងទៀត ដោយមកបានប្រហែលជា១ខែ ក៏ធ្វើតេស្ត ជាប់នៅនៅរោងចក្រ **ណេតហ្គេអេធី អិបភើរីល** ផ្នែកតុកាត់ មុខងារអូសក្រណាត់ នៅសង្កាត់ចក្រអង្រែ ខ័ណ្ឌមានជ័យ ។ ម្តងនេះខ្ញុំធ្វើតេស្តជាប់ដោយខ្លួនឯងដោយមិនបានបង់លុយឡើយ ។ ធ្វើការ៣ខែដំបូងបានប្រាក់ខែ៤០ដុល្លា ហើយគេមិន បង្ខំទេ តែខ្ញុំខំប្រឹងដោយខ្លួនឯងព្រោះខ្លាចអត់ជាប់ ។

រោងចក្រ **ណេតហ្គេអេធី អិបភើរីល** នេះ មានកម្មករ១០០០នាក់ ថៅកែជាជនជាតិចិន សហជីពឈ្មោះ សហជីព ជាតិនៃឧស្សាហកម្មកាត់ដេរកម្ពុជា ។ ខ្ញុំបានចូលជាសមាជិកសហជីពនេះ បន្ទាប់ពីមានតំណាងកម្មករម្នាក់ឈ្មោះសិទ្ធិ បានមកប្រាប់ថា បើកម្មករចូលជាសមាជិកសហជីព សហជីពនឹងជួយដោះស្រាយ ឬជួយធ្វើការតវ៉ាផ្សេងៗ ។ ប៉ុន្តែតាំងពី ចូលជាសមាជិកសហជីពមក ខ្ញុំមិនដែលមានបញ្ហាធំដុំទេ គ្រាន់តែថាបើមកមិនទាន់ ម៉ោង៥នាទី សហជីពគេជួយតវ៉ាមិន ឱ្យដាច់លុយព្រីម រាល់ពេលដែលយើងធ្វើខុស១-២ដង សហជីពអាចជួយបាន តែបើមានបញ្ហាច្រើនគេក៏មិនអាចជួយបាន ដែរ តែកម្មករនៅក្នុងរោងចក្រមិនសូវមានគេបញ្ឈប់ទេ ។ ធ្វើការនៅទីនេះស្រួលសុំច្បាប់ បើមានបំណាច់ឆ្នាំអត់ដាច់ លុយព្រីមទេ បើគ្មានបំណាច់ឆ្នាំគឺដាច់លុយព្រីម តែប្រាក់ខែ៤៥ដុល្លាដដែល ។ ប្រាក់ខែរបស់ខ្ញុំគិតជាមធ្យម៦០-៧០ដុល្លា ក្នុងខែបូកទាំងប្រាក់ថែមម៉ោង ហើយខែខ្លះបើថែមម៉ោងច្រើនគឺអាចបានរហូតដល់៩០ដុល្លា បើអត់មានការងារធ្វើបាន ប្រាក់ខែតែ៥០ភាគរយប៉ុណ្ណោះ គឺបានត្រឹម២០-៣០ដុល្លា ។ ខ្ញុំមិនសូវបានផ្ញើរលុយទៅផ្ទះញឹកញាប់ទេ ត្រូវសន្សំទុកពេល បានច្រើនទើបផ្ញើទៅ តាំងពីបានចូលធ្វើការមកខ្ញុំផ្ញើរលុយទៅផ្ទះបាន២ដងប៉ុណ្ណោះ គឺ១៥០ដុល្លា តែនៅពេលដែលរោង ចក្រគ្មានការងារគេអោយឈប់ម្តង១ខែ ម្តង២ខែ ហើយគេបើកប្រាក់ខែ៥០ភាគរយប៉ុណ្ណោះ ដូច្នេះខ្ញុំត្រូវត្រឡប់ទៅ យកលុយនិងអង្ករពីផ្ទះមកវិញ ព្រោះថាខ្ញុំត្រូវបង់ថ្លៃបន្ទប់គេជារៀងរាល់ខែ ។ ក្នុងមួយខែខ្ញុំចាយម្នាក់ឯងអស់៣០ដុល្លា ថ្លៃបន្ទប់ស្នាក់នៅ២០ដុល្លាក្នុងមួយខែ (នៅគ្នា៣នាក់ ត្រូវចែកគ្នាចេញថ្លៃបន្ទប់) ភ្លើង៦គីឡូ ១គីឡូ១០០០៛ ។

ពេលពួកខ្ញុំមកនៅដំបូងម្ចាស់ផ្ទះល្អនជាធម្មតាទេ តែនៅពេលភ្លើងឡើងថ្លៃ គាត់បានដើរបិទភ្លើងនៅពេលដែលគ្មាន កម្មករនៅ មិនតែប៉ុណ្ណោះបន្ទប់ដែលជួលនោះបានលេចទឹកនៅពេលដែលមានភ្លៀងខ្លាំង ធ្វើអោយពួកខ្ញុំពិបាកដេកណាស់ តែពួកខ្ញុំសុខចិត្តទ្រាំ ពីព្រោះបន្ទប់ជួលនោះវានៅជិតរោងចក្រ ហើយក៏មិនសូវមានមនុស្សច្រើនអ៊ូរអរផងដែរ ប៉ុន្តែ ប្រសិនជាមានបងប្អូន រឺមិត្តភក្តិមកលេង ម្ចាស់ផ្ទះមុខមិនសូវរីកប៉ុន្មានទេ ។

បើសិនរោងចក្របិទខ្ញុំនឹងត្រឡប់ទៅផ្ទះវិញ ព្រោះតាំងពីធ្វើការមកខ្ញុំមិនមានលុយកាក់សល់បន្តិចនោះទេ តែបើមាន ការងារធ្វើចេះតែធ្វើទៅ ព្រោះបើដូរទៅរកការងារនៅរោងចក្រផ្សេងទៀតខ្លាចធ្វើតេស្តមិនជាប់ ព្រោះខ្ញុំមិនចេះដេរ ដូច្នេះចេះតែទ្រាំធ្វើការនៅទីនេះបន្តទៅ ។

បើសិនជាមានលុយ ខ្ញុំចង់បើកហាងលក់ខោអាវ គ្រឿងក្រអូប សំភារៈតែងខ្លួនផ្សេងៗ តែគ្មានសង្ឃឹមទេ ព្រោះឥឡូវនេះ បើកលុយមកមិនដែលសល់ផងនោះ ។

## ករណីសិក្សាទី ៤២
## ថ្ងៃទី ២២ តុលា ២០០៥

នាងខ្ញុំឈ្មោះ ឡ ស រ៉ា អាយុ២៥ឆ្នាំ មានបងប្អូន៦នាក់ ប្រុស៣ ស្រី៣ ខ្ញុំជាកូនទី១ បច្ចុប្បន្នធ្វើការនៅ **រោងចក្រស្គតវើរ** ស្រុកកំណើតនៅ ភូមិឧកញ៉ាប៉ាង ឃុំសង្វែក ស្រុកកំពង់ត្រាច ខេត្តកំពង់ឆ្នាំង ។ ពុកម៉ែធ្វើស្រែចំការតែមិនបានដឹងថាគាត់មានស្រែប៉ុន្មានទេ ។ ក្នុងមួយឆ្នាំធ្វើស្រែ២ដង គឺស្រូវវស្សាបាន ៦០ថាំង និងស្រូវប្រាំងបាន១០០ថាំង (១ថាំង ២៤គីឡូក្រាម) ។ ស្រូវដែលធ្វើបាន គឺហូបមិនគ្រប់សំរាប់ ១ឆ្នាំទេ ព្រោះក្រៅពីធ្វើស្រែពុកម៉ែគ្មានមុខរបរអ្វីទៀតឡើយ ដូច្នេះពួកគាត់បានលក់ស្រូវខ្លះដើម្បីចំណាយលើ ម្ហូបអាហារ ព្យាបាលជំងឺ និងការសិក្សារបស់ប្អូន៧ជាដើម មិនតែប៉ុណ្ណោះត្រូវខ្ចីគេបន្ថែមខ្លះទៀតដើម្បីផ្គត់ផ្គង់នៅពេលចាំបាច់ ។

បានចូលធ្វើការរោងចក្រដោយសារបងថ្លៃស្រី ខាងពូជីដូនខ្ញុំដែលគាត់ជាគ្រូបង្រៀន ផ្ទះរបស់គាត់នៅចក្រអង្រែ ហើយគាត់មានផ្ទះជួលឱ្យសំរាប់ឱ្យកម្មករស្នាក់នៅ នៅម្ដុំចក្រអង្រែនោះឯង ។ ថ្ងៃមួយគាត់បានមកលេងផ្ទះខ្ញុំ ហើយប្រាប់ម៉ែឱ្យខ្ញុំនេះមកធ្វើការរោងចក្រនឹងគេទៅ គ្រាន់បានលុយកាក់ខ្លះជួយដោះស្រាយជីវភាពគ្រួសារ ដោយពេលនោះរោងចក្រកំពុងរើសកម្មករផង ទោះមិនចេះក៏គេយកទៅបង្រៀនដែរ ។ ប៉ុន្តែ ពុកមិនព្រមឱ្យខ្ញុំមកទេ ព្រោះលឺអ្នកភូមិនិយាយថាស្រីៗធ្វើការរោងចក្រមិនល្អ ចែជន្យ១ខែក្រោយមកពុកឈឺធ្ងន់ ឯចំណែកម៉ែមានទំងន់ប្អូនពៅ៦ខែ ថែមទាំងមានគ្រោះក្នុងតំរង់នោមទៀតផង ក្រោយពេលគាត់លេបថ្នាំដែលពេទ្យស្រុកឱ្យមកបាន១ខែនោះ គាត់ក៏ចុកពោះយ៉ាងខ្លាំងហើយពួកខ្ញុំបានយកគាត់មកពេទ្យរុស្ស៊ីនៅភ្នំពេញ ពេទ្យក៏ប្រាប់ថាកូនក្នុងពោះនោះបានស្លាប់ហើយ ហើយត្រូវការវះកាត់ជាបន្ទាន់ ដូច្នេះពុកក៏បានលក់គោអស់បួនក្បាល ព្រមទាំងខ្ចីលុយអ៊ុំខ្ញុំ៥០០ដុល្លាទៀត ទើបព្យាបាលជំងឺម៉ែបានជាសះស្បើយ អ៊ុំបានប្រាប់ឱ្យខ្ញុំមកធ្វើការនៅរោងចក្រទៅដើម្បីជួយដោះស្រាយជីវភាព ចំណែកលុយដែលជំពាក់ គាត់នោះពេលណាដែលមានលុយចាំសងក៏បាន បន្ទាប់មកពុកក៏បានឱ្យលុយខ្ញុំខ្លះដើម្បីមករកការងារធ្វើនៅភ្នំពេញ ។

ពេលនោះគឺក្នុងកំឡុងឆ្នាំ១៩៩៨ ខ្ញុំក៏បានមករកបងថ្លៃរបស់ពូនៅចក្រអង្រែ ដើម្បីពឹងគាត់ឱ្យជួយរកការងារឱ្យខ្ញុំធ្វើ គាត់ក៏បានសួរអ្នកដែលអាចនាំចូលទៅធ្វើការរោងចក្រ ពេលនោះគេបានប្រាប់ថារោងចក្រ **គីនតាយ** ត្រូវការរើសកម្មករ តែគេយកលុយមុនដោយម្នាក់ត្រូវបង់៥០ដុល្លា ខ្ញុំក៏បង់លុយឱ្យគេ៥០ដុល្លា ហើយគេប្រាប់ខ្ញុំថាត្រូវរង់ចាំសិន នៅពេលគេត្រូវការគាត់នឹងមកហៅ ។ ប៉ុន្តែខ្ញុំបានរង់ចាំរយៈពេល៣ខែ នៅតែមិនទាន់បានការងារធ្វើទៀត ដូច្នេះបងថ្លៃពូក៏ទៅយកលុយពីគេមកវិញ ។

បន្ទាប់មកនៅថ្ងៃ១៨ វិច្ឆិកា ១៩៩៨ ខ្ញុំបានចូលធ្វើកម្មករបណ្ដែតនៅរោងចក្រ **ហ្គោលតិច** បានតែ១ថ្ងៃ បើកលុយបាន ៦,០០០រៀល ខ្ញុំក៏ឈប់ពីទីនោះ ព្រោះគេឱ្យឈររហូតខ្ញុំទ្រាំទ្រអត់បាននោះទេ ។ ក្រោយពីឈប់ធ្វើការនៅហ្គោលតិច

បាន២-៣ថ្ងៃ អ្នកជួលផ្ទះបងថ្លៃពូម្នាក់បានប្រាប់ថារោងចក្រ **ស្តតវីរ** ត្រូវការរើសកម្មករ ខ្ញុំក៏សុំឱ្យគាត់ជួយនាំចូល ប៉ុន្តែខ្ញុំបានបង់ឱ្យគាត់៥០ដុល្លាទៅតាមការសុំរបស់គាត់ ។ ចាប់ផ្តើមចូលធ្វើការដំបូង គឺវេនយប់ ចូលម៉ោង៧យប់ ញ៉ាំបាយម៉ោង១២យប់ ចូលវិញម៉ោង១ ចេញមកផ្ទះម៉ោង៦ព្រឹក ជួនកាលថែមម៉ោងដល់ម៉ោង ១០ព្រឹកទៀតផង ។ ធ្វើការនៅទីនោះបាន១០ថ្ងៃ គេក៏យកទៅដាក់នៅរោងចក្រ **តាក់ហ្វាត** នៅចក្រអង្រែលើ ផ្នែកវេចខ្ចប់ វេនយប់ហើយត្រូវចេញចូលនៅម៉ោងដដែល ពេលធ្វើការត្រូវឈររហូត ដោយប្រាក់ខែគិតតាមចំនួយបុងដែលធ្វើបាន៧០ដុល្លា ពេលនោះខ្ញុំត្រូវបានញ៉ាំបាយក្នុងរោងចក្រតែខាងរោងចក្រគេកាត់លុយ ៣ដុល្លាក្នុងមួយខែ ។

រោងចក្រនេះគ្មានសហជីពទេ ការសុំច្បាប់មានការពិបាក ហើយប្រាក់ខែកម្មករធ្វើការវេនយប់មិនត្រូវបានគុណបន្ថែមឱ្យទេ ហើយកម្មករទាំងអស់ធ្វើការទាំងថ្ងៃអាទិត្យនិងថ្ងៃបុណ្យថែមទៀតផង ។ កម្មករវេនយប់ធ្វើការបាន១ខែត្រូវដូរមកវេនថ្ងៃវិញម្តង (១ខែដូរវេនម្តង) ចូលម៉ោង៧ព្រឹកហើយចេញញ៉ាំបាយម៉ោង១១ថ្ងៃត្រង់ ហើយត្រូវចូលវិញនៅម៉ោង១២ថ្ងៃត្រង់ នឹងចេញមកផ្ទះវិញនៅម៉ោង៦ល្ងាច ជួនថែមដល់ម៉ោង៩យប់ក៏មាន នៅពេលដែលមានខោប្រញាប់ត្រូវថែមម៉ោងដល់ភ្លឺ ហើយស្អែកឡើងអាចធ្វើការបន្តទៀតក៏មាន បើពេលយប់ងងុយគេងខ្លាំងខាងរោងចក្រអាចអោយគេងនៅក្នុងរោងចក្រដោយមិនឱ្យចេញមកផ្ទះនោះឡើយ ។ ធ្វើការនៅ**តាក់ហ្វាត**បានតែ៥ខែក៏សុំគេដូរមកស្តតវីរវិញ ព្រោះឆ្ងាយពីផ្ទះជួល (ជួលផ្ទះបងថ្លៃពូ) ម្យ៉ាងទៀតខ្ញុំមិនហ៊ានដើរឆ្លងថ្នល់ផង បន្ទាប់ពីស្នើសុំហើយខាងរោងចក្រក៏បានយល់ព្រមឱ្យមកធ្វើការនៅ **ស្តតវីរ** ព្រោះគិតថាវាជាសាខាជាមួយគ្នា។ កាលពីធ្វើការនៅរោងចក្រ តាក់ហ្វាត ខ្ញុំមិនបានដឹងថារោងចក្រដេរខោម៉ាកអ្វីនោះទេ គ្រាន់តែដឹងថាដេរខោកីឡាតែប៉ុណ្ណោះ ។

ពេលមករោងចក្រស្តតវីរ ខ្ញុំនៅផ្នែកវេចខ្ចប់ដដែល បានកន្លះខែក៏ត្រូវដូរវេនម្តង ។ ចំពោះច្បាប់ការងារនៅតាក់ហ្វាត និងស្តតវីរ គឺដូចគ្នា ត្រូវញ៉ាំបាយក្នុងរោងចក្រហើយគេកាត់លុយពីប្រាក់ខែ ៣ដុល្លាជារៀងរាល់ខែ ។ បើកប្រាក់ខែបាន៧០ដុល្លា ខ្ញុំបង់ថ្លៃផ្ទះ១៥ដុល្លា គិតទាំងញ៉ាំបាយជាមួយពួកគាត់ផង ។

ចូលដល់ឆ្នាំ២០០០ មានការបញ្ឈប់កម្មករជាច្រើននាក់ ដោយមិនគុណលុយឱ្យឡើយ ហើយខាងក្រុមហ៊ុនបានរើសបុគ្គលិកម្នាក់ឈ្មោះ អោន នួន ដែលធ្វើការនៅផ្នែករដ្ឋបាលឱ្យធ្វើជាប្រធានសហជីពនៅក្នុងរោងចក្រ ហើយបុគ្គលនោះមិនដែលជួយដោះស្រាយឱ្យកម្មករសោះ ។ មកដល់ឆ្នាំ២០០១ ប្រធានក្រុមផ្នែកអ៊ុតឈ្មោះ តុល ប៊ុនណាត់និងកូនចៅរបស់គាត់៦នាក់ទៀតត្រូវចិនបញ្ឈប់ពីការងារ ពេលនោះកម្មករដែលបានគេបញ្ឈប់នោះបានពឹងពាក់លោកអោន នួនអោយជួយដោះស្រាយ ពេលនោះគាត់បានស្នើឱ្យកម្មករផ្នែក បង្អើយការទាំងអស់ឱ្យឈរនៅមុខរោងចក្រដោយកុំព្រមចូលធ្វើការ បន្ទាប់មកពួកខ្ញុំបានយល់ព្រមធ្វើតាមសំណើររបស់គាត់ នៅពេលឃើញសភាពដូចនេះខាងក្រុមហ៊ុនក៏បានយល់ព្រមឱ្យអ្នកទាំង៦នោះចូលមកធ្វើការវិញ ។ ចាប់ពីពេលនោះមកកម្មករទាំងអស់ក៏បានលើក អោន នួនជាប្រធានសហជីពដោយបានបោះឆ្នោតត្រឹមត្រូវ ហើយធ្វើការគាត់បានធ្វើការសហការជាមួយសហព័ន្ធ ម៉មញឹម ។ ពេលដែលកម្មករមានបញ្ហាគាត់តែងតែជួយដោះស្រាយជានិច្ច ដូចជាសំនូមពរ មួយចំនួនកម្មករបានឱ្យគាត់ជួយទាមទារគឺៈ

កម្មករធ្វើការវេនយប់ត្រូវគុណលុយឱ្យ ឯថ្ងៃបុណ្យនិងថ្ងៃអាទិត្យ មិនត្រូវបង្ខំកម្មករឱ្យថែមម៉ោង ត្រូវឱ្យកម្មករស្ម័គ្រចិត្តដោយខ្លួនឯង ហើយសុំអោយឈប់ញ៉ាំបាយនៅក្នុងរោងចក្រ ។ សំនូមពរទាំងប៉ុន្មានខាងលើនេះ គឺ អោន នួន បានជួយទាមទារ និងដោះស្រាយបានសំរេចតាមសំនូមពររបស់កម្មករ ។ ចូលដល់ឆ្នាំ២០០៣ រោងចក្របានពង្រីកថែមអាគារ៥ជាន់ទៀត ប៉ុន្តែនាយកគ្រប់គ្រងផ្សេងគ្នា ដោយឱ្យកម្មករស៊ីប្រាក់ខែទាំងអស់គ្នា ពេលនោះហើយដែលសហជីពខាង ម៉មញឹម លែងសូវរវីរវល់ ឬ ជួយកម្មករទៀតហើយ ពេលណាមានរឿងពឹងគាត់ ភាគច្រើនគាត់ជួយនិយាយឱ្យខាងក្រុមហ៊ុនទៅវិញ ។ ហេតុដូច្នេះហើយបានជាកម្មករបង្កើតសហជីពមួយទៀត ឈ្មោះ ជឿនលឿន តែថ្ងៃមួយនៅដើមឆ្នាំ២០០៤ នោះ ខាងក្រុមហ៊ុនបានបញ្ឈប់កម្មករនៅផ្នែកតុកាត់មួយក្រុម ដោយគ្មានគុណលុយឱ្យតាមច្បាប់ឡើយ ហើយខាងសហជីព ជឿនលឿន និងកម្មករជាង១ពាន់នាក់ទៀតបានចេញមុខធ្វើកូដកម្មតវ៉ា តែត្រូវបានខាងក្រុមហ៊ុនបញ្ឈប់ពីការងារទាំងអស់ដោយគុណលុយឱ្យបានតែ ២០០-៣០០ដុល្លាប៉ុណ្ណោះក្នុងម្នាក់ៗ ដោយមិនត្រឹមត្រូវតាមច្បាប់ឡើយ ចំណែកឯខាងសហជីព១២នាក់ដែលរួមទាំងប្រធានផងនោះត្រូវបានគេព្យួរការងារ ហើយគេបានជួលប៉ូលីសឱ្យយាមនៅមុខរោងចក្រទៀតផងដើម្បីមិនឱ្យអ្នកទាំង១២នោះចូលមកក្នុងរោងចក្របានឡើយ ហើយក៏គ្មានកម្មករណាម្នាក់ហ៊ានចេញមុខជួយតវ៉ាឱ្យពួកគេឡើយ ។

ចូលដល់ឆ្នាំ ២០០៥ ក្រោយពីកូតាត្រូវបានបញ្ចប់ ច្បាប់ការងារនៅរោងចក្រ **ស្ពតវ៉ែរ** រឹតតែពិបាកឡើងៗ ដូចជាអនុញ្ញាតឱ្យច្បាប់បានលុះត្រាតែសហជីពសុំឱ្យ ឯតំលៃបុងពីមុន ១០០០ខោ បាន ១,២ដុល្លា តែឥឡូវនេះទាល់ តែបាន ១៥០០ខោ ទើបបាន ១,២ដុល្លា ។ អ្នកពោះធំវិញបើដាក់ច្បាប់សំរាលកូន៣ខែ បើកលុយសរុបបាន ៧០ដុល្លា ។ មានការផ្លាស់ប្តូរម៉ោងធ្វើការដូចជា ថ្ងៃចូលធ្វើការម៉ោង៦ព្រឹក ញ៉ាំបាយម៉ោង១០ ចូលម៉ោង១១ថ្ងៃត្រង់ បើគ្មានថែមម៉ោងចេញម៉ោង៣រសៀល បើមានថែមចេញម៉ោង៥ល្ងាច វេនយប់ចូលម៉ោង១១ថ្ងៃត្រង់ ញ៉ាំបាយម៉ោង៤រសៀល ចូលវិញម៉ោង៥ល្ងាច បើគ្មានថែមម៉ោងចេញម៉ោង៨យប់ បើថែមចេញម៉ោង១០យប់ ។

រោងចក្រ ស្ពតវ៉ែរ មានថៅកែជាជនជាតិចិន ចូលសញ្ជាតិខ្មែរ កម្មករ៧០០០នាក់ ឥឡូវនេះមានសហជីព៤គឺ:

១-សហជីពឯករាជ្យ ធ្វើការជាមួយសហព័ន្ធ រស់ សុខ

២-សហជីពខ្មែរ ធ្វើការជាមួយសហព័ន្ធ ជួន មុំថុល

៣-សហជីពសេរីពលករ ធ្វើការជាមួយសហព័ន្ធ សុខ រ៉ាវុធ

៤-សហព័ន្ធ ឆាន់ ណាមឿង ធ្វើការជាមួយសហជីព វាយនភណ្ឌកាត់ដេរ

កាលពីមុនខ្ញុំជាតំណាងកម្មករម្នាក់ធ្វើការឱ្យសហជីកលោកស្រី ម៉ម ញឹម តែឥឡូវខ្ញុំជាតំណាងកម្មករនៅសហជីពឯករាជ្យ សហជីពទាំងអស់ដែលធ្វើការនៅរោងចក្រស្ពតវ៉ែរមិនសូវជួយដោះស្រាយ ឬទាមទារឱ្យកម្មករទេ គិតតែពីផលប្រយោជន៏រៀងៗខ្លួនប៉ុណ្ណោះ ។ ទោះបីជាមានលក្ខខណ្ឌផ្លាស់ប្តូរ រឺការងារពិបាកជាងមុនយ៉ាងណាក៏ដោយក៏ខ្ញុំនៅតែត្រូវផ្ញើលុយទៅផ្ទះ ៣០-៤០ដុល្លាជារៀងរាល់ខែ ហើយលុយដែលសល់ប៉ុន្មានត្រូវទុកដាក់សំរាប់ការចាយវាយផ្សេងៗ ។ ខ្ញុំស្នាក់នៅបន្ទប់ជួលតូចចង្អៀតនៅជាប់នឹងបន្ទប់ទឹក ដល់ពេលមានគេមកងូតទឹកធ្វើឱ្យខ្ញុំគេងមិនសូវបានទេ ព្រោះគ្មានបន្ទប់ទឹក

គ្រប់គ្រាន់ ហើយកម្មករដែលស្នាក់នៅផ្ទះជួលមានច្រើន ។ កម្មករខ្លះពេលមកពីធ្វើការមិនសូវបានងូតទឹកទេ ព្រោះពេលខ្លះម្ចាស់ផ្ទះមិនសូវបូមទឹកទុកឱ្យបានច្រើនឡើយ ហើយម្ចាស់ផ្ទះតែងតែដើរប្រមូលលុយពីកម្មករនៅថ្ងៃទី១០ ជារៀងរាល់ខែ បើកម្មករអត់មានលុយឱ្យនៅថ្ងៃទី១០ទេនោះ នឹងត្រូវគាត់ស្តីឱ្យ ហ្បើគាត់ថាគ្មានពេលមកដើរប្រមូលលុយទេ ។

ជាកម្មកររោងចក្រស្គាល់គ្រប់រសជាតិអស់ហើយ ត្រូវគេបង្ខំអោយធ្វើការគ្មានពេលសំរាក ប្រឈមមុខនឹងជាតិគីមីជារៀងរាល់ថ្ងៃ ដែលធ្វើឱ្យសុខភាពយើងចុះខ្សោយ មិនតែប៉ុណ្ណោះត្រូវទទួលការរិះគន់ពីញាតិមិត្តជិតខាងថែមទៀតផង ។

ខ្ញុំមិនចង់រស់នៅភ្នំពេញទេ ខ្ញុំចង់រស់នៅជាមួយពុកម៉ែឯស្រុកកំណើតវិញ ហើយទៅថ្ងៃអនាគតខ្ញុំតែងសង្ឃឹមថានឹងអាចសល់លុយបន្តិចបន្តួចដើម្បីធ្វើដើមទុនរកស៊ី ប៉ុន្តែឥឡូវនេះសន្សំលុយមិនបានសោះ ព្រោះគ្រួសារខ្ញុំមិនទាន់សងបំណុលគេអស់នៅឡើយ ហើយឥលូវនេះធ្វើស្រូវពុំសូវបានទៀតផង។ ទៅថ្ងៃមុខបើខ្ញុំមានគ្រួសារហើយមានកូននោះ ខ្ញុំនឹងខិតខំឱ្យវាសិក្សារៀនសូត្រអោយបានច្រើន ព្រោះខ្ញុំមិនចង់ឱ្យវាមកធ្វើការរោងចក្រទេវាលំបាកវេទនាខ្លាំងណាស់ ។ ម្យ៉ាងវិញទៀតរបស់របរផ្សេងៗ និង ទំនិញនៅទីផ្សារកាន់តែឡើងថ្លៃ ហើយពុកក៏មានជំងឺប្រចាំកាយ ហើយមិនមានលុយសំរាប់ព្យាបាលនោះទេ។

## ករណីសិក្សាទី ៤៣
## ថ្ងៃទី ១៥ កញ្ញា ២០០៥

នាងខ្ញុំឈ្មោះ ម សម អាយុ២០ឆ្នាំ មិនទាន់រៀបការទេ មានបងប្អូន៦នាក់ ស្រី៥ ប្រុស១ ខ្ញុំជាកូនទី២ សព្វថ្ងៃរស់នៅភូមិថ្លុកវ៉ាយ ឃុំក្រសាំង ស្រុករមាសហែក ខេត្តស្វាយរៀង ។

ពុកម៉ែខ្ញុំប្រកបរបរធ្វើស្រែតែមិនដឹងថាមានស្រែប៉ុន្មានទេ គ្រាន់តែដឹងថាមួយឆ្នាំធ្វើស្រែបាន៤០ថាំងប៉ុណ្ណោះ ប៉ុន្តែផលស្រូវដែលទទួលបានមកមិនបានគ្រប់គ្រាន់សំរាប់ផ្គត់ផ្គង់ជីវភាពគ្រួសារពេញមួយឆ្នាំនោះឡើយ នៅពេលណាខ្វះខាតពុកទៅខ្ចីពីអ៊ុំយកមកញ៉ាំ ជួនកាលអ៊ុំអត់មានដែរ ដូច្នេះពុកបានទៅខ្ចីអ្នកនៅក្នុងភូមិ ហើយបើខ្ចីស្រូវ៥ថាំងស្រូវគេយកការវិញ២ថាំងកន្លះ ។ ផុតរដូវធ្វើស្រែពុកឡើងត្នោត ហើយក្នុងមួយរដូវលក់បាន ២០០,០០០៛ គ្រាន់បានជួយដោះស្រាយជីវភាព ទិញអង្ករ និងម្ហូបបានខ្លះ ។

ពេលកំពុងរៀនថ្នាក់ទី ៦ នៅសាលាតាមិញ មានមិត្តភក្តិរៀនជាមួយគ្នាម្នាក់បបួលខ្ញុំឈប់រៀនដើម្បីធ្វើការរោងចក្រ ពេលនោះដោយសារគ្រួសារខ្វះខាតផង ខ្ញុំក៏សំរេចចិត្តឈប់រៀន ហើយក៏សុំម៉ែមកភ្នំពេញ តែម៉ែមិនឱ្យមកដោយខ្លួនឯងទេ ។ គាត់បានពឹងបងជីដូនមួយខ្ញុំម្នាក់ដែលបានមកធ្វើការនៅរោងចក្រជាយូរមកហើយនោះ ជាអ្នកនាំមក តែពេលនោះម៉ែឱ្យខ្ញុំនៅជួយធ្វើស្រែ១ឆ្នាំសិនចាំមករកការងារធ្វើ បន្ទាប់មកបងជីដូនមួយបានទៅយកខ្ញុំមកភ្នំពេញតាមការពឹងពាក់របស់ម៉ែ ។ ពេលនោះពុកបានលក់គោឈ្មោលតូចមួយបាន ៣០០,០០០៛ ហើយឱ្យលុយនោះឱ្យមកខ្ញុំទាំងអស់ដើម្បីមករកការងារនៅភ្នំពេញ ។

មកដល់ភ្នំពេញបាន ២ថ្ងៃ បងជីដូនមួយរបស់ខ្ញុំគាត់បានទាក់ទងគេ ហើយប្រាប់ថាបង់ឱ្យគេ៥០ដុល្លាជាមុនទើបគេនាំចូលធ្វើការនៅរោងចក្រ **M&V** ពេលខ្ញុំបង់ឱ្យគេហើយ គេប្រាប់ឱ្យខ្ញុំទៅរៀនដេរនៅតាខ្មៅ២ខែសិន ពេលរៀនចេះនឹងមានចិនមកពីរោងចក្រ M&V រើសឱ្យចូលធ្វើការហើយ តែពេលខ្ញុំរៀនចេះគ្មានឃើញចិននៅ M&V មករើសទេ គឺមានតែចិននៅរោងចក្រ **សិនតាបូរ** នៅស្វាយរលំមករើសតែបងខ្ញុំមិនឱ្យទៅធ្វើការនៅទីនោះទេ ព្រោះឆ្ងាយពីគាត់ ដូច្នេះខ្ញុំក៏ឈប់រៀនដេរហើយទៅស្នាក់នៅផ្ទះជួលសិន ជួនពេលនោះដែរម្ចាស់ផ្ទះជួលមិនយកលុយខ្ញុំទេព្រោះគាត់អាណិតខ្ញុំ ។ នៅទីនោះបានមួយអាទិត្យខ្ញុំក៏ដើរធ្វើតេស្តគ្រប់រោងចក្រនៅ ចក្រអង្រែ ប៉ុន្តែខ្ញុំធ្វើតេស្តមិនដែលជាប់សោះ នៅពេលនោះលុយដែលពុកឱ្យមកពីផ្ទះ ខ្ញុំបានចាយអស់ហើយ ដូច្នេះក៏សំរេចចិត្តត្រឡប់ទៅស្រុកវិញ ។

ក្រោយមកបងស្រីរបស់ខ្ញុំក៏មកភ្នំពេញម្តង គឺមកជាមួយអ៊ុំស្រីសាច់ឆ្ងាយម្នាក់ អ៊ុំស្រីបាននាំបងស្រីចូលរៀនដេរនៅបឹងត្របែក ។ បងស្រីបានបង់លុយឱ្យអ្នកនាំចូលធ្វើការម្នាក់នោះអស់៤៥ដុល្លា គេបានប្រាប់បងស្រីថា ពេលរៀនចេះគេនឹងនាំ

ចូលធ្វើការនៅរោងចក្រ **តាក់ហ្វាត** តែពេលរៀនចេះហើយ មិនឃើញគេមកនាំទៅធ្វើការឡើយ ដោយចាំគេយូរពេក បងស្រីក៏ធ្វើតេស្តនៅរោងចក្រ តេវ៉ាតិច បន្ទាប់មកគាត់ក៏បានធ្វើនៅរោងចក្រនោះ ។

នៅពេលបងស្រីទៅស្រុកនៅថ្ងៃបុណ្យភ្ជុំបិណ្ឌ ខ្ញុំក៏មកភ្នំពេញម្តងទៀត ហើយដើរធ្វើតេស្តស្ទើរតែគ្រប់កន្លែងតែមិនដែលជាប់សោះដោយសារខ្ញុំតូចពេក មកបានតែកន្លះខែក៏សំរេចចិត្តត្រឡប់ទៅផ្ទះវិញ ។ ទៅស្រុកបាន៦ខែ ខ្ញុំក៏ត្រឡប់មកភ្នំពេញវិញទៀត អ៊ំស្រីរបស់ខ្ញុំប្រាប់ថាបង់លុយឱ្យគេ៥០ដុល្លា (បង់លុយឱ្យអ៊ំស្រី) រួចហើយគាត់ក៏នាំចូលធ្វើការនៅរោងចក្រ **យីងឡែន** ចក្រអង្រែលើ ផ្នែកកាត់អំបោះដោយខែទី១បានប្រាក់ ខែ២៥ដុល្លា ខែទី២បាន៣០ដុល្លា ។ រោងចក្រនេះឱ្យប្រុងថោកខ្លាំងណាស់ បើដេរអាវប៉ះម៉ូតស្រួល៥០០អាវ គេឱ្យ១ដុល្លា បើអាវពិបាកវិញ៣០០អាវឱ្យ១ដុល្លា ហើយបើគិតតាមកំលាំងរបស់ខ្ញុំក្នុង១ថ្ងៃ បានតែ១ដុល្លា ឬ៩កាក់ប៉ុណ្ណោះ ។ រោងចក្រនេះតូចណាស់ហើយម្យ៉ាងទៀតខ្ញុំបានធ្វើការនៅទីនេះយូរហើយតែមិនបានស្គាល់ថាបានផលិតម៉ាកអ្វីនោះទេ ។ ក្នុងរោងចក្រនេះធ្វើការតែ១វេនទេ ចូលម៉ោង៧ព្រឹកចេញញ៉ាំបាយម៉ោង១១ថ្ងៃត្រង់ ចូលវិញម៉ោង១២ ចេញម៉ោង៤រសៀល បើមានថែមម៉ោងចេញម៉ោង៦ល្ងាច ។ មិនសូវពិបាកក្នុងការសុំច្បាប់ទេតែគេកាត់លុយលើកទឹកចិត្ត៥ដុល្លា ហើយចំពោះការដេរវិញគេមិនដែលដាក់កំណត់ចំនួនដេរឡើយ តែគេកំណត់ចំពោះកម្មករថ្មីសាកល្បង៣ខែ បើធ្វើការល្អគេនឹងឱ្យធ្វើការបន្តហើយបើធ្វើការបានលុយតិច គេបន្ថែមអោយតែបើគ្រប់៣ខែហើយនៅតែមិនបានគ្រប់ចំនួនប្រាក់ឈ្នួលនោះ គេនិងបញ្ឈប់យើងតែម្តង ។

ខ្ញុំធ្វើការនៅរោងចក្រ **យីង ឡែន** បានតែ២ខែក៏សំរេចចិត្តត្រឡប់មកស្រុកវិញ ព្រោះប្រាក់ខែតិចពេកចាយមិនគ្រាន់ទេគ្រាន់តែថ្លៃផ្ទះ ៦ដុល្លាទៅហើយ ។ ទៅស្រុកវិញម្តងនេះខ្ញុំសល់បានលុយ ៧០,០០០៛ ដែរ ខ្ញុំក៏ទិញឥវ៉ាន់សំរាប់ធ្វើបង្អែមលក់នៅស្រុកតែប្រហែល៦ខែក្រោយមក ស្រាប់តែអ៊ំស្រីដែលធ្លាប់នាំខ្ញុំមកធ្វើការពីមុននោះ បានទៅភូមិរបស់ខ្ញុំហើយគាត់និយាយថាបើនរណាចង់រកការងារធ្វើនៅក្នុងរោងចក្រត្រូវមកតាមគាត់ ពេលនោះខ្ញុំក៏សំរេចចិត្តមកភ្នំពេញម្តងទៀត ឯម៉ែមិនចង់ឱ្យខ្ញុំមកទេ ព្រោះពេលមកភ្នំពេញម្តងៗ គាត់ត្រូវលក់គោ ជ្រូក ហើយដើរខ្ចីលុយគេ រីបើមានសល់របស់របរបន្តិចបន្តួចត្រូវប្រមូលលក់អស់ហើយ ទើបគាត់លែងចង់ឱ្យខ្ញុំមកតែពេលនោះគាត់ក៏ទៅខ្ចីលុយតារបស់ខ្ញុំ ១០០,០០០៛ ហើយលក់ជ្រូកមួយទៀតបានលុយ ២០០,០០០៛ សរុបទៅខ្ញុំមានលុយ ៣០០,០០០៛ ដើម្បីមកភ្នំពេញម្តងទៀត លុយនោះបង់គេ ៥០ដុល្លា ដើម្បីបានចូលធ្វើការ និងជិះឡានអស់ ១០,០០០៛ ។

ពេលមកដល់ភ្នំពេញបាន ១អាទិត្យ អ៊ំស្រីនោះបាននាំខ្ញុំចូលរោងចក្រ **ស្តតវែរ** ផ្នែកកាត់អំបោះ ដោយដំបូងគេឱ្យសាកល្បងរយៈពេល ២ខែសិន ទើបគេឱ្យចូលជាកម្មករពេញសិទ្ធិ ។ រោងចក្រស្តតវែរ អោយកម្មករយើងដេរស៊ីប្រាក់ខែហើយច្បាប់ការងារនៅក្នុងរោងចក្រនេះពិបាកខ្លាំងណាស់ ។ មានថ្ងៃមួយនោះខ្ញុំបានឱ្យបងខ្ញុំទៅជួយសុំច្បាប់តាមរយៈប្រធានខ្មែរដើម្បីទៅមើលតាឈឺគេបានអនុញ្ញាតឱ្យឈប់ តែពេលខ្ញុំត្រឡប់មកវិញត្រូវគេស្តីឱ្យ និងកាត់លុយព្រីមហើយកាត់លុយថ្ងៃ ១.៧ដុល្លា ថែមទៀតផង ពេលនោះខ្ញុំខឹងខ្លាំងណាស់តែមិនដឹងធ្វើយ៉ាងម៉េចទេ។

រោងចក្រនេះធ្វើការ ពីរវេន វេនទី១ចូលម៉ោង៦ព្រឹក ញ៉ាំបាយម៉ោង១០ ចូលម៉ោង១១ថ្ងៃត្រង់ ចេញវិញម៉ោង៣រសៀល បើថែមម៉ោង ចេញម៉ោង៥រសៀល និងបានលុយថ្លៃបាយ១០០០៛ ។ ចំណែកវេនទី២ បើថែមម៉ោងចូលម៉ោង ១១ថ្ងៃត្រង់ ញ៉ាំបាយម៉ោង៤រសៀល ចូលម៉ោង៥ល្ងាច ចេញម៉ោង១០យប់ បើមិនថែមម៉ោង ចូលម៉ោង២ រសៀល ញ៉ាំបាយម៉ោង៥ល្ងាច ចូលម៉ោង៥កន្លះ ចេញម៉ោង១០យប់ដដែល ។

ពេលចូលធ្វើការរោងចក្រស្គតវ៉ែរនៅខែដំបូងខ្ញុំបានប្រាក់ខែ៥០ដុល្លា តែក្រោយពីសាកល្បងអស់រយៈពេល២ខែ ខ្ញុំបានប្រាក់ខែពី៦០-៦៦ដុល្លា បូកទាំងថែមម៉ោង ។ រោងចក្រនេះថ្ងៃអាទិត្យ និងថ្ងៃបុណ្យមិនដែលធ្វើការទេ ។

ខ្ញុំធ្វើការនៅជាន់ទី២ អាគារ $1F_6$ ហើយអាគារនេះពិបាកជាងគេ ជាពិសេសនៅក្រុមកាត់អំបោះដែលខ្ញុំកំពុងធ្វើនេះហើយ ទាំងប្រធានខ្មែរ និង ប្រធានចិនប្រើពួកយើងឡើងវិល ដោយឱ្យទៅជួយក្រុមនេះបន្តិច ក្រុមនោះបន្តិច ហើយកម្មករទាំងអស់គ្មាននរណាម្នាក់ហ៊ានតវ៉ាឡើយ ។ ចំណែកសហជីពក៏មិនអើពើនឹងជួយដល់កម្មករដែរ កម្មករកាត់អំបោះត្រូវឈររហូតមិនឱ្យអង្គុយទេ បើគេឃើញអង្គុយ នឹងត្រូវប្រធានខ្មែរស្តីឱ្យមិនខាន បើប្រធានចិនឃើញដែរគេនឹងហៅយើងទៅការិយាល័យផ្តិតមេដៃដើម្បីព្រមាន ទោះបីជាអ្នកពោះធំក៏ត្រូវឈររហូតដែរ ។ មិនតែប៉ុណ្ណោះគេស្រែកអោយកម្មករថា "លឿន១" បង្ខំយើងឱ្យធ្វើការដូចសត្វធាតុ កម្មករសាកល្បងខ្លះមិនហ៊ានតវ៉ាអ្វីទេ ព្រោះគេថាបើហ៊ានតវ៉ានឹងដកចេញភ្លាម សូម្បីតែកម្មករពេញសិទ្ធិខ្លះដែលមានកុងត្រារយៈពេល១ឆ្នាំក៏មិនហ៊ានតវ៉ាដែរ ព្រោះពួកយើងខ្លាចគ្មានការងារធ្វើ បើត្រឡប់ទៅផ្ទះវិញក៏ធ្វើស្រែមិនបានដែរ ។ ចំណែកប្រធានខ្មែរវិញបើដឹងថាមានកម្មករណាម្នាក់និយាយជាមួយសហជីពផ្សេងពីសហជីពរបស់ខ្លួនកម្មករនោះនឹងត្រូវបានប្រធានខ្មែរប្រើច្រើនជាងគេមិនខាន ។ ប្រធានក្រុមខ្មែររើសអើងចំពោះកម្មករក្នុងក្រុមណាស់ ហើយពូកែប្តឹង និងយកចិត្តពួកចិនទៀតផង ។

រោងចក្រ ស្គតវ៉ែរមានសហជីព៤គឺ:

១-សហជីពឯករាជ ធ្វើការជាមួយសហព័ន្ធ រស់ សុខ

២-សហជីពខ្មែរ ធ្វើការជាមួយសហព័ន្ធ ជួន មុំថុល

៣-សហជីពសេរីពលករ ធ្វើការជាមួយសហព័ន្ធ សុខ វ៉ារុធ

៤-សហព័ន្ធ ឆាន់ ណាមឿង ធ្វើការជាមួយសហព័ន្ធវាយនភណ្ឌកាត់ដេរ

ខ្ញុំមើលទៅសហជីព ដូចជាមិនសូវដោះស្រាយអោយកម្មករទេ ហើយខ្ញុំក៏មិនដែលមានរឿងអ្វីត្រូវការពឹង សហជីពដែរ ដូច្នេះហើយបានជាខ្ញុំមិនចូលជាសមាជិកសហជីព ។ ពេលបើកលុយម្តង១ ខ្ញុំត្រូវផ្ញើរលុយទៅផ្ទះ៣០ដុល្លា ជារៀងរាល់ខែ សល់៣០ដុល្លាសំរាប់បង់ថ្លៃផ្ទះ៥ដុល្លា ថ្លៃអង្ករ៤ដុល្លា និងទុកចាយ២០ដុល្លា ។ បន្ទប់ដែលពួកខ្ញុំស្នាក់នៅតូចចង្អៀតណាស់ ហើយនៅគ្នា៦នាក់ បើនៅបែកគ្នានឹងទូលាយជាងនេះ ប៉ុន្តែយើងចង់ចំណាយតិចព្រោះបន្ទប់មួយត្រូវបង់៣០ដុល្លាក្នុងមួយ

ខែ ចំណែកទឹកភ្លើងគេមិនគិតយកលុយទេ បើមានបងប្អូនមកលេងត្រឹម៣-៤ថ្ងៃក៏គេមិនយកលុយដែរ តែបើនៅកន្លះខែឡើងទៅគេនឹងគិតលុយហើយ ។

ខ្ញុំចង់សន្សំលុយទុកទិញដី ដើម្បីធ្វើស្រែនៅពេលដែលខ្ញុំត្រឡប់ទៅផ្ទះវិញ ព្រោះសព្វថ្ងៃគ្រួសារខ្ញុំមានដីស្រែតិចតួចណាស់ ។ ម្យ៉ាងទៀតខ្ញុំមានគំនិតចង់លក់តវ៉ាន់បន្តិចបន្តួចនៅឯស្រុក ហើយមិនចង់រស់នៅភ្នំពេញឡើយ ប៉ុន្តែដោយសារគ្រួសារក្រពេក ទើបដាច់ចិត្តមកធ្វើការនៅភ្នំពេញដើម្បីជួយដោះស្រាយជីវភាព ហើយបើសិនជារោងចក្របិទ ខ្ញុំនឹងត្រឡប់ទៅស្រុកវិញ ទោះជាគ្រួសារក្រយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែត្រឡប់ទៅស្រុកវិញដែរ ហើយបើមានកូនខ្ញុំនឹងតស៊ូឱ្យកូនបានរៀនធ្វើពេទ្យ បើគ្មានលទ្ធភាពក៏ខ្ញុំមិនឱ្យកូនមកធ្វើការរោងចក្រដែរ ព្រោះខ្ញុំមានមេរៀនរួចទៅហើយ ថាវាពិបាកយ៉ាងណា។

ករណីសិក្សាទី ៤៤

ថ្ងៃទី ១៣-១៤ កញ្ញា ២០០៥

នាងខ្ញុំឈ្មោះ អ ស ណ អាយុ ២៤ឆ្នាំ សមាជិកក្នុងគ្រួសាររបស់ខ្ញុំមាន៨នាក់ បងប្អូន៦នាក់ ហើយខ្ញុំជាកូនទី៤ ស្រុកកំណើតនៅ ភូមិជីរោកណ្តាល ឃុំជីរោទិមួយ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម។ គ្រួសារខ្ញុំប្រកបរបរធ្វើចំការដោយមានដីចំការ**៥កន្លែង** តែមិនធ្វើស្រែទេ ហើយត្រូវទិញអង្ករពីផ្សារមកទុកសំរាប់បរិភោគ ។ ផលិតផលបន្លែដែលធ្វើបានពីចំការយើងយកទៅលក់ ឬក៏មានគេមកទិញដល់ចំការ ឯលុយដែលលក់បាន គឺសំរាប់ទិញ អង្ករបរិភោគមួយឆ្នាំវិញ ។

ខ្ញុំបានឈប់រៀននៅឆ្នាំ១៩៩៨ ដោយសារតែគ្រួសាររបស់ខ្ញុំគ្មានលទ្ធភាពជួយឧបត្ថមដល់ខ្ញុំ កាលនោះរៀនទើបបានថ្នាក់ទី៩ប៉ុណ្ណោះ ។ បន្ទាប់ពីឈប់រៀនខ្ញុំបានជួយធ្វើចំការពុកម៉ែ ប៉ុន្តែពីមួយឆ្នាំទៅមួយឆ្នាំ អាកាសធាតុរាំងស្ងួតដែលជាហេតុបណ្តាលឱ្យចំការមិនសូវទទួលបានផលប៉ុន្មានឡើយ ហេតុដូច្នេះខ្ញុំក៏សំរេចចិត្តមករកការងារធ្វើនៅភ្នំពេញដើម្បីជួយសំរាលបន្ទុកបន្ថែមដល់គ្រួសារ ហើយម្យ៉ាងទៀតបងស្រីរបស់ខ្ញុំពីរនាក់បានកំពុងធ្វើការនៅរោងចក្រ **គីនតាយ** ចាក់អង្រែក្រោម ខ័ណ្ឌមានជ័យ ក្រុងភ្នំពេញ ពួកគាត់បាននាំខ្ញុំមកនៅជាមួយ បន្ទាប់ពីរង់ចាំអស់រយៈពេល១ខែ ទើបគាត់សុំចិនបានដើម្បីឱ្យខ្ញុំបានចូលធ្វើការនៅផ្នែកដេរ ។ ខ្ញុំចូលធ្វើការនៅរោងចក្រ **គីនតាយ** នៅថ្ងៃទី២០ ឧសភា ឆ្នាំ២០០០ ។

ចូលធ្វើការដំបូងគេអោយខ្ញុំហាត់រៀនរហូតដល់ចេះ ដោយអោយប្រាក់ខែ១ថ្ងៃ ១,៦ ដុល្លា បីខែក្រោយគេឱ្យប្រាក់ខែ១ថ្ងៃ ១.៧៣ដុល្លា ។

រោងចក្រ **គីនតាយ** មាន៤អាគារៈ ផ្នែកតុកាត់ ដេរ បោកគក់ និងផ្នែកបង្ហើយការ ។ នៅឆ្នាំ២០០០ កម្មករដែលដេរនៅក្នុងក្រុមរបស់ខ្ញុំមិនត្រូវបានខាងរោងចក្របង្ខំឱ្យធ្វើការនោះទេ តែពេលធ្វើការត្រូវមកឱ្យទាន់ម៉ោង ។ ចំពោះការសុំច្បាប់វិញគឺមិនសូវតឹងរឹងនោះទេ តែបើសុំច្បាប់ច្រើនដងក្នុងខែដដែលនោះក៏ពិបាកណាស់ដែរ ។ ប៉ុន្តែចាប់ពីឆ្នាំ២០០៥មកស្ថានភាពដូចជាមានការប្រែប្រួលដូចជា មានការគុណលុយអោយផ្នែកបង្ហើយការ តុកាត់ បោកគក់ ហើយម្យ៉ាងទៀតខាងរោងចក្រមានគំរោងរើសកម្មករថ្មីឱ្យធ្វើការ ព្រោះកម្មករថ្មីងាយស្រួលសំរាប់ពួកគេក្នុងការគ្រប់គ្រង ។ មិនបានប៉ុន្មានថ្ងៃបន្ទាប់កម្មករបាននាំគ្នាធ្វើកូដកម្មដើម្បីទាមទារគុណលុយអោយផ្នែកដេរ ប៉ុន្តែថៅកែនិយាយថាមិនសមហេតុផលក្នុងការទាមទារប្រាក់នេះ ហើយណាមួយវាជារឿងខុសច្បាប់ ។ បន្ទាប់ពីការទាមទារមិនបានសំរេចមក ខាងរោងចក្របានប្រមានដោយផ្តិតមេដៃកម្មករដែលចូលរួមធ្វើកូដកម្ម បន្ទាប់ពីត្រឡប់ចូលមកធ្វើការវិញ។ ចំណែកប្រាក់ខែក៏បើកឱ្យផ្សេងគ្នាដែរ កម្មករធ្វើកូដកម្មគេដាក់ផ្សេង កម្មករដែលមិនធ្វើកូដកម្មគេដាក់ផ្សេង ។

រោងចក្រ **គីនតាយ** មានសហជីព២ C-CAWDU និងយុវជនខ្មែរ តែខ្ញុំមិនបានចូលជាសមាជិកសហជីពឡើយ ព្រោះគ្មានជំនឿ ចំនែកសហជីពយុវជនខ្មែរវិញ ចាំមើលសិនតើគេធ្វើការដើម្បីកម្មករឬយ៉ាងណា ?

តាំងពីចូលឆ្នាំ២០០៥ មក មិនសូវមានការងារធ្វើទេ ពេលណាគ្មានការងារធ្វើ គេឱ្យប្រាក់ខែ៥០ភាគរយ ប៉ុន្តែដល់ខែកញ្ញា ២០០៥ មានការងារធ្វើធម្មតាតែមិនមានការថែមម៉ោងទេ ឯថ្ងៃអាទិត្យក៏មិនធ្វើការដែរ។ ពេលខ្លះមានការបង្ខំយ៉ាងខ្លាំងចំពោះផ្នែកដេរ បើដេរឱ្យគេមិនទាន់ ថៅកែហៅកម្មករតាមក្រុមចូលក្នុងការិយាល័យដើម្បីស្តីឱ្យ ហើយសួរហេតុអ្វីក៏ដេរយឺត ? មិនតែប៉ុណ្ណោះគេដើរត្រួតពិនិត្យតាមក្រុមមិនឱ្យកម្មករណាដើរចេញពីម៉ាស៊ីនទេ គឺត្រូវប្រឹងរហូតមិនថាផ្នែកបង្កើយការ ផ្នែកដេរ ឬផ្នែកតុកាត់ឡើយ បើធ្វើការមិនទាន់ទេត្រូវធ្វើការថែមម៉ោង បើមិនថែមម៉ោងនឹងត្រូវគេបញ្ឈប់ពីការងារ ។ មិនតែប៉ុណ្ណោះគេបានបញ្ឈប់កម្មករពីការងារខ្លះឱ្យនៅសល់តិចជាងមុន តែត្រូវធ្វើការឱ្យលឿនតាមធម្មតាដូចមានកម្មករច្រើនអញ្ចឹងដែរ ។ កម្មករទាំងអស់តវ៉ាថា "យើងជាកម្មករមិនមែនជាគោក្របីនោះទេ យើងក៏ចេះនឿយហត់ដែរ បើចង់បានលឿនជាងនេះមកធ្វើខ្លួនឯងទៅ " ។ ម្យ៉ាងវិញទៀតគ្រប់ផ្នែកទាំងអស់ បើកម្មករណាធ្វើការយឺត ឬទៅបង្គន់ញឹកញាប់ ច្បាស់ជាត្រូវគេស្តីឱ្យមិនខាន ។

ប្រាក់ខែរបស់ខ្ញុំចាយមិនគ្រាន់ឡើយ ប្រសិនបើគ្មានការថែមម៉ោងធ្វើការនោះទេ ព្រោះខ្ញុំត្រូវចំណាយយ៉ាងច្រើនទៅលើបន្ទប់ស្នាក់នៅ ២០ដុល្លា ( បន្ទប់ ១ នៅគ្នា ៣នាក់) ថ្លៃភ្លើង ១០គីឡូ ហើយ១គីឡូ ១០០០៛ ថ្លៃម្ហូប ១០ដុល្លាប្រចាំខែ ។

ចំពោះម្ចាស់ផ្ទះជួលវិញ ដូចជាមិនសូវរើសអើងដូចមុនទេ ពេលយើងមានជំងឺគាត់ក៏តែងជួយហៅពេទ្យ ហើយជួយណែនាំពេទ្យណាដែលយកថ្លៃព្យាបាលថោកហើយមានប្រសិទ្ធិភាព មិនដូចម្ចាស់ផ្ទះដែលខ្ញុំជួលពីមុននោះទេ កូនចៅរបស់គាត់មើលងាយកម្មករដោយនិយាយថាកម្មករកាត់ដេរជាស្រីមិនល្អ គេមិនដែលគិតថាកម្មករដែលចាកចោលភូមិស្រុកដូចរូបខ្ញុំនិងមិត្តភក្តិដ៏ទៃទៀតមកធ្វើការរោងចក្រកាត់ដេរនេះដើម្បីជួយដល់គ្រួសារនោះឡើយ ហើយនៅពេលដែលពួកខ្ញុំចេញទៅខាងក្រៅម្តងៗគេតែងនិយាយថា ពួកខ្ញុំនេះចេញទៅរកប្រុសនៅខាងក្រៅហើយ ។

ខ្ញុំផ្ញើរលុយទៅផ្ទះ១០ដុល្លាជារៀងរាល់ខែឱ្យទៅពុកម៉ែ គាត់អាចចាត់ចែងយកទៅចំណាយលើការព្យាបាលគោក្របីឈឺជាដើម ។ គ្រួសារដែលនៅឯស្រុកក៏មានការខ្វះខាតណាស់ដែរ ព្រោះខែទឹកលិចមិនអាចធ្វើចំការបានទេ ដូច្នេះម្តាយខ្ញុំគាត់ទៅលក់ពោតកំបោរដើម្បីរកកំរៃខ្លះជួយដល់គ្រួសារ ។ រាល់ថ្ងៃខ្ញុំមានការបារម្ភខ្លាំងណាស់ចំពោះទឹកជំនន់ព្រោះខ្លាចគ្រួសារជួបការលំបាកនិងបង់ខាតយ៉ាងខ្លាំង ។

នៅថ្ងៃក្រោយបើរោងចក្របិទ ខ្ញុំមានតែវិលត្រឡប់ទៅផ្ទះវិញប៉ុណ្ណោះ ទោះជាខ្ញុំមានបំណងធ្វើជាអ្នកសំអាងការក៏ដោយតែវាគ្រាន់ជាក្តីស្រមៃតែប៉ុណ្ណោះ ព្រោះខ្ញុំខ្វះលទ្ធភាពក្នុងការធ្វើឱ្យវាបានសំរេចណាស់ ។ ខ្ញុំគិតរួចជាស្រេចថាទោះជាមានរោងចក្ររើសកម្មករនៅជាយដែនយ៉ាងណាក៏ដោយ ក៏ខ្ញុំនឹងមិនទៅទីនោះដែរ ព្រោះបទពិសោធន៍ដែលខ្ញុំមានដ៏លំបាកនេះវាគ្រប់គ្រាន់ណាស់ទៅហើយ ខ្ញុំគិតថាទៅធ្វើស្រែចំការវិញវាល្អជាង ។

ករណីសិក្សាទី ៤៥

ថ្ងៃទី ២០ កញ្ញា ២០០៥

នាងខ្ញុំឈ្មោះ ស ស ភ អាយុ២៦ឆ្នាំ បងប្អូន៦នាក់ ស្រី២ ប្រុស៤ ធ្វើការរោងចក្រ៣នាក់ នៅរៀន៣នាក់ ។ សព្វថ្ងៃរស់នៅ ភូមិតាំងក្រាំង ឃុំជីបាល ស្រីសន្ធរ ខេត្តកំពង់ចាម ។

គ្រួសារខ្ញុំមានដីស្រែជិត១ហិចតា ហើយមិនធ្លាប់លក់ទេ ឯទ្រព្យសម្បត្តិគ្មានអ្វីធំដុំក្រៅពីមាន់ឡើយ ពួកខ្ញុំប្រើ មធ្យោបាយធ្វើដំណើរដោយកង់ ហើយមានទឹកអណ្តូងខ្លួនឯង ពេលណាទឹកអណ្តូងលែងចេញ ទិញទឹកគេ ឬ ទៅដងទឹកនៅស្រះវត្ត ។ នៅក្នុងភូមិគ្មានភ្លើងអគ្គិសនីទេ គឺប្រើភ្លើងអាគុយ ចំណែកម្ហូបអាហារវិញទិញនៅពេលគេមកលក់តាមផ្ទះ ។

ខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ ហើយក៏មិនធ្លាប់បានទទួលវគ្គបណ្តុះបណ្តាលជំនាញអ្វីដែរ ។ ខ្ញុំបានរៀបការក្រោយពេលដែលចូលធ្វើការរោងចក្រ ហើយឥលូវនេះខ្ញុំមានកូនស្រីម្នាក់រួចទៅហើយអាយុ ៦ឆ្នាំហើយ ។ កាលនោះខ្ញុំបានសំរេចចិត្តមកធ្វើការនៅរោងចក្រដោយខ្លួនឯង ព្រោះតែស្ថានភាពគ្រួសារក្រពេក ហើយពុកម៉ែគាត់មិនបានជំទាស់នោះទេ ។ ពេលមករកការងារធ្វើដំបូង ខ្ញុំបានរង់ចាំ១អាទិត្យតែដោយសារមិនទាន់បានការងារធ្វើក៏ត្រឡប់ទៅផ្ទះវិញសិន មិនយូរប៉ុន្មានក៏ត្រឡប់មកម្តងទៀតហើយបានធ្វើការតែម្តងនៅរោងចក្រ **Mighty** នៅបាក់ខែង ផ្នែកតម្បាញ ។ ការនោះមិនបានសូកអ្នកណាឱ្យនាំចូលធ្វើការនោះទេ តែខ្ញុំមានបងប្អូនធ្វើការនៅផ្នែកសន្តិសុខជាអ្នកជួយ ។ ពេលបានការងារធ្វើមានអារម្មណ៍ភ័យខ្លាចបាត់បង់ទៅវិញ ព្រោះការងារនោះវាឿយហត់ជាខ្លាំង ខ្លាំងទ្រាំទ្រអត់បានត្រូវគេបណ្តេញចេញពីការងារ មិនតែប៉ុណ្ណោះខ្លាចមានគ្រោះថ្នាក់នៅតាមផ្លូវពេលធ្វើដំណើរត្រឡប់មកបន្ទប់ស្នាក់នៅវិញ ។

ខ្ញុំធ្វើការនៅ **Mighty** បាន៨ឆ្នាំហើយតាំងពីចាប់ផ្តើមធ្វើការមិនដែលប្តូររោងចក្រឡើយ ។ នៅទីនេះខ្ញុំបានប្រាក់ខែល្អគួរសមព្រោះគិតតាមចំនួនឡូដែលខ្ញុំផលិតប្រចាំថ្ងៃ ហើយក្នុងមួយខែបើខ្ញុំត្បាញបានច្រើនបំផុតនោះគឺអាចបានប្រាក់ឈ្នួលប្រហែលជា ១០០ដុល្លាដែរ បូកជាមួយប្រាក់ធ្វើការថែមម៉ោង ។ ពេលណាធ្វើការថែមម៉ោងកម្មករទាំងអស់អាចនិងទទួលបានលុយបាយទៀតផង ។ ក្រៅពីនោះខ្ញុំបានលុយផ្សេងៗទៀតដូចជា លុយព្រឹម បំណាច់ឆ្នាំ អតីតភាព ធ្វើការថ្ងៃបុណ្យ និងថ្ងៃអាទិត្យ(គុណនិង២) ។ ខ្ញុំមិនចូលចិត្តការងារថែមម៉ោងទេ ពីព្រោះធ្វើឱ្យខ្ញុំហត់នឿយ កំលាំងក៏ចុះខ្សោយ ព្រោះមិនសូវបានសំរាក ហើយមិនសូវបានចូលរួមក្នុងសកម្មភាពសង្គមផង ។

រោងចក្រ Mighty ផលិតម៉ាក Gap, Old Navy, Banana Republic បើកម្មករត្បាញលឿនបានច្រើននោះប្រាក់ខែក៏បានច្រើន បើកម្មករណាយឺតត្បាញបានតិច ប្រាក់ខែក៏បានតិចទៅតាមហ្នឹងដែរ ប៉ុន្តែអ្នកលឿនបំផុត បានប្រាក់ខែត្រឹមតែ១០០ដុល្លានេះឯង ឯអ្នកយឺត៧០-៨០ដុល្លា ។ ធ្វើការ៨ម៉ោងក្នុងមួយថ្ងៃ និងមានពេលសំរាកបន្តិចបន្តួច

ធ្វើការថែម២ម៉ោងក្នុងមួយថ្ងៃ បើមានអាវប្រញាប់ថែម៤ម៉ោងទៀត ប៉ុន្តែយូរៗម្តង ។ កន្លែងធ្វើការតូចចង្អៀត ក្តៅហើយមានបន្ទប់ទឹក៣៥ សំរាប់ប្រុស១០ ស្រី២៥ តែមិនគ្រាន់ទេ នៅពេលខ្លះស្ទះព្រោះកម្មករច្រើនពេក ។ រោងចក្រនេះធ្វើការតែ១វេនទេ ដោយសារមានអាវប្រញាប់ទើបគេសុំឱ្យកម្មករធ្វើការ២វេន ចំពោះកម្មករវេនយប់ប្រាក់ខែគុណនិង២ តែខ្ញុំវិញធ្វើការតែវេនថ្ងៃមិនដែលដូរឡើយ ព្រោះការដូរវេននេះអាស្រ័យលើការស្ម័គ្រចិត្តរបស់កម្មករ ហើយនៅក្នុងក្រុមរបស់ខ្ញុំមានគ្នា៤០-៤៥នាក់ ។

ថ្ងៃអាទិត្យគឺឈប់សំរាកមិនធ្វើការនោះទេ ហើយចំពោះការឈប់ឈឺ បើមានសំបុត្រពេទ្យ រោងចក្រឱ្យឈប់រហូតដល់ជាសះស្បើយចាំចូលធ្វើការវិញ ។ ក្នុងករណីឈឺធ្ងន់គេឱ្យច្បាប់៣ខែ ខែទី១គេឱ្យទៅគ្រួសារ១០០ដុល្លា ទីពីរ៧០ដុល្លា ទីបី៥០ដុល្លា បើឈប់លើសពី៣ខែខាងរោងចក្រគេឱ្យព្យួរការងារសិន តែបើឈឺធម្មតាគេឱ្យច្បាប់២-៣ថ្ងៃ ។ ចំពោះអ្នកពោះធំវិញ គេឱ្យច្បាប់សំរាលកូន៣ខែ ប្រាក់ខែ៥០% ឯកម្មករដែលរៀបអាពាហ៍ពិពាហ៍ គឺបានច្បាប់៧ថ្ងៃ ប្រសិនបើមានសមាជិកគ្រួសារណាស្លាប់ គេឱ្យច្បាប់៣ថ្ងៃ ហើយកាលពីមុនគេមិនកាត់លុយបំណាច់ឆ្នាំទេតែឥឡូវនេះគេកាត់ ។

នៅក្នុងរោងចក្រមានគ្លីនិកតូចមួយ ពេលកម្មករឈឺបន្តិចបន្តួចអាចចុះទៅពិនិត្យនៅទីនោះ ហើយពេទ្យទាំងនោះអាចឱ្យថ្នាំលេបបានខ្លះ ។ ខ្ញុំក៏ធ្លាប់វិលមុខ ឈឺក្បាល និងនឿយហត់ដែរ តែមិនដែលឈឺធ្ងន់ទេ គ្រាន់តែទៅសុំថ្នាំនៅពេទ្យក្នុងរោងចក្រទៅក៏រួចទៅហើយ តែខ្ញុំក៏មិនសូវចូលចិត្តទៅពិនិត្យពេទ្យក្នុងរោងចក្រញឹកញាប់ទេ ព្រោះសេវាកម្មមិនសូវល្អ ហើយកម្មករក៏ច្រើន ណាមួយមិនសូវមានថ្នាំប៉ុន្មានទេ ទៅពេទ្យឯកជនវិញល្អជាង ព្រោះគេយកលុយទើបមានសេវាកម្មល្អ ។

ការពិតខ្ញុំមិនចូលចិត្តការងារប្រើដោយកំលាំងបែបនេះទេ ព្រោះនឿយហត់ខ្លាំងណាស់ ប៉ុន្តែខ្ញុំគ្មានជំរើសដោយខ្ញុំគ្មានការអប់រំដូច្នេះហើយទើបទ្រាំធ្វើការទាំងលំបាកនេះទៅ ។ នៅពេលណាខ្ញុំមានបញ្ហាទាំងការងារនិងគ្រួសារខ្ញុំតែងពិភាក្សាជាមួយមិត្តភក្តិ ពេលខ្លះគេអាចជួយបាន ពេលខ្លះគេជួយមិនបានទេ តែវាក៏ធ្វើឱ្យខ្ញុំធូរចិត្តបន្តិចដែរ ។ ពេលមានបញ្ហាការងារនៅក្នុងរោងចក្រ ខ្ញុំតែងតែទៅរកតំណាងឱ្យជួយ ហើយក៏ធ្លាប់ចូលរួមធ្វើបាតុកម្មដែរ គឺដើម្បីទាមទារប្រាក់ឡូ ហើយលទ្ធផលបានសំរេចចិត្ត ។

រោងចក្រនេះមានសហជីពបីៈ C-CAWDU/ NIFTUE និងមួយទៀតមិនស្គាល់ឈ្មោះឡើយ ហើយអ្នកគ្រប់គ្រងសហជីពមូលដ្ឋាននៅក្នុងរោងចក្រដែលខ្ញុំបានចូលជាសមាជិកឈ្មោះ ស្រ៊ុន ទូច តែសហជីពមិនដែលបានហៅកម្មករទៅចូលរួមសកម្មភាពផ្សេងៗទេ គេដឹងតែមួយខែគេត្រូវដើរប្រមូលលុយពីកម្មករ១០០០៛ ដោយខ្ញុំមិនដឹងថាគេយកលុយទាំងនោះទៅធ្វើអ្វីទេ ។ ខ្ញុំយល់ថានៅពេលធ្វើបាតុកម្ម គឺវាផ្តល់ផលប្រយោជន៍ដល់កម្មករច្រើន ម្យ៉ាងធ្វើឱ្យកម្មករមានការជឿជាក់ទាំងស្រុងលើសហជីព រហូតដល់ពេលខ្លះកម្មករលែងជួយ ឬគិតគូរដោយខ្លួនឯងហើយ ទោះជាមាន

បញ្ហាតែបន្តិចក៏គេពឹងសហជីពឱ្យជួយរហូត ។ ខ្ញុំក៏បានចូលជាសមាជិកសហជីព៣ឆ្នាំមកហើយ ព្រោះខ្ញុំគិតថាពេលមានបញ្ហា ឬការទាមទារអ្វីមួយនោះ គឺពួកគេអាចជួយនិងដោះស្រាយឱ្យបាន ។

ក្នុង១ខែ ខ្ញុំចំណាយអស់៣០-៤០ដុល្លា ។ បន្ទប់ជួលមួយ១២ដុល្លាក្នុង១ខែ នៅគ្នា៣នាក់ ថ្លៃទឹក៨០០០៛ ភ្លើង១៥០០០៛ ចំណាយលើការថែរក្សាសុខភាពបន្តិចបន្តួច៥ដុល្លាប៉ុណ្ណោះក្នុង១ខែ ។ ពួកយើងទាំងបីមានសោរបន្ទប់រៀងខ្លួន នៅពេលទំនេរយើងអាចទៅដើរលេងនៅខាងក្រៅបាន ប្រសិនបើមានមិត្តភក្តិមកលេងនៅបន្ទប់នោះម្ចាស់ផ្ទះមិនថាអីស្តី ឱ្យនោះទេ តែកុំឱ្យរំខានដល់អ្នកដល់ដទៃ ។ ផ្ទះជួលនៅជិតរោងចក្រមានសុវត្ថិភាពងាយស្រួលដើរទៅធ្វើការដោយចំណាយតែ៥នាទី ហើយពេលចេញពីធ្វើការថែមម៉ោងពេលយប់មិនដែលមានបញ្ហាទេ គ្រាន់តែមានអារម្មណ៍ភ័យខ្លាចប៉ុណ្ណោះ ។ ពេលព្រឹកខ្ញុំទៅធ្វើការនៅរោងចក្រជាទៀងទាត់ និងពេលថ្ងៃខ្ញុំញ៉ាំបាយផ្សារ ហើយពេលល្ងាចទិញម្ហូប១៥០០ ទៅ ២០០០៛ មកចំអិនញ៉ាំនៅបន្ទប់ជួលដោយខ្លួនឯង ។ ជារៀងរាល់ខែខ្ញុំត្រូវចំណាយទៅលើកូនស្រីខ្ញុំអស់ប្រហែល ១០-១៥ដុល្លា ក្នុង១ខែ ។ ខ្ញុំជាអ្នកសំរេចចិត្តរឿងចាយវាយ នឹងទុកដាក់លុយកាក់នៅក្នុងគ្រួសារ តែមិនដែលសន្សំលុយបានទេ ព្រោះត្រូវចំណាយច្រើន ។ ជាធម្មតាខ្ញុំផ្ញើរលុយទៅផ្ទះ៣០-៤០ដុល្លា ក្នុងមួយខែ។

បន្ទាប់ពីចូលធ្វើការនៅរោងចក្រមក ខ្ញុំមានអារម្មណ៏សប្បាយចិត្តដែរ ព្រោះអាចជួយសំរាលបន្ទុកគ្រួសារបានច្រើន ដូចជាផ្តល់លុយឱ្យម៉ែទិញអង្ករ ជួលគេភ្ជួររាស់ ស្ទូង ច្រូត ទិញម្ហូបអាហារ ប្អូន១រៀន ព្រមទាំងចំណាយផ្សេង១មួយចំនួនទៀត ។ ប៉ុន្តែទន្ទឹមនឹងនោះ ខ្ញុំក៏ពិបាកចិត្តដែរព្រោះការងារមិនស្ថេរភាពឡើយ ហើយបើបើកប្រាក់ខែបានច្រើនខ្ញុំសប្បាយចិត្តណាស់ ព្រោះពីមុនមិនដែលមានការងារធ្វើបានលុយដូច្នេះទេ ម្យ៉ាងទៀតខ្ញុំក៏មានសេរីភាពជាងមុនព្រោះនៅឆ្ងាយពីឪពុកម្តាយ ។

នៅក្នុងរោងចក្រឧស្សាហ៍មានភ្ញៀវចុះមកមើលក្នុងម៉ោងធ្វើការញឹកញាប់ណាស់ ពេលនោះខាងរោងចក្រតែងឱ្យកម្មករគ្រប់ផ្នែកធ្វើការ សំអាត ពាក់ កាត និងពេលខ្លះពាក់ម៉ាសផងដែរ ។

មកដល់ថ្ងៃទី២២ កុម្ភៈ ២០០៥ ស្រាប់តែរោងចក្រផ្អាក់ធ្វើការចំនួន២ខែ ដល់ថ្ងៃទី២២ មេសា ២០០៥ ទើបចូលធ្វើការវិញហើយរោងចក្រក៏បើកលុយឱ្យកម្មករដោយប្រាប់ថារោងចក្រត្រូវបិទទ្វារ ហើយជាហេតុធ្វើឱ្យកម្មករមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ពួកយើងបានទៅរកសហជីព តែគាត់បែរជាឆ្លើយយករួចខ្លួនសិនទៅ ហើយមិនបានអើពើនឹងកម្មករឡើយ ព្រមទាំងប្រាប់កម្មករឱ្យទទួលយកលុយនោះថែមទៀតផង ។ កម្មករឆ្ងល់គ្រប់គ្នា១ហេតុអ្វីបានជាសហជីពយល់ព្រមឱ្យកម្មករទទួលយកលុយនោះដោយមិនប្រាប់កម្មករជាមុន ។ នៅពេល នោះដែរមានលេចលឺពាក្យចចាមអារ៉ាមថាសហជីពបានទទួលសំណូកពីរោងចក្រ ហេតុដូច្នេះហើយបានជាពួកគេមិនគិតអំពីប្រយោជន៏របស់កម្មកររាប់ពាន់នាក់សោះ

ខ្ញុំបានដឹងបានច្រើនពីច្បាប់ការងារនៅក្នុងស្រុកខ្មែរ ព័ត៌មានទាក់ទងនិងវិស័យកាត់ដេរនៅកម្ពុជា និងច្បាប់ថ្មី១ដ៏ទៃទៀត ហើយព័ត៌ទាំងនេះខ្ញុំបានមកពីការចូលរួមកម្មវិធីផ្សេង១នៅក្នុងសង្គម ។

## ករណីសិក្សាទី ៤៦
## ថ្ងៃទី ២៣ តុលា ២០០៥

នាងខ្ញុំឈ្មោះ ស អ អាយុ២១ឆ្នាំ មានបងប្អូន១១នាក់ ប្រុស៤ ស្រី៧ បង៧របស់ខ្ញុំបានរៀបការរួច២នាក់ ហើយខ្ញុំជាកូនទី៨ ឯប្អូន១ទាំងអស់នៅរៀន ។ គ្រួសារខ្ញុំរស់នៅភូមិកំណប់ ឃុំទំនប់ធំ ស្រុកពញាលឺ ខេត្តកណ្ដាល ។

គ្រួសាររបស់ខ្ញុំធ្វើស្រែចំការ តែក្នុងមួយឆ្នាំមួយៗធ្វើស្រែមិនសូវបានគ្រប់គ្រាន់ទេ ។ ពីមុនមានដី៤ហិចតា តែក្រោយមកចែកដី អោយបងដែលរៀបការរួចអស់១ហិចតា ក្រោយមកប្រហែលជានៅឆ្នាំ១៩៩៤-១៩៩៥ ម៉ែបានលក់ដីមួយកន្លែង (ដីទួលធ្វើចំការ) ឱ្យទៅអង្គការមួយ (មិនស្គាល់ឈ្មោះ) តែមិនដឹងថាលក់បានតំលៃប៉ុន្មានទេ ព្រោះនៅពេលនោះខ្ញុំនៅក្មេងពេក តែបានលឺថាពួកគាត់បានជ្រុលលក់ដីនោះព្រោះចាញ់បោកគេឃោសនា ដោយពេលនោះគេប្រាប់ថា បើយើងមិនលក់ គឺគ្មានផ្លូវចូលទៅដីនោហទេ ព្រោះថាដីនៅជុំវិញត្រូវបានគេលក់អស់ហើយ ។

ការធ្វើស្រែគឺពឹងផ្អែកទៅលើតែទឹកភ្លៀងមួយមុខប៉ុណ្ណោះ ហើយក្រៅពីធ្វើស្រែមិនបាននោះ បងប្អូនក៏ឈឺច្រើនទៀត ឯប្អូន៧របស់ខ្ញុំវិញពួកវាត្រូវទៅរៀន ហើយការរៀនសូត្រគឺត្រូវការលុយជាចាំបាច់ ដូច្នេះហើយបានជាខ្ញុំសំរេចចិត្តមកធ្វើការរោងចក្រក្រែងអាចជួយដោះស្រាយជីវភាពគ្រួសារបានខ្លះ ។

ខ្ញុំមកធ្វើការរោងចក្រជាមួយបងស្រី ប៉ុន្តែពេលមកដល់ភ្នំពេញដំបូងមិនទាន់បានការងារធ្វើភ្លាមៗទេ ស្នាក់នៅនិងហូបចុកជាមួយបងស្រី (ម្ចាស់ផ្ទះមិនទាន់យកលុយថ្លៃផ្ទះនោះទេ) ប្រហែលជា៤ខែក្រោយទើបអ្នកបកប្រែដែលស្គាល់ជាមួយបងស្រីបានសុំឱ្យខ្ញុំបានចូលធ្វើការនៅរោងចក្រ **៦ជាន់** ។ ពេលចូលទៅខ្ញុំខំប្រឹងប្រែងធ្វើការជាខ្លាំង មានខែមួយនោះខ្ញុំបានបើកលុយបានដល់ ១០០ដុល្លា ហើយលុយនោះខ្ញុំត្រូវផ្ញើរទៅផ្ទះទាំងអស់ ឯការចាយវាយលើបងស្រីជាអ្នករ៉ាប់រ៉ង ។ ប៉ុន្តែធ្វើការនៅទីនេះបានតែ២ឆ្នាំ រោងចក្រក៏រំសាយបិទ ហើយបើកលុយឱ្យតែ១០០ដុល្លា មិនត្រឹមត្រូវតាមច្បាប់ឡើយ មុនពេលរោងចក្របិទ គេឱ្យយើងសំរាក២ខែ អោយប្រាក់ត្រឹមតែ៥០ភាគរយប៉ុណ្ណោះ ។ នៅថ្ងៃបើកលុយនោះដែរ គេបានយកប៉ូលីស និង PM មកដាក់នៅជាន់ទី១ ជាន់ទី២ និងនៅពាសពេញមុខរោងចក្រ ចំណែកកម្មករមិនបានដឹងថារោងចក្របិទទេ គ្រាន់តែដឹងថាគេបានដឹកតវ៉ាន់ចេញពីរោងចក្រទៅអស់ហើយ នៅសល់តែម៉ាស៊ីនប៉ុណ្ណោះ ព្រមទាំងគំរាមកម្មករថាបើហ៊ានតវ៉ា ខាងរោងចក្រនឹងមិនបើកលុយឱ្យទេ ។ ពេលនោះកម្មករភាគច្រើនទើបតែមកពីផ្ទះមិនបានដឹងរឿងអ្វីសោះ ឃើញតែមានប៉ូលីសច្រើនបែបនោះ មានការភ័យខ្លាចជាខ្លាំងគ្មាននរណាម្នាក់ហ៊ានតវ៉ាទេ ម្យ៉ាងទៀតគេមិនអនុញ្ញាតឱ្យយើងឈរជុំគ្នានៅមុខរោងចក្រទៀតផង ដូច្នេះគេបើកលុយឱ្យប៉ុណ្ណាក៏ត្រូវតែទទួលដោយគ្មានការតវ៉ាឡើយ ។

បន្ទាប់មកខ្ញុំបានទៅរៀនដេរបន្ថែម បានកន្លះខែក្រោយមកក៏ធ្វើតេស្តជាប់បានធ្វើការនៅរោងចក្រ **ភើហ្វិចតា** ដោយគ្មានបង់លុយអោយអ្នកណានោះទេ។

រោងចក្រនេះគេកំនត់ថាបើយើងមិនធ្វើការថែមម៉ោងទេគេមិនទទួលយើងឱ្យធ្វើការឡើយ ធ្វើការបាន២ខែប្តូរកិច្ចសន្យាម្តង ហើយបន្ទាប់មក៣ខែទើបប្តូរកិច្ចសន្យាម្តងទៀត ។ ធ្វើការនៅរោងចក្រភើហ្វិចតានេះពិបាកសុំច្បាប់ណាស់ ពេលទៅបន្ទប់ទឹកយូរ ឬញ៉ាំកញ្ចប់ពេកនឹងត្រូវគេស្តីឱ្យ ការដេរត្រូវគេបង្ខំ និងមានកំណត់ បើដេរមិនបានគ្រប់កំណត់ទេត្រូវធ្វើការថែមម៉ោង ហើយបើថែមម៉ោងនៅតែមិនគ្រប់ទៀត គេនឹងហៅទៅប្រជុំដើម្បីស្តីឱ្យម្តង ។ ធ្វើការថែមដល់ម៉ោង៦ល្ងាច បានលុយបាយ១០០០៛ បើបន្តដល់ម៉ោង៩យប់បានលុយ ៥០០៛ទៀត និងមានឡានជូនមកផ្ទះ ។

រោងចក្រ **ភើហ្វិចតា** គ្មានសហជីពទេ មានតែតំណាងកម្មករ ពេលកម្មករមានបញ្ហាខាងតំណាងអាចជួយដោះស្រាយបានប៉ុន្តែលុះត្រាតែកម្មករស្រុះស្រួលគ្នាដែរ បើមិនស្រុះស្រួលគ្នាទេថៅកែអាចចោទមកតំណាងថាជាអ្នកបំផុសបំផុលមិនខាន

បើសិនរោងចក្របិទ ខ្ញុំមានបំណងចង់ទៅរៀនកាត់ម៉ូដសំលៀកបំពាក់ ដើម្បីបើកហាងកាត់ដេរនៅឯស្រុកកំណើតព្រមទាំងចិញ្ចឹមជ្រូក មាន់ទា និងធ្វើស្រែចំការនៅផ្ទះ និងលក់ដូរបន្តិចបន្តួចដើម្បីចិញ្ចឹមជីវិតទៅថ្ងៃអនាគត ។

ករណីសិក្សាទី ៤៧

ថ្ងៃទី ១៨ ធ្នូ ២០០៥

នាងខ្ញុំឈ្មោះ អ ថ រី អាយុ២៤ឆ្នាំ បច្ចុប្បន្នធ្វើការនៅរោងចក្រ **តេវ៉ាតិច** ស្រុកកំណើតនៅភូមិឧត្ដម ស្រុកពាមជ ខេត្តព្រៃវែង មានបងប្អូន៤នាក់ ប្រុស២ ស្រី២ ហើយខ្ញុំជាកូនទី៤ ។ ពុកម៉ែខ្ញុំជាកសិករ តែមិនដឹងថាមានដីស្រែប៉ុន្មានទេ គ្រាន់តែដឹងថាមានស្រែតិចតួចណាស់ ឯផលស្រូវដែលធ្វើបាននោះមិនគ្រប់គ្រាន់ទេ ត្រូវទិញគេ ឬខ្ចីបុលគេបន្ថែមទៀត ស្ទើរតែជារៀងរាល់ឆ្នាំ ។ នៅផ្ទះខ្ញុំជួយធ្វើស្រែពុកម៉ែ ។

ខ្ញុំមកធ្វើការរោងចក្រដោយសារមានបងប្អូននៅភូមិជាមួយគ្នា ដែលបានមកធ្វើការមុននោះ គេបានប្រាប់ថានៅភ្នំពេញមានរោងចក្របើកច្រើន ហើយក៏ត្រូវការរើសកម្មករ ។ នៅពេលនោះម្ដាយរបស់ខ្ញុំជាស្ត្រីមេម៉ាយ ឯការធ្វើស្រែក៏មិនសូវបានផល ហើយម៉ែក៏ជំពាក់បំណុលគេច្រើនទៀត ខ្ញុំក៏សំរេចចិត្តចេញពីស្រុក ពេលចេញមកនោះត្រូវចងការប្រាក់គេដើម្បីធ្វើដំណើរមកភ្នំពេញរកការងារធ្វើ ។

មកដល់ភ្នំពេញដំបូងខ្ញុំត្រូវរង់ចាំមួយអាទិត្យទើបបានចូលធ្វើការនៅរោងចក្រ **តេវ៉ាតិច** នេះតែម្ដង នៅផ្នែកដេរភ្ជាប់ ឆ្នាំ២០០០ ។ នៅផ្នែកនេះមានតែមួយវេនទេ គឺចាប់ផ្ដើមពីម៉ោង៦កន្លះព្រឹកដល់ម៉ោង៣កន្លះ ក្នុងចន្លោះម៉ោងនោះកម្មករត្រូវបានអនុញ្ញាតអោយសំរាកញុំាបាយមួយម៉ោង បើសិនជាប្រញាប់នាំខោចេញនោះ ចិនឱ្យថែមម៉ោងរហូតដល់ម៉ោង៨យប់ទើបឱ្យចេញមកផ្ទះវិញ ។ ដំបូងខ្ញុំជាកម្មករបណ្ដែតទទួលបានប្រាក់ខែ៤០ដុល្លា និងលុយព្រឹម៥ដុល្លា ៣ខែក្រោយមកក៏ក្លាយជាកម្មករពេញសិទ្ធិ ប្រាក់ខែ៤៥ដុល្លា និងលុយព្រឹម៥ដុល្លា បើបូកទាំងថែមម៉ោងប្រហែលជា ៦០ដុល្លាក្នុងមួយខែ ។ ឥឡូវខ្ញុំបានប្រាក់ខែ៦៥ដុល្លាទាំងលុយលើកទឹកចិត្តផ្សេងមួយទៀត ៥០០០រៀលផង ។

កម្មករសន្លប់ស្ទើររាល់ថ្ងៃ គេយកកម្មករដែលសន្លប់ទៅគ្លីនិកក្នុងរោងចក្រ ពេលកម្មករនោះដឹងខ្លួនហើយត្រូវត្រឡប់មកធ្វើការវិញ បើសន្លប់រយៈពេលយូរគេនឹងយកទៅពេទ្យឯកជន ហើយគេអនុញ្ញាតឱ្យទៅសំរាកនៅផ្ទះ កម្មករដែលសន្លប់មិនត្រូវបានខាងរោងចក្រកាត់ប្រាក់ខែទេ ។ ទោះជាខ្ញុំធ្វើការបាន២ឆ្នាំមកហើយតែគ្មានសល់លុយទេ ព្រោះពេលបើកលុយត្រូវផ្ញើរទៅឱ្យម៉ែ ៥ ទៅ ១០ ដុល្លារាល់ខែ ដើម្បីផ្គត់ផ្គង់គ្រួសារ និងមួយចំណែកទៀតត្រូវចំណាយទៅលើទឹកភ្លើង ថ្លៃផ្ទះ និងទុកចាយ១៥ដុល្លា ។ ខ្ញុំនៅផ្ទះជួលតូចចង្អៀតមួយ បន្ទប់ទឹកមិនគ្រប់គ្រាន់សំរាប់កម្មករប្រើប្រាស់នោះទេ ហើយបើសិនជាមានបងប្អូនមកលេង ម្ចាស់ផ្ទះមិនថាអ្វីទេបើបានទៅប្រាប់គាត់មុន តែបើសិនមិនបានទៅប្រាប់គាត់ទេ គាត់នឹងគិតលុយក្នុង១ថ្ងៃ ២០០០៛ ។

ទោះបីជាល័ក្ខខ័ណ្ឌការងារនៅរោងចក្រនេះពិបាកយ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែសំរេចចិត្តធ្វើការនៅទីនេះបន្តទៀតដែរ ពីព្រោះខ្ញុំមិនទាន់មានអត្តសញ្ញាណប័ណ្ណ ដូច្នេះពិបាកទៅរកការងារធ្វើនៅរោងចក្រផ្សេងទៀតណាស់ ។

កម្មករពេញសិទ្ធិគ្រប់ផ្នែកដែលធ្វើការនៅរោងចក្រ **តេវ៉ាតិច** បើចង់ឈប់ត្រូវសុំច្បាប់២ថ្ងៃមុន បើសុំច្បាប់១អាទិត្យនឹងដាច់លុយព្រីម៥០០០៛ ហើយពិបាកណាស់សុំច្បាប់ណាស់ ពេលខ្លះគេមិនអនុញ្ញាតឱ្យហើយថែមទាំងស្តីឱ្យទៀត ហើយពេលកម្មករណាម្នាក់ឈឺ ក៏ពិបាកសុំច្បាប់ណាស់ដែរ ដោយត្រូវរកតំណាងកម្មករមកសុំច្បាប់ឱ្យ ពេលសុំច្បាប់ម្តងៗ កម្មករទាំងអស់ត្រូវទៅសុំការអនុញ្ញាតពីប្រធានខ្មែរ ប្រធានចិន និងមេកន្ត្រៃទៀត វាច្រើនលំដាប់ថ្នាក់ពេក ។

នៅរោងចក្រនេះមានថៅកែជាជនជាតិចិន មានកម្មករភាគច្រើនជាស្ត្រី តែខ្ញុំអត់បានដឹងថាមានកម្មករប៉ុន្មាននាក់នោះទេ សូម្បីតែផលិតអាវតម្បាញម៉ាកអ្វីក៏មិនបានដឹងដែរ គ្រាន់តែដឹងថាមួយក្រុមមាន៦០នាក់ ។ រោងចក្រនេះមានសហជីព ចំនួន៣ គឺៈ សេរីពលករ និង២ទៀតខ្ញុំមិនបានស្គាល់ឈ្មោះនោះទេ ។

ឥឡូវនេះ ខ្ញុំមិនបានចូលជាសមាជិកសហជីពណាទេ កាលពីមុនខ្ញុំបានចូលជាសមាជិកសហជីពសេរីពលករ តែដោយសារនៅពេលដែលមានរឿងរ៉ាវជាមួយចិន ខ្ញុំបានទៅរកសហជីពឱ្យជួយដោះស្រាយ តែគេមិនបានជួយ ខ្ញុំទេ ថែមទាំងស្តីឱ្យខ្ញុំថា កុំប៉ិនមានរឿងរ៉ាវជាមួយចិនពេក ហេតុនេះហើយទើបធ្វើឱ្យខ្ញុំគិតឃើញថា មានតែខ្លួនឯងទេដែលអាចជួយខ្លួនឯងបាន ដូច្នេះ ខ្ញុំក៏ដកខ្លួនពីសហជីពសេរីតាំងពីពេលនោះមក ។

កម្មករម្នាក់ៗត្រូវដេរឱ្យបានលើសពីប្រាក់ខែ៤៥ដុល្លា បើដេរមិនបានលើសក្នុងរយៈពេល៣ខែ នឹងត្រូវបានចិនបញ្ឈប់ពីការងារមិនខាន ចំពោះរឿងកម្មករបណ្តែតខាងសហជីពមិនបានជួយដោះស្រាយទេ ។ កម្មករបណ្តែតចូលធ្វើការយឺត ១០នាទី ចំនួន៣ដង គេនឹងហៅទៅព្រមាន ។ រោងចក្រមិនបង្ខំឱ្យថែមម៉ោងទេ តែបើមានអាវប្រញាប់គេនិងបង្ខំ ។ គេអនុញ្ញាតឱ្យកម្មករពោះធំចេញញ៉ាំបាយ ឬចេញទៅផ្ទះមុនម៉ោង៥នាទី ។ រោងចក្រកំណត់ឱ្យដេរបើដេរមិនគ្រប់ចំនួនកំណត់ទេនោះ មេកន្ត្រៃដែលនៅខាងថៅកែនឹងហៅប្រធានក្រុមចិន និងប្រធានក្រុមខ្មែរទៅស្តីឱ្យមិនខាន បើមិនអញ្ចឹងទេ មេកន្ត្រៃនឹងមកស្តីឱ្យដោយខ្លួនឯង ។ ចំពោះការងារប្រចាំថ្ងៃ គេបង្ខំឱ្យធ្វើការរហូតគ្មានពេលសំរាកឡើយ ទាល់តែដល់ម៉ោង កណ្តឹងរោទិ៍ទើបគេឱ្យចេញញ៉ាំបាយ ឬចេញទៅផ្ទះតែម្តង ។ កម្មករត្រូវវាយបុង ពេលចាប់ផ្តើមចូលពេលព្រឹក ពេលញ៉ាំបាយ ពេលចូលវិញពេលល្ងាច និងពេលចេញទៅផ្ទះ បើមានថែមម៉ោងក៏ត្រូវវាយបុងដែរ មានកម្មករខ្លះមិនបានញ៉ាំបាយផងទេ ព្រោះត្រូវរង់ចាំយូរពេកទំរាំតែបានវាយបុង ដល់ម៉ោងចូលធ្វើការវិញល្មម ។

ទៅថ្ងៃអនាគតបើរោងចក្របិទខ្ញុំប្រហែលជាមិនទៅស្រុកទេ ត្រូវតែនៅភ្នំពេញបន្តហើយធ្វើការនៅរោងចក្រទឹកកកជាមួយប្តីខ្ញុំ ព្រោះបើសិនជាទៅស្រុកក៏គ្មានមុខរបរអ្វីដើម្បីធ្វើដែរ ដូច្នេះខ្ញុំមិនដឹងថាបានលុយឯណា ដើម្បីផ្គត់ផ្គង់គ្រួសារនោះទេ ព្រោះដីស្រែមានតិចតួចហើយទឹកធ្វើស្រែក៏គ្មានទៀត ណាត្រូវទិញជីហើយតំលៃរបស់វិញកាន់តែឡើងថ្លៃជារៀងរាល់ឆ្នាំ ហើយម្យ៉ាងទៀតបើមានលទ្ធភាពខ្ញុំចង់លក់ដូរនៅផ្សារ ព្រោះធ្វើការនៅរោងចក្រយូរមកបានប្រឈមមុខនឹងជាតិគីមី ធ្វើអោយសុខភាពចុះទ្រុឌទ្រោមជាលំដាប់មិនអាចធ្វើការយូរទៀតបានឡើយ ។

## ករណីសិក្សាទី ៤៨
## ថ្ងៃទី ២០ កក្កដា ២០០៥

នាងខ្ញុំឈ្មោះ ផ សភ រស់នៅភូមិព្រៃចំការ ឃុំស្ពឺ ស្រុកបាភ្នំ ខេត្តព្រៃវែង ។ ខ្ញុំមានបងប្អូន ៧នាក់ ( ស្រី២ និង ប្រុស៥នាក់) ហើយពុកម៉ែខ្ញុំ ជាកសិករធ្វើស្រែ។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី២ ព្រោះគ្រួសារខ្ញុំក្រីក្រ ហើយពុកម៉ែខ្ញុំមិននៅជុំគ្នាទេ ព្រោះពុកនៅធ្វើការនៅខេត្តផ្សេង ។ តែក្រោយមកទៀតពុកក៏បានយកម៉ែទៅនៅជាមួយគាត់នៅឯខេត្តកំពង់ចាម ហើយខ្ញុំមិនបានទៅជាមួយគាត់ទេ គឺខ្ញុំនៅជាមួយបងស្រី ។ តែដោយជីវភាពខ្វះខាតមួយឆ្នាំក្រោយមក ម៉ែក៏យកខ្ញុំទៅនៅជាមួយគាត់វិញនៅកំពង់ចាម នៅទីនោះពុក និង បងប្រុសខ្ញុំ២នាក់ទៀតធ្វើជាកម្មករជៀជ័រកៅស៊ូ ហើយក្នុងមួយខែ គេបើកប្រាក់ខែ និងអង្ករអោយ តែដោយសារគ្រួសារមានសមាជិកច្រើន ហូបមិនដែលបានគ្រប់គ្រាន់ទេ ចុងខែត្រូវទិញអង្ករគេស្ទើរតែរាល់ខែ ។

បន្ទាប់ខ្ញុំក៏បានទៅនៅជាមួយអ៊ុំស្រីនៅឯមេមត់ ហើយគាត់ជាអ្នករែងមាស នៅទីនោះមិនបានប៉ុន្មានខែផង ខ្ញុំក៏មានគ្រុនចាញ់ ហើយក៏បានត្រលប់មកនៅជាមួយម៉ែវិញ ។ កាលនោះខ្ញុំទើបតែមានអាយុត្រឹម ១៥ឆ្នាំប៉ុណ្ណោះ តែពុកម៉ែខ្ញុំឧស្សាហ៍ឈ្លោះគ្នាណាស់ ម៉ែរឹងនិងពុកគាត់ក៏ត្រឡប់មកនៅព្រៃវែងវិញ តែពុកមិនបានមកតាមម៉ែនោះទេ។ មួយឆ្នាំក្រោយមកពុកក៏បានមកនៅជាមួយវិញ តែពេលនោះធ្វើស្រែក៏លែងបាន ព្រោះអត់មានលុយ ខ្ចីលុយគេទិញជីដាក់ស្រែ តែផលស្រូវបានមកក៏មិនល្អ ម្យ៉ាងទៀតគ្រួសារខ្ញុំគ្មានគោក្របីដើម្បីធ្វើស្រែនោះទេ ត្រូវទៅបណ្ដាក់គេ ហើយខ្ញុំ និងម៉ែក៏បានទៅស្ទូងឱ្យគេ ទើបបានគេឱ្យគោមកភ្ជួរស្រែ ។ ខ្ញុំមានដីជាងមួយហិចតា ក្នុងមួយឆ្នាំដាក់ជីអស់ ២បាវកន្លះ ដោយមួយបាវថ្លៃ៤០០០០រៀល ។ ក្នុងមួយឆ្នាំចំណាយសរុបអស់ប្រហែល ១០ម៉ឺនក្នុងការធ្វើស្រែ តែពេលបានផលមកហូបមិនគ្រាន់ទេគឺបានត្រឹមតែសងគេ និងទុកពូជខ្លះ ហើយជួនកាលមិនមានពូជទុកទៀត ។ ពេលខ្វះហូប ម៉ែបានទៅបុលស្រូវគេយកមកហូប គេបានយកការស្នើនិងដើមក្នុងមួយរដូវ ហើយដល់ពេលជំពាក់គេច្រើនពេក គ្រួសារខ្ញុំលែងហ៊ានទៅបុលគេទៀត អង្ករនៅលស់តិចតួចនាំគ្នាដាំបបរហូប ។

ដោយឃើញគ្រួសារពិបាកពេកខ្ញុំ និងពុកខ្ញុំ បានចាកចេញពីស្រុកទៅរកការងារធ្វើនៅភ្នំពេញ។ ហើយពុកធ្វើជាកម្មករសំនង់ និងខ្ញុំធ្វើការឡរតដ្ឋនៅអ្នកលឿង។ មួយអាទិត្យគេបើកលុយឱ្យម្ដង បាន៣០០០០-៣៥០០០រៀល ហើយកន្លះខែយកទៅឱ្យម៉ែនៅឯស្រុកម្ដង ៣០០០០-៤០០០០រៀល ។ ខ្ញុំទុកខ្លះចាយខ្លួនឯង ហើយលុយដែលផ្ញើរទៅ ម៉ែបានទិញអង្ករ ម្ហូប ថ្នាំពេទ្យ និងសំភារៈផ្សេងៗទៀត ។ ពុកធ្វើការសំនង់ មួយថ្ងៃបាន៥០០០រៀល ហើយមួយខែពុកទៅផ្ទះម្ដង និងឱ្យលុយម៉ែ ៧ម៉ឺន ។ ខ្ញុំធ្វើការនៅឡរតដ្ឋបានមួយឆ្នាំ ខ្ញុំក៏ឈប់ព្រោះខ្ញុំហត់ខ្លាំងពេក ហើយណាមួយបានលុយតិចពេក ។ ពេលនោះខ្ញុំបានត្រលប់ទៅផ្ទះវិញ នៅផ្ទះបានមួយឆ្នាំ គឺធ្វើស្រែដូចពីមុនអញ្ចឹង តែក្រោយមកពុកគាត់បានហៅខ្ញុំទៅដាំបាយឱ្យមេការសំនង់ តែ មិនបានប៉ុន្មានផងពុកក៏ត្រលប់មកផ្ទះវិញ ហើយខ្ញុំក៏ឈប់ដាំបាយនៅទីនោះទៅ ។

បន្ទាប់មកខ្ញុំក៏បានជួបអ៊ីប្រុសម្នាក់ ដែលនៅស្រុកជាមួយគ្នា គាត់បាននាំមកនៅជាមួយគេនៅជិតផ្សារថ្មី។ ម្ចាស់ផ្ទះនោះគាត់ជាអ្នកលក់ទឹកសណ្តែត និងនំបញ្ចុក ហើយខ្ញុំនៅជាមួយគេមិនបានប៉ុន្មានផង ម្ចាស់ផ្ទះក៏សុំពុកម៉ែខ្ញុំឱ្យខ្ញុំនៅជាមួយគាត់រហូត ប៉ុន្តែនៅបានមួយឆ្នាំ ពេលដល់ខែធ្វើស្រែខ្ញុំក៏សុំគាត់ត្រលប់មកធ្វើស្រែវិញព្រោះនឹកផ្ទះខ្លាំងណាស់។ នៅបានជាងមួយឆ្នាំ ពូមីងខ្ញុំនៅអ្នកលឿងក៏បានផ្តាំខ្ញុំ ឱ្យមកធ្វើការនៅរោងចក្រ នៅបាក់ខែង គឺរោងចក្រម៉ៃទីស្តិចត្រា។

ពេលខ្ញុំមកដល់ដំបូងខ្ញុំសុំឱ្យគេជួយចូលធ្វើការ ពេលនោះគេយកថ្លៃនាំចូល៣ម៉ឺនរៀល ខ្ញុំបានសុំគេឱ្យចុះតំលៃ គេអាណិតខ្ញុំគេយកពីខ្ញុំតែមួយម៉ឺនប៉ុណ្ណោះ ខ្ញុំបានធ្វើការនៅផ្នែកដេរករ។ ខ្ញុំចូលធ្វើការនៅឆ្នាំ ១៩៩៧ ហើយពេលចូលបានកន្លះខែចិនបើកលុយឱ្យបាន ៣៥០០០រៀល ដល់ខែក្រោយៗមកខ្ញុំបើកលុយបាន ៨-១០ម៉ឺនរៀល ហើយខ្ញុំធ្វើការថែមម៉ោងដល់ម៉ោង១០យប់។ ដល់ក្រោយៗមកទៀតប្រាក់ខែខ្ញុំក៏បានឡើងជាបន្ត បន្ទាប់មកថៅកែរោងចក្រ ក៏បានបើកលុយឱ្យកម្មករជាលុយដុល្លាវិញ ហើយពេលនោះខ្ញុំបើកបានប្រហែល ៦០ទៅ១០០ដុល្លា។ លុយដែលបើកមក ខ្ញុំផ្ញើរទៅផ្ទះស្ទើរតែទាំងអស់គឺទុកតែ ១៥ទៅ២០ដុល្លាប៉ុណ្ណោះសំរាប់ចាយ ។ លុយដែលផ្ញើរទៅផ្ទះ ម៉ែបានយកទៅដោះស្រាយជីវភាពគ្រួសារ និងសងបំណុលគេ។ បងស្រីខ្ញុំម្នាក់ដែលមានគ្រួសារហើយ គាត់ជំងឺជាទំងន់ ជីវភាពគាត់ខ្វះខាតជាខ្លាំង ខ្ញុំបានជួយគាត់ខ្លះដែរ តែក្រោយមកគាត់ក៏ស្លាប់ចោលកូន ៥នាក់ ដោយសារទាស់កូនខ្ចី។ កូនទាំង៥នាក់របស់គាត់ ខ្ញុំក៏យកថែទាំដោយទិញសៀវភៅ ខោអាវ និងឱ្យលុយចាយ។ ៥ខែក្រោយមកឪពុកខ្ញុំក៏បានស្លាប់ម្នាក់ទៀត ដោយសារជំងឺកើតពិស។ ពេលដែលគាត់ឈឺខ្ញុំមិនបានដឹងទេ ទាល់តែគាត់ស្លាប់ទើបគេមកតាមខ្ញុំ។ ពេលគាត់ឈឺម៉ែមើលអស់លុយជាច្រើនប៉ុន្តែខ្ញុំមិនដឹងអត់ប៉ុន្មានទេ។ ហើយពេលធ្វើបុណ្យឱ្យពុកហើយ ខ្ញុំជំពាក់គេ៧០ដុល្លាទៀតពីមិត្តភ័ក្ត តែគេមិនយកការទេ។

បន្ទាប់ពីបុណ្យពុកចប់សព្វគ្រប់ខ្ញុំក៏ត្រឡប់មកធ្វើការវិញ ដើម្បីរកលុយទៅសងគេ។ នៅក្នុងរោងចក្រនេះគឺគិតលុយឱ្យតាមឡូដែលធ្វើ ហើយខ្ញុំទទួលអាចទទួលបានប្រាក់ខែសមរម្យ តែខែណាអត់មានការងារធ្វើ ខ្ញុំបានលុយតិចតួចដូចនេះគ្មានលុយផ្ញើទៅផ្ទះទេ។ ក្នុងមួយឆ្នាំរោងចក្រនេះ ធ្វើការបានតែ ៥-៦ខែប៉ុណ្ណោះ។ ពេលសុំច្បាប់មិនសូវពិបាកទេ បើមានច្បាប់អត់ដាច់លុយព្រីមទេ តែបើអត់ច្បាប់វិញដាច់លុយព្រីម។ ពេលធ្វើការគេមិនបានបង្ខំនោះទេ តែពេលអាវប្រញាប់ម្តងៗ គេឱ្យយើងថែមម៉ោងដល់ម៉ោង ១០យប់ រឺឱ្យយើងធ្វើការដល់ទល់ភ្លឺតែម្តង។ នៅក្នុងរោងចក្រនេះមានលុយព្រីម អតីតភាព បំណាច់ឆ្នាំ និងលុយផ្សេងៗទៀត។ ប្រសិនបើធ្វើការថែម២ម៉ោងខាងរោងចក្រគេឱ្យលុយបាយ ១០០០រៀលទៀត ហើយបើថែមម៉ោងដល់ម៉ោង ១០យប់ នឹងមានលុយបាយ ១០០០រៀល និងមីមួយកញ្ចប់ទៀត ។ រោងចក្រនេះមានថៅកែជាជនជាតិចិន និងមានសហជីពច្រើន តែខ្ញុំអត់ស្គាល់ទេ គឺខ្ញុំដឹងតែសហជីព ដែលខ្ញុំចូលជាសមាជិកប៉ុណ្ណោះ គឺសហជីពជាតិនៃឧស្សាហកម្មវាយនភ័ណ្ឌកាត់ដេរកម្ពុជា ហើយមួយខែខ្ញុំត្រូវបង់១០០០រៀលឱ្យគេខាងសហជីពគេដើរប្រមូលនៅពេលដែលកម្មករបើកប្រាក់ខែរួច ។ សហជីពតែងតែជួយដោះស្រាយគ្រប់រឿង បាតុកម្មទាមទារតំលៃឡូ លុយបាយ និងរឿងជាច្រើនទៀត។

ប្រសិនជាអត់មានការងារធ្វើខាងរោងចក្រគេឱ្យលុយ ៥០ភាគរយ។ កម្មករធ្លាប់ធ្វើបាតុកម្មទាមទារតំលៃឡើ ហើយទាមទារកម្មករដែលស៊ីប្រាក់ខែឱ្យឡើងបន្ថែមទៀត ។ បន្ទាប់ពីពុកស្លាប់មិនបានប៉ុន្មានផង ម៉ែខ្ញុំក៏ធ្លាក់ខ្លួនឈឺទៀត ពេលនោះគាត់ជំងឺភ្នែក ហើយតាខ្ញុំក៏ឈឺដូចម៉ែខ្ញុំដែរ តែមិនបានប៉ុន្មានផងតារបស់ខ្ញុំគាត់ក៏បានស្លាប់ទៅ។ ពេលនោះម៉ែខ្ញុំក៏ធ្លាក់ខ្លួនឈឺខ្លាំងទៅៗ ខ្ញុំក៏នាំគាត់ទៅព្យាបាលនៅមន្ទីរពេទ្យជាច្រើន ហើយចាប់តាំងពីម៉ែឈឺមក ប្រាក់ខែខ្ញុំមិនដែលសល់ទេ អស់រាល់ខែហើយខែខ្លះត្រូវជំពាក់លុយគេថែមទៀត ហើយបានខ្ចីម្តងៗ ១០ ទៅ ២០ម៉ឺនរៀល ហើយធ្វើការសងគេម្តងបន្តិចៗ។ ជំងឺម៉ែខ្ញុំកាន់តែខ្លាំងឡើងៗ ក្រៅពីឈឺភ្នែកគាត់មានជំងឺជាច្រើនមុខទៀត គាត់បានស្លាប់នៅពេលរោងចក្រដែលខ្ញុំធ្វើបានផ្អាកដំនើរការរយៈពេល២ខែទៀត បន្ទាប់ពីធ្វើបុណ្យឱ្យគាត់ហើយនោះខ្ញុំនៅជំពាក់លុយគេ ៦០ម៉ឺនរៀល តែខ្ញុំអត់មានលុយសងគេទេព្រោះខ្ញុំអត់ការងារធ្វើ។ ខ្ញុំក៏លក់គោមួយក្បាលទៀតបានមួយលានរៀលដើម្បីយកទៅសងបំណុលគេ ហើយសល់ខ្លះទុកសំរាប់ធ្វើបុណ្យបន្តទៀត។

រោងចក្រខ្ញុំមិនដែលព្យួរទេតាំងពីខ្ញុំចូលធ្វើការមក ទើបតែចុងឆ្នាំ ២០០៤ និងដើមឆ្នាំ ២០០៥ នេះទេ ដែលអត់មានការងារធ្វើ ហើយក៏ព្យួរការងារកម្មករ ២ខែ តែម្តងទៅ។ លុះដល់ពេលចូលមកវិញស្រាប់តែគេបើកលុយឱ្យកម្មករហើយ គេប្រាប់ថាបិទរោងចក្រ។ ខ្ញុំធ្វើការនៅទីនេះ ៨ឆ្នាំហើយ ខ្ញុំបើកលុយបានតែ ១៦០ដុល្លា តែខ្ញុំឆ្ងល់ថាហេតុអីបានជារោងចក្របិទ មិនបានប្រាប់នឹងជូនដំនឹងដល់កម្មករជាមុនសោះ។ នៅថ្ងៃបើកលុយនោះ មានប៉ូលីសពេញរោងចក្រហើយ ពេលនោះកម្មករគ្រប់គ្នាឆ្ងល់ ក៏បានទៅសួរសហជីពដែលជាតំណាងកម្មករ តែគេមិនបានឆ្លើយប្រាប់ទេ ហើយគេរកលេសថាជាប់រវល់។ កម្មករគ្រប់គ្នានាំគ្នាឆ្ងល់ថាហេតុអ្វីបានជាសហជីពព្រមទទួលលុយដែលរោងចក្របើកឱ្យកម្មករ ទោះជាដឹងថាមិនគ្រប់នោះ ព្រោះរាល់ពេលសហជីពតែងតែជួយដោះស្រាយជានិច្ច។ ស្រាប់តែរោងចក្របិទទ្វារបែរជាព្រមទទួលយកលុយខុសច្បាប់ទៅវិញ។

ហើយពេលបើកលុយហើយគឺមានឡានមកចាំយកកម្មករទៅធ្វើការនៅរោងចក្រឯភ្នំពេញ។ បន្ទាប់ពីរោងចក្របិទខ្ញុំក៏ត្រលប់ទៅផ្ទះវិញ ព្រោះគ្មានអ្នកណានៅផ្ទះ។ ខ្ញុំនៅផ្ទះបានកន្លះឆ្នាំខ្ញុំក៏បានមករកការងារនៅភ្នំពេញវិញ។ ខ្ញុំបានចូលធ្វើការនៅរោងចក្រ **វិងរិច** តែមិនបានអស់លុយកាក់នោះទេ គឺខ្ញុំបានទៅធ្វើតេស្តជាប់ដោយខ្លួនឯង។ គេថារោងចក្រនេះស្រួលតែតាមពិតវាមិនបានស្រួលដូចពាក្យគេថានោះទេ ទាំងប្រធានចិន និងខ្មែរ គឺកាចខ្លាំងណាស់។ គេឱ្យថែមម៉ោងរាល់ថ្ងៃហើយចេញនៅម៉ោង១០យប់ តែថ្ងៃសៅរ៍អត់ថែមម៉ោងទេ។ ថ្ងៃអាទិត្យធ្វើការធម្មតា ចេញម៉ោង៤:៣០ ល្ងាច។ ពេលធ្វើការនៅក្នុងរោងចក្រនេះខ្ញុំទ្រាំមិនបានទេ ព្រោះក្រុមហ៊ុនបង្ខំឱ្យថែមម៉ោងដល់ម៉ោង១០យប់។ ជើងរបស់ខ្ញុំឡើងហើម នឹងស្ពឹកអស់ហើយ ។ ខ្ញុំនៅផ្ទះជួលឆ្ងាយពីរោងចក្រ ពេលចេញពីធ្វើការយប់ខ្ញុំខ្លាចណាស់ ហើយតែងតែនាំគ្នារត់។ ច្បាប់នៅក្នុងរោងចក្រហាមមិនឱ្យនិយាយគ្នា ។

នៅក្នុងរោងចក្រនេះបានបង្កើតសហជីព ពេលកម្មករមិនថែមម៉ោងគេក៏កត់ឈ្មោះឱ្យសហជីពដែរ ហើយពេលវាយបុងខុសពេលយកទៅក្នុងការិយាល័យ គេសួរថា " ឈប់ខ្លួនឯង រឺអត់ " គេមិនឱ្យយើងនិយាយតជាមួយគេទេ បើមិនតមាត់

គេគ្រាន់តែកាត់លុយព្រឹមប៉ុណ្ណោះ តែបើតមាត់គឺគេបញ្ឈប់យើងតែម្តង។ ហើយខ្ញុំធ្វើការបានតែ ២អាទិត្យក៏ឈប់ព្រោះទ្រាំមិនបាន តែដំបូងឡើយគេមិនបើកលុយឱ្យខ្ញុំទេ ខ្ញុំចាំទាល់តែដល់បើកឱ្យទើបខ្ញុំចេញ ក្រោយមកគេក៏បើកលុយឱ្យ។ ពេលនោះខ្ញុំក៏ត្រឡប់ទៅផ្ទះវិញ តែនឹកឃើញថាពីមុនមានការងារធ្វើគ្រាន់បានលុយមកដោះស្រាយខ្លះ ដល់ឥលូវអត់មានការងារធ្វើគ្រួសារលំបាកកាន់តែខ្លាំងមែនទែន។ មុននិងត្រឡប់មកផ្ទះវិញខ្ញុំបានដើររកការងារធ្វើ តែវាពិបាកណាស់ព្រោះខុសជំនាញរបស់ខ្លួន រោងចក្រដែលគេរើសនៅភ្នំពេញ គឺភាគច្រើនជារោងចក្រដេរ តែខ្ញុំមិនចេះដេរទេ។

## ករណីសិក្សាទី ៤៩

## ថ្ងៃទី ២៦ កក្កដា ២០០៥

នាងខ្ញុំឈ្មោះ យ សភក មានអាយុ ២៧ឆ្នាំ ធ្វើការនៅរោងចក្រ M & V ផ្នែកដេរភ្ជាប់។ គ្រួសារខ្ញុំរស់នៅភូមិតុងរ៉ុង ឃុំតុងរ៉ុង ស្រុកព្រៃឈរ ខេត្តកំពង់ចោម។ ខ្ញុំមានបងប្អូន ៦នាក់ ហើយខ្ញុំជាកូនទី៤។ ខ្ញុំមានបងប្អូន ៣នាក់ ធ្វើការនៅភ្នំពេញ ហើយគ្រួសារខ្ញុំធ្វើស្រែ ក្រៅពីធ្វើស្រែគឺធ្វើនំបញ្ចុកលក់។ គ្រួសារខ្ញុំមានដីស្រែ ៨០អា ធ្វើស្រែឆ្នាំខ្លះអាចហូបគ្រប់ហើយឆ្នាំខ្លះមិនអាចហូបគ្រប់នោះទេ។ ខ្ញុំឈប់រៀនបានត្រឹមថ្នាក់ទី៥ កាលឆ្នាំ១៩៩៧ ព្រោះរៀនមិនចេះ និងជាប់រវល់ជួយលក់ម៉ែ ភ្លេចការរៀនសូត្រ ហើយខ្ញុំចង់រកការងារធ្វើ ដោយសារឃើញគ្រួសារពិបាក ពុកម៉ែចាញ់បោកគេ ដោយជួយធានាឱ្យគេខ្ចីលុយ ហើយគេរត់ចោលស្រុក ទើបត្រូវជំពាក់គេ។

ខ្ញុំបានសំរេចចិត្តមកតាមពូ ដែលគាត់ធ្វើសន្តិសុខនៅ វាលិញ ចាក់អង្រែ។ ប៉ុន្តែពេលខ្ញុំមកដល់ដំបូងខ្ញុំមិនទាន់មានការងារធ្វើភ្លាមទេ គឺត្រូវរង់ចាំ២ខែឯនោះ។ ពេលមកម៉ែឱ្យលុយ ២ម៉ឺន និងមានលុយសន្សំខ្លួនឯង ២ម៉ឺនទៀត ហើយពេលមកដល់ ខ្ញុំរវល់តែជួយលក់បបរពូទំរាំតែបានការងារធ្វើ។ ពេលខ្ញុំចូលធ្វើការខ្ញុំមិនអស់លុយទេ ហើយកាលនោះរោងចក្រមិនសូវពិបាកទេ មិនតឹងតែងទេ អាចលេងសើចបាន តែខ្ញុំបានឈប់ធ្វើការនៅទីនោះ ពីព្រោះប្រាក់ខែតិចពេក គឺបានតែ ៣០ដុល្លា បូកទាំងថែមម៉ោង ហើយអត់ឡើងប្រាក់ខែសោះ។

ខ្ញុំក៏ត្រឡប់ទៅផ្ទះវិញធ្វើស្រែនិងលក់នំបញ្ចុកដដែល តែលក់មិនសូវដាច់ទេ។ មួយឆ្នាំក្រោយមក ខ្ញុំក៏សំរេចចិត្តមកភ្នំពេញមកទៀត ដោយសារឃើញអ្នកភូមិមកស្ទើរតែអស់គ្នាទៅហើយ។ ខ្ញុំលឺគេថានៅរោងចក្រ **តេវ៉ាតិច** មានគេរើសកម្មករ ខ្ញុំក៏ទៅធ្វើតេស្ត ហើយបានជាប់ធ្វើការនៅទីនោះ។ ខ្ញុំធ្វើការបាន ៦ខែ ខ្ញុំក៏ឈប់ព្រោះផ្នែកដែលខ្ញុំធ្វើគេរំរូវឱ្យឈរធ្វើការ និងអត់មានម៉ោងសំរាក ថែមម៉ោងរហូត អត់មានលុយបាយ អត់លុយព្រឹមទៀតផង ទើបខ្ញុំប្តូរការងារសុំគេរៀនដេរនៅវាលិញ។ មួយឆ្នាំក្រោយមកទើបខ្ញុំទៅធ្វើតេស្តនៅរោងចក្រ M & V ជាប់ផ្នែកដេរភ្ជាប់ នៅក្នុងឆ្នាំ២០០៣។ ពេលចូលដំបូងគេឱ្យដេរស៊ីឡូភ្លាម ព្រោះខ្ញុំចេះស្រាប់។ ក្នុងមួយខែខ្ញុំបើកលុយ ២ដង ហើយកន្លះខែដំបូងខ្ញុំបាន ២៥ដុល្លា។ ថៅកែរោងចក្រនេះជាជនជាតិចិន ពេលចូលដំបូងគេមិនបង្ខំទេ តែបើកម្មករណាដេរអត់គ្រប់ប្រាក់គោល គេនឹងស្តីឱ្យ។ នៅក្នុងរោងចក្រនេះ មានសហជីព ២ គឺសហជីពឯករាជ្យ ដោយលោក រស់ សុខ និងសហជីពវាយនភណ្ឌ ដោយលោកស្រី ម៉ម ញឹម ។ សហជីពបានទាំងនេះអាចជួយដោះស្រាយឱ្យកម្មករបានខ្លះដែរដូចជា ពេលតំលៃឡូចុះថោក។

នៅក្នុងរោងចក្រមានពេទ្យ តែពេទ្យដូចជាមិនសូវយកចិត្តទុកដាក់មកលើកម្មករទេ ពេលមានកម្មករសន្លប់គេ ឱ្យយកទៅផ្ទះ ហើយគេអត់គិតលុយឱ្យទេ។ តែស្រួលក្នុងការសុំច្បាប់ ខ្ញុំអាចផ្ញើរកាតទៅតាមមិត្តភក្តិឱ្យគេជួយសុំច្បាប់ឱ្យក៏បានដែរ

ចាប់ពីឆ្នាំ ២០០៥ តំលៃឡូចុះថោក ម៉ូតដែលធ្លាប់ដេរពីមុន ១ដុល្លា ចុះនៅសល់ ៨កាក់ ហើយម៉ូតខ្លះចុះថោកជាង៨កាក់នេះទៅទៀត។ សហជីពតវ៉ាតែមិនបានដូចមុន ហើយបើកម្មករតវ៉ាខ្លាំង សហជីពថាឱ្យទ្រាំដេរទៅ ហើយគាត់និយាយថាចង់មានការងារធ្វើ ឬក៏អត់? ចុះតិចតួចចេះតែទ្រាំធ្វើទៅ។ ច្បាប់ការងារស្រួលដូចធម្មតា តែអត់សូវមានការងារធ្វើទេ ក្នុងមួយឆ្នាំនេះគិតទៅថែមម៉ោងបានត្រឹមតែមួយខែអស់ហើយ។ ខ្ញុំមានលុយតែ ៣៥ដុល្លាប៉ុណ្ណោះ ក្នុងកន្លះខែដោយអត់ថែមម៉ោងសោះ។

ពេលបើកប្រាក់ខែម្តងៗ ខ្ញុំអត់ដែលផ្ញើរលុយទៅផ្ទះសោះ ព្រោះខ្ញុំត្រូវចំណាយច្រើន ទំនិញឡើងថ្លៃ ហើយប្រាក់ខែតិច។ តែកាលពីមុន ខ្ញុំបានផ្ញើរទៅផ្ទះបានខ្លះដែរ មួយខែប្រហែលជា៣០ដុល្លាដែរ ព្រោះខ្ញុំចាយអស់តិច។ កាលពីមុនអ្នកស្រុកគេធ្លាប់បាននិយាយថា អ្នកទៅធ្វើការនៅភ្នំពេញ គឺទៅធ្វើស្រីខូច តែឥលូវគ្មាននរណានិយាយអំពីវាទៀតនោះទេព្រោះអ្នកសឹងតែទាំងអស់ហើយដែលឱ្យកូនមកធ្វើការរោងចក្រ ។ ម្ចាស់ផ្ទះដែលខ្ញុំជួលគេមិនសូវនិយាយស្តីជាមួយទេ ពេលដែលពួកខ្ញុំដើរទៅណាមកណា គេតែងមើលលើមើលក្រោមដែរ តែគេមិនដែលថាអីឱ្យទេ។

បើសិនរោងចក្របិទ ខ្ញុំគិតថាត្រឡប់ទៅស្រុកវិញ ដើម្បីទៅធ្វើស្រែ និងលក់នំបញ្ចុកវិញ។ បើសិនថ្ងៃក្រោយមានលុយ ខ្ញុំចង់លក់តវ៉ាន់ ចាបហួយ និងចង់ចិញ្ចឹមជ្រូក។

ករណីសិក្សាទី ៥០

ថ្ងៃទី ០៤ កក្កដា ២០០៥

ខ្ញុំបាទឈ្មោះ ណេ នម មានអាយុ ២៧ឆ្នាំ។ គ្រួសារខ្ញុំរស់នៅ ភូមិកណ្តាល ឃុំកោះចរ៉ាម ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។ ខ្ញុំមានបងប្អូន ៨នាក់ (ប្រុស៤ និងស្រី៤)។ បងប្អូនខ្ញុំ៥នាក់ បានរៀបការរួចហើយ។ ខ្ញុំអត់មានពុកម៉ែទេ គឺពួកគាត់ស្លាប់ពេលខ្ញុំនៅតូចម្ល៉េះ ហើយរាល់ថ្ងៃខ្ញុំរស់នៅជាមួយបងស្រី។ ខ្ញុំរៀនបានត្រឹមថ្នាក់ទី៥ ក៏ឈប់ព្រោះជីវភាពលំបាកពេក។ ពេលខ្ញុំឈប់រៀនបានមួយរយៈក្រោយមក បង១ឱ្យខ្ញុំទៅបួស ខ្ញុំបួសបាន៣ទៅ៤ឆ្នាំក៏សឹកត្រឡប់មកនៅផ្ទះវិញ ។ នៅក្នុងផ្ទះអ្នកដែលអាចរកប្រាក់ចំណូលបាននោះមានតិចជាងអ្នកហូប ព្រោះបងប្អូនខ្ញុំច្រើនហើយបង១ គាត់ មានកូនច្រើន រកបានមកហូបមិនដែលគ្រប់ទេ។ ដីស្រែមាន ៣ហិចតា ហើយក្នុងមួយឆ្នាំ១ត្រូវការចំណាយច្រើន ណាថ្លៃម្ហូប ថ្លៃជី ថ្លៃទឹក។ ហើយក្នុងមួយឆ្នាំប្រើជីអស់ ៣បាវ (មួយបាវ=៦៥០០០ទៅ៧០០០០រៀល) តែលាយជាមួយអាចម៍គោ។ ក្នុងមួយអាទិត្យត្រូវដាក់ទឹកក្នុងស្រែ២ដង ហើយចំណាយលុយអស់ពី ១០០០០ទៅ២០០០០រៀល ដូចនេះក្នុងមួយឆ្នាំខ្ញុំត្រូវចំនាយលុយប្រហែល ២០ម៉ឺនទៅ៣០ម៉ឺនរៀល ក្នុងការធ្វើស្រែ។ ប៉ុន្តែឆ្នាំនេះធ្វើស្រែមិនសូវបានទេ ក្រៅពីធ្វើស្រែខ្ញុំបានជួយលក់បន្លែ និងលក់ត្រីតាមផ្ទះអ្នកភូមិ។

ដោយសារតែជីវភាពទីទាល់ពេក មិនបានប៉ុន្មានខ្ញុំបានមករកការងារធ្វើនៅភ្នំពេញ ពេលមកដល់ដំបូងខ្ញុំបានរង់ចាំអស់រយៈពេលមួយខែទើបបានការងារធ្វើ។ កាលនោះពេលចេញពីផ្ទះមក ខ្ញុំមានលុយតែ៨០០០រៀលប៉ុណ្ណោះ គឺបងជាអ្នកឱ្យមក។ រយៈពេលមួយខែដែលរង់ចាំរកការងារធ្វើ ខ្ញុំបានស្នាក់នៅជាមួយបង ហើយថ្លៃទឹកភ្លើង បងជាអ្នកចេញឱ្យ។ ខ្ញុំមករកការងារធ្វើនៅឆ្នាំ២០០០ គឺធ្វើនៅរោងចក្រ **សាំ ហាន់** ផ្នែកត្បាញ ខ្ញុំចូលធ្វើការដំបូងបានប្រាក់ខែ ២០ដុល្លា ហើយរយៈពេល ៣ខែ ក្រោយមកក៏ក្លាយជាកម្មករពេញសិទ្ធិបានប្រាក់ខែ ៤៥ដុល្លា ។

ពេលចូលដំបូងពិបាកខ្លះដែរតែខ្ញុំត្រូវប្រឹងប្រែងធ្វើវាអោយបានល្អ លក្ខខណ្ឌការងារនៅកន្លែងហ្នឹងមិនសូវពិបាកទេ។ ពេលឈឺអាចសុំច្បាប់បាន តែគេកាត់លុយព្រឹម៥ដុល្លា។ ចំពោះកន្លែងត្បាញវិញច្បាប់មិនសូវតឹងតែង ដូចជាផ្នែកខាងដេរនោះទេ។ កន្លែងខ្ញុំគេធ្វើពីរវេន ថ្ងៃ និងយប់ តែអ្នកធ្វើការយប់ គេមិនគុណលុយឱ្យទេ គឺប្រាក់ខែធម្មតា ដូចអ្នកធ្វើការថ្ងៃដែរ គឺតំលៃអាវស្មើគ្នា តែបើធ្វើការថ្ងៃបុណ្យ និងថ្ងៃអាទិត្យ គឺគេគុណលុយបន្ថែមឱ្យ។

រោងចក្រខ្ញុំមានសហជីព២ គឺស៊ីខៅខូ និងសាមគ្គីភាព។ ខ្ញុំមិនបានចូលជាសមាជិកសហជីពទេ។ សហជីពនេះបានជួយកម្មករច្រើនខ្លះដែរដូចជារឿងតវ៉ា តំលៃអាវ រឿងធ្វើការយប់ គេមិនគុណលុយឱ្យ ហើយថ្ងៃបុណ្យ និងថ្ងៃអាទិត្យដែលខាងរោងចក្រមិនបានគុណលុយឱ្យ ។ រឿងតវ៉ាតំលៃអាវ ជូនតវ៉ាបានសំរេច តែជូនមិនបានសំរេចទេ ហើយថ្ងៃបុណ្យ និងថ្ងៃអាទិត្យ ជួនធ្វើការជួនអត់ធ្វើ។ ពេលខ្លះត្រូវគេបង្ខំឱ្យថែមម៉ោងប្រសិនបើអាវប្រញាប់។ ផ្នែកខាងដេរជួនកាលត្រូវដេរមួយយប់ទល់ភ្លឺ ហើយមួយព្រឹកទល់ល្ងាចទៀតទើបគេឱ្យចេញត្រឡប់មកផ្ទះ។ នៅក្នុងរោងចក្រមានអ្នក

សន្ទប់ច្រើន ទាំងខាងដេរ និងខាងត្បាញ មិនថាប្រុសស្រីទេ ប៉ុន្តែភាគច្រើនគឺស្រី។ ពេលសន្ទប់ខាងក្រុមហ៊ុនគេជួយមើលខ្លះដែរ ហើយដូចជាករណី មានគ្រោះថ្នាក់ក្នុងរោងចក្រអញ្ចឹង ខាងក្រុមហ៊ុនបានចេញលុយឱ្យខ្លះ។

ប្រាក់ខែខ្ញុំជាមធ្យមបានពី ៦០ទៅ៧០ដុល្លាក្នុងមួយខែ ហើយខ្ញុំត្រូវចំណាយទៅលើថ្លៃផ្ទះ ទឹកភ្លើង ម្ហូប តែជួនកាលត្រូវចំណាយច្រើនទៅលើការឈឺថ្កាត់ ប្រហែលជាអស់ ២៥ទៅ៣៥ដុល្លា ទាំងសំលៀកបំពាក់របស់ខ្ញុំផង ម្យ៉ាងត្រូវផ្ញើរទៅផ្ទះក្នុងមួយខែ ២០ទៅ៣០ដុល្លា ទៅតាមខែដែលខ្ញុំបានប្រាក់ខែតិច រឺច្រើន។ បងស្រីខ្ញុំនៅឯស្រុក ខ្វះខាតពេលដល់រដូវធ្វើស្រែម្តងៗ គាត់ត្រូវខ្ចីគេ ហើយបានលុយដែលខ្ញុំផ្ញើទៅជូនគាត់ គាត់យកទៅសងគេនិងទុកទិញម្ហូប បង់ថ្លៃសាលាឱ្យកូនគាត់ ហើយពេលមានបុណ្យការអី អាចបានលុយហ្នឹងជួយទប់ខ្លះ។

ពេលចូលឆ្នាំ ២០០៤ ក្នុងរោងចក្រមានការប្រែប្រួលខ្លះៗ ដូចជា កាត់បន្ថយបុ្កខ្លះនៅក្នុងរោងចក្រ ហើយមិនសូវមានការងារធ្វើ ម្យ៉ាងតំលៃអាវក៏មានការធ្លាក់ចុះទៀត។ ចូលដល់ពាក់កណ្តាលឆ្នាំ គេបានរើសកម្មករបណ្តែតច្រើនជាមុន។ ចំពោះការបើកប្រាក់ខែមិនទៀងទាត់ លើសថ្ងៃរហូត ។ កម្មករនៅផ្នែកខ្លះបានធ្វើបាតុកម្ម ព្រោះតំលៃអាវធ្លាក់ចុះហើយការធ្វើការឥលូវតែ ៨ម៉ោងប៉ុណ្ណោះមិនមានថែមម៉ោងដូចមុនទៀតទេ។ កាលពីមុនធ្វើការ១០ម៉ោង ហើយតំលៃអាវបានថ្លៃដូចជាអាវមួយថ្លៃ ៣៨០០រៀល ក្នុងមួយថ្ងៃត្បាញបាន ៧ទៅ៨អាវ តែឥលូវអាវមួយបានតែ ២៥០០រៀល ហើយក្នុងមួយថ្ងៃត្បាញបានតែ ៥ទៅ៦អាវប៉ុណ្ណោះ។

ក្រោយមកនៅក្នុងខែកញ្ញាឆ្នាំមុន ថៅកែរោងចក្រមិនព្រមបើកលុយឱ្យកម្មករទេ ដល់ថ្ងៃកំនត់ត្រូវបើកលុយ តែថៅកែរោងចក្រនិយាយថាលុយបង្វិលមិនទាន់ទេ ហើយថាចាំថ្ងៃទី១០ ដល់ថ្ងៃទី១០គេបាននិយាយថាចាំថ្ងៃទី១៥ គឺគេកុហកកម្មករ ពីមួយថ្ងៃទៅមួយថ្ងៃ គេថាឱ្យកម្មករបន្តធ្វើការទៅគេនឹងបើកលុយឱ្យ។ ការរង់ចាំពីមួយថ្ងៃទៅមួយថ្ងៃ ក្រោយមកមានអន្តរាគមន៏ ខាងរដ្ឋាភិបាល គឺលោកហេងពៅ បានចុះមករៀបចំ និងឃាត់ខ្លួនថៅកែរោងចក្រមិនឱ្យទៅណាទេ។ ពេលល្ងាចម៉ោង៥ គេបានបើកប្រាក់ខែឱ្យកម្មករ នឹងលុយធ្វើការយប់ ២ខែ។ ចំពោះលុយធ្វើការយប់ ២ខែ កម្មករខ្លះបានតែកម្មករខ្លះ អត់បានទេ ។ អ្នកអត់បានព្រោះពួកគេទៅផ្ទះ ពេលពួកគេត្រឡប់មកវិញ ចិននឹងស្រាវជ្រាវបើកប្រាក់ខែឱ្យ។

ក្រោយមកគេថារោងចក្រត្រូវព្យួរ ២ខែ ហើយពួកយើងនាំគ្នាទៅផ្ទះអស់ ២ខែក្រោយមកពួកខ្ញុំបានចូលធ្វើការវិញ កម្មករផ្នែកខ្លះមានការងារធ្វើ តែផ្នែកខ្លះចូលគ្រាន់តែចុះវត្តមានប៉ុណ្ណោះ ហើយកម្មករខ្លះធ្វើការជាង២ខែ តែថៅកែមិនបានបើកលុយឱ្យទេ។ គេតែងតែនិយាយថាខោអាវគ្មានអ្នកកម្ម៉ង់ ហើយដល់ថ្ងៃកំណត់ គេតែងតែកុហកកម្មកររហូត។ កាលនោះខ្ញុំគ្មានលុយឱ្យថ្លៃផ្ទះគេទេ ហើយលុយថ្លៃបាយ គេទាររាល់ថ្ងៃ តែខ្ញុំកុហកគេរហូត ព្រោះអីថៅកែរោងចក្រគាត់ក៏កុហកខ្ញុំដែរ។

ពួកខ្ញុំបានធ្វើកូដកម្មអស់រយៈពេលជាច្រើនថ្ងៃ ហើយអ្នកខ្លះត្រូវបានប៉ូលីសវាយបែកមុខបែកមាត់ ពេលប៉ូលីសខាងរដ្ឋាភិបាលជាអ្នកវាយមកលើកម្មករ ។ បន្ទាប់មកពេលល្ងាចគេបានបើកប្រាក់ខែ ២ខែចុងក្រោយឱ្យដល់កម្មករទាំងអស់ នៅពេលបើកប្រាក់ខែចុងក្រោយ គេប្រាប់ថារោងចក្រព្យួរ ២ឆ្នាំ ហើយគេថា២ឆ្នាំក្រោយចាំមកធ្វើការវិញ។ បន្ទាប់មកកម្មករមិនយល់ព្រមនោះទេបានធ្វើកូដកម្មម្តងទៀត អស់រយៈពេល៣ខែ។ កម្មករដែលធ្វើការតវ៉ារួមទាំងខ្ញុំផងដែលនោះត្រូវបានប៉ូលីសវាយ បាញ់ផ្សែងពុល ហើយខាងរដ្ឋាភិបាលហាមមិនឱ្យកម្មករណាម្នាក់ចូលទៅមុខរោងចក្រទៀតទេ។ ពេលនោះពួកខ្ញុំបានធ្វើក្បួនដង្ហែទៅកាន់មុខរដ្ឋសភា ហើយត្រូវបានពួកប៉ូលីសស្ទះបំបែកហ្វូងក្រុមកម្មករ នឹងហាមមិនឱ្យនៅជុំគ្នា ។ ប៉ុន្តែពួកយើងនៅតែតស៊ូរហូតមកដល់ឥលូវ ហើយឥលូវនេះគេកំពង់តែដោះស្រាយនៅឡើយ ពួកខ្ញុំទាំងអស់គ្នាមិនបានទទួលអ្វីទាល់តែសោះនៅពេលរោងចក្របិទ សូម្បីតែមួយរៀលក៏គ្មានបានផង។

ខ្ញុំរាល់ថ្ងៃកំពុងរកការងារថ្មីធ្វើ ប៉ុន្តែរកមិនទាន់បានទេ។ ឥលូវខ្ញុំនៅជាមួយបង គាត់ធ្វើការនៅរោងចក្រផ្សេង។ ខ្ញុំគិតរួចហើយ ខ្ញុំត្រូវតែរកការងារថ្មីធ្វើទៀតទោះនៅឆ្ងាយយ៉ាងណាក៏ដោយ ឱ្យតែគេត្រូវការខ្ញុំ។ ប៉ុន្តែលុះត្រាតែទីកន្លែងនោះមានលក្ខខណ្ឌការងារល្អដែរ តែប្រសិនបើមិនល្អទេនោះប្រហែលជាខ្ញុំអាចត្រឡប់ទៅផ្ទះវិញ ហើយរកការងារផ្សេងៗនៅទីនោះអ្វី។

**ឈ្មោះរោងចក្រ:** គីនតាយ, តាក់ហ្វាត, ចយហ្វុល, អិល អេ, អិល អេ២, ឈាវយ៉ូ, អ៊ីមអែនវី, វ៉ាយធិច, យូនីវើស្សលអ៊ីមផរ៉ល(៦ជាន់), ភី ស៊ី ស៊ី អេស, ស៊ីឡាំហ្វួរ, វ៉ែរវេល, ហុងវ៉ា, កាណាឌីយ៉ា, ញូញៀន, ប្រាយស្កាយ, ណេតហ្គេអ៊ីធី អ៊ីបភែរេល, ស៊ូព្រីមមា, ឃៃនធើវេន, មិថុនា, ហ្គោលតិច, ស្កូតវ៉ែរ, សិនតាបួរ, សាំហាន់, ឃីងខ្មៃន, រ៉ូស៊ីង, ភើហ្វិចតា, ញូវអរេណាថ៍, ហ្គូលស៊ីង, តេរ៉ាតិច, ម៉ុនដូតិច, ម៉ាកាឡូត៥, ក្តាបន្ទះ...



**ឧបត្ថមដោយ**


WOMYN'S AGENDA FOR CHANGE

ផ្ទះលេខ១ វិថីស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
ប្រអប់សំបុត្រ លេខ ៨៨៣
ទូរស័ព្ទលេខ (+៨៥៥) ០១២ ២២២ ១៧១
ទូរស័ព្ទ/ទូរសារលេខ (+៨៥៥) ០២៣ ៧២២ ៤៣៥
អ៊ីមែល wac@womynsagenda.org
www.womynsagenda.org


